IJM



# ការឆ្លើយតបរបស់ប្រព័ន្ធ
# យុត្តិធម៌ទៅនឹងពលកម្ម
# ដោយបង្ខំ និងការជួញដូរ
# ពលកម្មឆ្លងដែននៅកម្ពុជា

RCG RESEARCH AND COMMUNICATIONS GROUP

IJM

Walmart.org

# ខែធ្នូ ឆ្នាំ ២០២២

ឯកសារបោះពុម្ពផ្សាយនេះ ផលិតដោយមូលនិធិ Walmart Foundation សហកាជាមួយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)។ ឯកសារនេះ ត្រូវបានរៀបចំឡើងដោយក្រុមសិក្សាស្រាវជ្រាវ និងទំនាក់ទំនង (RCG)។


info@rcgglobal.com

www.rcgglobal.com

**ទំនាក់ទំនង៖**

Gavan Blau

*ក្រុមសិក្សាស្រាវជ្រាវ និងទំនាក់ទំនង (RCG)*

gavan.blau@rcgglobal.com

www.rcgglobal.com



**អ្នកប្រឹក្សាយោបល់ជំនាញ ដែលបានរួមចំណែកក្នុងកិច្ចការសិក្សាស្រាវជ្រាវ៖**

ស្ងួង សុខសុភា

ទី សុណ្ណារី

Sean Hatwell

Phil Marshall


## សេចក្តីប្រកាសពុំទទួលខុសត្រូវ


ទស្សនៈរបស់អ្នកនិពន្ធដែលបានបង្ហាញនៅក្នុងឯកសារស្រាវជ្រាវនេះ គឺពុំឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មូលនិធិ Walmart Foundation និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ IJM នោះឡើយ។



# មាតិកា


## សេចក្តីសង្ខេប

**. សាវតារ និងវិធីសាស្ត្រ.........8**

១.១ ទិដ្ឋភាពទូទៅអំពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ.........8

១.២ របាយការណ៍ គោលបំណង និងវិសាលភាព.........8

១.៣ សំណួរស្រាវជ្រាវ.........9

១.៤ ការប្រមូលទិន្នន័យ និងវិធីសាស្ត្រ.........10

១.៥ ដែនកំណត់.........11

១.៦ ការពិចារណាអំពីក្រមសីលធម៌.........11

**.ពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សនៅក្នុងបរិបទកម្ពុជា.........⁄ 1**

២.១ ទិដ្ឋភាពទូទៅអំពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ.........13

២.២ ពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សឆ្លងដែន.........14

២.៣ ពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សផ្សេងទៀតនៅក្រៅប្រទេស.........16

**៣. ក្របខណ្ឌច្បាប់ និងគោលនយោបាយ.........⁄ 6**

៣.១ ក្របខណ្ឌច្បាប់.........18

៣.២ ក្របខណ្ឌគោលនយោបាយអំពីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស.........19

៣.៣ ក្របខណ្ឌស្តីពីចំណាកស្រុកការងារ.........20

**៤. ភាគីពាក់ព័ន្ធ និងការគូសផែនទីដំណើរការស៊ើបអង្កេត.........00**

៤.១ សាវតារភាគីពាក់ព័ន្ធ និងអាទិភាព.........22

៤.២ ការគូសផែនទីដំណើរការស៊ើបអង្កេត និងតុលាការកម្ពុជា.........29

**៥. ការដោះស្រាយ និងការរាំងជនល្មើស.........15**

៥.១ ការតាមដានត្រួតពិនិត្យ និងអធិការកិច្ច.........37

៥.២ ការស៊ើបអង្កេតពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស.........44

៥.៣ ការផ្តន្ទាទោសលើករណីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស.........59

**៦. ការគាំទ្រជនរងគ្រោះ និងសាក្សី.........50**

៦.១ ការកំណត់អត្តសញ្ញាណជនរងគ្រោះ.........72

៦.២ ការការពារ និងការគាំទ្រជនរងគ្រោះ.........81

៦.៣ ដំណោះស្រាយ និង សំណង.........88

**៧.ការសហការជាមួយភាគីពាក់ព័ន្ធ.........71**

៧.១ ការសម្របសម្រួលអន្តរទីភ្នាក់ងារ.........93

៧.២ កិច្ចសហប្រតិបត្តិការឆ្លងដែន.........98

**៨.ទំនុកចិត្តរបស់ភាគីពាក់ព័ន្ធទៅលើប្រព័ន្ធយុត្តិធម៌.........⁄ . 3**

**៩.សេចក្តីសន្និដ្ឋាន និងអនុសាសន៍.........⁄ . 7**

# ពាក្យកាត់

| | |
|---|---|
| ABC | សមាគមធនាគារនៅកម្ពុជា |
| ACRA | សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា |
| ACT | កម្មវិធីអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស |
| ACTIP | អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| AHJPD | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| CSO | អង្គការសង្គមស៊ីវិល |
| CTIP | ការប្រឆាំងអំពើជួញដូរមនុស្ស |
| FGD | កិច្ចពិភាក្សាក្រុមគោលដៅ |
| DOSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| FL/TIP | ពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស |
| ICRC | គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម |
| IJM | អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IVJ | ចៅក្រមស៊ើបសួរ |
| MAC | សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា |
| MFAIC | ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MLAT | សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoU | អនុស្សារណៈនៃការយោគយល់ |
| MoWA | ក្រសួងកិច្ចការនារី |
| MRC | មជ្ឈមណ្ឌលធនធានពលករចំណាកស្រុក |
| NCCT | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NTF | ក្រុមការងារថ្នាក់ជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |

| | |
|---|---|
| OSH | សុវត្ថិភាព និងសុខភាពការងារ |
| PAC | មជ្ឈមណ្ឌលបណ្ឌិត្យសភានគរបាល |
| PTC | មជ្ឈមណ្ឌលសំចតប៉ោយប៉ែត |
| PCCT | គណៈកម្មាធិការខេត្តប្រឆាំងអំពើជួញដូរមនុស្ស |
| PoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត |
| RCG | ក្រុមស្រាវជ្រាវ និងទំនាក់ទំនង |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SOP | ស្តង់ដារនីតិវិធីប្រតិបត្តិ |
| TIP | អំពើជួញដូរមនុស្ស |
| UN | អង្គការសហប្រជាជាតិ |
| US DOS | ក្រសួងការបរទេសសហរដ្ឋអាមេរិក |



# សេចក្ដីសង្ខេប

# សេចក្តីសង្ខេប

ការសិក្សានេះ គឺមានគោលបំណងវាយតម្លៃទៅលើប្រសិទ្ធភាព និងវឌ្ឍនភាពប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជា ក្នុងការឆ្លើយតបទៅនឹងករណីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សទាំងក្នុងស្រុក និងក្រៅស្រុក ដោយផ្តោតជាពិសេសលើពលករចំណាកស្រុករបស់កម្ពុជាដែលកំពុងធ្វើការនៅក្នុងវិស័យនេសាទនៅឯប្រទេសថៃ។ លើសពីនេះ តួនាទីនៃកិច្ចសហការឆ្លងដែនរវាងប្រព័ន្ធយុត្តិធម៌ប្រទេសថៃនិងកម្ពុជា ក្នុងការឆ្លើយតបទៅនឹងពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស គឺជាចំណុចដ៏សំខាន់។ ការសិក្សាស្រាវជ្រាវនេះ គឺជាសមាសធាតុមួយក្នុងចំណោមសមាសធាតុទាំងបី នៃគម្រោងសិក្សាស្រាវជ្រាវថ្នាក់តំបន់ដែលត្រូវបានរៀបចំឡើងដោយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដែលត្រួតពិនិត្យទៅលើប្រសិទ្ធភាពប្រព័ន្ធយុត្តិធម៌ផ្តោតទៅលើពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសកម្ពុជា ថៃ និងមីយ៉ាន់ម៉ា។

របកគំហើញនៃការសិក្សានេះ គឺផ្អែកលើឯកសារពាក់ព័ន្ធនានាដែលមានស្រាប់ និងសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ចំនួន ៥៥ នាក់ ក្នុងនោះមាន៖ មន្ត្រីរដ្ឋាភិបាល ចៅក្រម ព្រះរាជអាជ្ញា នគរបាល និងតួអង្គប្រព័ន្ធយុត្តិធម៌នៃអង្គការមិនមែនរដ្ឋាភិបាលជាច្រើននាក់។ សម្ភាសន៍ទាំងនេះ ត្រូវបានធ្វើឡើងនៅក្នុងចន្លោះខែ មករា និងខែមេសា ឆ្នាំ ២០២២ ដែលផ្តោតលើទីតាំងខេត្តចំនួនប្រាំមួយនៅទូទាំងប្រទេស។ របកគំហើញនៃការស្រាវជ្រាវនេះ បានច្របាច់បញ្ចូលគ្នារវាងសម្ភាសន៍ស៊ីជម្រៅ និងកិច្ចពិភាក្សាក្រុមគោលដៅ ជាមួយនឹងពលករចំណាកស្រុកចំនួន ២១ នាក់ និងជនរងគ្រោះពីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សដោយផ្តោតលើបទពិសោធន៍ និងទស្សនៈយល់ឃើញរបស់ពួកគេទៅលើប្រព័ន្ធយុត្តិធម៌។ ការសិក្សានេះដែរ ក៏មានគោលបំណងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពដែលសម្រេចបាន រាប់ចាប់តាំងពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដែកបានសិក្សាលើប្រធានដូចគ្នានេះនៅអំឡុងឆ្នាំ ២០១៦។

## ៤ របកគំហើញសំខាន់ៗ៖ កិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពថ្មីៗ

ចំណុចសំខាន់នៃការសិក្សានេះ គឺការរៀនសូត្រអំពីភាគីពាក់ព័ន្ធសំខាន់ៗ រួមមាន៖ រដ្ឋាភិបាល តុលាការ នគរបាល និងអង្គការមិនមែនរដ្ឋាភិបាល អំពីថាតើសកម្មភាពដែលបានអនុវត្តមានអ្វីខ្លះ និងវិសាលភាពនៃកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធជាក់លាក់បានចូលរួមចំណែកកម្រិតណាដែរដល់វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សរបស់ប្រព័ន្ធយុត្តិធម៌កម្ពុជា។ ចំណុចសំខាន់ៗមានដូចខាងក្រោម៖

### › ការទប់ស្កាត់

- **ចំណាកស្រុកជាប្រក្រតី៖** រាជរដ្ឋាភិបាលកម្ពុជា បានបង្កើននូវលទ្ធភាពក្នុងការទទួលបានឯកសារចំណាកស្រុកសម្រាប់ពលករ តាមរយៈការបង្កើតនីតិវិធីដាក់ពាក្យស្នើសុំនៅទីតាំងកាន់តែច្រើនកន្លែង។
- **ការតាមដានត្រួតពិនិត្យ៖** វិស័យជ្រើសរើសបុគ្គលិក និងវិស័យធនាគារ បានចាត់វិធានការបឋមដោយឆ្ពោះទៅរកស្វ័យនិយ័តកម្មដែលមិនជាប់កាតព្វកិច្ចផ្លូវច្បាប់ តាមរយៈការបង្កើតក្រមប្រតិបត្តិ។ ក្រុមការងារនឹងតាមដានមើលថាតើកិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺគ្រាន់តែជាកំណែទម្រង់បែបសំណេរលើក្រដាស ឬក៏ថាវានឹងមានឥទ្ធិពលយ៉ាងណាដែរ។

## ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

- **ការស៊ើបអង្កេត៖** ការយល់ដឹងអំពីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស និងសមត្ថភាពរបស់មន្ត្រីនៅកម្រិតមូលដ្ឋាន មន្ត្រីតុលាការ និងរដ្ឋាភិបាល គឺមានការកែលម្អឱ្យកាន់តែប្រសើរឡើង។ បណ្ឌិត្យសភាបណ្ដុះបណ្ដាលនរគបាល បានរៀបចំកម្មវិធីបណ្ដុះបណ្ដាលថ្មីមួយ ដោយបានដាក់បញ្ចូលនូវធាតុចូលអំពីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សទៅក្នុងមេរៀនផងដែរ។
- **ការបង្រ្កាបការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត៖** អាជ្ញាធរដែលបានផ្ដល់សម្ភាសន៍បានឱ្យដឹងថា ចាប់តាំងពីខែ សីហា ឆ្នាំ ២០២២ មក មានការ "ចុះបង្រ្កាប" ទីតាំងអគារ និងកន្លែងគោលដៅនានាដែលជាប់សង្ស័យថាជាទីតាំងប្រតិបត្តិការបទល្មើសបច្ចេកវិទ្យា។ ប្រភពដដែលបានឱ្យដឹងដែរថា មានការចុះអធិការកិច្ចពលកររាប់រយនាក់នៅក្នុងអំឡុងពេលនេះ និងមានមនុស្សប្រមាណ ជាង ២០០០នាក់ ត្រូវបានជួយសង្គ្រោះពីទីតាំងការងារដែលប្រព្រឹត្តអំពើរំលោភបំពាន។ ការចុះអធិការកិច្ចនេះ គឺដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិសំខាន់ៗ ព្រមទាំងសម្ពាធពីសំនាក់សាធារណជន។ ដោយឡែក របាយការណ៍បានបង្ហាញថា កិច្ចប្រឹងប្រែងនេះ គឺបានដោះស្រាយករណីមានសក្ដានុពលត្រឹមតែមួយចំណែកតូចប៉ុណ្ណោះ ហើយវិស័យបទល្មើសបច្ចេកវិទ្យានេះដែរ គឺទំនងជារីកលូតលាស់ឡើង។ ដូច្នេះ ការបន្តកិច្ចប្រឹងប្រែងចុះអធិការកិច្ចនាពេលអនាគត គឺជារឿងសំខាន់ណាស់។ ជាមួយគ្នាដែរ ភាគីពាក់ព័ន្ធចូលរួមសម្ភាសបានលើកឡើងថា មានការប្រឆាំងកើតឡើងក្នុងខណ:ពេលកំពុងស៊ើបអង្កេតលើប្រតិបត្តិករឆបោកតាមប្រព័ន្ធអ៊ីនធឺណិតនោះគឺដោយសារតែប្រតិបត្តិករទាំងនោះ ត្រូវបានគេជឿថាមានទំនាក់ទំនងជាមួយនឹងអ្នកមានឥទ្ធិពល។ ការណ៍នេះ គឺមានសង្គតិភាពជាមួយនឹងការពិតដែលថា នៅក្នុងចំណោមពលករដែលត្រូវបានជួយសង្រោះ គឺពុំមានពលករណាម្នាក់ត្រូវបានកំណត់ជាផ្លូវការថាជាជនរងគ្រោះនៃការជួញដូរមនុស្សនោះទេ។ គួរកត់សំគាល់ផងដែរថា មានសកម្មភាពចុះបង្រ្កាបក្នុងអំឡុងខែ សីហា ឆ្នាំ ២០២២ នៅក្រោយពេលបញ្ចប់កិច្ចការប្រមូលទិន្នន័យបឋមសម្រាប់ការសិក្សាស្រាវជ្រាវនេះ។
- **ការផ្ដន្ទាទោស៖** តុលាការបានចាប់ផ្ដើមយុទ្ធនាការមួយដែលជាលទ្ធផលបានពន្លឿនដំណើរការជំនុំជម្រះសំណុំរឿងនៅតុលាការជាច្រើនដែលបានបង្កកទុកពុំទាន់បានដោះស្រាយនៅឡើយ។ ជាមួយគ្នានេះផងដែរ តុលាការបានធ្វើវឌ្ឍនភាពការប្រមូលទិន្នន័យសំណុំរឿងផ្ទៃក្នុង។ ប៉ុន្តែទោះជាយ៉ាងណានេះក្ដី ក៏នៅតែមានភាពពុំច្បាស់លាស់សម្រាប់តួអង្គក្នុងប្រព័ន្ធយុត្តិធម៌នានាផ្សេងទៀត។ ការប្រើប្រាស់កម្មវិធីទំនាក់ទំនងអនឡាញបានពន្លឿនដំណើរការ និងប្រសិទ្ធភាពនៃការចេញដីកាពីសំនាក់តុលាការ។
- **ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌៖** មន្ត្រីរដ្ឋាភិបាលដែលបានចូលរួមក្នុងការស្ទង់មតិបានលើកឡើងថា ពួកគេគឺមានភាពឯករាជ្យអាចទំនាក់ទំនងកិច្ចការងារបាន និងមានយុត្តិធម៌ក្នុងការឆ្លើយតបទៅនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ មន្ត្រីនគរបាល និងមន្ត្រីរដ្ឋាភិបាលបានគូសបញ្ជាក់ថា ពួកគេបានបើកទូលាយដើម្បីឱ្យសាធារណ:ជនអាចទាក់ទងការងារផ្សេងៗបាន។ អង្គការសង្គមស៊ីវិលមួយចំនួនចូលរួមសម្ភាសបានលើកឡើងថា មានកំនើនឡើងនូវទំនុកចិត្តក្នុងចំណោមសាធារណ:ជនលើប្រព័ន្ធយុត្តិធម៌ក្នុងសំណុំរឿងនានា ប៉ុន្តែក៏បានលើកឡើងដែរអំពីមន្ទិលសង្ស័យលើប្រព័ន្ធយុត្តិធម៌ដែលបន្តពុំគាំទ្រដល់ប្រជាជនសាមញ្ញប៉ុន្តែបែរជាគាំទ្រតួអង្គបុព្វសិទ្ធិទៅវិញ។

## ការកំណត់អត្តសញ្ញាណ និងការគាំទ្រជនរងគ្រោះ

- **ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយប្រើប្រាស់គោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ៖** មន្ត្រីមួយចំនួនបាននិងកំពុងប្រើប្រាស់គោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបានរាយការណ៍ពីមតិយោបល់ត្រលប់ជាវិជ្ជមាន។ ដោយឡែក មានមន្ត្រីមួយចំនួនផ្សេងទៀតគិតថា គោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនេះគឺពុំមានប្រសិទ្ធភាព និងមិនចង់ប្រើប្រាស់គោលការណ៍ទាំងនេះនោះទេ

ហើយគណៈកម្មាធិការជាតិប្រឆាំងអំពើជួញដូរមនុស្ស បច្ចុប្បន្នគឺកំពុងស្វែងរកមតិយោបល់ត្រលប់ពីបណ្តាភាគីទាំងមូលគឺពាក់ព័ន្ធនានាក្នុងបំណងធ្វើទម្រង់សម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះជាថ្មី ដើម្បីបង្កើនការប្រើប្រាស់ និងសង្គតិភាពនៃនិតិវិធីកំណត់អត្តសញ្ញាណទាំងមូលនៅតាមបណ្តានាយកដ្ឋាននានា។

- **មជ្ឈមណ្ឌលសំចត៖** មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានពង្រីកសេវារបស់ខ្លួនដោយគ្របដណ្តប់លើជនរងគ្រោះជាបុរសនៃពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សបន្ថែមពីលើស្ត្រី និងកុមារ។ មជ្ឈមណ្ឌលសំចតថ្មីនេះ ត្រូវបានបើកដំណើរការដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) នៅស្រុកកំរៀង ខេត្តបាត់ដំបង។
- **ការបញ្ជូន និងសេវាគាំទ្រដល់ជនរងគ្រោះ៖** មានគម្រោងជាច្រើនសម្រាប់មជ្ឈមណ្ឌលផ្តល់សេវាថែទាំថ្មីមួយ នៅឯស្រុក កណ្តាលស្ទឹង ដែលនឹងដំណើរការដោយ នាយកដ្ឋានស្តារនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)។ រាជរដ្ឋាភិបាលកម្ពុជា បានបន្តសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងបើកមជ្ឈមណ្ឌលសម្រាប់ពលករចំណាកស្រុកបន្ថែមឱ្យបានច្រើនទៀត។

## › កិច្ចសហប្រតិបត្តិការ និងការសហការ

- **ការសហការក្នុងស្រុក៖** កិច្ចសហការក្នុងស្រុកផ្តោតលើពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស នៅតែបន្តដឹកនាំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) តាមរយៈក្រុមការងារទាំង ៦ របស់ខ្លួន។ ថ្វីត្បិតក្រុមការងារទាំងនេះដើរតួជាតំណាងយន្តការសម្រាប់ការសហការដ៏សំខាន់បំផុតនៅកម្ពុជា ប៉ុន្តែយន្តការនេះគឺស្ថិតនៅកម្រិតថ្នាក់ក្រសួងប៉ុណ្ណោះ។ ទន្ទឹមគ្នានេះដែរ ការសហការផ្សេងៗជាច្រើន គឺត្រូវការចាំបាច់នៅកម្រិតប្រតិបត្តិការ និងកម្រិតនាយកដ្ឋាន ប៉ុន្តែមានមន្ត្រីជាច្រើនបានប្រាប់ឱ្យដឹងថា ពួកគេបានដឹងអំពីតួនាទីរវាងគ្នាច្រើនជាងមុនបន្តិចបន្តួចប៉ុណ្ណោះ និងបានបង្កើនទំនាក់ទំនងការងារពាក់ព័ន្ធនឹងការបញ្ជូនករណី និងការសហការជាបន្តបន្ទាប់។
- **ការសហការឆ្លងដែន៖** នៅអំឡុង ឆ្នាំ ២០២១ និងឆ្នាំ ២០២២ ប្រទេសថៃ និងកម្ពុជាបានចុះហត្ថលេខាលើស្តង់ដារនីតិវិធីប្រតិបត្តិ (SOPs) ក្នុងគោលបំណងចែងអំពីរបៀបនៃការសហការយ៉ាងណាឱ្យបានល្អបំផុតទៅលើកិច្ចការមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះពីការជួញដូរមនុស្សនៅកម្ពុជា និងកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស។ ស្តង់ដារនីតិវិធីប្រតិបត្តិទាំងនេះ បច្ចុប្បន្នគឺត្រូវបានរៀបចំរួចរាល់សម្រាប់ការអនុវត្ត។

# ៤ របកគំហើញសំខាន់ៗ៖ បញ្ហា និងគម្លាតចម្បងៗ

ការសិក្សានេះ បានសាកសួរភាគីពាក់ព័ន្ធសំខាន់ៗ ក្នុងគោលបំណងកំណត់រកសមាសធាតុរបស់ប្រព័ន្ធយុត្តិធម៌កម្ពុជាដែលអាចកែលម្អឱ្យបានកាន់តែប្រសើរដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស។ ចំណុចសំខាន់ៗដែលបានកំណត់នោះ មានដូចខាងក្រោម៖

## › ការទប់ស្កាត់

- **ចំណាកស្រុកប្រក្រតី៖** រដ្ឋាភិបាលមានឆន្ទៈតិចតួចក្នុងការធ្វើការងារជាមួយប្រទេសថៃដើម្បីដោះស្រាយចំណុចខ្វះខាតនៃការរៀបចំនៅក្នុងប្រព័ន្ធអនុស្សារណៈនៃការយោគយល់ ដែលគ្រប់គ្រងលើបណ្តាញចំណាកស្រុកប្រក្រតីសម្រាប់ពលករកម្ពុជា។ ជាលទ្ធផល បណ្តាញចំណាកស្រុកនៃអនុស្សារណៈនៃការយោគយល់ នៅតែពុំមានភាពទាក់ទាញ និងសុវត្ថិភាពសម្រាប់ពលករចំណាកស្រុកនោះទេ ។

- **ការយល់ដឹង និងការបណ្តុះបណ្តាលអំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស៖** ពុំមានគោលដៅ និងបទដ្ឋានច្បាស់លាស់ក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃទៅលើលទ្ធផលនៃកិច្ចប្រឹងប្រែងបណ្តុះបណ្តាលើការយល់ដឹង។
- **ការចែករំលែកទិន្នន័យអំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស៖** ការប្រមូលទិន្នន័យ និងការចែករំលែកព័ត៌មានពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស គឺមានកង្វះខាតនៅក្នុងប្រព័ន្ធទាំងមូល។ ការកែលម្អលើការប្រមូលទិន្នន័យក្នុងស្រុកមួយចំនួនគឺត្រូវសម្រេចបាន ដូចជា ការគ្រប់គ្រងសំណុំរឿងនៅក្នុងប្រព័ន្ធតុលាការជាដើម។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) បច្ចុប្បន្ន គឺកំពុងបង្កើតនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យមួយនៅកម្រិតនាយកដ្ឋាន ដោយមានការសហការពីបណ្តាអង្គការមិនមែនរដ្ឋាភិបាលនានា។
- **ការតាមដានត្រួតពិនិត្យ៖** ការត្រួតពិនិត្យឯករាជ្យលើវិស័យជ្រើសរើសពលករ និងមីក្រូហិរញ្ញវត្ថុ គឺនៅមានកម្រិតតិចតួចនៅឡើយ ដែលវិស័យទាំងពីរនេះ គឺកំពុងបោះជំហានឆ្ពោះទៅរកស្វ័យនិយ័តកម្មដែលពុំជាប់កាតព្វកិច្ចផ្លូវច្បាប់ប៉ុណ្ណោះ ដែលកត្តានេះទំនងជាពុំសូវមានឥទ្ធិពលខ្លាំងអ្វីនោះទេ។ មួយវិញទៀត មានកាតព្វកិច្ចតិចតួចបំផុតដែលត្រូវបានដាក់ទៅលើភ្នាក់ងារជ្រើសរើសពលករដើម្បីធានានូវសុវត្ថិភាពរបស់ពលករចំណាកស្រុកនៅក្រៅប្រទេស ឬពិន័យលើកំសោយសមត្ថភាពអនុវត្តការងារ។

## > ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

- **ការស៊ើបអង្កេត៖** មានការហាមឃាត់ក្នុងចំណោមនគរបាលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតទីតាំងការងារដែលជាប់ពាក់ព័ន្ធនឹងតួអង្គ និងមន្ត្រីមានឥទ្ធិពល។ មួយវិញទៀត ជាញឹកញាប់ នគរបាលបានសង្កត់ធ្ងន់ទៅលើការស៊ើបអង្កេតសមាជិកគ្រួសារ និងមិត្តភក្តិដែលពួកគេពុំមែនជាមេខ្យល់សកម្មនោះទេ គឺគ្រាន់តែជាអ្នកជួយទាក់ទងរកការងារឱ្យធ្វើប៉ុណ្ណោះ បើធៀបនឹងមេខ្យល់ និងបណ្តាញជ្រើសរើសពលករអាជីព។
- **ធនធានស៊ើបអង្កេត៖** នគរបាលខេត្តត្រូវបង្ខំចិត្តចេញប្រាក់ហោប៉ៅផ្ទាល់ខ្លួនជាមុនសិនដើម្បីរ៉ាប់រងការចំណាយពាក់ព័ន្ធនឹងកិច្ចការងារស៊ើបអង្កេតដោយសង្ឃឹមថានឹងបានសំណងមកវិញនៅពេលក្រោយ។ បញ្ហាមួយទៀត គឺកង្វះបន្ទប់សម្ភាសន៍ជនរងគ្រោះឯកជន ដែលបានប៉ះពាល់ដល់ការរក្សាព័ត៌មានសម្ងាត់របស់ជនរងគ្រោះ។ ទន្ទឹមគ្នានេះដែរ កង្វះមន្ត្រីនគរបាលជាស្ត្រីក៏ជាបញ្ហាមួយដែរ ដើម្បីធានាបាននូវសម្ភាសន៍ដែលយកចិត្តទុកដាក់លើយេនឌ័រ។
- **សមត្ថភាពស៊ើបអង្កេត៖** សមត្ថភាពស៊ើបអង្កេតរបស់នគរបាលនៅកម្រិតមូលដ្ឋាន និងតាមបណ្តាខេត្តគឺអាចពុំទាន់គ្រប់គ្រាន់ក្នុងការផលិតភស្តុតាងសំណុំរឿង និងបង្កើតអង្គហេតុសំណុំរឿងនៅអង្គសវនាការ។ ការយល់ដឹង និងការអនុវត្តវិធីសាស្ត្រសម្ភាសន៍ដែលគិតគូរដល់ការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះ គឺកម្រណាស់។ ការបណ្តុះបណ្តាលស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ចាំបាច់គឺត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ក្នុងកម្មវិធីបណ្តុះបណ្តាល ពីព្រោះការអនុវត្តចេះតែវិវត្តទៅមុខ ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនិងបទល្មើសបច្ចេកវិទ្យា។
- **ការកំណត់អត្តសញ្ញាណជនល្មើស៖** ជនសង្ស័យនៃអំពើជួញដូរមនុស្ស តែងតែរត់គេចខ្លួន នៅខណៈដែលសំណុំរឿងកំពុងត្រូវបានស៊ើបអង្កេត។ ដោយឡែក ប្រសិនបើពុំមានការចោទប្រកាន់ចេញដោយព្រះរាជអាជ្ញានោះទេ ជនសង្ស័យអាចត្រូវបានឃាត់ខ្លួនត្រឹមតែ ៤៨ ម៉ោងប៉ុណ្ណោះ ក្នុងករណីពួកគេបានត្រូវចាប់ខ្លួន ។ ទោះយ៉ាងណា ការកំណត់អត្តសញ្ញាណជនល្មើសនៅតែជួបការលំបាក ដោយសារតែព័ត៌មានពាក់ព័ន្ធនឹងមេខ្យល់នៅមានកម្រិត។
- **ការចូលរួមរបស់ជនរងគ្រោះក្នុងសវនាការកាត់ទោស៖** ការចូលរួមសហការក្នុងសវនាការកាត់ទោសសំណុំរឿង គឺនៅតែពុំទាក់ទាញជនរងគ្រោះនោះទេ ដោយសារឧបសគ្គផ្នែកហិរញ្ញវត្ថុ និងពេលវេលា។ ជារឿយៗ ជនរងគ្រោះជ្រើសរើសដំណោះស្រាយក្រៅផ្លូវការជាជាងត្រាំត្រែងរង់ចាំសវនាការជម្រះក្តី។ លើសពីនេះ អង្គការសង្គមស៊ីវិលបានលើកឡើងថា សហគមន៍យល់ឃើញថាពួកគាត់ពុំអាចប្រើប្រាស់ប្រព័ន្ធតុលាការបានឡើយ ក្នុងន័យសំដៅលើការចាត់វិធានការប្រឆាំងនឹងជនមានបុព្វសិទ្ធិ ដែលប្រការនេះចូលរួមចំណែកធ្វើឱ្យជនរងគ្រោះទទួលយកដំណោះស្រាយក្រៅប្រព័ន្ធតុលាការ។

- **ការផ្តន្ទាទោស និងការវិនិច្ឆ័យទោស៖** បុគ្គលមានអំណោចត្រូវបានគេមើលឃើញថាមានឥទ្ធិពលលើច្បាប់ និងគេចវេសពីការផ្តន្ទាទោស។ កិច្ចខិតខំរបស់តុលាការកាលពីពេលថ្មីៗពាក់ព័ន្ធនឹងរឿងស្នូះកកកុញអ្នកទោសក្នុងពន្ធនាគារបានធ្វើឱ្យមានការផ្លាស់ប្តូរទិសដៅកម្មវិធីនានា ហើយការឃុំឃាំងនៅក្នុងទីតាំងគឺត្រូវកំណត់ពេលវេលាជាក់លាក់ដោយតុលាការ។ លទ្ធភាពចំណាយក្រៅផ្លូវការគួបផ្សំនឹងការលំបាកក្នុងការអនុវត្តដីកាសំណង នាំឱ្យមានឱកាសតិចតួចបំផុតដែលជនល្មើសនឹងមកប្រឈមមុខនឹងទណ្ឌកម្មធ្ងន់ធ្ងរ។

## > ការកំណត់អត្តសញ្ញាណ និងការគាំទ្រដល់ជនរងគ្រោះ

- **ការកំណត់អត្តសញ្ញាណជនរងគ្រោះ៖** ជារួម ការកំណត់អត្តសញ្ញាករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សគឺពុំទាន់គ្រប់គ្រាន់នៅឡើយនោះទេ ដែលនេះមានន័យថា មានជនរងគ្រោះជាច្រើនពុំដែលបានបន្តនីតិវិធីតាមប្រព័ន្ធយុត្តិធម៌តាំងពីដំបូងឡើយ។ ការពិនិត្យពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សជាបឋម គឺពុំទាន់បានអនុវត្តគ្រប់គ្រាន់នៅឡើយទេនៅក្នុងបរិបថមានហានិភ័យខ្ពស់ មានជាអាទិ៍ កង្វះចំនួនធនធានអធិការ និងវិស័យត្រួតពិនិត្យតាមដាន។ ជនបរទេសនៅកម្ពុជា និងពលករទេសន្តរប្រវេសន៍នៅថៃ ជារឿយៗត្រូវបានបញ្ជូនត្រលប់មកកាន់ប្រទេសកំណើតវិញក្នុងនាមជាពលករពុំស្របច្បាប់ ដោយពុំមានការត្រួតពិនិត្យមើលថាជាករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សឬយ៉ាងណានោះទេ។ ទន្ទឹមនឹងនេះដែរ គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៅកម្ពុជា គឺពុំត្រូវបានប្រើប្រាស់ក្នុងទម្រង់ដូចគ្នានោះទេ ស្របពេលតួអង្គសំខាន់ៗមួយចំនួនប្រើប្រាស់ទម្រង់កំណត់អត្តសញ្ញាណផ្សេងៗទៀត ដែលកត្តានេះបានរាំងដល់ការសហការប្រកបដោយប្រសិទ្ធភាព។
- **សេវាគាំទ្រសម្រាប់ជនរងគ្រោះ និងសាក្សីនៅក្នុងដំណើរការកាត់ក្តី៖** ជនរងគ្រោះ និងសាក្សីពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាលសម្រាប់សេវាគាំទ្រផ្នែកច្បាប់ និងសង្គមកិច្ចតាមរយៈការដំណើរការស៊ើបអង្កេត និងជំនុំជម្រះក្តី និងអាចខ្វះខាតជំនួយគាំទ្រដោយហេតុថាសេវាសង្គមកិច្ចរបស់រដ្ឋាភិបាលជារឿយៗពុំត្រូវបានបញ្ចូលទៅក្នុងសំណុំករណីភ្លាមៗទាន់ពេលវេលា ឬពុំមានការគាំទ្រសោះតែម្តង។ បច្ចេកទេសចោទសួរសំណួររំសើបទៅកាន់ជនរងគ្រោះគឺត្រូវបានគេលើកឡើងច្រំដែលថានៅពុំមានលក្ខណៈគ្រប់គ្រាន់នៅឡើយទេនៅក្នុងការរៀបចំការកាត់ក្តីនោះ។
- **ការបញ្ជូនករណី និងសេវាគាំទ្រដល់ជនរងគ្រោះ៖** ខណៈដែលធនធានជារួមនៅមានកម្រិតនោះ ធនធានជាក់លាក់ដែលខ្វះខាតត្រូវបានគូសបញ្ជាក់។ ក្នុងនោះ សេវាគាំទ្រដល់ជនរងគ្រោះជាបុរសក៏មានកង្វះខាតច្រើនដែរ។ មជ្ឈមណ្ឌលសំចតខ្វះខាតកន្លែងស្នាក់ និងបន្ទប់សម្ភាសន៍គ្រប់គ្រាន់។ ជនរងគ្រោះគឺកម្រអាចទទួលបានសេវាប្រឹក្សាផ្លូវចិត្តណាស់។ មួយវិញទៀត កន្លែងស្នាក់សម្រាប់ជនរងគ្រោះជាពិសេសបុរសក៏មានកង្វះខាតផងដែរ។
- **សេវាសមាហរណកម្ម៖** សេវាគាំទ្រសមាហរណកម្ម ជារឿយៗពុំបានផ្តល់ដល់ជនរងគ្រោះនូវជម្រើសជីវភាពប្រកបដោយចីរភាពនោះទេ ដែលកត្តានេះបានបណ្តាលឱ្យពួកគេធ្វើចំណាកស្រុកម្តងទៀត។ នៅពេលដែជនរងគ្រោះត្រលប់ផ្ទះកំណើតវិញ ពួកគេបន្តទទួលរងការរិះគន់ មាក់ងាយ និងគម្លាតឆ្ងាយពីសង្គម។ លើសពីនេះ កង្វះខាតការស្រាវជ្រាវអំពីតម្រូវការរយៈពេលវែងរបស់ជនរងគ្រោះ និងការតាមដានត្រួតពិនិត្យលើស្តង់ដារនៃការផ្តល់សេវាកម្មក៏ជាបញ្ហាចោទដែរ។
- **ដំណោះស្រាយចំពោះជនរងគ្រោះ៖** ប្រព័ន្ធតុលាការ ពុំមែនជាជម្រើសមធ្យោបាយដែលទាក់ទាញសម្រាប់ជនរងគ្រោះក្នុងការស្វែងរកដំណោះស្រាយនោះទេ។ ផ្ទុយទៅវិញ ជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សបានបន្តដោះស្រាយករណីផ្សេងៗតាមរយៈការបង់ប្រាក់ក្រៅផ្លូវការនៅក្រៅប្រព័ន្ធតុលាការវិញ។ ដីកាសំណងចេញពីតុលាការនៅតែបន្តជាបញ្ហាចោទខ្លាំងនៅពេលអនុវត្តជាក់ស្តែង ដែលកត្តានេះទាមទារកំណែទម្រង់។ ថវិកា ឬគ្រោងការណ៍សំណងសម្រាប់ជនរងគ្រោះ ជាតម្រូវការចាំបាច់ណាស់ដើម្បីធានាថាជនរងគ្រោះទទួលបានសំណង។
- **កិច្ចសហការក្នុងស្រុក៖** ភាគីពាក់ព័ន្ធបានលើកឡើងថា ពួកគេនៅតែពុំទាន់បានដឹងពេញលេញនូវតួនាទីរបស់ពួកគេ

រៀងៗខ្លួននោះទេ។ គោលការណ៍ណែនាំស្ដីពីកិច្ចសហការពុំមានភាពជាក់លាក់ និងមានភាពលំបាកក្នុងការអនុវត្តជាក់ស្ដែង។ មន្ត្រីតុលាការ និងនគរបាលចាំបាច់ត្រូវកសាងទំនាក់ទំនងការងារ ដើម្បីសហការគ្នាឱ្យកាន់តែមានប្រសិទ្ធភាពជាងនេះ។ មានឯកសារស្ដីពីការសហការគ្នារវាងបណ្ដាភាគីពាក់ព័ន្ធជាច្រើន ដែលពុំត្រូវបានអនុវត្តតាម ឬជ្រួតជ្រាបដឹងឮពីសំណាក់ព័ន្ធភាគីពាក់ព័ន្ធផ្សេងៗនោះទេ។ សមត្ថភាពការងាររបស់តួអង្គប្រព័ន្ធយុត្តិធម៌ គឺពុំទទួលបានការកែលម្អទៅតាមកាលវេលានោះទេ ដោយសារតែសម្ព័ន្ធព័ត៌មានមតិយោបល់ត្រឡប់ជាព័ត៌មានសំណុំរឿង ក្នុងនោះរួមមានសេចក្ដីសម្រេចពុំផ្ដន្ទាទោស ដែលពុំត្រូវបានចែករំលែកជាមួយភាគីពាក់ព័ន្ធដទៃទៀតនោះទេ។

- **កិច្ចសហការប្រឆ្លងដែន៖** ស្របពេលដែលកិច្ចសហការឆ្លងដែនត្រូវបានអនុវត្តនៅកម្រិតក្រសួងនោះ កិច្ចសហការនៅកម្រិតប្រតិបត្តិការគឺមានបណ្ដាញមួយចំនួនតូចប៉ុណ្ណោះ។ ដូច្នេះ កត្តានេះនៅតែបញ្ហាលំបាកសម្រាប់នគរបាលកម្ពុជាដើម្បីទទួលបានភស្តុតាង និងជម្រុញឱ្យមានការស៊ើបអង្កេតពីសំណាក់សមភាគីនៅក្រៅប្រទេស ក្នុងនោះរួមទាំងប្រទេសថៃផងដែរ។ ការស៊ើបអង្កេតរួម គឺកម្រនឹងកើតមានណាស់។ ជនរងគ្រោះក្នុងស្រុកបន្តជួបការលំបាកពាក់ព័ន្ធនឹងការបន្តនីតិវិធីដោះស្រាយតាមផ្លូវច្បាប់ និងបន្តនីតិវិធីដោះស្រាយនេះនៅក្រៅប្រទេសផងដែរ។ កិច្ចសហការក្នុងដំណើរការជំនុំជម្រះក្ដី ជួនកាលត្រូវបានអនុវត្តក្រៅផ្លូវការ ប៉ុន្តែពុំមែនតាមរយៈយន្តការ MLAT នោះទេ ដោយហេតុថាយន្តការនេះត្រូវបានគេចាត់ទុកថាចំណាយកម្លាំងច្រើន និងពុំមានប្រសិទ្ធភាពឡើយ។ មន្ត្រីស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ ត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពក្នុងការគាំទ្រដល់មាតុភូមិនិវត្តន៍ ប៉ុន្តែជាទូទៅពុំមានការឆ្លើយតបរហ័សចំពោះបណ្ដឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សពីពលករចំណាកស្រុកនោះទេ។

**ដំណោះស្រាយ និងការណែនាំនានា ត្រូវបានយកទៅពិភាក្សាក្នុងផ្នែកទី៩ នៃរបាយការណ៍នេះ ដែលស្របតាមប្រធានបទខាងក្រោម៖**

១. ជំរុញលទ្ធភាពរបស់ពលករចំណាកស្រុក តាមរយៈការដោះស្រាយបញ្ហាខ្វះខាតការរៀបចំប្រព័ន្ធចំណាកស្រុក ដែលរារាំងពលករពីការការពារខ្លួនឯង។

២. ពង្រឹងកិច្ចការការងារកំណត់អត្តសញ្ញាណ តាមរយៈការជំរុញទឹកចិត្តដល់បណ្ដាតួអង្គប្រព័ន្ធយុត្តិធម៌ក្នុងការត្រួតពិនិត្យបន្ថែមលើពលករដែលប្រឈមនឹងហានិភ័យខ្ពស់ជាងគេ កំណត់អត្តសញ្ញាណករណី និងតាមដានត្រួតពិនិត្យទីតាំងមានហានិភ័យបន្ថែមទៀតឱ្យបានច្រើនឡើង។

៣. ផ្ដល់ការលើកទឹកចិត្តដល់ជនរងគ្រោះឱ្យចូលរួម ដើម្បីឱ្យពួកគេចូលប្រើប្រាស់ និងបន្តស្ថិតក្នុងប្រព័ន្ធយុត្តិធម៌ ដោយលុបបំបាត់របាំងរារាំងនានា តាមរយៈការផ្ដល់ការគាំទ្រ និងលទ្ធភាពទទួលបានដំណោះស្រាយផ្សេងៗ។

៤. បង្កើតបណ្ដាញផ្សេងៗសម្រាប់បណ្ដាតួអង្គប្រព័ន្ធយុត្តិធម៌ ដើម្បីសម្របសម្រួលកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាពជាងនេះបន្ថែមទៀត។



# ១ សាវតារ និងវិធីសាស្ត្រ

# ១ សាវតារ និង វិធីសាស្ត្រ

## ១.១ ទិដ្ឋភាពទូទៅនៃអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) បានត្រូវបង្កើតឡើងដំបូងនៅឆ្នាំ១៩៩៧ គឺជាអង្គការលំដាប់ថ្នាក់សកលមួយមានគោលដៅការពារប្រជាជនក្រីក្រពីអំពើហិង្សា។ អង្គការនេះ ធ្វើការសហការក្នុងភាពជាដៃគូជាមួយអាជ្ញាធរមូលដ្ឋានជាច្រើននៅទូទាំង ១៤ ប្រទេសដែលមានកម្មវិធីចំនួន ២១ របស់ខ្លួន (រួមមាន កម្ពុជា ថៃ និងមីយ៉ាន់ម៉ា ផងដែរ) ដើម្បីប្រឆាំងនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរពលកម្ម ការជួញដូរផ្លូវភេទ អំពើហិង្សាលើស្ត្រី និងកុមារ និងការប្រើអំណាចរំលោភបំពានពីសំណាក់នគរបាលមកលើប្រជាជនងាយរងគ្រោះ និងក្រីក្រ។ អង្គការ IJM អនុវត្តកិច្ចការងារជួយសង្គ្រោះ និងស្តារសម្បទាជនរងគ្រោះ ជំរុញឱ្យជនល្មើសមានទំនួលខុសត្រូវ និងពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ អឺរ៉ុបខាងកើត អាហ្វ្រិក និងអាមេរិកឡាទីន។ អង្គការនេះ បាននិងកំពុងបំពេញបេសកម្មកម្មវិធីការិយាល័យរបស់ខ្លួននៅកម្ពុជាចាប់តាំងពីឆ្នាំ ២០០៤ មក និងគាំទ្រដល់ការស៊ើបអង្កេត និងការផ្តន្ទាទោសឆ្លងដែនដែលរក្សាបាននូវការកាត់ទោសជនល្មើសសំខាន់ៗជាច្រើនពាក់ព័ន្ធក្នុងបណ្តាញជួញដូរពលករខ្មែរជាច្រើននាក់ក្នុងវិស័យទូកនេសាទនៅប្រទេសថៃ។

## ១.២ របាយការណ៍ គោលបំណង និង វិសាលភាព

នៅឆ្នាំ២០២១ អង្គការ IJM បានសហការជាមួយក្រុមស្រាវជ្រាវ និងទំនាក់ទំនង (RCG) ឱ្យចុះសិក្សាគម្រោងស្រាវជ្រាវមួយដែលផ្តោតលើប្រទេសចំនួន ៣ ដោយប្រើប្រាស់វិធីសាស្ត្រសិក្សាចម្រុះ ក្នុងគោលបំណងដើម្បីវាយតម្លៃអំពី៖ (១) វឌ្ឍនភាពសមត្ថភាពនៃការអនុវត្តការងារ និងប្រសិទ្ធភាពប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ថៃ និងមីយ៉ាន់ម៉ា ក្នុងការឆ្លើយតបទៅនឹងអំពើការជួញដូរមនុស្ស និងពលកម្មដោយបង្ខំ ជាពិសេសវិស័យគ្រឿងសមុទ្រថៃ និង (២) វិសាលភាពនៃកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងប្រទេសទាំង ៣ ក្នុងការដោះស្រាយជុំវិញបញ្ហាអំពើជួញដូរពលកម្មឆ្លងដែន។

របាយការណ៍នេះ មានគោលបំណងសង្ខេបអំពីរបកគំហើញស្តីពីប្រទេសកម្ពុជាដែលជាសមាសធាតុមួយនៃគម្រោងសិក្សាស្រាវជ្រាវថ្នាក់តំបន់ទាំងមូល។ របកគំហើញទាំងនេះ នឹងត្រូវយកទៅប្រើប្រាស់ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការប្រើប្រាស់ធនធាន និងកិច្ចការការងាររបស់អង្គការ IJM នៅក្នុងរយៈពេលខ្លី និងមធ្យម។ របាយការណ៍នេះ ក៏នឹងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពការងារដោយរាប់ចាប់តាំងពីការចុះសិក្សាវាយតម្លៃប្រៀបធៀបនៅកម្ពុជារៀបចំដោយ អង្គការ IJM កាលពីឆ្នាំ២០១៦ មក។

## ១.៣ សំណួរស្រាវជ្រាវ

### ការសិក្សានេះ មានគោលបំណងតបឆ្លើយទៅនឹងសំណួរស្រាវជ្រាវចំនួន ៤ ដូចខាងក្រោម៖

| | |
|---|---|
| ១ | តើបច្ចុប្បន្នភាពរបស់រដ្ឋាភិបាលក្នុងកិច្ចខិតខំប្រឹងប្រែង ការកំណត់អាទិភាព ការសហការ និងឆន្ទៈនយោបាយ យ៉ាងណាដែរសម្រាប់ជាការឆ្លើយតបផ្នែករដ្ឋបាល និងឧក្រិដ្ឋកម្មយុត្តិធម៌នៅកម្ពុជា/មីយ៉ាន់ម៉ា/ថៃ ទៅនឹងពលកម្មដោយបង្ខំក្នុងវិស័យនេសាទ និងគ្រឿងសមុទ្រ និងវិស័យពាក់ព័ន្ធផ្សេងៗទៀត? |
| ២ | តើបច្ចុប្បន្នភាពនៃកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងបណ្តារដ្ឋាភិបាលពាក់ព័ន្ធយ៉ាងណាដែរ៖ (ក) រវាងកម្ពុជា និងថៃ (ខ) រវាងមីយ៉ាន់ម៉ា និងថៃ និងរវាងមីយ៉ាន់ម៉ា និងប្រទេសគោលដៅផ្សេងទៀត និង(គ) រវាងថៃ និងកម្ពុជា និងរវាងថៃ និងមីយ៉ាន់ម៉ា ដើម្បីដោះស្រាយពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សឆ្លងដែន? |
| ៣ | តើបណ្តាភាគីពាក់ព័ន្ធ (ទាំងរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល) និងអ្នកទទួលផលយល់ឃើញ និងមានទំនុកចិត្តយ៉ាងដូចម្តេចខ្លះទៅលើសមត្ថភាពនៃប្រព័ន្ធយុត្តិធម៌ក្នុងការដោះស្រាយបញ្ហាពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ក៏ដូចជាកិច្ចសហប្រតិបត្តិការឆ្លងដែន? ជាពិសេស ថាតើវឌ្ឍនភាពបានសម្រេចដល់កម្រិតណាខ្លះ មានចន្លោះខ្វះខាត និងបញ្ហាប្រឈមអ្វីខ្លះ និងថាតើអ្វីខ្លះជាសមាសធាតុនៃនីតិវិធីសំណុំរឿងទាំងមូល (ចាប់តាំងពីការកំណត់អត្តសញ្ញាណជនរងគ្រោះរហូតដល់ការកាត់ទោស និងបន្តរហូតដល់សេវាគាំទ្រដល់អ្នករួចជីវិត ការស្តារនីតិសម្បទា និង មាតុភូមិនិវត្តន៍) ដែលអនុវត្តបានល្អ ឬបានឃើញថាមានវឌ្ឍនភាពទៅមុខ? |
| ៤ | តើបណ្តាភាគីពាក់ព័ន្ធមានអនុសាសន៍សំខាន់ៗអ្វីខ្លះចំពោះដំណើរការប្រព័ន្ធយុត្តិធម៌ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីដោះស្រាយកាន់តែល្អប្រសើរលើការជួញដូរពលកម្ម និងកិច្ចសហប្រតិបត្តិការឆ្លងដែន? |

សំណួរសិក្សាស្រាវជ្រាវទាំង ៤ នេះគឺត្រូវបានចោទសួរឡើង និងបញ្ចូលទៅក្នុងក្របខណ្ឌប្រមូលទិន្នន័យដោយគិតគូរពីក្របខណ្ឌវាស់វែងជាសកល និងទ្រឹស្តីអំពីការផ្លាស់ប្តូររបស់អង្គការ IJM ដែលចាត់ទុកប្រព័ន្ធយុត្តិធម៌ថាមានតួនាទីទ្វេក្នុងការរារាំងជនល្មើសនិងគាំទ្រដល់ជនរងគ្រោះ។ លើសពីនេះ អង្គការ IJM បានបង្កើតឧបករណ៍វាស់វែងសម្រាប់ធ្វើការងារកម្មវិធីរបស់ខ្លួននៅគ្រប់ទីតាំងការងារ និងការសិក្សាស្រាវជ្រាវនេះបានដកស្រង់សំណួរដោយផ្ទាល់ចេញពីឧបករណ៍ស្ទង់មតិដែលមានទំនុកចិត្តរបស់អង្គការ IJM ដែលអនុញ្ញាតឱ្យមានការប្រៀបធៀបឆ្លងបរិបថតាមពេលវេលា។

## ១.៤ ការប្រមូលទិន្នន័យ និងវិធីសាស្ត្រ

ការប្រមូលទិន្នន័យ រួមមានសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ៤៥ នាក់ជាមន្ត្រីប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធសំខាន់ៗ ដែលត្រូវបានកំណត់អត្តសញ្ញាណជាមួយនឹងអង្គការ IJM ។ ភាគីពាក់ព័ន្ធទាំងនេះ មានដូចជា មន្ត្រីរដ្ឋាភិបាល មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល ព្រះរាជអាជ្ញា ចៅក្រម និងនគរបាល នៅថ្នាក់ជាតិ រាជធានីភ្នំពេញ និងថ្នាក់ខេត្តចំនួន៥ នៃប្រទេសរួមមាន៖ បន្ទាយមានជ័យ ព្រៃវែង កំពង់ធំ កំពង់ចាម និងសៀមរាប។ សម្ភាសន៍ផ្ទាល់ ត្រូវបានរៀបចំនៅចន្លោះខែមករា ដល់ខែមេសា ឆ្នាំ២០២២ ដោយប្រើប្រាស់វិធីសាស្ត្រកម្រងសំណួរពាក់កណ្តាលសម្ភាសន៍។

ក្រុមសិក្សាស្រាវជ្រាវ ក៏បានសម្ភាសពិភាក្សាក្រុមគោលដៅសរុបចំនួន ៤ ផងដែរ។ ក្រុមចំនួន ២ ក្នុងចំណោមក្រុមគោលដៅទាំង ៤ ដែលមានរួមបញ្ចូលពលករចំណាកស្រុកនៅប្រទេសថៃដែលពុំធ្លាប់ជាជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ រីឯ កិច្ចពិភាក្សាក្រុមគោលដៅចំនួន ២ ទៀត បានធ្វើឡើងជាមួយពលករខ្មែរជាច្រើនដែលទើបបានត្រលប់មកកម្ពុជាវិញ ដែលពួកគេធ្លាប់មានបទពិសោធន៍ខ្លះៗពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងបានចូលរួមក្នុងប្រព័ន្ធយុត្តិធម៌របស់ប្រទេសថៃ ឬកម្ពុជា។ សម្ភាសន៍ស៊ីជម្រៅចំនួន ៣ ត្រូវបានធ្វើឡើងជាមួយជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ដែលពួកគេធ្លាប់មានបទពិសោធន៍ច្រើនចូលរួមក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ត្រូវបានបង្កើតឡើងដើម្បីអនុវត្តតាមក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ និងសម្ភាសន៍ជនរងគ្រោះផងដែរ។

តារាង ១៖ ទិន្នន័យដែល ប្រមូលសម្រាប់បានការសិក្សានេះ

| ប្រភពទិន្នន័យ | ចំនួនអ្នកចូលរួម |
|---|---|
| សម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ | ៤៥ |
| • ទីភ្នាក់ងាររដ្ឋាភិបាលនានា | ១៦ |
| • មន្ត្រីតុលាការ – ព្រះរាជអាជ្ញា និងចៅក្រម | ១១ |
| • មន្ត្រីអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនានា | ៩ |
| • មន្ត្រីនគរបាល | ៧ |
| **កិច្ចពិភាក្សាក្រុមគោលដៅ** | ២១ |
| • ពលករខ្មែរនៅប្រទេសថៃ | ១៥ |
| • ជនរួចជីវិតពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សដែលបានត្រលប់មកកម្ពុជាវិញ | ៦ |
| **សម្ភាសន៍ស៊ីជម្រៅជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សដែលទើបត្រលប់មកវិញ** | ៣ |
| សិក្ខាសាលាផ្ទៀងផ្ទាត់ជាមួយភាគីពាក់ព័ន្ធ | ៦០+ |

អ្នកសម្ភាសន៍បានកត់ត្រាចំណុចសំខាន់ៗដែលលេចឡើងជាក់ស្តែងក្នុងអំឡុងពេលសម្ភាសន៍ និងសម្រង់សម្តីពាក់ព័ន្ធសំខាន់ៗជាទម្រង់សរសេរលាយលក្ខណ៍អក្សរ។ សម្ភាសន៍ដែលចប់សព្វគ្រប់ ត្រូវបានបញ្ចូលជាទម្រង់កំណត់ត្រា ហើយទិន្នន័យ គឺត្រូវបានវិភាគបែបគុណវិស័យ ដោយបានចាត់ទិន្នន័យទាំងនោះជាក្រុមទៅតាមប្រធានបទគន្លឹះ ដែលវាបានអនុញ្ញាតឱ្យកំណត់ទម្រង់អត្តសញ្ញាណដែលកើតឡើងញឹកញាប់ និងឆ្លោះទៅរកការវិភាគលម្អិតមួយ។[2] វិធីសាស្ត្ររបស់ Miles និង Huberman គឺត្រូវបានជ្រើសរើសអនុវត្តតាម ដោយបែងចែកការវិភាគជា ៣ ជំហាន៖ (១) ការបង្រួមទិន្នន័យ (២) ការបង្ហាញទិន្នន័យ និង (៣) ការទាញសេចក្តីសន្និដ្ឋាន។[3] បន្ទាប់មក ក្រុមការងារស្រាវជ្រាវបានឆ្លុះបញ្ចាំង និងផ្សារភ្ជាប់ព័ត៌មានទៅនឹងសំណួរស្រាវជ្រាវដើម្បីទាញចេញជាសេចក្តីសន្និដ្ឋានដូចបានគូសបញ្ជាក់ក្នុងរបាយការណ៍សិក្សានេះ

## ១.៥ ដែនកំណត់

របាយការណ៍នេះ ផ្តោតសំខាន់ទៅលើករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សឆ្លងដែនទៅប្រទេសថៃ ហើយជាពិសេសការស្រាវជ្រាវនេះគឺជាប់ពាក់ព័ន្ធនឹងការសិក្សាស្រដៀងគ្នាផ្សេងទៀតស្តីពីប្រព័ន្ធយុត្តិធម៌នៅប្រទេសថៃ និងមីយ៉ាន់ម៉ា។ ជាលទ្ធផល ការប្រមូលទិន្នន័យជាមួយនឹងបណ្តាប្រទេសគោលដៅផ្សេងទៀត គឺនៅមានកម្រិតនៅឡើយ ហើយការវិភាគលើការសហការគ្នាជាមួយប្រទេសទាំងនោះ គឺផ្តោតទៅលើសកម្មភាព និងមតិយល់ឃើញរបស់បណ្តាតួអង្គក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

មួយវិញទៀត នៅឆ្នាំ២០២២ មានករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សកម្រិតខ្ពស់ជាច្រើនករណីពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។ ទោះជាយ៉ាងនេះក្តី វិសាលភាពនៃការសិក្សានេះ គឺពុំបានផ្តោតជាពិសេសទៅលើករណីទាំងនេះឡើយ ហើយការប្រមូលទិន្នន័យ គឺពុំផ្តោតលើទីតាំងសំខាន់ៗនៃករណីការឆបោកតាមប្រព័ន្ធអ៊ីនធឺណិតនោះដែរ ដូច្នេះមតិត្រលប់ដែលប្រមូលបានស្តីពីប្រធានបទពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនេះ គឺនៅមានកម្រិត។ លើសពីនេះ មានសកម្មភាពផ្លូវការផ្សេងៗពាក់ពន្ធនឹងប្រធានបទនេះ ដែលបានកើតឡើងបន្ទាប់ពីការប្រមូលទិន្នន័យបឋមសម្រាប់ការសិក្សានេះត្រូវបានបញ្ចប់រួចរាល់។

## ១.៦ ការគិតគូរអំពីក្រមសីលធម៌

ការសិក្សាស្រាវជ្រាវនេះ គឺត្រូវបានរៀបចំត្រួតពិនិត្យដោយអ្នកពិគ្រោះយោបល់ផ្នែកក្រមសីលធម៌សិក្សាស្រាវជ្រាវឯករាជ្យចំនួន ២រូប ដែលពួកគេសុទ្ធតែមានជំនាញខ្ពស់លើវិស័យនេះ។ រាល់សម្ភាសន៍ទាំងអស់ ជាការចូលរួមដោយស្ម័គ្រចិត្ត ក្នុងនោះអ្នកផ្តល់សម្ភាសន៍ទទួលយល់ព្រមលើទម្រង់ស្នើសុំដែលផ្តល់ជូននៅមុនពេលចាប់ផ្តើមសម្ភាសន៍។ រាល់អ្នកចូលរួមសម្ភាសន៍និងកិច្ចពិភាក្សាក្រុមគោលដៅ (FGDs) ទាំងអស់បានដឹងឮថា អត្តសញ្ញាណរបស់ពួកគេនឹងត្រូវរក្សាជាអនាមិក ហើយរាល់ព័ត៌មានដែលបានផ្តល់ក្នុងពេលសម្ភាសន៍នឹងពុំចាត់ទុកថាជាមតិបុគ្គលផ្ទាល់ខ្លួន ឬអង្គភាពដែលពួកគេបម្រើការងារនោះទេ។

អាស្រ័យហេតុនេះ រាល់សម្រង់សម្តី ឬសម្រង់សម្តីដែលមានការកែសម្រួល ដែលអ្នកចូលរួមម្នាក់ៗបានលើកឡើង គឺត្រូវបានចាត់ចូលទៅក្នុងក្រុមភាគីពាក់ព័ន្ធទូទៅប៉ុណ្ណោះ ដែលសម្តៅដល់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការអន្តរជាតិ។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ គឺត្រូវបានកំណត់អត្តសញ្ញាណតាមសញ្ជាតិ។



# ២ ពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនៅក្នុងបរិបទកម្ពុជា

# ២ ពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនៅក្នុងបរិបទកម្ពុជា

ប្រជាជនកម្ពុជានៅតែបន្តជួបបទពិសោធពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ទាំងក្នុង និងក្រៅប្រទេស ហើយបទពិសោធនេះក៏កើតមានដែរលើជនបរទេសមួយចំនួនដែលកំពុងធ្វើការងារក្នុងប្រទេសកម្ពុជា។ យោងតាមរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក (US DOS) (តទៅនេះនឹងហៅកាត់ថា របាយការណ៍ US TIP) កម្ពុជាពុំបានចាត់វិធានការឱ្យបានគ្រប់គ្រាន់នោះទេក្នុងការប្រឆាំងនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សដែលបានកើតឡើងនៅក្នុងដែនដីរបស់ខ្លួន ក៏ដូចជាពលរដ្ឋកម្ពុជាដែលនៅក្រៅប្រទេសផងដែរ។ ហេតុដូច្នេះហើយ ទើបកម្ពុជាត្រូវបានចាត់ចូលនៅលំដាប់ទី ២ នៃបញ្ជីឃ្លាំមើលរបាយការណ៍ US TIP សម្រាប់រយៈពេល៣ឆ្នាំជាប់ៗគ្នា គឺនៅមុនពេលដែលប្រទេសនេះត្រូវបានទម្លាក់ចុះមកនៅលំដាប់ទី៣ នៅឆ្នាំ២០២២។

*រូបភាព ១៖ របាយការណ៍ស្តីពីការជួញដូរមនុស្សសហរដ្ឋអាមេរិក US TIP ចាត់លំដាប់ថ្នាក់ប្រទេសកម្ពុជាតាមឆ្នាំ*

**ចំណាត់ថ្នាក់កម្ពុជាតាមឆ្នាំ**




## ២.១ ទិដ្ឋភាពទូទៅនៃអន្តរការបេសកកម្មយុត្តិធម៌អន្តរជាតិ

ខាងក្រោមនេះ ជាទីតាំងកំណត់សំខាន់ៗពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនៅកម្ពុជា៖

- **ឡរឥដ្ឋ៖** ប្រជាជនកម្ពុជាប្រមាណជាង ១០.០០០ នាក់ (រួមទាំង កុមារប្រមាណ ៤.០០០ នាក់) រស់នៅ និងបម្រើការងារក្នុងទីតាំងឡឥដ្ឋចំនួន ៤៨៦ កន្លែង នៅកម្ពុជា ដែលពួកគេត្រូវបានគេរកឃើញថាបានជួបប្រទះនឹងការបង្ខិតបង្ខំការងារពាក់ព័ន្ធនឹងបំណុលជាប់តជំនាន់។[៩]
- **ការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសបច្ចេកវិទ្យា៖** មានរបាយការណ៍សំខាន់ៗមួយចំនួនស្តីពីជនបរទេស និងប្រជាជនកម្ពុជាដែលត្រូវបានសន្យាថានឹងផ្តល់ការងារក្នុងប្រទេសកម្ពុជា តាមរយៈការផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺ

ណិត។ ប៉ុន្តែផ្ទុយស្រឡះ កម្មករនិយោជិតទាំងនេះ គឺត្រូវបានក្រុមឧក្រិដ្ឋកម្មអន្តរជាតិបង្ខំឱ្យបម្រើការងារឆបោកតាមប្រព័ន្ធអ៊ីនធឺណិត និងបានបង្ខាំងពួកគេទុកក្នុងអគារដែលមានសន្តិសុខយាមកាមតឹងរ៉ឹង។ ការអនុវត្តបែបនេះ ត្រូវបានគេរកឃើញនៅទូទាំងប្រទេស រួមទាំងនៅខេត្តព្រះសីហនុផងដែរ។[៥]

- **សំណង់៖** អង្គការមិនមែនរដ្ឋាភិបាល និងសហជីពពលករ បានរាយការណ៍នៅក្នុងឆ្នាំ២០២០ ថា ឈ្មួញជើងសារពលករបរទេស គឺបានជ្រើសរើសពលករទេសន្តប្រវេសន៍បរទេសជាច្រើននាក់ដោយបោកបញ្ឆោតពួកគេ ក្នុងនោះមានពលករមកពីប្រទេសបង់ក្លាដែស ចិន និងនេប៉ាល់ ឱ្យមកបម្រើការងារនៅក្នុងការដ្ឋានសំណង់ដែលគ្រប់គ្រងដោយជនជាតិចិន និងការដ្ឋានសំណង់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា។ ពលករមួយចំនួនជំពាក់បំណុលក្រុមហ៊ុនជ្រើសរើសពលករ និងត្រូវបានគេដកហូតយកលិខិតឆ្លងដែនរបស់ខ្លួនទៀតផង។[៦]
- **ពលកម្មដោយបង្ខំ៖** ការរាយការណ៍អំពីពលកម្មដោយបង្ខំដែលមានលក្ខណៈជាប្រព័ន្ធនៅកម្ពុជាក៏ត្រូវបានលើកឡើងផងដែរ ដែលមានពាក់ព័ន្ធនឹងវិស័យកសិកម្ម ការងារតាមផ្ទះ ការសុំទានដោយបង្ខំ និងវិស័យកំសាន្ត។

## ២.២ ពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សឆ្លងដែន

ថៃ គឺជាប្រទេសគោលដៅចម្បងសម្រាប់ពលករចំណាកស្រុកកម្ពុជា ដែលមានចំនួនពលករសរុបច្រើនជាង ៩០% នៃចំនួនពលករចំណាកស្រុកកម្ពុជាសរុបដែលបម្រើការងារនៅក្រៅប្រទេស។ តាមស្ថិតិ ពលករចំណាកស្រុកកម្ពុជាមានរហូតដល់ ២ លាននាក់ ត្រូវបានគេប៉ាន់ស្មានថារស់នៅ និងធ្វើការងារជាទៀងទាត់ក្នុងទឹកដីថៃ នៅមុនពេលការរីករាលដាលនៃជំងឺកូវីដ-១៩។ ដោយសារតែជម្រើសការងារក្នុងស្រុកមានកម្រិត ទើបជំរុញឱ្យពលរដ្ឋកម្ពុជាជាច្រើននាក់ងាយទៅស្វែងរកការងារនៅទឹកដីថៃជាប្រទេសជិតខាង។ ជាក់ស្តែង កម្រិតជីវភាពរបស់ប្រជាជនកម្ពុជារស់នៅជនបទដែលពឹងអាស្រ័យលើកសិកម្ម គឺកាន់តែលំបាកទៅ ដោយសារកត្តាប្រែប្រួលប្រជាសាស្ត្រ អភិវឌ្ឍន៍សេដ្ឋកិច្ច កំនើនថ្លៃចំណាយ និងការប្រែប្រួលអាកាសធាតុ។ នៅអំឡុងឆ្នាំ ២០២០ និង ២០២១ ការរាលដាលជំងឺកូវីដ-១៩ បានធ្វើឱ្យបណ្តាញចំណាកស្រុកនេះកាន់តែមានភាពស្មុគស្មាញ ក្នុងនោះមានការបិទច្រកព្រំដែន និងការផ្អាកអនុស្សារណៈនៃការយោគយល់ស្តីពីការជ្រើសរើសពលករ។ កត្តារាំងលំនាំធម្មតានៃចំណាកស្រុកនេះបានជំរុញឱ្យមានចំណាកស្រុកខុសប្រក្រតីកាន់តែច្រើនឡើងរវាងប្រទេសទាំងពីរនិងបង្កើនភាពងាយរងគ្រោះទៅនឹងភាពក្រីក្រកាន់តែខ្ពស់ ការបង្ខិតបង្ខំ និងកង្វះខាតការគាំទ្រពីសំណាក់អាជ្ញាធរ។

នៅពេលធ្វើចំណាកស្រុកទៅប្រទេសថៃ ទាំងទៀងទាត់ និងពុំទៀងទាត់ ប្រជាពលរដ្ឋកម្ពុជាជួបប្រទះនឹងហានិភ័យ និងភាពងាយរងគ្រោះជាច្រើនរួមមាន៖

- **ប្រព័ន្ធចំណាកស្រុករៀបចំពុំបានល្អក្រោមអនុស្សារណៈនៃការយោគយល់ស្តីពីពលកម្មទ្វេភាគី[៧]៖** ពលករចំណាកស្រុកកម្ពុជាមួយភាគធំ ជ្រើសរើសយកវិធីក្រៅផ្លូវការដើម្បីអាចបានទៅធ្វើការងារនៅក្រៅប្រទេសជាជាងការឆ្លងតាមបណ្តាញអនុស្សារណៈនៃការយោគយល់ផ្លូវការ។ កត្តានេះ គឺបណ្តាលមកពីដំណើរការនៃអនុស្សារណៈនៃការយោគយល់នោះមានហ៊ុមព័ទ្ធដោយថ្លៃចំណាយខ្ពស់ ស្មុគស្មាញ និងល័ក្ខខណ្ឌតម្រូវរដ្ឋបាលចំណាយពេលយូរ ទីភ្នាក់ងារជ្រើសរើសពលករពុំអាចទាក់ទង និងជឿទុកចិត្តបាន និងការផ្គត់ផ្គង់មានលក្ខណៈរឹតត្បិត។
- **ភ្នាក់ងារជ្រើសរើសពលករដែលពុំមានការត្រួតពិនិត្យតាមច្បាប់ត្រឹមត្រូវនៅកម្ពុជា៖** ទីភ្នាក់ងារជ្រើសរើសពលករឯកជន ជារឿយៗយកកម្រៃច្រើនហួស ឬបោកបញ្ឆោតពលករចំណាកស្រុកឱ្យរៀបចំដាក់ឯកសារចំណាកស្រុក និងធានាតិចតួចបំផុតលើសុវត្ថិភាពរបស់ពលករនៅក្រៅប្រទេស។ កិច្ចសន្យាជ្រើសរើសពលករចែងអំពីការការពារប៉ុន្តែពុំគ្រប់គ្រាន់ រីឯអ្នកជ្រើសរើសពលករទៀតសោតគឺជាមនុស្សអាត្មានិយម ដែលជារឿយៗដាក់ពលករនៅទីកន្លែងដែលខ្វះសុវត្ថិភាព និងការគាំទ្រ និងពុំទទួលខុសត្រូវអ្វីទាល់តែសោះ។ ល័ក្ខខណ្ឌតម្រូវពីរដ្ឋាភិបាលឱ្យដាក់ប្រាក់

មួយភាគធំសម្រាប់ធានាសន្តិសុខបានក្លាយជាឧបសគ្គរាំងដ៏ធំមួយចំពោះក្រុមហ៊ុន ឬអ្នកដែលទើបទទួលបានអាជ្ញាប័ណ្ណថ្មីថ្មោង។ លើសពីនេះ មេខ្យល់ដែលពុំមានអាជ្ញាប័ណ្ណ ឬមេខ្យល់ដែលទទួលអាជ្ញាប័ណ្ណបន្តពីគេជាច្រើនក៏ផ្តល់សេវាជ្រើសរើសពលករដោយគ្មានគណនេយ្យភាព ហើយស្រដៀងគ្នានេះដែរ ពួកគេអាចយកកម្រៃពីពលករលើសកម្រិត បោកបញ្ឆោត ឬពុំផ្តល់ឯកសារផ្លូវច្បាប់នោះទេ។ ភ្នាក់ងារជ្រើសរើសពលករជាច្រើនឆបោកពលករចំណាកស្រុក និងយកកម្រៃលើការធ្វើដំណើរ លិខិតឆ្លងដែន និងថ្លៃចំណាយផ្សេងៗទៀតពីពលករនៅពេលពួកគេមកដល់ប្រទេសគោលដៅ ឬថែមទាំងកាត់យកប្រាក់ខែរបស់ពួកគេផងដែរ។

- **ការជាប់បំណុលហួសកម្រិត[៨]៖** វិស័យមីក្រូហិរញ្ញវត្ថុដែលពុំមានការត្រួតពិនិត្យត្រឹមត្រូវ បានធ្វើឱ្យមានការផ្តល់កម្ចីបែបគេងយកប្រយោជន៍ខ្លាំងពីប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជា ហើយការជាប់បំណុលហួសកម្រិត គឺជាកត្តាជំរុញចម្បងមួយឱ្យពួកគេទៅធ្វើការងារនៅក្រៅប្រទេសដែលផ្តល់ប្រាក់ឈ្នួលការងារខ្ពស់។ បំណុល ក៏ជាកត្តាសំខាន់មួយដែរ ដែលរារាំងពលករពីការចាកចេញពីស្ថានភាពការងារដែលមានការរំលោភបំពាន។ ការជាប់បំណុលកើតចេញពីភាពក្រីក្រទូទៅ ដោយសារតែពលករជាច្រើននាក់ខ្វះខាតប្រាក់កាសរ៉ាប់រងបន្ទុកគ្រួសារ និងបានខ្ចីបុលគេដើម្បីដោះស្រាយបញ្ហា។
- **ភាពងាយរងគ្រោះទូទៅរបស់ពលករចំណាកស្រុកនៅប្រទេសថៃ៖** ប្រព័ន្ធការងារពលកររបស់ប្រទេសថៃធានាតិចតួចលើសុវត្ថិភាពរបស់ពលករចំណាកស្រុកផ្លូវការ និងក្រៅផ្លូវការ។ ពលករមានភ្នាក់ងារគាំទ្រតិចតួច និងពឹងផ្អែកទាំងស្រុងលើនិយោជក និងមេខ្យល់ពាក់ព័ន្ធនឹងការងាររដ្ឋបាលនានា។ យន្តការបណ្តឹងតវ៉ា គឺពុំមានសម្រាប់ពលករចំណាកស្រុកនោះទេ ហើយពលករ គឺពុំត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិជួបប្រជុំឡើយដោយហេតុថាសកម្មនេះពុំអាច ផ្លាស់ប្តូរនិយោជកដោយស្របច្បាប់នោះឡើយ ហើយក្នុងករណីជាច្រើន ពលករត្រូវបានគេបង្ខំឱ្យខ្ចីបុលពីនិយោជកដើម្បីទូទាត់ថ្លៃចំណាយរដ្ឋបាល។[៩] មន្ត្រីការងារថៃត្រួតពិនិត្យតិចតួចប៉ុណ្ណោះលើល័ក្ខខណ្ឌការងាររបស់ពលករចំណាកស្រុក។

លទ្ធផលជាក់ស្តែងគឺថា ពលករចំណាកស្រុកកម្ពុជាមួយភាគធំធ្លាប់ទទួលរងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនៅប្រទេសថៃ ក៏ដូចជាបង្ហាញឱ្យឃើញពីសូចនាករពលកម្មដោយបង្ខំ ដែលជាលទ្ធផលនៃការជាប់បំណុលរបស់និយោជក ការដកហូតលិខិតឆ្លងដែន និងឯកសារអត្តសញ្ញាណ ការរឹតត្បិតការធ្វើដំណើរ ការរក្សាទុកប្រាក់ឈ្នួល ការរំលោភបំពានការងារ ការរំលោភបំពានផ្លូវកាយ និងការបង្ខិតបង្ខំ។ បញ្ហាទាំងនេះកាន់តែយ៉ាប់យ៉ឺនទៅៗក៏ព្រោះតែអសមត្ថភាពនៃប្រើប្រាស់យន្តការបណ្តឹងតវ៉ា និងដំណោះស្រាយ ការលំបាកក្នុងការផ្លាស់ប្តូរការងារ និងកត្តាចងភ្ជាប់កាតព្វកិច្ចជាច្រើន។ វិស័យពាក់ព័ន្ធជាក់លាក់ រួមមាន៖

- **នេសាទ៖** ភាពងាយរងគ្រោះកម្រិតខ្ពស់បានរួមចំណែកដល់ការរីករាលដាលខ្លាំងនៃការរំលោភបំពានការងារលើពលករនេសាទ ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ យ៉ាងទូលំទូលាយ និងជាគោលដៅនៃវិធានការរបស់រដ្ឋាភិបាល។
- **សំណង់៖** ប្រាក់ឈ្នួលដែលពុំបានបើកឱ្យការមៅការបន្ត និងការឆបោក គឺសុទ្ធតែត្រូវបានគេលើកឡើងថាជាបញ្ហាក្នុងវិស័យនេះ គួបផ្សំជាមួយនឹងកត្តាផ្សេងៗដែលចងភ្ជាប់កាតព្វកិច្ចពលករទៅនឹងនិយោជក ដែលជាលទ្ធផលនៃប្រព័ន្ធចំណាកស្រុកមួយ គឺពលករពុំមានឯកសារត្រឹមត្រូវនោះទេ។
- **ការកែច្នៃគ្រឿងសមុទ្រ ការងារសណ្ឋាគារ បដិសណ្ឋារកិច្ច កសិកម្ម កម្មន្តសាល៖** ទាំងនេះ គឺជាវិស័យផ្សេងៗទៀតដែលមានពលករចំណាកស្រុកកម្ពុជាជាច្រើនបានចូលធ្វើការងារក្នុងប្រទេសថៃ ហើយបំណុលកើតមានក្នុងដំណើរការចំណាកស្រុក ដែលអាចចងភ្ជាប់កាតព្វកិច្ចពលករចំពោះនិយោជករបស់ពួកគេយ៉ាងមានប្រសិទ្ធភាព។

## ២.៣ ពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សផ្សេងទៀតនៅក្រៅប្រទេស

ប្រទេសគោលដៅចម្បងៗផ្សេងទៀតសម្រាប់ពលករចំណាកស្រុកកម្ពុជា រួមមាន៖ ប្រទេសចិន ម៉ាឡេស៊ី ជប៉ុន និងកូរ៉េ។ ចំពោះពលរដ្ឋកម្ពុជាដែលត្រូវបានគេជួញដូរទៅក្រៅប្រទេស ជាពិសេសក្នុងទម្រង់មានហានិភ័យខ្ពស់រួមមាន៖

- **ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖** ករណីជួញដូរកូនក្រមុំជាស្ត្រីជនជាតិខ្មែរជាច្រើន ជាពិសេសទៅប្រទេសចិន ដោយធ្វើដំណើរឆ្លងកាត់តាមបណ្តាញផ្លូវគោកដែលអសុវត្ថិភាព ហើយជាលទ្ធផលធ្វើឱ្យមាន បទប្បញ្ញត្តិដាក់បន្ទុកលើកម្រៃសេវាសម្រាប់ការធ្វើដំណើរតាមផ្លូវអាកាសនៅឆ្នាំ ២០១៨។[១០]
- **ចម្ការដូងប្រេងនៅម៉ាឡេស៊ី៖** ករណីមួយចំនួនតូចត្រូវបានលើកឡើងថាមានពលរដ្ឋកម្ពុជាត្រូវបានគេជួញដូរឱ្យទៅបម្រើការងារនៅចម្ការដូងប្រេងម៉ាឡេស៊ី។
- **ទាសភាពតាមផ្ទះ៖** ករណីពាក់ព័ន្ធមួយចំនួនតូចត្រូវបានគេរាយការក្នុងប្រទេសម៉ាឡេស៊ី និងអារ៉ាប់រួម ហើយក៏ទំនងជាមានដែរក្នុងទីតាំងផ្សេងៗទៀត។



# ៣ ក្របខណ្ឌច្បាប់ និង គោលនយោបាយ

# ៣ ក្របខណ្ឌច្បាប់ និង គោលនយោបាយ

## ៣.១ ក្របខណ្ឌច្បាប់

បទដ្ឋានច្បាប់សម្រាប់ការផ្តន្ទាទោសពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សគឺមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ ២០០៨)។ ទោះបីជានៅមានចន្លោះប្រហោងក្តីដូចដែលបានកត់សម្គាល់ពាក់ព័ន្ធនឹងបញ្ហាលេចឡើងថ្មី មានជាអាទិ៍ បទល្មើសបច្ចេកវិទ្យាជាដើមនោះ ក្របខណ្ឌច្បាប់កម្ពុជាស្តីពីការជួញដូរមនុស្សគឺគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនប្រព្រឹត្តអំពើជួញដូរមនុស្ស និងបណ្តាញជួញដូរមនុស្ស។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ ២០០៨) គឺស្របតាមបទដ្ឋានអន្តរជាតិ និងត្រូវបានបំពេញបន្ថែមដោយបទល្មើសដែលរួមបញ្ចូលការកេងប្រវ័ញ្ច ឬការសម្របសម្រួលដល់បទល្មើសជួញដូរមនុស្ស។ ច្បាប់នេះដាក់បញ្ចូលបទបញ្ញត្តិសម្រាប់នីតិបុគ្គល និងផ្តល់ឱ្យនូវការរឹបអូសផលនៃបទល្មើសជួញដូរមនុស្ស បើទោះជាច្បាប់នេះពុំបានចែងអំពីការបង្កក ឬការរឹបអូសយកផលនៃបទល្មើសមុនពេលផ្តន្ទាទោសក៏ដោយ។

យោងតាមចំណុចខ្សោយនានានៅក្នុងពិធីសារស្តីពីការជួញដូរមនុស្សរបស់អង្គការសហប្រជាជាតិ គឺពុំមានបញ្ញត្តិសម្រាប់ការពុំដាក់ទណ្ឌកម្មជនរងគ្រោះនោះទេចំពោះបទល្មើសដូចដែលបានប្រព្រឹត្តបណ្តាលមកពីត្រូវជួញដូរ និងបទប្បញ្ញត្តិនៅក្នុងច្បាប់នៅមានកម្រិតសម្រាប់ការការពារជនរងគ្រោះជារួម។ ទោះជាយ៉ាងនេះក្តី ចន្លោះខ្វះខាតនេះ គឺត្រូវបានបំពេញបន្ថែមពាក់កណ្តាលដោយគោលនយោបាយស្តីពីការពារសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្ស (ប្រកាសលេខ ៨៥២) ឯកសារគោលនយោបាយលម្អិតដែលចែងអំពីបទដ្ឋានអប្បបរមាក្នុងផ្នែកនេះ។ ដូចគ្នានេះដែរ ជំនួយដល់ជនរងគ្រោះ នីតិវិធីការពារ និងបទដ្ឋានអប្បបរមា គឺមានចែងក្នុងគោលការណ៍ណែនាំស្តីពីទម្រង់ និងនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរមនុស្សសម្រាប់ការផ្តល់សេវាសមស្រប (ឆ្នាំ ២០១៥) (គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ)។ ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដែលនឹងអនុវត្តលើ ករណីជួញដូរមនុស្ស ហើយបច្ចុប្បន្នច្បាប់នេះដែរគឺកំពុងត្រូវបានបញ្ចប់ជាស្ថាពរ។

ច្បាប់ការងារ (ឆ្នាំ ១៩៩៧) និងវិសោធនកម្មច្បាប់ការងារ (ឆ្នាំ២០០៧) បានចែងអំពីបទដ្ឋានដែលធ្វើនិយ័តកម្មការងារ។ ដោយឡែក កម្ពុជាមានច្បាប់ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ដែលខុសគ្នាពីបណ្តាប្រទេសនានាក្នុងតំបន់។ ផ្នែកទី ៥ នៃច្បាប់ការងាររបស់កម្ពុជា (ឆ្នាំ ១៩៩៧) បានចែងពីការប្រព្រឹត្តឧក្រិដ្ឋកម្មនៃពលកម្មដោយបង្ខំឬពលកម្មកំហិត ហើយច្បាប់នេះក៏ដាក់បញ្ចូលឯកសារយោងជាក់លាក់ក្នុងសេវាកម្មក្នុងស្រុក ដែលជានិច្ចកាលពុំរួមបញ្ចូលក្នុងបទប្បញ្ញត្តិការងារនោះទេ។ ទោះជាយ៉ាងនេះក្តី ការផាកពិន័យ គឺមានលក្ខណៈស្រាល បើធៀបទៅនឹងកម្រិតស្ថានភាពទំងន់បទល្មើស និងចំពោះឈ្មួញជួញដូរពលកម្មដោយបង្ខំនៅក្រោមច្បាប់ស្តីពីការជួញដូរមនុស្ស។ លើសពីនេះ ការជ្រើសរើសមនុស្សឱ្យបម្រើការងារដើម្បីទូរទាត់សងបំណុលដែលអាចជាការព្រមព្រៀងដោះបំណុលអាចនាំឱ្យមានការពិន័យតិចតួច។[១១] តាមមធ្យោបាយនេះ វាអាចទៀរួចក្នុងការ "ទម្លាក់" ករណីជួញដូរមនុស្សដោយចាត់ទុកថាជាករណីការងារ ដែលនាំឱ្យមានការ

ដាក់ទណ្ឌកម្មកម្រិតស្រាលជាងមុនចំពោះជនល្មើស និងជនរងគ្រោះពុំមានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេក្នុងនាមជាបុគ្គលដែលត្រូវបានគេជួញដូរ។[១២]

ជាចុងក្រោយ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា គឺដឹកនាំដោយនីតិវិធីតុលាការដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ២០០៧)។

## ៣.២ ក្របខណ្ឌគោលនយោបាយអំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋានសម្របសម្រួលសកម្មភាពប្រឆាំងការជួញដូរមនុស្ស ស្របតាមផែនការសកម្មភាពជាតិស្តីពីការបង្ក្រាបការជួញដូរមនុស្ស ការរត់ពន្ធ ការកេងប្រវ័ញ្ចការងារ និងផ្លូវភេទ (ឆ្នាំ ២០១៩–២០២៣)។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រក្សាបាននូវក្រុមការងារបច្ចេកទេសចំនួន ៦ ក៏ដូចជាគណៈកម្មាធិការខេត្តប្រឆាំងការជួញដូរមនុស្សនៅក្រោមបង្គាប់ផងដែរ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរៀបចំផលិតរបាយការណ៍ប្រចាំឆ្នាំដែលចងក្រងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រឆាំងការជួញដូរមនុស្ស រួមទាំងទិន្នន័យអំពីការផ្តន្ទាទោស និងការដាក់ទណ្ឌកម្ម។ នៅឆ្នាំ ២០២១ មូលនិធិរបស់រដ្ឋាភិបាល គឺត្រូវបានកាត់បន្ថយប្រមាណពី ១.៣៣ លានដុល្លារអាមេរិក ចុះមកត្រឹម ៥៥៣,០៨០ ដុល្លារអាមេរិក ដោយសារផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចបណ្តាលមកពីការរាលដាលនៃជំងឺកូវីដ-១៩។

*រូបភាព ២៖ ថវិការបស់ គ.ជ.ប.ជ (ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សសហរដ្ឋអាមេរិក)*




ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តផែនការសកម្មភាពការងារដាច់ដោយឡែក ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ (២០១៦– ២០២៥) មានគោលបំណងកាត់បន្ថយពលកម្មកុមារ និងចំណងកាតព្វកិច្ចបំណុល។ ផែនការនេះ ផ្តោតលើវិស័យសេវាកម្ម កសិកម្ម រ៉ែ និងថាមពល និងអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងវិធានការផ្លូវច្បាប់ និងការសហការជាមួយសង្គមស៊ីវិល។



## ៣.៣ ក្របខណ្ឌស្តីពីចំណាកស្រុកការងារ

អនុក្រឹត្យលេខ ១៩០ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន (ឆ្នាំ ២០១១) និងប្រកាសបំពេញបន្ថែមចំនួន ៨ (ច្បាប់) ចែងអំពីក្របខណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលករខ្មែរ។ ក្របខណ្ឌនេះ ជាទូទៅត្រូវបានចាត់ទុកថាជាក្របខណ្ឌគ្រប់ជ្រុងជ្រោយដែលមានវិសាលភាពក្នុងការសម្រេចបាននូវការជ្រើសរើសពលករដោយស្មើភាព ប្រសិនបើអនុវត្តប្រកបដោយប្រសិទ្ធភាព។

ដោយសារចំនួនពលករចំណាកស្រុកមានជាង ៩០% ពីកម្ពុជាចូលទៅកាន់ទឹកដីថៃ ច្បាប់ជាក់លាក់ដែលគ្រប់គ្រងបណ្តាញចំណាកស្រុកនេះ គឺមានសារៈសំខាន់ណាស់ ដែលច្បាប់មានចែងក្នុងអនុស្សារណៈនៃការយោគយល់ឆ្នាំ ២០០៣ រវាងប្រទេសទាំងពីរ ពោលគឺ អនុស្សារណៈនៃការយោគយល់រវាងកម្ពុជា និងថៃ ស្តីពីកិច្ចសហប្រតិបត្តិការស្តីពីការជ្រើសរើសពលករ (២០០៣)។ រវាងប្រទេសទាំងពីរនេះ កម្ពុជាមានកិច្ចព្រមព្រៀងមួយចំនួនស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សជាមួយប្រទេសថៃ រួមទាំងការរៀបចំស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) ដើម្បីអនុវត្តគោលដៅគោលនយោបាយ។

កិច្ចព្រមព្រៀងទាំងនេះរួមមាន៖

- អនុស្សារណៈនៃការយោគយល់រវាងប្រទេសថៃ និងកម្ពុជាស្តីពីការលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងការជួយជនរងគ្រោះនៃការជួញដូរមនុស្ស (ឆ្នាំ២០០៣)
- អនុស្សារណៈនៃការយោគយល់រវាងប្រទេសថៃ និងកម្ពុជាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីសម្រាប់ការលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងការជួយជនរងគ្រោះនៃការជួញដូរមនុស្ស (ឆ្នាំ២០១៤)
- អនុស្សារណៈនៃការយោគយល់ស្តីពីការពង្រឹងការគ្រប់គ្រងមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះនៃការជួញដូរមនុស្សដោយមានការសាងសង់មជ្ឈមណ្ឌលសំចតនៅប៉ោយប៉ែតដែលមានឯកទេសសម្របសម្រួលដល់ជនរងគ្រោះនៃការជួញដូរមនុស្សឱ្យត្រលប់មកស្រុកកំណើតវិញ (ឆ្នាំ២០១៩)
- ស្តង់ដារនីតិវិធីប្រតិបត្តិស្តីពីមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះនៃការជួញដូរពលរដ្ឋខ្មែររវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ (ឆ្នាំ២០២១) និង
- ស្តង់ដារនីតិវិធីប្រតិបត្តិ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ (ឆ្នាំ២០២២)។

ជាក់ស្តែង អាយុជីវិតរបស់ពលករចំណាកស្រុកកម្ពុជា គឺមួយផ្នែកធំត្រូវបានគ្រប់គ្រងដោយច្បាប់ប្រទេសថៃ ជាពិសេសព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងការងាររបស់កម្មករនិយោជិតបរទេស (ឆ្នាំ២០១៧)។ បញ្ញត្តិនេះ តម្រូវឱ្យពលករចំណាកស្រុកទាំងអស់ចុះបញ្ជីជាមួយរដ្ឋាភិបាល ដែលដាក់ចេញនូវការពិន័យ និងទណ្ឌកម្មចម្បងៗសម្រាប់អាជីវកម្មណាដែលជួលពលករចំណាកស្រុកមិនមានឯកសារមកបម្រើការងារ និងបង្កើតការផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ សម្រាប់ការរឹបអូសសៀវភៅការងាររបស់ពលករចំណាកស្រុក។ ដូចដែលបានពិភាក្សានៅទូទាំងឯកសារនេះ បញ្ហាជាច្រើនស្ថិតនៅក្នុងប្រព័ន្ធការិយាធិបតេយ្យ ដែលធ្វើឱ្យពលករជាច្រើនជួបប្រទះនឹងឧបសគ្គរាំងក្នុងការទទួលបានការការពារ និងការដោះស្រាយ។[១៣]

កម្ពុជា ក៏មានអនុស្សារណៈនៃការយោគយល់ទ្វេភាគីជាមួយបណ្តាប្រទេសផ្សេងទៀត ដែលមានពលករខ្មែរចំណាកស្រុកទៅបម្រើការងារផងដែរ ដែលអនុស្សារណៈនោះចែងអំពីលក្ខខណ្ឌតម្រូវជ្រើសរើស និងផ្តល់ការងារ។ ប្រទេសទាំងនេះរួមមាន៖ ម៉ាឡេស៊ី អារ៉ាប៊ីសាអូឌីត ហុងកុង កាតា កូរ៉េខាងត្បូង និងគុយវ៉ែត។ កម្ពុជាមានកិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពីការជួញដូរមនុស្សជាមួយប្រទេសវៀតណាម និងជាផ្នែកមួយនៃកិច្ចព្រមព្រៀងប្រចាំតំបន់មួយចំនួននៅក្រោមអាស៊ាន។ កាលពីពេលថ្មីៗនេះ ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ដែលបង្កើតការិយាល័យសហប្រតិបត្តិការអនុវត្តច្បាប់ចិន-កម្ពុជានៅឆ្នាំ ២០១៩ និងបន្តសុពលភាពនៅឆ្នាំ ២០២១។



# ៤ ភាគីពាក់ព័ន្ធ និងការគូសផែនទីដំណើរការ

# ៤ ភាគីពាក់ព័ន្ធ និងការគូស ផែនទីដំណើរការ

## ៤.១ សាវតារភាគីពាក់ព័ន្ធ និងអាទិភាព

### គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT)

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៤[១៤] ដែលជាយន្តការថ្នាក់ជាតិសម្រាប់សម្របសម្រួលកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ គណៈកម្មាធិការជាតិនេះ ជួយគាំទ្រដល់ក្រសួងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗទៀតជាច្រើនទៀត ដើម្បីសហការគ្នាបង្កើតច្បាប់ គោលនយោបាយ និងផែនការស្ដីអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (CTIP) ក៏ដូចជាប្រមូលព័ត៌មានអំពីកិច្ចខិតខំប្រឹងប្រែងទាំងនោះផងដែរ។

គណៈកម្មាធិការជាតិនេះ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការសម្របសម្រួលរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយត្រួតពិនិត្យមើលក្រុមការងារក្រោមឱវាទនៅថ្នាក់ខេត្ត តាមរយៈគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (PCCT)។ គណៈកម្មាធិការខេត្តនីមួយៗ មានផែនការតាមមូលដ្ឋាន ដែលគូសបញ្ជាក់ពីរបៀបរាយការណ៍ស្ដីពីករណីជួញដូរមនុស្សទៅកាន់នគរបាល កិច្ចការងារការពារជនរងគ្រោះ និងសកម្មភាពទប់ស្កាត់នៅថ្នាក់ខេត្ត។

គណៈកម្មាធិការជាតិ NCCT ត្រួតពិនិត្យលើក្រសួងស្ថាប័នចំនួន ២១ និងអង្គភាពជំនាញចំនួន ៥ ជាសមាជិក។ ចាប់តាំងពីឆ្នាំ ២០១៤ (យោងតាមសេចក្ដីសម្រេចលេខ ០៩៤/១៤) គណៈកម្មាធិការជាតិនេះ បាន និងកំពុងត្រួតពិនិត្យលើក្រុមការងារអន្តរក្រសួងចំនួន៦៖

- ក្រុមការងារទប់ស្កាត់ ដឹកនាំដោយ ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ
- ក្រុមការងារកិច្ចការតុលាការ ដឹកនាំដោយ ក្រសួងយុត្តិធម៌
- ក្រុមការងារចំណាកស្រុក ដឹកនាំដោយ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង
- ក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ។

ការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺដឹកនាំដោយផែនការយុទ្ធសាស្រ្តជាតិស្ដីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣។ ក្រុមការងារគោលដៅនីមួយៗ បានបង្កើតផែនការការងារផ្ទាល់ខ្លួនដើម្បីបន្សុីទៅនឹងផែនការយុទ្ធសាស្រ្តជាតិ។

យោងតាមបុគ្គលិកបម្រើការងាររបស់គណៈកម្មាធិការជាតិនេះ បានឱ្យដឹងថា គណៈកម្មការធិការជាតិកំពុងផ្តោតកិច្ចការងាររបស់ខ្លួនលើចំណុចមួយចំនួនដូចខាងក្រោម៖

- ការបង្កើតសន្ទានុក្រមសម្រាប់វិស័យអំពើជួញដូរមនុស្ស
- បន្តបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធសំខាន់ៗអំពីការប្រើប្រាស់ទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះ ដែលបានផ្តល់ជូនស្របតាមគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ
- ការសម្រិតសម្រាំងទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះជាមួយភាគីពាក់ព័ន្ធ
- លើកកម្ពស់ការសហការក្នុងចំណោមសមាជិក
- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងបង្ការ និងបង្ក្រាប
- ផ្តោតលើការផ្លាស់ប្តូរឥរិយាបថក្នុងចំណោមអ្នកទទួលភារកិច្ច និងបុគ្គលិកជួរមុខ
- កៀរគរកិច្ចខិតខំប្រឹងប្រែងអន្តរទីភ្នាក់ងារ និងសម្របសម្រួលការងារ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការងាររបស់តួអង្គប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

គណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាច្រើន ក៏បានចូលរួមនៅក្នុងកម្មវិធីការបណ្តុះបណ្តាលពាក់ព័ន្ធនានា។ បុគ្គលិកបានរាយការណ៍ថា តាមរយៈកិច្ចសហការណ៍ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលដៃគូ ពួកគេបានរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សចំនួន ១៥៦ លើក សម្រាប់មន្រ្តីរដ្ឋាភិបាល នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន ៥.៧២០ នាក់ នៅឆ្នាំ ២០២១ ។

គួរកត់សម្គាល់ផងដែរ គណៈកម្មាធិការជាតិនេះ គឺពុំបានតស៊ូមតិសម្រាប់ការផ្លាស់ប្តូរគោលនយោបាយសំខាន់ៗនៅក្នុងច្បាប់ និងក្របខណ្ឌស្តីពី ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សនោះទេ។ តាមទស្សនៈរបស់គណៈកម្មាធិការ ក្របខណ្ឌបច្ចុប្បន្ន គឺមិនទាន់គ្រប់គ្រាន់នោះទេ និងចាំបាច់ត្រូវផ្តោតលើការអនុវត្ត។

## › ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាក្រសួងរបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវលើបញ្ហាពាក់ព័ន្ធនឹងការងារដូចជា លក្ខខណ្ឌការងារ ទំនាក់ទំនងវិស័យ ការរក្សារបបបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈ ព័ត៌មានទីផ្សារការងារ ការចូលរួមរបស់កម្លាំងពលកម្ម និងមុខរបរ។

ក្រសួងនេះ គឺទទួលខុសត្រូវចំពោះការត្រួតពិនិត្យអធិការកិច្ចការងារ នៅតាមកន្លែងធ្វើការ។ តាមទ្រឹស្តី ប្រសិនបើក្រសួងរកឃើញថាមានករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ក្រសួងនឹងបញ្ជូនករណីនេះបន្ត ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ប្រការនេះគឺកម្រនឹងកើតមានណាស់ ដោយសារតែអធិការកិច្ចមិនបានយកចិត្តទុកដាក់ទៅលើពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនោះឡើយ។ នៅពេលកើតមានករណីបញ្ហាការងារណាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរាយការណ៍ថា អនុវត្តវិធីសាស្រ្ត "ដោះស្រាយបញ្ហា" ពោលគឺ ធ្វើការសម្រុះសម្រួលរវាងកម្មករនិយោជិត និងនិយោជក។ ក្រសួងគឺ គឺពុំមិនបានផ្តោតទៅលើការដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តកំហុស និងជារឿយៗមិនបានចាត់វិធានការផ្លូវច្បាប់ដើម្បីផ្តន្ទាទោសដល់ជនល្មើសនោះទេ។

មកទល់បច្ចុប្បន្ននេះ ការបំពេញតួនាទីរបស់ក្រសួងនេះ នៅក្នុងការប្រឆាំងនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស គឺនៅមានកម្រិតនៅឡើយ។ យោងតាមការរាយការណ៍របស់បុគ្គលិកក្រសួងនេះ អាណត្តិរបស់ក្រសួងគឺមានកំណត់ និង

ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីការងារ ដែលមានលក្ខណៈមិនទូលំទូលាយ។ បច្ចុប្បន្ន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំពុងបង្កើតក្រុមការងារអន្តរក្រសួងស្តីពីការជួញដូរមនុស្ស (យោងតាម "សេចក្តីសម្រេច លេខ ៩៧") ដែលបង្ហាញអំពីវត្ថុបំណងមួយចំនួន ដើម្បីធ្វើយ៉ាងណាឱ្យក្រុមការងារមានលក្ខណៈសកម្មជាងមុននៅក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ក្រុមការងារ នឹងផ្តោតការយកចិត្តទុកដាក់ទាំងមូលលើការធ្វើការងារជាមួយភាគីថៃ ដើម្បីលើកកម្ពស់កិច្ចសហការ និងរក្សាឱ្យបាននូវអ្នកចូលរួមចម្រុះ។ ស្របពេលដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានមន្ទិលអំពីភាពចាំបាច់នៅក្នុងការរៀបចំបង្កើតក្រុមការងារដាច់ដោយឡែកពីក្រុមការងារបច្ចុប្បន្ននៅក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជឿថា ក្រុមការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺមិនអាចមានលទ្ធភាពគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃពលកម្មដោយបង្ខំដែលចាំបាច់ត្រូវដោះស្រាយនោះទេ។ បច្ចុប្បន្ននេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា ក្រសួងកំពុងផ្តោតការយកចិត្តទុកដាក់លើការបង្កើនសមត្ថភាព និងចំណេះដឹងបច្ចេកទេសរបស់ខ្លួនផ្តោតលើពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ដើម្បីដឹកនាំក្រុមការងារបានប្រកបដោយប្រសិទ្ធភាពនៅពេលដែលក្រុមការងារនេះបានបង្កើតឡើង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏កំពុងផ្តោតលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទៅលើការបង្ការពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស តាមរយៈការអប់រំកម្មករនិយោជិតឱ្យយល់ដឹងដឹងអំពីកិច្ចសន្យាការងាររបស់ពួកគេ និងអំពីសារៈសំខាន់តម្រូវការកិច្ចសន្យា ដើម្បីជៀសសវាងការកេងប្រវ័ញ្ច និងការរំលោភបំពានលើការងារ។ ក្រសួងនេះ វៈ បានផ្តល់វគ្គបណ្តុះបណ្តាលជាសាធារណៈនានាស្តីពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការតម្រង់ទិសមុនពេលចេញដំណើរសម្រាប់ប្រជាពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមយ៉ាងច្រើននៅក្នុងការគ្រប់គ្រងការបញ្ជូនពលករខ្មែរទៅបម្រើការងារនៅក្រៅប្រទេស ហេតុដូច្នេះ វាជាការសំខាន់ណាស់ក្នុងការពង្រឹងក្របខណ្ឌ និងរចនាសម្ព័ន្ធចំណាកស្រុកការងារឱ្យបានរឹងមាំ។ គំនិតផ្តួចផ្តើមថ្មីដ៏សំខាន់មួយកាលពីឆ្នាំកន្លងទៅថ្មីៗនោះគឺថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់អនុព័ន្ធការងារដល់ស្ថានទូតបរទេសជាអ្នកតំណាងរបស់ខ្លួននៅក្នុងប្រទេសគោលដៅចម្បងៗសម្រាប់ពលករចំណាកស្រុកកម្ពុជា។ អនុព័ន្ធការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយគាំទ្រដល់ការងារផ្នែកទទួលបណ្តឹងការងារ ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

## > ក្រសួងយុត្តិធម៌ (MOJ)

ក្រសួងយុត្តិធម៌ ត្រួតពិនិត្យលើប្រព័ន្ធតុលាការនៃប្រទេសកម្ពុជា រួមទាំង ការគ្រប់គ្រងចៅក្រម តុលាការ អយ្យការ ការស៊ើបអង្កេតរបស់តុលាការ និងក្របខណ្ឌរដ្ឋបាលពាក់ព័ន្ធនានា។ ក្រសួងយុត្តិធម៌ មានតួនាទីសម្របសម្រួលការគ្រប់គ្រងការផ្តន្ទាទោសលើករណីជួញដូរមនុស្ស និងដឹកនាំការផ្លាស់ប្តូរផ្សេងៗនៅក្នុងប្រព័ន្ធតុលាការ ប៉ុន្តែចាំបាច់គឺត្រូវការកិច្ចសហប្រតិបត្តិការពីក្រសួងស្ថាប័នផ្សេងៗ ដើម្បីអនុម័តលើការផ្លាស់ប្តូរទាំងនោះ។

ក្រសួងយុត្តិធម៌ ក៏ធ្វើការងារជាមួយតួអង្គតុលាការ ដើម្បីផ្តន្ទាទោសលើពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងសមត្ថភាពគ្រប់គ្រងលើសំណុំរឿងតាមរយៈការបណ្តុះបណ្តាល។ បច្ចុប្បន្ន ក្រសួងនេះគឺកំពុងធ្វើការងារជាមួយអង្គការមិនមែនរដ្ឋាភិបាល ដូចជា អង្គការសកម្មភាពដើម្បីកុមារ (APLE) និងអង្គការវីនរ៉ក់ (Winrock) ក៏ដូចជា កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ACT) ស្តីពីការពង្រឹងសមត្ថភាពប្រឆាំងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស

សម្រាប់អយ្យការ និងចៅក្រម និង នគរបាលយុត្តិធម៌។ យោងតាមការសម្ភាសន៍បានឱ្យដឹងថា ក្រសួងយុត្តិធម៌ បច្ចុប្បន្នគឺកំពុងផ្តោតលើកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សរបស់ខ្លួន ដូចខាងក្រោម៖

- ការបន្តពង្រឹងសមត្ថភាព និងការអភិវឌ្ឍន៍សមត្ថភាពរបស់ព្រះរាជអាជ្ញា និងចៅក្រម។
- លើកកម្ពស់សមត្ថភាពជំនាញពាក់ព័ន្ធនឹងការជួញដូរកុមារ ដោយមានជំនួយពីអង្គការសកម្មភាពដើម្បីកុមារ។
- ប្រមូលទិន្នន័យអំពីការបណ្តុះបណ្តាល ការស៊ើបអង្កេត និងការផ្តន្ទាទោសលើពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។
- បង្កើតក្រុមការងារបច្ចេកទេសជំនាញនៅក្នុងតុលាការ ពាក់ព័ន្ធនឹងប្រធានបទ ដូចជា៖ ការងារ កុមារ និងពាណិជ្ជកម្ម។ បច្ចុប្បន្ន ពុំមានតុលាការជំនាញនោះទេ ស្របពេលដែលសមាជិកតុលាការទាំងអស់ ផ្តោតលើបញ្ហាផ្លូវច្បាប់ទាំងអស់។ បុគ្គលិកក្រសួងយុត្តិធម៌បានរាយការណ៍ថា បច្ចុប្បន្ន ពួកគេកំពុងផលិតរបាយការណ៍សង្ខេប និងការស្រាវជ្រាវអំពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ។

ក្រសួងយុត្តិធម៌ ក៏កំពុងធ្វើការងារលើការបង្កើតតុលាការការងារថ្មីសម្រាប់ឆ្នាំ ២០២៣។ តុលាការនេះ គឺរំពឹងថានឹងធ្វើសេចក្តីសម្រេចចិត្តលើបញ្ហានានាពាក់ព័ន្ធនឹងសិទ្ធិការងារ លក្ខខណ្ឌការងារ និងទំនាក់ទំនងការងារជាមួយកម្ពុជា។ ក្រសួងយុត្តិធម៌ បានបង្កើតគណៈកម្មការមួយ ដែលមានសមាសភាព ២០ រូប ដោយមានអាណត្តិទូលំទូលាយសម្រាប់ការរៀបចំតុលាការការងារ ដែលក្នុងនោះមានសមាជិកមកពី ក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈប្រតិភូរដ្ឋាភិបាល តុលាការ ព្រមទាំងមន្ត្រី និងជំនាញការដែលបានជ្រើសរើសផងដែរ។

## > ក្រសួងកិច្ចការនារី (MOWA) – រួមទាំងការិយាល័យទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការិយាល័យនៃនាយកដ្ឋានការពារផ្លូវច្បាប់

ក្រសួងកិច្ចការនារី មានកាតព្វកិច្ចលើកកម្ពស់ស្ថានភាពស្ត្រីនៅទូទាំងប្រទេសកម្ពុជា។ នាយកដ្ឋានការពារផ្លូវច្បាប់ ដែលរួមមានការិយាល័យទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ទទួលខុសត្រូវចំពោះការបង្កើតច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការដាក់ទណ្ឌកម្មលើការជួញដូរស្ត្រី និងកុមារ។ នាយកដ្ឋាននេះ ក៏ស្វែងរកការគាំទ្រសម្រាប់ការអនុវត្តច្បាប់ទាំងនេះ និងលើកកម្ពស់ការយល់ដឹងរបស់សាធារណជនប្រកបដោយប្រសិទ្ធភាពផងដែរ។

ក្រសួងកិច្ចការនារី ជាទូទៅចូលរួមនៅក្នុងនៅដំណាក់កាលអន្តរាគមន៍ដំបូងនៃករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ដោយសារតែក្រសួងសហការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសង្គ្រោះជនរងគ្រោះ រួមទាំងជនរងគ្រោះដែលនៅប្រទេសគោលដៅផងដែរ។ ក្រសួងកិច្ចការនារី ក៏ធ្វើការងារដើម្បីគាំទ្រជនរងគ្រោះតាមរយៈដំណើរការតុលាការរួមទាំងការគាំទ្រផ្នែកច្បាប់សម្រាប់ជនរងគ្រោះ តាមរយៈការផ្តល់មេធាវីពីអង្គការមិនមែនរដ្ឋាភិបាល។

បច្ចុប្បន្ននេះ ក្រសួងនេះ គឺកំពុងធ្វើការងារជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើគម្រោង "សុត្ថិភាព និងយុត្តិធម៌" ដែលគាំទ្រដោយអង្គការសហប្រជាជាតិដើម្បីស្ត្រី និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ គម្រោងនេះមានគោលបំណងគាំទ្រសិទ្ធិរបស់ស្ត្រីដែលជាពលករចំណាកស្រុក។

## > នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (AHJPD) ក្រសួងមហាផ្ទៃ (MOI)

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន គឺជានាយកដ្ឋានជំនាញនៃនគរបាលជាតិកម្ពុជា ដែលមាន

អាណត្តិក្នុងការបង្ក្រាប និងស៊ើបអង្កេតពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សដែលកើតឡើង។ នាយកដ្ឋាននេះ គឺស្ថិតនៅក្រោមឱវាទរបស់ក្រសួងមហាផ្ទៃ។ នាយកដ្ឋាននេះ និងក្រសួងមហាផ្ទៃ បានបង្កើតប្រព័ន្ធទូរស័ព្ទជំនួយទាន់ហេតុការណ៍សម្រាប់ជនរងគ្រោះ និងសាក្សីនៃការជួញដូរមនុស្ស និងសម្រាប់ប្រជាពលរដ្ឋដែលមានបំណងរាយការណ៍អំពីករណីជួញដូរមនុស្ស និងសកម្មភាពសង្ស័យពាក់ព័ន្ធ។ នាយកដ្ឋានប្រនេះដែរ ដឹកនាំការស៊ើបអង្កេតករណី និងបន្ទាប់មកបញ្ជូនបន្តករណីនេះទៅតុលាការ។

យោងតាមប្រភពពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានកត់សម្គាល់ថា លក្ខណៈនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស គឺមានការវិវត្តន៍ ជាពិសេសចាប់តាំងពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យមានការជួញដូរ ការបោកបញ្ឆោត និងការឆបោកតាមប្រព័ន្ធអ៊ីនធឺណិតកាន់តែច្រើនឡើង។ បុគ្គលិកនៃនាយកដ្ឋាននេះផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់ការឆ្លើយតបទៅនឹងការជួញដូរមនុស្សតាមប្រព័ន្ធអ៊ីនធឺណិត តាមរយៈការបណ្តុះបណ្តាលដែលផ្តោតលើឧក្រិដ្ឋកម្ម និងទម្រង់ថ្មីៗនៃការជួញដូរមនុស្ស។ នាយកដ្ឋាននេះក៏មានគោលបំណងធ្វើការងារជាមួយភាគីពាក់ព័ន្ធជាច្រើន ដូចជា វិស័យនានា និងក្រសួងស្ថាប័នផ្សេងៗ ដើម្បីផ្លាស់ប្តូរការអនុវត្តនៅក្នុងវិស័យដែលបង្កើតបានជាភាពងាយរងគ្រោះចំពោះការជួញដូរមនុស្ស។ នាយកដ្ឋាននេះ ក៏បានរាយការណ៍ឱ្យដឹងអំពីការកើនឡើងនៃចំនួនបុគ្គលិកផងដែរកាលពីឆ្នាំកន្លងទៅនេះ។

## > នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MOSVY)

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះនៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានភារកិច្ចកំណត់អត្តសញ្ញាណជនរងគ្រោះ និងជួយនៅក្នុងកិច្ចការងារធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍ជនរងគ្រោះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ទទួលខុសត្រូវចំពោះការផ្តល់សេវាដល់ជនរងគ្រោះនៃការជួញដូរមនុស្ស រួមទាំង ការពិគ្រោះយោបល់លើផ្នែកសុខភាព សេវាផ្នែកច្បាប់ ការស្តារនីតិសម្បទា ជំនាញការងារបំណិនជីវិត មុខរបរ ការគាំទ្រផ្សេងៗ និងសេវាធ្វើសមាហរណកម្មវិញ ក៏ដូចជាការតាមដានគ្រួសារក្នុងករណី ដែលជនរងគ្រោះជាកុមារ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា នឹងបញ្ជូនជនរងគ្រោះទៅកាន់អង្គការមិនមែនរដ្ឋាភិបាលក្នុងករណីក្រសួងមិនអាចផ្តល់សេវាបាន។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានការិយាល័យ និងបុគ្គលិកសង្គមកិច្ចនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកដែលត្រូវបានចាត់តាំងឱ្យគាំទ្រដល់ជនរងគ្រោះក្នុងការធ្វើសមាហរណកម្ម និងការគ្រប់គ្រងករណី (កិច្ចការសង្គម)។ នៅថ្នាក់ខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត (DOSVY) មានទំនួលខុសត្រូវច្បាស់លាស់លើការដោះស្រាយករណីជួញដូរមនុស្សរួមមាន៖

- **ការបង្ការ៖** ផ្សព្វផ្សាយព័ត៌មានសម្រាប់សហគមន៍ និងពង្រឹងសមត្ថភាពសម្រាប់មន្ត្រីសង្គមកិច្ច និងអាជ្ញាធរមូលដ្ឋានឱ្យបំពេញតួនាទីរបស់ពួកគេ។
- **ការគាំទ្រជនរងគ្រោះ៖** សម្របសម្រួលការគាំទ្រចម្បង (អាហារ ការថែទាំវេជ្ជសាស្ត្រ ការវាយតម្លៃតម្រូវការសេវាបន្ថែម)។
- **ការធ្វើសមាហរណកម្ម៖** សម្របសម្រួលការធ្វើសមាហរណកម្មជនរងគ្រោះ តាមដានករណី និងបញ្ចប់ករណី។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** បច្ចុប្បន្ន គឺកំពុងផ្ដោតការយកចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងលើគំនិតផ្ដួចផ្ដើមខាងក្រោម៖

- មជ្ឈមណ្ឌលសំចតសង្គមកិច្ចដែលទើបបើកថ្មីសម្រាប់ការថែទាំជនរងគ្រោះនៅស្រុកកំរៀង។
- ពង្រឹងសមត្ថភាពបុគ្គលិកលើការប្រតិបត្តិការនៃមជ្ឈមណ្ឌលសំចតថ្មី។
- មជ្ឈមណ្ឌលថែទាំថ្មីនៅស្រុកកណ្ដាលស្ទឹងដែលធ្វើប្រតិបត្តិការដោយនាយកដ្ឋានស្ដារនីតិសម្បទានៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។
- អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្រិតនាយកដ្ឋាន ដោយសហការជាមួយ អង្គការ រតនៈអន្តរជាតិ។
- រៀបចំសេចក្ដីព្រាងនីតិវិធីប្រតិបត្តិ ដើម្បីជាជំនួយដល់សមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងការអនុវត្តការងារ ការកំណត់តួនាទី និងលើកកម្ពស់កិច្ចសហការ។
- កម្មវិធីអនុវត្តសាកល្បងនៅក្នុងខេត្តចំនួន ៣ ដែលបណ្ដុះបណ្ដាលបុគ្គលិកសង្គមកិច្ច ក្នុងការផ្ដល់ការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះដែលពាក់ព័ន្ធនឹងសំណុំរឿងតុលាការ។
- ការបណ្ដុះបណ្ដាលវិជ្ជាជីវៈសម្រាប់បុរសដែលជាជនរងគ្រោះនៃការជួញដូរមនុស្សដែលមកពីវិស័យនេសាទពាណិជ្ជកម្ម។

បច្ចុប្បន្ន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងបុគ្គលិកសង្គមកិច្ច គឺមានការយល់ដឹង និងចំណេះដឹងពាក់ព័ន្ធនឹងដំណើរការនីតិវិធីតុលាការនៅមានកម្រិតនៅឡើយ ហើយក៏មិនត្រូវបានរួមបញ្ចូលនៅក្នុងរាល់ដំណើរការតុលាការនោះដែរ។ បុគ្គលិកដែលបានសម្ភាសន៍បានឱ្យដឹងថា ប្រសិនបើមានឱកាស ការរៀបចំឱ្យមានមន្ត្រីសុខុមាលភាពសង្គមនៅតុលាការ គឺពិតជាមានប្រយោជន៍ណាស់ក្នុងការផ្ដល់ការគាំទ្រដល់ជនរងគ្រោះ។

## › ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ (MFAIC)

ស្ថានទូតនានានៅក្រៅប្រទេសរបស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលមានអនុព័ន្ធការងារទទួលបន្ទុកលើកិច្ចការទទួលបណ្ដឹងការងារ និងគាំទ្រដល់ពលករចំណាកស្រុក។ នៅពេលដែលជនរងគ្រោះនៃការជួញដូរមនុស្ស គឺជាប្រជាពលរដ្ឋកម្ពុជាដែលត្រូវបានគេជួញដូរនៅក្រៅប្រទេស ស្ថានទូតសាមី នឹងបញ្ជូនករណីនេះទៅកាន់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ប៉ុន្តែទទួលខុសត្រូវចំពោះការធ្វើមាតុភូមិនិវត្តន៍ ការប្រគល់ ទទួល និងការធ្វើសមាហរណកម្ម។

## › ប្រព័ន្ធតុលាការ៖ តុលាការ និងគណៈមេធាវីកម្ពុជា

តួអង្គប្រព័ន្ធតុលាការសំខាន់នៅក្នុងតុលាការ រួមមាន៖ ចៅក្រម ចៅក្រមស៊ើបសួរ និង ព្រះរាជអាជ្ញា។១៥ តុលាការ ស្ថិតក្រោមការណែនាំពីក្រសួងយុត្តិធម៌ ផ្ដោតលើការពន្លឿនដំណើរការនីតិវិធីតុលាការ ដោយការលុបបំបាត់ការកកស្ទះសំណុំរឿងមិនទាន់ដោះស្រាយ។ បុគ្គលិកនៅក្នុងស្ថាប័ននេះ បានប្រឹងប្រែងធ្វើឱ្យដំណើរការតុលាការមានលក្ខណៈសាមញ្ញ តាមរយៈការជំរុញឱ្យមានការចេញដីកាតាមកម្មវិធីតេលេក្រាម (Telegram) ឬកម្មវិធីស្រដៀងគ្នាផ្សេងទៀត ជាជាងការចេញតាមរយៈសេវាប្រៃសណីយ៍។

តុលាការ ក៏កំពុងធ្វើការងារទៅលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធតុលាការ ដើម្បីធ្វើឱ្យទីស្នាក់ការតុលាការទាំងអស់នៅទូទាំងប្រទេសមានស្តង់ដារដូចគ្នា។ ការកែលម្អនេះ នឹងរួមបញ្ចូលការសាងសង់អន្តេវាសិកដ្ឋានសម្រាប់ ព្រះរាជអាជ្ញា និង

ថៅក្រម ដើម្បីស្នាក់នៅក្នុងអំឡុងពេលជំនុំជម្រះក្តីនៅតាមបណ្តាខេត្ត។ ការកសាងសមត្ថភាពពាក់ព័ន្ធនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស សម្រាប់ព្រះរាជអាជ្ញា និងថៅក្រម គឺកំពុងត្រូវបានបន្តអនុវត្ត។

## › នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ សង្គ្រោះជនរងគ្រោះដែលមានសក្តានុពលណាមួយ ដែលត្រូវការ ការជួយសង្គ្រោះជាចាំបាច់ កំណត់អត្តសញ្ញាណឧក្រិដ្ឋកម្ម ស៊ើបអង្កេត និងចាប់ខ្លួនជនសង្ស័យ កសាងសំណុំរឿងជួញដូរមនុស្ស និងបញ្ជូនសំណុំរឿងទៅកាន់តុលាការ។ បច្ចុប្បន្ន នគរបាលយុត្តិធម៌ ផ្តោតការយកចិត្តជាចម្បងទៅលើការបន្តពង្រឹងសមត្ថភាពរបស់នគរបាល ដើម្បីអាចឱ្យមានលទ្ធភាពឆ្លើយតបទៅនឹងបច្ចេកទេសថ្មីៗដែលប្រើប្រាស់ដោយឧក្រិដ្ឋជន និងទិន្នន័យការថ្មីៗអំពី ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។

ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងផ្នែកប្រឆាំងការជួញដូរមនុស្ស កងរាជអាវុធហត្ថជាតិ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងផ្នែកប្រឆាំងការជួញដូរមនុស្ស កងរាជអាវុធហត្ថជាតិ ទទួលខុសត្រូវលើការអនុវត្តការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរមនុស្ស។



## ៤.២ ការគូសផែនទីដំណើរការស៊ើបអង្កេត និងតុលាការកម្ពុជា

ផ្នែកនេះ បង្ហាញអំពីដំណើរការនៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ដោយសារតែដំណើរការទាំងនេះពាក់ព័ន្ធនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ដំណើរការទាំងនេះ រួមបញ្ចូលការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ ការស៊ើបអង្កេតសំណុំរឿង និងការឆ្លើយតបដោយប្រព័ន្ធយុត្តិធម៌ ការគូសផែនទីដំណើរការប្រព័ន្ធការងារ និងការសហការឆ្លងដែន។

### ៤.២.១ ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺជាដំណើរការដឹកនាំបុគ្គលដែលបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះនៃការជួញដូរមនុស្សពីសំណាក់អាជ្ញាធរពាក់ព័ន្ធ នឹងបញ្ជូនបន្តទៅរកជំនួយ។ ជំនួយដល់ជនរងគ្រោះ នីតិវិធីការពារ និងបទដ្ឋានអប្បបរមា គឺមានចែងនៅក្នុងគោលការណ៍ណែនាំស្តីពីទម្រង់ និងនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរមនុស្សសម្រាប់ការផ្តល់សេវាសមស្រប (ឆ្នាំ ២០១៥) ហៅកាត់ថា គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ជាទូទៅ ដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះ រួមមានបីដំណាក់កាល៖ - ការកំណត់អត្តសញ្ញាណបឋម ការកំណត់អត្តសញ្ញាណផ្លូវការ និងការបញ្ជូនទៅរកជំនួយ។ ដំណាក់កាលទាំងនេះ គឺមានរៀបរាប់លម្អិតបន្ថែមដូចខាងក្រោមនេះ៖

- **ការកំណត់អត្តសញ្ញាណបឋម៖** យោងតាម មន្ត្រី ឬបុគ្គលដែលមានចំណេះដឹងអំពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស បានឱ្យដឹងថា បុគ្គលម្នាក់កំពុងបង្ហាញអំពីកត្តាហានិភ័យនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ដោយផ្អែកលើការអង្កេត ការប្រាស្រ័យទាក់ទង និងសន្ទនា។ ការកំណត់អត្តសញ្ញាណបឋម អាចរួមបញ្ចូលទាំងឧបករណ៍ត្រួតពិនិត្យផងដែរ។ បន្ទាប់មក បុគ្គលនោះ នឹងត្រូវបានបញ្ជូនទៅរកជំនួយ និងធ្វើការវាយតម្លៃបន្ថែម ប្រសិនបើពួកគេយល់ព្រម។
- **ការកំណត់អត្តសញ្ញាណផ្លូវការ៖** ការកំណត់អត្តសញ្ញាណនេះ គឺជាការកំណត់ផ្លូវការថាបុគ្គលណាម្នាក់ គឺជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ដំណាក់កាលនេះ ជាទូទៅគឺតម្រូវឱ្យបុគ្គលនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឆ្លើយតបនឹងទម្រង់ជាច្រើនដើម្បីទទួលបានជំនួយ និងបើកការស៊ើបអង្កេត និងដំណើរការនីតិវិធីផ្លូវច្បាប់ទៅលើអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សដែលបានចោទប្រកាន់។ ឧបករណ៍ដាច់ដោយឡែកសម្រាប់ការកំណត់អត្តសញ្ញាណផ្លូវការ គឺជាការសម្ភាសន៍ដែលបានរៀបចំជារចនាសម្ព័ន្ធ ដូចមានចែងនៅក្នុង គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលអាចជាទម្រង់ "ខ្លី" ឬ ទម្រង់ "វែង ឬ"លម្អិត"។ ការកំណត់អត្តសញ្ញាណផ្លូវការ ត្រូវតែធ្វើឡើងដោយមន្ត្រីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (សូមមើលផ្នែក ៦.៥.១)។
- **ការបញ្ជូនទៅរកជំនួយ៖** នៅពេលដែលបានកំណត់អត្តសញ្ញាណជាផ្លូវការពីសំណាក់អាជ្ញាធរពាក់ព័ន្ធហើយ ប្រសិនបើមានការអនុញ្ញាត គួរតែបញ្ជូនជនរងគ្រោះនៃការជួញដូរមនុស្សនោះ ទៅកាន់សេវាពិគ្រោះយោបល់ ឬ វិធានការ និងការគាំទ្របន្ថែម។



*តារាង ២៖ តួអង្គដែលទទួលខុសត្រូវចំពោះការកំណត់អត្តសញ្ញាណជនរងគ្រោះបឋម*

| តួអង្គទទួលខុសត្រូវ[១៦] | នីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះបឋម |
|---|---|
| **អ្នកមានសិទ្ធិកំណត់អត្តសញ្ញាណ** | • កំណត់អត្តសញ្ញាណបឋម ផ្អែកលើសូចនាករស្តីពីការជួញដូរមនុស្ស<br>• បំពេញ និងដាក់ជូនទម្រង់ និងនីតិវិធីទៅកាន់នគរបាលយុត្តិធម៌អាចជាទម្រង់ "ខ្លី" ឬទម្រង់ "វែង" ឬ "លម្អិត" |
| នគរបាលយុត្តិធម៌ | • សង្គ្រោះជនរងគ្រោះនៃការជួញដូរមនុស្សណាមួយដែលត្រូវការឱ្យជួយសង្គ្រោះ<br>• កំណត់អត្តសញ្ញាណឧក្រិដ្ឋកម្ម និងនីតិវិធី<br>• ស៊ើបអង្កេត និងចាប់ខ្លួនជនសង្ស័យ<br>• កសាងសំណុំរឿង និងបញ្ជូនសំណុះរឿងទៅកាន់តុលាការ<br>• បំពេញ និងដាក់ជូនទម្រង់បែបបទ និងនីតិវិធីជូនដល់មន្ត្រីសង្គមកិច្ច |
| មន្ត្រីសង្គមកិច្ច | • ស្វែងរកសេវាសម្រាប់ជនរងគ្រោះនៃការជួញដូរមនុស្ស<br>• ផ្តល់ការពិគ្រោះយោបល់នៅពេលដែលសមស្រប<br>• ធ្វើសមាហរណកម្មជនរងគ្រោះនៃការជួញដូរមនុស្ស រួមទាំង ការគ្រប់គ្រង និងការតាមដានសំណុំរឿង<br>• បំពេញ និងដាក់ជូនទម្រង់បែបបទ និងនីតិវិធីជូនដល់ទីកន្លែងផ្តល់សេវា ឬអ្នកផ្តល់សេវា |
| អ្នកផ្តល់សេវា | • ផ្តល់សេវាសមស្របដល់ជនរងគ្រោះនៃការជួញដូរមនុស្ស៖ សុខភាព សេវាផ្លូវច្បាប់ ការស្តារនីតិសម្បទា ជំនាញការងារ បំណិនជីវិត មុខរបរ និងការគាំទ្រផ្សេងៗ |

រាជរដ្ឋាភិបាលកម្ពុជា ក៏ធ្វើប្រតិបត្តិការបង្កើតមជ្ឈមណ្ឌលសំចត រួមគ្នាជាមួយនឹងអង្គការសង្គមស៊ីវិល ដូចជា មជ្ឈមណ្ឌលសំចតនៅប៉ោយប៉ែត្រ ដែលមន្ត្រីមជ្ឈមណ្ឌល ត្រួតពិនិត្យពលករចំណាកស្រុកដែលត្រលប់មកវិញ និងកំណត់អត្តសញ្ញាណជនរងគ្រោះក្នុងចំណោមពលករជាមនុស្សពេញវ័យ និងកុមារ។ បន្ទាប់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុវត្តការសម្ភាសន៍បឋមលើពលករដែលត្រលប់មកវិញរួចរាល់ហើយ ក្រសួងនឹងបញ្ជូនពលករទៅកាន់អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានសម្រាប់ការសម្ភាសន៍ ដើម្បីកំណត់សេវាសមស្រប ការថែទាំ ការស្តារនីតិសម្បទា ឬការបញ្ជូនត្រលប់ទៅកាន់ភូមិកំណើតវិញភ្លាមៗ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាលពីពេលថ្មីៗនេះបានដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះផ្អែកលើការអនុវត្ត និងឧបករណ៍ត្រួតពិនិត្យសម្រាប់ប្រើប្រាស់នៅមជ្ឈមណ្ឌលសំចត ដើម្បីជួយលើកកម្ពស់នីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ធ្វើប្រតិបត្តិការស្របតាមគោលការណ៍ណែនាំ ដែលបានគូសបញ្ជាក់អំពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំក្នុងមណ្ឌលនៃជនរងគ្រោះ និងផ្សព្វផ្សាយឯកសារទាំងនេះជូនដល់មជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល។

## ៤.២.២ ការស៊ើបអង្កេតសំណុំរឿង និងការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌ

ការស៊ើបអង្កេតបឋម គឺត្រូវបានអនុវត្តដោយនគរបាលក្នុងមូលដ្ឋាន។ នៅពេលកំណត់រកករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សដែលអាចកើតមាន នគរបាលមូលដ្ឋាន នឹងជូនដំណឹងដល់នគរបាលយុត្តិធម៌ ហើយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នឹងដឹកនាំការស៊ើបអង្កេត។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលជានាយកដ្ឋានជំនាញនៃនគរបាលជាតិកម្ពុជា នឹងដឹកនាំនគរបាលមូលដ្ឋាននៅក្នុងការប្រមូលភស្តុតាង និងការវិភាគសំណុំរឿង។

នៅកម្រិតផ្ទៃក្នុង នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ធ្វើប្រតិបត្តិការជាគំរូកណ្តាល (hub-and-spoke model) ដោយមានអង្គភាពជំនាញកណ្តាលនៅរាជធានីភ្នំពេញ ដែលបំពេញបន្ថែមដោយអង្គភាពរងនៅតាមខេត្តនីមួយៗ។ អង្គភាពខេត្ត អាចបើកការស៊ើបអង្កេតដោយខ្លួនឯងបាន ហើយអង្គភាពកណ្តាលដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ ក៏អាចផ្តល់ការណែនាំដល់អង្គភាពខេត្តទាំងនោះផងដែរ។ តាមការណែនាំពីអគ្គស្នងការ អង្គភាពកណ្តាលអាចទទួលខុសត្រូវចំពោះសំណុំរឿងដែលធ្វើប្រតិបត្តិការដោយអង្គភាពខេត្ត។ គុណវិបត្តិមួយចំពោះការរៀបចំបែបកណ្តាល (hub and spoke) គឺថា មេបញ្ជាការខេត្តរាយការណ៍ជូនដល់ស្នងការនគរបាលខេត្ត និងពុំរាយការណ៍ជូនដល់ប្រធានអង្គភាពជំនាញកណ្តាលដែលម្តងម្កាលបង្កើតឱ្យមានការលំបាក ដោយសារតែមានចំណុចខ្វាស់គ្នាទៅលើអាទិភាពនោះទេ។

នៅពេលដែលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានភស្តុតាងគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងសំណុំរឿង នាយកដ្ឋាននឹងនាំជនល្មើសសង្ស័យមកសាកសួរចម្លើយ និងប្រមូលភស្តុតាងបន្ថែម។ តាមការអនុវត្តជាក់ស្តែង នាយកដ្ឋានកោះហៅជនសង្ស័យ ហើយ ប្រសិនបើជនសង្ស័យមិនអនុវត្តតាមការកោះហៅរបស់នគរបាលទេ នោះនគរបាលនឹងអនុវត្តដីកាចាប់ខ្លួនពីព្រះរាជអាជ្ញា។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក៏អាចបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញា និងអនុវត្តដីកាចាប់ខ្លួនពីពេលដំបូងដែរ។

*រូបភាព ៣៖ ផែនទីនៃដំណើរការចាប់ខ្លួន*



នៅពេលព្រះរាជអាជ្ញាចូលរួមក្នុងសំណុំរឿង ព្រះរាជអាជ្ញានឹងធ្វើការងារជាមួយនគរបាល ដើម្បីរៀបចំសំណុំរឿងដើម្បីជំនុំជម្រះ តាមរយៈការប្រមូលទិន្នន័យនៅសល់ណាមួយដែលត្រូវការចាំបាច់ និងបើកការស៊ើបអង្កេតបន្ថែម ប្រសិនបើចាំបាច់។ ព្រះរាជអាជ្ញាមានតួនាទីសម្រេចថាតើមានភស្តុតាងគ្រប់គ្រាន់ដើម្បីដំណើរការជំនុំជម្រះដែរឬទេ និងសម្រេចថាតើគួរធ្វើការចោទប្រកាន់ពីបទអ្វីខ្លះ។

នៅពេលរៀបចំសំណុំរឿងរួចរាល់ហើយ សំណុំរឿងនឹងត្រូវបញ្ជូនទៅកាន់តុលាការ។ ចៅក្រមស៊ើបសួរ នឹងទទួលខុសត្រូវលើការរៀបចំសវនាការដំបូងសម្រាប់សំណុំរឿង និងចេញសេចក្តីបង្គាប់ ដោយធានាថាសំណុំរឿងនេះគឺរួចរាល់ក្នុងការដំណើរការពីអយ្យការ និងមេធាវីការពារក្តី។ នៅពេលដែលសំណុំរឿងរួចរាល់សម្រាប់សវនាការ សំណុំរឿងនេះនឹងត្រូវជំនុំជម្រះ និងសម្រេចដោយចៅក្រមជំនុំជម្រះ។ បន្ទាប់ពីចេញសេចក្តីសម្រេច សំណុំរឿងនេះអាចប្តឹងឧទ្ធរណ៍បាន និងបញ្ជូនទៅកាន់សាលាឧទ្ធរណ៍ដើម្បីត្រួតពិនិត្យ។

ដំណើរការនៃការនាំយកសំណុំរឿងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សទៅដោះស្រាយនៅតុលាការគឺត្រូវបានសង្ខេបដូចខាងក្រោម៖

*រូបភាព ៩៖ ផែនទីដំណើរការតុលាការ*




## ៤.២.៣ ការគូសផែនទីដំណើរការនៃប្រព័ន្ធការងារ

ចំពោះបណ្តឹងការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតការិយាល័យនៅថ្នាក់ខេត្ត ដើម្បីតាមដានត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសពលករ និងដោះស្រាយបណ្តឹងពីពលករ រួមទាំងគ្រោះថ្នាក់នៃការជួញដូរមនុស្សដែលអាចកើតមាន។ ទោះជាយ៉ាងនេះក្តី បុគ្គលិកលើកឡើងថា ប្រសិនបើមានករណីអំពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សសង្ស័យ ពួកគេនឹងបញ្ជូនករណីនេះទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ទោះបីជាករណីនេះកម្រនឹងកើតមាននៅក្នុងការអនុវត្តជាក់ស្តែងក៏ដោយ។

ជាក់ស្តែង ករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សដែលអាចកើតមានជាច្រើន ត្រូវបានចាត់ទុកថាជាជម្លោះការងារ។ នៅក្រោមច្បាប់ស្តីពីការងារកម្ពុជា ឆ្នាំ ២០០៧ នៅពេលដែលមានវិវាទការងាររវាងពលករ និងនិយោជករបស់ពួកគេ និយោជកអាចដាក់ពាក្យបណ្តឹងទៅកាន់មន្ទីរការងារខេត្ត ប្រសិនបើករណីនេះកើតឡើងនៅក្នុងខេត្ត។ ប្រសិនបើករណីនេះកើតឡើងនៅរាជធានីភ្នំពេញ ករណីនេះចាំបាច់ត្រូវតែបញ្ជូនទៅកាន់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ បណ្តឹងនេះ នឹងត្រូវបញ្ជូនទៅសម្រុះសម្រួល និងប្រសិនបើមិនអាចសម្រុះសម្រួលបានលទ្ធផលដែលអាចទទួលយកបានភាគីណាមួយក្នុងចំណោមភាគីទាំងពីរអាចដាក់ពាក្យបណ្តឹងទៅតុលាការ។[១៧] នៅមុនពេលវិធានការតុលាការណាមួយ វិវាទអាចត្រូវបានបញ្ជូនដើម្បីសម្រុះសម្រួលបឋមទៅកាន់អធិការការងារនៅក្នុងខេត្ត ឬក្រុងនៅពេលដែលភាគីណាមួយ

ក្នុងចំណោមគូភាគីចាប់ផ្តើមប៉ុណ្ណោះ។
ប្រសិនបើបានដាក់ពាក្យបណ្តឹង អធិការការងារ ត្រូវកំណត់សវនាការដែលនឹងត្រូវធ្វើឡើងនៅក្នុងរយៈពេលបីសប្តាហ៍យ៉ាងយូរ នៅពេលទទួលបានបណ្តឹង។ នៅក្នុងមាត្រា ៣០១ "អធិការការងារ ក្រោយពេលបានទទួលពាក្យបណ្តឹង គឺត្រូវសាកសួរភាគីទាំងសងខាង ឱ្យដឹងពីកម្មវត្ថុនៃវិវាទ រួចសាកល្បងផ្សះផ្សាភាគីដោយយកច្បាប់បទបញ្ជា អនុសញ្ញារួម ឬកិច្ចសន្យាការងារម្នាក់ៗជាមូលដ្ឋាន។" គូភាគីអាចទទួលបានជំនួយ ឬ អ្នកតំណាងនៅសវនាការ។
លទ្ធផលនៃការផ្សះផ្សាត្រូវមានចុះក្នុងកំណត់ហេតុ ដែលធ្វើដោយអធិការការងារ មានបញ្ជាក់ពីការយល់ព្រម ឬមិនយល់ព្រមលើការផ្សះផ្សានៃភាគី ។ កំណត់ហេតុ ត្រូវមានចុះហត្ថលេខាអធិការការងារ និងភាគីទាំងអស់ និងត្រូវចម្លងចែកភាគីផងដែរ។ ការព្រមព្រៀងដែលបានធ្វើឡើងនៅចំពោះមុខអធិការការងារ គឺជាការព្រមព្រៀង ដែលយកជាការបានចំពោះមុខច្បាប់ ។ ក្នុងករណី ដែលពុំមានការផ្សះផ្សាគ្នា សាមីភាគីអាចប្តឹងទៅសាលាក្តីមានសមត្ថកិច្ចនៅក្នុងរយៈពេលពីរខែ បើពុំនោះទេ សិទ្ធិប្តឹងនេះនឹងត្រូវផុតកំណត់ ។

*រូបភាព ៥៖ ផែនទីនៃដំណើរការប្រព័ន្ធការងារ*






## ៤.២.៤ ដំណើរការបញ្ជូនជនរងគ្រោះ

កាតព្វកិច្ចក្នុងការជួយដល់ជនរងគ្រោះនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស គឺមានចែងនៅក្នុងគោលនយោបាយស្តីពីការការពារសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរមនុស្ស (ប្រកាសលេខ ៨៥២) រួមទាំង បទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរមនុស្ស (ប្រកាសលេខ ៨៥៧) (ឆ្នាំ ២០០៩) (គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការការពារ)។

គោលនយោបាយស្តីពីការការពារជនរងគ្រោះនេះ គឺត្រូវបានត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងចែងអំពីគោលការណ៍ និងនីតិវិធីសម្រាប់ការការពារ និងការគាំទ្រជនរងគ្រោះ រួមទាំង៖

- ល័ក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងសំណុំរឿង ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការអន្តរាគមន៍វិបត្តិមាតុភូមិនិវត្តន៍ ការទទួល ការធ្វើផែនការសំណុំរឿង ការវាយតម្លៃ ការស្តារឡើងវិញ ការធ្វើសមាហរណកម្ម ការតាមដាន និងការបិទសំណុំរឿង
- សិទ្ធិរបស់ជនរងគ្រោះចាប់ពីពេលកំណត់អត្តសញ្ញាណ រហូតដល់ការធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ
- គំរូនៃការការពារជនរងគ្រោះ និងការថែទាំនៅក្នុងមណ្ឌលរបស់រដ្ឋាភិបាល មណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍

គោលនយោបាយស្តីពីការការពារ ក៏ចែងអំពីទំនួលខុសត្រូវរបស់ក្រសួងស្ថាប័ន និងមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា រួមទាំងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីការការពារជនរងគ្រោះ។ គោលនយោបាយនេះ ក៏មានចែងអំពីសិទ្ធិចំនួនដប់មួយរបស់ជនរងគ្រោះផងដែរ៖ (១) សុវត្ថិភាព និងការការពារ (២) អត្តសញ្ញាណបុគ្គល (៣) ឯកជនភាព និង ការរក្សាព័ត៌មានសម្ងាត់ (៤) សេចក្តីថ្លៃថ្នូរ (៥) ព័ត៌មាន (៦) សេវា (៧) យុត្តិធម៌ (៨) ភាពប្រក្រតី (៩) ការចូលរួម (១០) ការធ្វើសេចក្តីសម្រេច និង (១១) សេរីភាពក្នុងការធ្វើដំណើរ។

គោលនយោបាយស្តីពីការការពារជនរងគ្រោះ ក៏រួមបញ្ចូលបទដ្ឋានស្តង់ដារសម្រាប់ការថែទាំជនរងគ្រោះ ដែលតម្រូវឱ្យអ្នកផ្តល់សេវាអនុវត្តវិធីសាស្ត្រយកចិត្តទុកដាក់លើជនរងគ្រោះ និងផ្អែកលើសិទ្ធិនៅគ្រប់ដំណាក់កាលទាំងអស់នៃការឆ្លើយតប និងការធ្វើសមាហរណកម្ម។ បទដ្ឋានទាំងនេះ ចែងអំពីល័ក្ខខណ្ឌតម្រូវនៅក្រោមផ្នែកនៃការថែទាំខាងក្រោម៖

- លំនៅដ្ឋាន ការថែទាំ និងការស្នាក់នៅ
- ជំនួយវេជ្ជសាស្ត្រ
- ការគាំទ្រផ្លូវចិត្ត និងការពិគ្រោះយោបល់
- ការអប់រំ ការបណ្តុះបណ្តាល និងបំណិនជីវិត
- ឱកាសពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច
- ជំនួយ និងការគាំទ្រផ្នែករដ្ឋបាល
- វិធានការសុវត្ថិភាព និងសន្តិសុខ
- ជំនួយដល់សមាជិកគ្រួសាររបស់ជនរងគ្រោះ
- ការគ្រប់គ្រងករណី

គោលនយោបាយស្តីពីការការពារជនរងគ្រោះ ក៏មានចែងផងដែរអំពីដំណើរការសម្រាប់ការបញ្ជូនដូចខាងក្រោម៖

*រូបភាព ៦៖ ផែនទីនៃដំណើរការបញ្ជូនជនរងគ្រោះ*






## ៤.២.៥ ការសហការឆ្លងដែន

ចំពោះពលករចំណាកស្រុកដែលបានត្រលប់មកពីប្រទេសថៃវិញ ការសហការឆ្លងដែន គឺមានសារៈសំខាន់ណាស់ក្នុងការសម្របសម្រួលដល់លទ្ធភាពទទួលបានប្រព័ន្ធច្បាប់ប្រទេសថៃ។ ដំណើរការនេះ ពឹងផ្អែកលើការគាំទ្រដល់ស្ថាប័នរដ្ឋាភិបាលកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទំនាក់ទំនងជាមួយក្រសួងភាគីនៅក្នុងប្រទេសថៃដូចខាងក្រោម៖

*រូបភាព ៧៖ ផែនទីដំណើរការសហការអន្តរជាតិ*




មានដំណើរការផ្លូវការមួយ សម្រាប់ការសហការ ដែលរួមបញ្ចូលមន្ត្រីថៃ ដែលចេញលិខិតអញ្ជើញដល់ភាគីកម្ពុជា ដូចដែលបានបង្កើតនៅឆ្នាំ ២០០៥ នៅក្រោមសន្ធិសញ្ញាអាស៊ានស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ (MLAT)។ តាមការអនុវត្តជាក់ស្តែង MLAT អាចមានភាពយឺតយ៉ាវ និងត្រូវដំណើរការការងារច្រើន ដែលនាំឱ្យមានការសហការក្រៅផ្លូវការរវាងមន្ត្រី។ ជំនួសមកវិញ អង្គការមិនមែនរដ្ឋាភិបាលតែងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើជាអ្នកទំនាក់ទំនង និងអ្នកសម្របសម្រួលចម្បង រវាងជនរងគ្រោះ និងរដ្ឋាភិបាលនៃប្រទេសទាំងពីរ។



# ៥ ការដោះស្រាយ និង ការរារាំងជនល្មើស

# ៥ ការដោះស្រាយ និង ការរារាំងជនល្មើស

## ៥.១ ការតាមដានត្រួតពិនិត្យ និងអធិការកិច្ច

ការតាមដានត្រួតពិនិត្យ និងអធិការកិច្ចលើតួអង្គសំខាន់ៗ និងកន្លែងការងារ គឺជាការទទួលខុសត្រូវចំពោះការរក្សាឱ្យបាននូវបទដ្ឋានច្បាប់ជាច្រើន ដែលកាត់បន្ថយលទ្ធភាពនៃការកើតឡើងនូវពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងការពារមនុស្សពីភាពងាយរងគ្រោះផ្សេងៗ។

### ៥.១.១ អធិការកិច្ចកន្លែងធ្វើការ

យោងតាមអ្នកផ្តល់ព័ត៌មានសំខាន់ៗ អធិការកិច្ចកន្លែងធ្វើការ គឺពុំបានអនុវត្តញឹកញាប់ និងប្រកបដោយប្រសិទ្ធភាពនោះទេដើម្បីកំណត់រកពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ ជាមួយគ្នានេះ អធិការកិច្ចការងារ គឺពុំសូវផ្តោតការយកចិត្តទុកដាក់លើការអនុវត្តក្រមច្បាប់ការងារនោះដែរ និងត្រូវបានអនុវត្តដោយមានការយល់ដឹងតិចតួចប៉ុណ្ណោះអំពីសូចនាករនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ ឧទាហរណ៍ ឡូតដូជាច្រើន គឺត្រូវបានធ្វើអធិការកិច្ចនៅពេលមានរបាយការណ៍លេចឡើងស្តីពីការរីកសាយភាយនៃការអនុវត្តវិធីចងកាតព្វកិច្ចនឹងបំណុល។ ទោះបីជាយ៉ាងនេះក្តី អធិការការងារពុំបានកំណត់រកឃើញករណីណាមួយអំពីពលកម្មដោយបង្ខំនៅតាមឡូតដូនោះទេ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងស្រដៀងគ្នាថា ក្រសួងកម្រទទួលបានរបាយការណ៍អំពីករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សណាស់ ប៉ុន្តែដោយឡែក ការិយាល័យរបស់ក្រសួងក៏ពុំមានបណ្តាញផ្លូវការសម្រាប់ទទួលបណ្តឹងពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនោះដែរ។

ភាគីពាក់ព័ន្ធមួយចំនួនបានរៀបរាប់ថា នៅពេលដែលអធិការការងារចុះធ្វើអធិការកិច្ចដោយ "ពុំបានផ្តល់ដំណឹងជាមុន" កន្លែងធ្វើការជារឿយៗបានទទួលការជូនដំណឹងមុនរួចទៅហើយអំពីអធិការកិច្ចនោះ ដែលអនុញ្ញាតឱ្យពួកគេធានាថាពួកគេលាក់បាំងភស្តុតាងនានាអំពីការរំលោភបំពានទៅលើកម្លាំងពលកម្មណាមួយ។ ប្រសិនបើមានការកំណត់រកឃើញបណ្តឹង នោះក្រសួងនឹងអនុវត្តវិធីសាស្ត្រ "ដោះស្រាយបញ្ហា"។ ប្រការនេះ មានន័យថា ការឆ្លើយតបជាផ្លូវការតាមផ្លូវច្បាប់គឺត្រូវបានគេជៀសវាង ដើម្បីជាប្រយោជន៍ដល់ការសម្រុះសម្រួលក្រៅផ្លូវការជាមួយនឹងនិយោជក ដែលប្រការនេះអនុញ្ញាតឱ្យពួកគេជៀសផុតពីផលវិបាកតាមផ្លូវច្បាប់។

នៅពេលចុះអនុវត្តអធិការកិច្ចនៅតាមរោងចក្រ អធិការកិច្ចទាំងនេះ គឺបានរាយការណ៍អំពីក្តីបារម្ភពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណកម្មករនិយោជិតបរទេស និងថាតើពួកគេមានឯកសារផ្លូវច្បាប់ដែលតម្រូវដែរឬទេតែប៉ុណ្ណោះ។ យោងតាមរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក ឆ្នាំ ២០២២ មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ បានអនុវត្តអធិការកិច្ចចំនួន ២.៩៦៦ លើកនៅតាមរោងចក្រ និងអាជីវកម្មផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០២១។ យោងតាមរបាយការណ៍ដដែលនេះ អាជ្ញាធរបានដាក់ពិន័យដល់អាជីវកម្មសរុបចំនួន ២៣៣ លានរៀល (៥៨.៥២០ ដុល្លារអាមេរិក) ពីបទរំលោភបំពានការងារ។

ចាប់តាំងពីខែសីហា ឆ្នាំ ២០២២ គឺបន្ទាប់ពីការបញ្ចប់សម្ភាសន៍សម្រាប់ការសិក្សានេះ គេសង្កេតឃើញថាមានកិច្ចខិតខំប្រឹងប្រែងចុះ "បង្ក្រាប" នៅតាមទីតាំង និងទីកន្លែងនានាដែលសង្ស័យថាជាទីតាំងប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសបច្ចេកវិទ្យាដែលមានអង្គភាពចាត់តាំង។ ភាគីពាក់ព័ន្ធបានលើកឡើងថា អធិការកិច្ចការងាររាប់រយនាក់បានធ្វើប្រតិបត្តិការក្នុងអំឡុងពេលនេះ និងមានមនុស្សប្រហែលជាងពីរពាន់នាក់ត្រូវបានជួយសង្គ្រោះពីកន្លែងការងារដែលមានការរំលោភបំពាន ដែលនេះជាលទ្ធផលនៃអធិការកិច្ចការងារនេះផងដែរ។ អធិការកិច្ចនេះ កើតឡើងដើម្បីឆ្លើយតបទៅនឹងការរាយការណ៍លើប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិសំខាន់ៗ និងសម្ពាធពីសាធារណជន។ ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងទាំងនេះដោះស្រាយបានត្រឹមតែមួយចំណែកតូចនៃករណីដែលអាចកើតមានប៉ុណ្ណោះ រីឯវិស័យនេះហាក់បីដូចជាកាន់តែរីកលូតលាស់ឡើង ដូច្នេះវាគឺជាការសំខាន់ណាស់ដែលត្រូវរក្សាឱ្យបាននូវកិច្ចខិតខំប្រឹងប្រែងនេះនាពេលអនាគត។ នៅមុនពេលកិច្ចខិតខំប្រឹងប្រែងទាំងនេះ ភាគីពាក់ព័ន្ធបានស្នើឱ្យមានការប្រឆាំងទៅនឹងការស៊ើបអង្កេតប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ដោយសារពួកគេជឿថាមានជាប់ពាក់ព័ន្ធនឹងបុគ្គលមានអំណាច។ ប្រការនេះ គឺមានសង្គតិភាពជាមួយការពិតដែលថា ក្នុងចំណោមពលករដែលបានជួយសង្រ្គោះ គឺគ្មានពលករណាម្នាក់ត្រូវបានចាត់ថ្នាក់ជាផ្លូវការថាជាជនរងគ្រោះនៃការជួញដូរមនុស្សនោះទេ។

## ៥.១.២ ការដោះស្រាយបញ្ហាប្រឈមស្តីអំពីបណ្តាញចំណាកស្រុកដែលបានចុះអនុស្សារណៈនៃការយោគយល់រវាងប្រទេសថៃ និងកម្ពុជា

អនុស្សារណៈនៃការយោគយល់រវាងប្រទេសកម្ពុជា និងថៃ ចែងអំពីក្របខណ្ឌសម្រាប់ការចំណាករបស់ពលរដ្ឋកម្ពុជាចូលទៅធ្វើការងារនៅប្រទេសថៃ។ ទោះជាយ៉ាងនេះក្តី បណ្តាញចំណាកស្រុកដែលបានចុះអនុស្សារណៈនៃការយោគយល់នេះ គឺពុំបានទាក់ទាញអារម្មណ៍ពលករចំណាកស្រុកជាច្រើននោះទេ ដោយសារតែពួកគេពុំជឿជាក់ថាបណ្តាញទាំងនេះផ្តល់ឱ្យពលករនូវសុវត្ថិភាព ទំនុកចិត្ត ភាពងាយស្រួល ឬអត្ថប្រយោជន៍ហិរញ្ញវត្ថុអ្វីឡើយ។ ពលករទេសន្តរប្រវេសន៍បន្តជ្រើសរើសបណ្តាញចំណាកស្រុកក្រៅផ្លូវការ ពីព្រោះវាមានភាពងាយស្រួលជាង និងករណីភាគច្រើនគេបានយល់ឃើញថាមានសុវត្ថិភាព និងតម្លៃសមរម្យជាង។

បញ្ហានានានបណ្តាញដែលបានចុះអនុស្សារណៈនៃការយោគយល់ រួមមាន៖

- ទីតាំងមានកម្រិត ដែលពលករចំណាកស្រុកអាចដាក់ពាក្យស្នើសុំធ្វើលិខិតឆ្លងដែន ដែលជារបាំងរារាំងដល់ការទទួលបានសេវា។
- ថ្លៃចំណាយដំបូងខ្ពស់ ដែលបង្កឱ្យមានការជាប់បំណុល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងនិយោជកក្នុងចំនួនច្រើន។
- ពលករចំណាកស្រុកមានជម្រើសតិចតួចក្នុងការទទួលបានការងារ ដែលអាចរារាំងដល់បណ្តាញគាំទ្រសង្គមកិច្ចសម្រាប់ពលករចំណាកស្រុក និងរារាំងពួកគេពីការបម្រើការងារឱ្យនិយោជកដែលពួកគេស្គាល់។
- ការកេងប្រវ័ញ្ចពីភ្នាក់ងារជ្រើសរើសពលករ។
- ការសាយភាយនៃអ្នកជ្រើសរើសពលករមិនមានអាជ្ញាប័ណ្ណ និងមេខ្យល់ដែលមិនអាចជឿទុកចិត្តបាននៅតំបន់ជនបទ ដែលច្បាប់ថៃផ្តល់លទ្ធភាពជាក់ស្តែងតិចតួចបំផុតក្នុងការប្រើប្រាស់យន្តការបណ្តឹងតវ៉ា។
- ការខកខានជាច្រើនពីសំណាក់អាជ្ញាធរថៃក្នុងការប្រកាន់ខ្ជាប់តាមសិទ្ធិរបស់ពលករចំណាកស្រុក។
- ច្បាប់ប្រទេសថៃបានដាក់ការរឹតត្បិតលើលទ្ធភាពរបស់ពលករក្នុងការផ្លាស់ប្តូរការងារ។

លើសពីនេះ ប្រព័ន្ធអនុស្សារណៈនៃការយោគយល់នេះ ហាក់បីដូចជាពុំសូវបានប្រើជាប្រយោជន៍ជុំកំភួនក្នុងការផ្លាស់ប្តូរការយល់ឃើញក្នុងចំណោមនិយោជកជនជាតិថៃឡើយ ដែលថា៖ (១) ពួកគេអនុគ្រោះខ្លាំងដល់ពលករទេសន្តរប្រវេសន៍

ដែលបានផ្តល់ការងារឱ្យពួកគេធ្វើ និង (២) សិទ្ធិរបស់នយោជិក គឺមានកម្រិតខ្ពស់ជាងកន្លែងធ្វើការងារទៅទៀត។ សមាជិកក្រុមសិក្សាស្រាវជ្រាវរបស់ក្រុមស្រាវជ្រាវ និងទំនាក់ទំនង (RCG) មានបទពិសោធន៍ជាក់ស្តែងចំពោះអ្នកតំណាងនិយោជកដែលបានមកធ្វើអន្តរាគមន៍ ក្នុងខណៈពេលដែលពួកគាត់កំពុងជជែកពិភាក្សាគ្នាជាមួយពលករនៅក្រៅម៉ោងការងារ និងនៅឆ្ងាយពីកន្លែងធ្វើការ។

អនុស្សារណៈនៃការយោគយល់ បានបណ្តាលឱ្យពលករចំណាកស្រុកធ្លាក់ក្រោមអំណាចរបស់អ្នកជ្រើសរើសពលករ និងនិយោជកដោយបានគ្រប់គ្រងជីវិតការងាររបស់ពួកគេ និងរារាំងពលករពុំឱ្យអនុវត្តសិទ្ធិរបស់ពួកគេគ្រប់ពេលវេលា។ ផ្ទុយទៅវិញ ទំនួលខុសត្រូវ គឺត្រូវបង្វែរដាក់មកលើពលករចំណាកស្រុកទៅវិញ ដែលពួកគេទាំងនេះមានអំណាចតិចតួច ឬពុំមានអំណាចទាល់តែសោះក្នុងការធានាសុវត្ថិភាពផ្ទាល់ខ្លួន ជាជាងការដាក់ទំនួលខុសត្រូវទៅលើអ្នកកាន់អំណាចក្នុងការធានាសុវត្ថិភាពរបស់ពលករចំណាកស្រុក ដូចជានិយោជក រដ្ឋាភិបាល អ្នកជ្រើសរើស និងភ្នាក់ងារជ្រើសរើសពលករជាដើមនោះ។ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា និងភាគីខាងថៃ ធ្វើការងារឱ្យបានម៉ឺងម៉ាត់ក្នុងការដោះស្រាយពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស (ជាពិសេស ពលកម្មដោយបង្ខំ) សម្រាប់ពលករចំណាកស្រុកនៅប្រទេសថៃ នោះប្រព័ន្ធអនុស្សារណៈនៃការយោគយល់ គឺចាំបាច់ត្រូវតែត្រួតពិនិត្យឡើងវិញជាពិសេសនៅកម្រិតមូលដ្ឋាន។

បើទោះបីជាបញ្ហានេះ ជាបញ្ហាដ៏ធំមួយដែលបានកំណត់រកឃើញថាបានចូលរួមចំណែកដល់ភាពងាយរងគ្រោះទៅនឹងពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សចំពោះពលករចំណាកស្រុកក្តី ក៏ការខិតខំប្រឹងប្រែងពីសំណាក់រដ្ឋាភិបាលក្នុងការចរចាជាមួយខាងភាគីថៃគឺនៅមានកម្រិតតិចតួចនៅឡើយ ដើម្បីកែលម្អការកំណត់គោលនយោបាយចំណាកស្រុក។ ដោយទទួលស្គាល់អំពីគុណតម្លៃនៃវិធានការរួម កម្ពុជាបាន និងកំពុងដើរតួនាទីដឹកនាំកិច្ចពិភាក្សាជាមួយប្រភពបណ្តាញពលករចំណាកស្រុកធំៗពីរផ្សេងទៀតនៅក្នុងប្រទេសថៃ គឺ មីយ៉ាន់ម៉ា និង ឡាវ ដូច្នេះទើបបណ្តាប្រទេសទាំងនេះអាចមានលទ្ធភាពចរចារួមគ្នាជាមួយអាជ្ញាធរថៃពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពលករចំណាកស្រុករបស់ប្រទេសផងខ្លួន។[១៨]
ទោះជាយ៉ាងនេះក្តី ហេតុការណ៍នៅក្នុងប្រទេសមីយ៉ាន់ម៉ាបានបង្ហាក់ដល់កិច្ចខិតខំប្រឹងប្រែងលើការងារទាំងនេះ ដែលសម្ភាសន៍ភាគីពាក់ព័ន្ធបានបញ្ជាក់យ៉ាងច្បាស់ថា ពុំមានឆន្ទៈពិតប្រាកដក្នុងការចាត់វិធានការនៅពេលនេះនោះទេ។ ផ្ទុយមកវិញ ភាគីពាក់ព័ន្ធបន្តព្យាយាមកែលម្អលើប្រព័ន្ធដែលមានចំណុចខ្វះខាតលើការរចនាមូលដ្ឋាន។ ការផ្លាស់ប្តូរជាវិជ្ជមានមួយដែលបានលើកឡើងក្នុងការសិក្សានេះ គឺកំណើនភាពងាយស្រួលក្នុងការទទួលបានឯកសារចំណាកស្រុកតាមរយៈការផ្តល់ទីតាំងបន្ថែមទៀតសម្រាប់ការដំណើរការរដ្ឋបាល។

## ៥.១.៣ ការតាមដានត្រួតពិនិត្យលើភ្នាក់ងារជ្រើសរើសពលករ

ដើម្បីឱ្យពលករអាចធ្វើចំណាកស្រុកផ្លូវការតាមរយៈបណ្តាញអនុស្សារណៈនៃការយោគយល់គ្នាបាន ពលករចាំបាច់ត្រូវឱ្យភ្នាក់ងារជ្រើសរើសពលករក្នុងប្រទេសកម្ពុជាចូលរួមនៅក្នុងការដំណើរការឯកសារចំណាកស្រុក ដូចជា លិខិតឆ្លងដែន ទិដ្ឋាការ និងប័ណ្ណ និងសៀវភៅការងារ។ ទីភ្នាក់ងារជ្រើសរើសពលករ ក៏ដើរតួនាទីសំខាន់ផងដែរតាមរយៈការផ្តល់ការងារ ផ្តល់ជំនួយ និងទំនាក់ទំនងទៅកាន់ការងារនៅក្រៅប្រទេសនៅមុនពេលធ្វើដំណើរ។
ទោះជាយ៉ាងនេះក្តី អង្គការសង្គមស៊ីវិលបានលើកឡើងថា ភ្នាក់ងារជ្រើសរើសពលករបានដើរតួនាទីតិចតួចបំផុតក្នុងការការពារពលករចំណាកស្រុកពីគ្រោះថ្នាក់នានា និងជារឿយៗភ្នាក់ងារផ្ទាល់ក៏បានរួមចំណែកដល់ភាពងាយរងគ្រោះ និងការកេងប្រវ័ញ្ចលើពលករផងដែរ។ ទីភ្នាក់ងារជ្រើសរើសពលករកម្រនឹងដកនិយោជិកដែលពុំល្អចេញ ដែលកត្តានេះគឺពុំអនុលោមទៅតាមបទដ្ឋានការងារនោះឡើយ។ លើសពីនេះ ភ្នាក់ងារជ្រើសរើសពលករមានទំនួលខុសត្រូវតិចតួចប៉ុណ្ណោះក្នុងការធានាសុវត្ថិភាពរបស់ពលករចំណាកស្រុក បន្ទាប់ពីបញ្ជូនពួកគេទៅធ្វើការងារនៅក្រៅប្រទេស និងពុំបានតាមដានត្រួតពិនិត្យល័ក្ខខណ្ឌការងារឱ្យបានទៀងទាត់ឡើយ។ លើសពីនេះ ពួកគេថែមទាំងពុំបានផ្តល់ជំនួយឱ្យបានគ្រប់

គ្រាន់នោះទេ នៅពេលដែលការរំលោភបំពានការងារ និងល័ក្ខខណ្ឌមានលក្ខណៈកេងប្រវ័ញ្ចកើតមាននោះ។

បើទោះបីជាភ្នាក់ងារជ្រើសរើសពលករទទួលខុសត្រូវចំពោះការធានាឱ្យបាននូវការរៀបចំកម្មវិធីបណ្តុះបណ្តាលមុនពេលចេញដំណើរក្តី ក៏កម្មវិធីនេះផ្តោតស្ទើរតែទាំងស្រុងទៅលើទំនួលខុសត្រូវរបស់ពលករជាជាងសិទ្ធិរបស់ពួកគេ។ បន្ថែមលើសនេះ គុណភាព គឺមានភាពខុសគ្នា និងបានបង្រៀនតិចតួចដល់ពលករអំពីការការពារខ្លួនឯងពីនិយោជកដែលរំលោភបំពាន និងកាលៈទេសៈបំពារបំពាន។ អង្គការសង្គមស៊ីវិលបានលើកឡើងថា ភ្នាក់ងារជ្រើសរើសពលករគួរតែត្រូវបានជំរុញឱ្យទទួលខុសត្រូវ តាមរយៈការធ្វើនិយ័តកម្ម និងតាមដានត្រួតពិនិត្យ។ ទោះជាយ៉ាងនេះក្តី អាជ្ញាធរស្ទាក់ស្ទើរក្នុងការធ្វើនិយ័តកម្ម និងតាមដានត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់ទៅលើភ្នាក់ងារជ្រើសរើសពលករ ដោយហេតុថាភ្នាក់ងារមួយចំនួន គឺជាប់ពាក់ព័ន្ធផលប្រយោជន៍របស់ឧកញ៉ា (អ្នកជំនួញមានឥទ្ធិពល) និងបុគ្គលមានឥទ្ធិពល។

ក្នុងករណីជាច្រើន ភ្នាក់ងារជ្រើសរើសពលករ ជាប្រភពនៃការកេងប្រវ័ញ្ច និងភាពងាយរងគ្រោះសម្រាប់ពលករ តាមរយៈការគិតកម្រៃសេវាហួសកម្រិត ការផ្តល់ឯកសារពុំត្រឹមត្រូវ ឬការអនុវត្តតាមអ្នកជ្រើសរើសពលករបន្តដែលគ្មានអាជ្ញាប័ណ្ណ និងពុំអាចជឿទុកចិត្តបាន ដែលពលករត្រូវបានគេយកកម្រៃសេវាហួសហេតុ ដែលទំនងជាត្រូវ "ជាប់អន្ទាក់" ក្នុងការងាររបស់ពួកគេដោយសារកាតព្វកិច្ចបំណុល។ ខាងក្រោមនេះ ជាឧទាហរណ៍មួយអំពីភ្នាក់ងារជ្រើសរើសពលករកេងប្រវ័ញ្ចៈ

> "ទីភ្នាក់ងារជ្រើសរើសពលករមួយចំនួនតូចបានបោកបញ្ឆោតសហគមន៍តាមរយៈការសន្យាបណ្តុះបណ្តាលពលករ និងផ្តល់ការងារល្អឱ្យពួកគេធ្វើនៅឯក្រៅប្រទេស។ សហគមន៍បានជឿទុកចិត្ត និងបានបង់ប្រាក់ឱ្យទីភ្នាក់ងារទាំងនោះប្រហែល ២.០០០ ទៅ ៣.០០០ ដុល្លារអាមេរិក ក្នុងម្នាក់។ ជាក់ស្តែង ទីភ្នាក់ងារនោះ គឺគ្រាន់តែផ្តល់ការបណ្តុះបណ្តាលដែលគ្មានលក្ខណៈជាប្រព័ន្ធ និងបន្ទាប់ពីពីរបីខែក្រោយមក ពលករគឺពុំទទួលបានការងារនៅក្រៅប្រទេសនោះទេ ដោយគ្រាន់តែត្រូវបានគេនាំមកស្នាក់នៅរាជធានីភ្នំពេញប៉ុណ្ណោះ។ ប៉ុន្តែ ប្រការនេះ គឺមានការលំបាកក្នុងការចាត់វិធានការ ដោយហេតុថាពុំមានកិច្ចសន្យាជាក់លាក់ជាមួយទីភ្នាក់ងារនោះទេ។"
>
> អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ជាការឆ្លើយតប ស្ថាប័នកំពូលនៅក្នុងវិស័យជ្រើសរើសពលករ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) ត្រូវបានជំរុញឱ្យអនុវត្តវិធានការនានា ដើម្បីលើកកម្ពស់បទដ្ឋានក្នុងវិស័យទៅវិញ។ កាលពីខែមករា ឆ្នាំ២០២០ ក្រមប្រតិបត្តិមួយត្រូវបានបង្កើតឡើងសម្រាប់ទីភ្នាក់ងារជ្រើសរើសពលករឯកជនតាមរយៈកិច្ចសហការរវាងសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគម្រោង TRIANGLE របស់អង្គការពលកម្មអន្តរជាតិក្នុងតំបន់អាស៊ាន។[១៩] ក្រមប្រតិបត្តិនេះ មានគោលការណ៍ចំនួន ១២ សម្រាប់ការជ្រើសរើសពលករប្រកបដោយសីលធម៌ រួមទាំង ការកាត់បន្ថយថ្លៃសេវាចំណាកស្រុក ការផ្តល់ការបណ្តុះបណ្តាលមុនពេលចេញដំណើរ ការផ្តល់យន្តការដោះស្រាយវិវាទ ការការពារសេរីភាពក្នុងការធ្វើដំណើរ ការគោរពតាមច្បាប់ពាក់ព័ន្ធទាំងអស់ និងការការពារសិទ្ធិរបស់ពលករ។ ទោះជាយ៉ាងនេះក្តី ក្រមប្រតិបត្តិនេះ គឺក្រមមានលក្ខណៈស្ម័គ្រចិត្ត និងពុំមានចងភ្ជាប់កាតព្វកិច្ចនោះទេ ព្រមទាំងមានវឌ្ឍនភាពតិចតួចក្នុងការដាក់ឱ្យអនុវត្ត ចាប់តាំងពីបានដាក់ចេញឱ្យប្រើប្រាស់មក។ ទោះជាយ៉ាងនេះក្តី ប្រការនេះទំនងជាការរារាំងដោយដាក់កម្រិតការជ្រើសរើសចំនួនពលករទាបក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា និងអង្គការពលកម្មអន្តរជាតិ (ILO) គឺកំពុងស្ថិតក្នុងដំណើរការនៃការអភិវឌ្ឍយន្តការមួយដើម្បីត្រួតពិនិត្យលើការអនុវត្តការងាររបស់សមាជិក ដើម្បីធានាឱ្យបាននូវការប្រកាន់ខ្ជាប់តាមក្របខណ្ឌច្បាប់ និងក្រមប្រតិបត្តិ។

សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានលើកឡើងថា សមាគមកំពុងចាត់វិធានការលើកកម្ពស់ស្វ័យនិយ័តកម្មក្នុងវិស័យ រួមមានៈ

- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ធ្វើការងារជាមួយសមាជិករបស់ខ្លួន និងអង្គការ ILO ដើម្បីលើកទឹកចិត្តឱ្យមានការពុំគិតថ្លៃសេវាសម្រាប់ពលករចំណាកស្រុក ដែលហៅម្យ៉ាងទៀតថា "គោលការណ៍និយោជកចេញថ្លៃចំណាយ"។
- ការជំរុញឱ្យសមាជិកផ្តល់យន្តការបណ្តឹងតវ៉ារឹងមាំ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងស្តីពីការកេងប្រវ័ញ្ច ឬភាពខុសច្បាប់ក្នុងការផ្តល់ការងារដល់ពលករ។
- ការឆ្លើយតបទៅនឹងការប្រព្រឹត្តខុសឆ្គងរបស់សមាជិកតាមរយៈ៖ (១) ការព្រមាន (២) ការជូនដំណឹងដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យព្យួរវិញ្ញាបនបត្រ និង (៣) ការបញ្ចប់សមាជិកភាព។
- រៀបចំវគ្គបណ្តុះបណ្តាលសមាជិកពីរដងក្នុងមួយឆ្នាំអំពីច្បាប់ គោលនយោបាយ និងដំណើរការស្តីពីការជ្រើសរើសពលករ និងការការពារពលករចំណាកស្រុក។
- ធ្វើការងារជាមួយអង្គការ ILO ដើម្បីអភិវឌ្ឍកម្មវិធីទូរស័ព្ទមួយសម្រាប់ឱ្យពលករចំណាកស្រុកទទួលបានព័ត៌មាន និងស្នើសុំការគាំទ្រ។
- ធ្វើការងារជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអនុវត្តអធិការកិច្ចច្បាស់លាស់ និងចៃដន្យទៅលើក្រុមហ៊ុនសមាជិក ដើម្បីធានាបាននូវការលើកលែងថ្លៃសេវាបន្ថែមលើពលករ និងថ្លៃសេវាទាំងនេះសមស្របតាមក្របខណ្ឌកិច្ចសន្យា។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ទីភ្នាក់ងារជ្រើសរើសពលករស្តីពីការអនុវត្តការជ្រើសរើសពលករប្រកបដោយសីលធម៌ និងការការពារសិទ្ធិរបស់ពលករចំណាកស្រុក។
- អនុវត្តការត្រួតពិនិត្យនៅទីតាំងធ្វើការរបស់ពលករចំណាកស្រុកនៅប្រទេសគោលដៅ ដោយសហការជាមួយការិយាល័យពលករនៃស្ថានទូតកម្ពុជា។
- ការរៀនឆ្លើយតបនឹងបណ្តឹងរបស់ពលករតាមរយៈការផ្តល់នូវការគាំទ្រផ្លូវច្បាប់ និងការព្យាយាមសម្រុះសម្រួលជាមួយនិយោជក ដោយសហការជាមួយការិយាល័យពលករនៅស្ថានទូត (ជាជាងការបន្តទៅដោះស្រាយតាមនីតិវិធីផ្លូវច្បាប់)។

កាលពីពេលថ្មីៗកន្លងទៅនេះ មានការលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាកំពុងចាប់អារម្មណ៍លើការដាក់កម្រិតលើថ្លៃសេវាជ្រើសរើសពលករ ដូចបានអនុវត្តក្នុងប្រទេសមីយ៉ាន់ម៉ា។ ប្រការនេះ បញ្ឈប់គំរូ "និយោជកចេញថ្លៃចំណាយ" ប៉ុន្តែអាចនឹងមានភាពជាក់ស្តែងជាងនេះនៅក្នុងបរិបទបច្ចុប្បន្ន ដែលអ្នកជ្រើសរើសពលករពុំគិតថ្លៃសេវាពីពលករទំនងជាគ្មានគំរូអាជីវកម្មដែលអាចស្វែងរកប្រាក់ចំណេញបាននោះទេ។ ទោះជាយ៉ាងនេះក្តី សម្ភាសន៍ពុំបានបង្ហាញអំពីផែនការណាមួយចំពោះចំណាប់អារម្មណ៍នេះនៅឡើយទេ ស្របពេលដែលអ្នកជ្រើសរើសពលករអាចនឹងស្វាគមន៍ចំពោះការផ្លាស់ប្តូរ ការតាមដានត្រួតពិនិត្យអ្នកជ្រើសរើសពលករ គឺជាគំនិតផ្តួចផ្តើមសំខាន់មួយដែលត្រូវសហការគ្នាអនុវត្ត។

ទោះជាយ៉ាងណាក៏ដោយ ស្វ័យនិយ័តកម្មក្នុងវិស័យ គឺនៅពុំទាន់បានបំលែងទៅជាមុខងារត្រួតពិនិត្យសំខាន់អ្វីនៅឡើយនោះទេ ហើយក្តីបារម្ភនានាត្រូវបានលើកឡើងដែរអំពីវិសាលភាពដែលសមាគមអ្នកជ្រើសរើសពលករតំណាងឱ្យផលប្រយោជន៍នៃសមាជិកទាំងអស់ ដែលផ្ទុយទៅនឹងទីភ្នាក់ងារធំៗដែលបានចូលរួមនៅក្នុងការគ្រប់គ្រងសមាគម។ ពលករចំណាកស្រុកមានការលំបាកក្នុងការទាក់ទងភ្នាក់ងារជ្រើសរើសពលករ នៅពេលដែលពួកគេត្រូវការការគាំទ្រពីក្រៅប្រទេស និងពលករជាច្រើនពុំដឹងអំពីយន្តការបណ្តឹងតវ៉ា ឬយន្តការគាំទ្រក្នុងវិស័យជាក់លាក់ណាមួយនោះទេ។ ស្ថាប័នឧស្សាហកម្មនៅតែបន្តទុកឱ្យសមាជិកម្នាក់ៗឆ្លើយតបនឹងករណីរបស់ពលករម្នាក់ៗតាមដែលពួកគេយល់ឃើញថាសមស្រប និងមានការបង្ហំតិចតួចប៉ុណ្ណោះក្នុងការផ្តល់ការគាំទ្រដែលប្រសើរជាងនេះ។ ទន្ទឹមនឹងនេះ ស្ថាប័នឧស្សាហកម្មបានលើកឡើងថា ពួកគេបានទទួលពាក្យបណ្តឹងតិចតួចបំផុតពីពលករចំណាកស្រុកពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចនៅកន្លែងការងារឬការជួញ

ផ្លូវ និងពួកគេពុំទទួលបានពាក្យបណ្តឹងអំពីការឆបោកពីសំណាក់ភ្នាក់ងារជ្រើសរើសពលករនោះឡើយ។ ប្រការនេះបានបង្ហាញឱ្យឃើញថាបណ្តាញទាំងនេះ គឺពុំបានផ្តល់ជូន ឬប្រើប្រាស់ឱ្យបានទូលំទូលាយនោះទេ។

ជារួម ការតាមដានត្រួតពិនិត្យលើភ្នាក់ងារជ្រើសរើសពលករ គឺពុំបានអនុវត្តជាញឹកញាប់នោះទេ និងនៅមានកម្រិតនៅឡើយ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា ក្រសួងបានទទួលពាក្យបណ្តឹងពីពលករនៅតាមការិយាល័យរបស់ខ្លួននៅថ្នាក់ខេត្តដើម្បីដោះស្រាយ ប៉ុន្តែវិធានការណ៍នេះពុំត្រូវបានប្រើប្រាស់ ឬផ្សព្វផ្សាយឱ្យបានទូលំទូលាយជាសាធារណៈនោះទេ។ បើទោះបីជាក្តីបារម្ភច្រើនស្តីពីតួនាទីរបស់អ្នកជ្រើសរើសពលករកាលពីឆ្នាំកន្លងទៅក្តី ក៏នៅតែពុំមានវិធានការធំដុំណាមួយត្រូវបានអនុវត្តចំពោះទីភ្នាក់ងារជ្រើសរើសពលករនីមួយៗនៅឡើយទេ។

## ៥.១.៤ ការតាមដានត្រួតពិនិត្យវិស័យមីក្រូហិរញ្ញវត្ថុ

បច្ចុប្បន្ន មានការសិក្សារបស់បណ្ឌិតសភា និងបណ្តាសង្គមស៊ីវិលជាច្រើនស្តីពីផលប៉ះពាល់នៃឥណទានរបស់មីក្រូហិរញ្ញវត្ថុ (MFI) មកលើប្រជាពលរដ្ឋកម្ពុជា ដែលបានបង្ហាញថា ឥណទាននេះ គឺជាកត្តាជំរុញមួយដែលនាំឱ្យមានចំណាកស្រុកការងារ ការបាត់បង់ដីធ្លី និងសម្ពាធលើជីវភាពរស់នៅ។[២០] នៅក្នុងការសិក្សាមួយ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា គ្រួសារចន្លោះពី ២៥% ទៅ ៥០% នៃគ្រួសារជាប់បំណុលសរុបចំនួន ២.៨ លានគ្រួសារនៅកម្ពុជា គឺជំពាក់បំណុលលើសកម្រិតស្របពេលដែលកម្ពុជាត្រូវបានរាយការណ៍ថា ជាប្រទេសមួយក្នុងចំណោមប្រទេសក្នុងពិភពលោកដែលមានអនុបាតឥណទានធៀបទៅនឹងផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ខ្ពស់បំផុត។ ប្រការនេះ មានន័យថា បុគ្គលម្នាក់ៗជារឿយៗមានជួបបទពិសោធន៍ទំហំឥណទានមានលក្ខណៈខ្ពស់ជាងប្រាក់ចំណូលដោយឡែកៗពីគ្នា។

លើសពីនេះ បំណុល និងចំណាកស្រុក គឺមានទំនាក់ទំនងយ៉ាងច្បាស់ ដោយពលរដ្ឋកម្ពុជាច្រើននាក់បានខ្ចីបុលគេ ដើម្បីរ៉ាប់រងលើការចំណាយធ្វើចំណាកស្រុក ឬធ្វើចំណាកស្រុក ក្នុងគោលបំណងរកលុយមកសងបំណុល។[២១] ការសិក្សាជាច្រើនបានបង្ហាញថា ក្នុងការអនុវត្តជាក់ស្តែង មន្ត្រីឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាទូទៅបានធ្វើដំណើរតាមភូមិនៅជនបទ ដោយព្យាយាមប្រមូលបំណុល និងចេញឥណទានថ្មីៗ។ ក្នុងនោះ មានករណីជាច្រើនដែលគ្រួសារមួយអាចទទួលបានឥណទានក្នុងកម្រិតខ្ពស់តាមរយៈការបញ្ជូនកូនឱ្យទៅធ្វើការងារនៅក្រៅប្រទេស។ ករណីផ្សេងទៀតគឺថាសមាជិកគ្រួសាររងសម្ពាធដែលត្រូវបញ្ជូនកូនៗឱ្យធ្វើការងារនៅក្រៅប្រទេសដើម្បីរកលុយមកសងបំណុល។ មន្ត្រីឥណទានទទួលបានប្រាក់រង្វាន់លើកទឹកចិត្ត ដើម្បីជំរុញឱ្យពួកគេផ្តល់ឥណទានកាន់តែច្រើន ដូច្នេះបើទោះបីជាវិធីសាស្ត្រសម្ពាធទាំងនេះពុំត្រូវបានអនុម័តជាផ្លូវការក្តី ក៏ពួកគេទទួលបានការលើកទឹកចិត្តឱ្យអនុវត្តដែរ។

> "យើងធ្វើការងារជាមួយពលករចំណាកស្រុក។ ពួកគេបាននិយាយថា ពួកគេធ្វើចំណាកស្រុកដោយសារតែពួកគេពុំអាចរកប្រាក់ដើម្បីសងបំណុលបាន។"

**អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល**

បំណុល គឺពុំត្រឹមតែជាកត្តាជំរុញមួយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្កើននូវការពឹងផ្អែកលើនិយោជក និងការងារថ្មីរបស់របស់ពលករចំណាកស្រុកទៀតផង ដែលកត្តានេះធ្វើឱ្យពួកគេមានជម្រើសតិចតួច ប្រសិនបើពួកគេជួបប្រទះនឹងស្ថានភាពការងារមានការកេងប្រវ័ញ្ច។ ពលករចំណាកស្រុកនៅទឹកដីថៃ គឺត្រូវបានគេបង្ខំឱ្យបន្តធ្វើការងារ ដើម្បីធានាថាពួកគេបំពេញទៅតាមការទូទាត់សងបំណុល និងរក្សាប្លង់ដីរបស់ពួកគេ។ ដូច្នេះ វាជាការចាំបាច់ក្នុងការបង្កើននិយ័តកម្មលើវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីរារាំងឥរិយាបថដែលជំរុញមនុស្សឱ្យធ្វើចំណាកស្រុកទាំងប្រថុយប្រថាន ដែលអាចរួមចំណែកដល់ការសាយភាយពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។

អ្នកផ្តល់ព័ត៌មានសំខាន់ៗបានលើលឡើងថា ស្ថាប័នវិស័យពាក់ព័ន្ធនានា រួមមាន សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និង សមាគមធនាគារនៅកម្ពុជា (ABC) គឺកំពុងព្យាយាមកែលម្អប្រតិបត្តិការរបស់ខ្លួនតាមរយៈស្វ័យនិយ័តកម្ម។ ជាដំបូងសមាគមបានដាក់ចេញក្រមប្រតិបត្តិស្វ័យនិយ័តកម្មសម្រាប់អ្នកផ្តល់កម្ចីនៅឆ្នាំ ២០២២។[២២] ទី២ និយោជិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ បច្ចុប្បន្ន គឺតម្រូវឱ្យឆ្លងកាត់ការបណ្តុះបណ្តាលស្តីពីការផ្តល់កម្ចីប្រកបដោយក្រមសីលធម៌ ដើម្បីទទួលបានវិញ្ញាបនបត្រដែលបញ្ជាក់ថាអាចបំពេញការងារបាន។ ចុងក្រោយ វិស័យនេះ គឺកំពុងមានការវិនិយោគច្រើនទៅលើការបណ្តុះបណ្តាលស្តីពីចំណេះដឹងហិរញ្ញវត្ថុសម្រាប់អតិថិជនកម្ចីប្រាក់។ ទោះបីជាមានអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា គំនិតផ្តួចផ្តើមទាំងនេះនៅពុំទាន់ដឹងច្បាស់ថាមានការលើកទឹកចិត្តដល់អ្នកផ្តល់ព័ត៌មានផ្សេងទៀតឬមួយយ៉ាងណានោះទេ ដោយចង្អុលបង្ហាញអំពីការពិតដែលថាវិធានការទាំងនេះ គឺទំនងជាពុំដំណើរការ ពុំទាន់បានអនុវត្ត និងពុំចងភ្ជាប់កាតព្វកិច្ចនៅឡើយទេ។ កម្ចីខ្នាតតូច ជាអាជីវកម្មដែលនៅតែផ្តល់ផលចំណេញច្រើនដដែល ហើយបំណុលវិញក៏នៅបន្តជាកត្តាជំរុញសំខាន់នៃការធ្វើចំណាកស្រុកទាំងប្រថុយប្រថាន ដោយពុំមានការតាមដានត្រួតពិនិត្យម៉ត់ចត់ទៅលើវិស័យ និងការផ្លាស់ប្តូររចនាសម្ព័ន្ធ។



## ៥.២ ការស៊ើបអង្កេតពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

ផ្នែកនេះ ផ្ដោតលើដំណើរការស៊ើបអង្កេតពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស រួមទាំង បញ្ហាប្រឈមដែលមានស្រាប់ និងកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមទាំងនេះ។

### ៥.២.១ ការឆ្លើយតបរហ័សទៅនឹងបណ្ដឹង និងការរាយការណ៍

ជាទូទៅ អ្នកឆ្លើយតបសម្ភាសន៍បានលើកឡើងថា អាជ្ញាធរបានឆ្លើយតបរហ័សទៅនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ហើយជាវិធានការឆ្លើយតបបែបប្រតិកម្មជាជាងបែបបង្ការ។ ទោះជាយ៉ាងនេះក្ដី អាជ្ញាធរបានបង្ហាញពីភាពស្ទាក់ស្ទើររបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការរាយការណ៍អំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ អ្នកផ្ដល់ព័ត៌មានក៏បានលើកឡើងថា នៅកម្រិតមូលដ្ឋាន អាជ្ញាធរអាចបដិសេធពុំចាប់ខ្លួន និងផ្ដន្ទាទោសបុគ្គលក្នុងមូលដ្ឋានដែលមានឥទ្ធិពល ដូចជា ម្ចាស់អាជីវកម្មលេចធ្លោ និងអ្នកមានឥទ្ធិពលនយោបាយដោយខ្លាចរអានឹងផលវិបាកផ្សេងៗ។
ស្រដៀងគ្នានេះដែរ នៅពេលស៊ើបអង្កេតជាបឋមដោយដាក់គោលដៅលើបុគ្គលដែលលេចធ្លោ សំណុំរឿងនោះជារឿយៗគឺត្រូវបានដោះស្រាយដោយប្រើលុយកាក់ ឬការបង្ខិតបង្ខំផ្សេងៗ។

ផ្នែកមួយ ដែលអាជ្ញាធរបានបង្ហាញពីភាពស្ទាក់ស្ទើរក្នុងការស៊ើបអង្កេត គឺវិស័យឡូតដ្ឋ។ របាយការណ៍លម្អិត បានបង្ហាញពីការកើតឡើងនៃចំណងបំណុលក្នុងវិស័យនេះរយៈពេល ៥ ឆ្នាំ កន្លងមក។[២៣] ទោះជាយ៉ាងនេះក្ដី យោងតាមរបាយការណ៍ស្ដីពីការជួញដូរមនុស្សសហរដ្ឋអាមេរិក ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បន្តបដិសេធលើរឿងរ៉ាវដែលកើតឡើងពាក់ព័ន្ធនឹងពលកម្មកុមារ និងចំណងបំណុលក្នុងឧស្សាហកម្មឥដ្ឋ។ នគរបាលដែលបានសម្ភាស៍បានចាត់ទុកថាការងារនេះគឺជាភារកិច្ចរបស់អធិការការងារក្នុងការកំណត់រកបញ្ហាក្នុងវិស័យនេះ និងបញ្ជូនករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សណាមួយទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលកត្តានេះបានបង្ហាញពីការបដិសេធចំពោះដែនយុត្តាធិការត្រួតគ្នារវាងនគរបាល និង ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ នគរបាលក៏បានលើកឡើងដែរថា អង្គការមិនមែនរដ្ឋាភិបាលគួរតែធ្វើកិច្ចការងារច្រើនជាងនេះដើម្បីបង្ការការងារពលកម្មក្នុងឧស្សាហកម្មឡូតដ្ឋ។

អាជ្ញាធរ ជារឿយៗក៏មានប្រតិកម្មទៅនឹងរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ និងការស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលដែលបានផ្សព្វផ្សាយពីករណីកម្រិតខ្ពស់ និងសម្ពាធពីសាធារណជន តួយ៉ាងដូចជា ករណីពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា កាស៊ីណូអនឡាញ និង ការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត។ ហេតុការណ៍នៃការជួញដូរជាច្រើន ត្រូវបានគូសបញ្ជាក់ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមក ដែលជនបរទេសត្រូវបានគេបោកបញ្ឆោតមកកាន់កម្ពុជា ដោយសន្យាថានឹងផ្ដល់ការងារក្លែងក្លាយ និងជាបន្តបន្ទាប់បានគេបង្ខំឱ្យពួកគេស្នាក់ក្នុងបរិវេណអគារ និងប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត។ របាយការណ៍ស៊ើបអង្កេតសំខាន់មួយស្ដីពីប្រធានបទនេះ បានផ្សព្វផ្សាយក្នុងសារព័ត៌មាន Al Jazeera កាលពីខែកក្កដា ឆ្នាំ ២០២២។[២៤] នៅខែសីហា មានការចំណាយធនធានយ៉ាងច្រើនទៅលើការស៊ើបអង្កេតទីតាំងសង្ស័យផ្សេងៗ។ មុនពេលសកម្មភាពនេះ ភាគីពាក់ព័ន្ធត្រូវបានចោទសួរសំណួរថាតើសំណាក់អាជ្ញាធរមួយចំនួនធ្លាប់ស្ទាក់ស្ទើរស្រដៀងគ្នាដែរឬទេក្នុងការស្វែងរកករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងកំណត់អត្តសញ្ញាណជនល្មើសដែលទទួលខុសត្រូវ ដោយសារតែមានបុគ្គលមានឥទ្ធិពលនៅក្នុងវិស័យ។[២៥]

## ៥.២.២ ដំណើរការនៃការស៊ើបអង្កេតពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

ជាដំបូង ការស៊ើបអង្កេត ត្រូវបានអនុវត្តដោយនគរបាលក្នុងមូលដ្ឋាន។ ការស៊ើបអង្កេតនេះ ជាទូទៅ រួមបញ្ចូលសម្ភាសន៍ជនរងគ្រោះ និងសាក្សី ព្រមទាំងការប្រមូលភស្តុតាងសំខាន់ៗ។ ការស៊ើបអង្កេតសំណុំរឿង និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវបានអនុវត្តរួមគ្នា ដូច្នេះនគរបាលនឹងអនុវត្តតាមគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពាក់ព័ន្ធ ក្នុងអំឡុងពេលសម្ភាសន៍ជនរងគ្រោះ។

"ចំពោះការស៊ើបអង្កេតវិញ យើងមានបញ្ជីត្រួតពិនិត្យធាតុដែលត្រូវរួមបញ្ចូលជាករណីជួញដូរមនុស្ស។ យើងគ្រាន់តែអនុវត្តតាមបញ្ជីត្រួតពិនិត្យនេះ ដូច្នេះយើងនឹងពុំបង្កើតកំហុសអ្វីនោះទេ។"

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

តាមការអនុវត្តជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលជារឿយៗអនុវត្តការស៊ើបអង្កេតបឋមមួយចំនួនតាមរយៈការប្រមូលព័ត៌មាន និងសម្ភាសន៍ជនរងគ្រោះ បន្ទាប់ពីជនរងគ្រោះបានរាយការណ៍ដោយផ្ទាល់ទៅកាន់អង្គការមិនមែនរដ្ឋាភិបាល។ បន្ទាប់មក អង្គការមិនមែនរដ្ឋាភិបាលបញ្ជូនសំណុំរឿង និងឯកសារពាក់ព័ន្ធទៅដល់នគរបាល។

ពេលករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សបានបង្ហាញពីភស្តុតាងជាក់ស្តែង សំណុំរឿងនេះនឹងត្រូវរាយការណ៍ទៅដល់នគរបាលយុត្តិធម៌ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅរាជធានីភ្នំពេញ។ នគរបាលយុត្តិធម៌ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នឹងដឹកនាំការស៊ើបអង្កេត និងដឹកនាំនគរបាលមូលដ្ឋាននៅក្នុងការប្រមូលភស្តុតាងបន្ថែម។ បន្ទាប់ពីកសាងសំណុំរឿងបឋមរួចហើយ នគរបាលមូលដ្ឋាន នឹងបញ្ជូនសំណុំរឿងទៅកាន់នគរបាលយុត្តិធម៌ ដើម្បីត្រួតពិនិត្យ និងសម្រេចលើជំហានបន្ទាប់។

ប្រសិនបើករណីនេះជាករណីជាក់ស្តែង នគរបាលយុត្តិធម៌នឹងបញ្ជូនសំណុំរឿងនេះទៅកាន់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអនុវត្តតាមគោលការណ៍ណែនាំស្តីពីការស៊ើបអង្កេតសម្រាប់ព្រះរាជអាជ្ញារបស់ក្រសួងមហាផ្ទៃ។ នៅដំណាក់កាលនេះ ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌ និងនគរបាលមូលដ្ឋាន គឺទំនងជាសហការគ្នាក្នុងការចុះប្រមូលភស្តុតាងបន្ថែម និងស៊ើបអង្កេត។ ជារឿយៗ ដំណាក់កាលនេះនឹងរួមបញ្ចូលការចេញដីកា និងការចាប់ខ្លួនជនសង្ស័យ។

ប្រសិនបើឧក្រិដ្ឋកម្មនេះកំពុងបន្ត និងពាក់ព័ន្ធនឹងការជួយសង្គ្រោះ ដំណាក់កាលនេះហៅថា បេសកកម្ម "បង្ក្រាប"។ ក្នុងកាលៈទេសៈទាំងនេះ នគរបាលផ្តោតការយកចិត្តទុកដាក់លើការបង្ក្រាបអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះ។ យោងតាមមន្ត្រីរដ្ឋាភិបាល ករណីប្រមាណជាង ៣០០ ករណី គឺត្រូវបានបង្ក្រាបកាលពីឆ្នាំកន្លងទៅ។

ចំពោះបេសកកម្មចុះបង្ក្រាប គឺអាស្រ័យលើប្រភេទនៃបទល្មើស។ យើងចាំបាច់ត្រូវតែធ្វើការបង្ក្រាបឱ្យបានត្រឹមត្រូវ និងផ្អែកលើមូលដ្ឋានច្បាប់។ យើងវាយតម្លៃ និងរាយការណ៍ជូនដល់គណៈគ្រប់គ្រងផ្ទាល់របស់យើង ដើម្បីសុំដំបូន្មាន និងការណែនាំអំពីជំហានបន្ទាប់។ ប្រសិនបើចាំបាច់ យើងនឹងស្នើសុំការណែនាំពីព្រះរាជអាជ្ញា ឱ្យចេញដីកាដើម្បីចាប់ខ្លួន ឬឃាត់ខ្លួនជនសង្ស័យ។ – នគរបាលខេត្ត

នគរបាលយុត្តិធម៌ មានសិទ្ធិអំណាចក្នុងការសរសេររបាយការណ៍សំណុំរឿងផ្លូវការ ប៉ុន្តែមិនចាត់ប្រភេទបទល្មើសឡើយ ដែលការចាត់ថ្នាក់បទល្មើសនេះ គឺជាការងាររបស់ព្រះរាជអាជ្ញា។ នគរបាលយុត្តិធម៌ នឹងផ្តល់អនុសាសន៍នៅក្នុងសំណុំរឿងភាគច្រើន។ បន្ទាប់ពីការស៊ើបអង្កេត ព្រះរាជអាជ្ញានឹងពិចារណាលើសំណុំរឿងទាំងនោះ។ ព្រះរាជអាជ្ញានឹងវាយតម្លៃ

សំណុំរឿងដែលបានកសាងឡើងគ្រប់គ្រាន់ និងមានភស្តុតាងគ្រប់គ្រាន់ ព្រមទាំងអាចឱ្យដំណើរការនីតិវិធីសំណុំរឿង និងជ្រើសរើសបទចោទប្រកាន់។ ពួកគេអាចធ្វើការងារជាមួយនគរបាល ដើម្បីប្រមូលភស្តុតាងបន្ថែមតាមការចាំបាច់ មុនពេលបញ្ជូនសំណុំរឿងទៅតុលាការ។

យើងចាំបាច់ត្រូវរក្សាតុល្យភាពរវាងកម្រិតនៃបទល្មើសដែលជនល្មើសបានប្រព្រឹត្ត។ យើងត្រូវវាយតម្លៃចំណុចនេះ។ យើងក៏ត្រូវពិចារណាផងដែរថាតើត្រូវបង្ហាញសំណុំរឿងនេះដល់សាធារណជនដែរឬទេ។ តើការបើកចំហសំណុំរឿងនេះជួយកាត់បន្ថយចំនួនឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដែរឬទេ? យើងចាំបាច់ត្រូវតែពិចារណាលើចំណុចទាំងនេះ។ ព្រះរាជអាជ្ញា ចៅក្រម មានតួនាទីវាយតម្លៃអង្គហេតុនៃសំណុំរឿងស្របតាមច្បាប់ និងថាតើមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្កើតអង្គហេតុចោទប្រកាន់នៃសំណុំរឿងនេះដែរឬទេ។ ព្រះរាជអាជ្ញា និងតុលាការ អាចអនុវត្តការសម្ភាសន៍បន្ថែមជាមួយជនរងគ្រោះ និងសាក្សី ដើម្បីស្វែងរកព័ត៌មានបន្ថែមមុនពេលអនុវត្តការជំនុំជម្រះ និងធ្វើសេចក្តីសម្រេច។ ទោះជាយ៉ាងនេះក្តី អ្នកអង្កេតការណ៍កត់សម្គាល់ឃើញថា តុលាការអាចរួសរាន់ធ្វើការស៊ើបអង្កេត និងពួកគេរំពឹងថាសំណុំរឿងនេះបានរៀបចំរួចរាល់អស់ហើយ។ ចំណុចនេះគូសបញ្ជាក់ដោយសម្រង់សម្តីខាងក្រោម និងបានពិភាក្សាបន្ថែមនៅក្នុងផ្នែក ៥.២.១០។

"សំណុំរឿង គឺនគរបាលជាអ្នកកសាង។ យើងគ្រាន់តែអញ្ជើញជនរងគ្រោះមកសួរនាំដើម្បីបំភ្លឺបន្ថែមតែប៉ុណ្ណោះ។"

ចៅក្រម

## ៥.២.៣ បញ្ហាប្រឈមក្នុងការស៊ើបអង្កេតពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

ទាំងនគរបាល និងអង្គការសង្គមស៊ីវិល បានលើកឡើងថា បញ្ហាប្រឈមសំខាន់ៗនៃការស៊ើបអង្កេត គឺជាការកំណត់អត្តសញ្ញាណ និងការកំណត់ទីតាំងជនល្មើស។ នៅក្នុងករណីជាច្រើន ជនល្មើសគឺពុំរស់នៅក្នុងបរិវេណក្បែរជនរងគ្រោះនោះទេ ហើយនគរបាលមានការលំបាកក្នុងការស្វែងរកជនល្មើស។

ករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សភាគច្រើន ពាក់ព័ន្ធនឹងជនរងគ្រោះដែលនៅក្រៅប្រទេស ដូច្នេះការស៊ើបអង្កេតរបស់នគរបាល ជារឿយៗផ្តោតលើការកសាងសំណុំរឿងប្រឆាំងនឹងមេខ្យល់ដំបូង ដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជា ជាជាងជនល្មើសចម្បងដែលមានទីតាំងនៅក្រៅប្រទេស។ ទោះបីជាយ៉ាងនេះក្តី មេខ្យល់ផ្ទាល់ គឺជួនកាលក៏ពិបាកក្នុងការស្វែងរកដែរ។

"សមត្ថភាពរបស់នគរបាល និងតុលាការ គឺនៅមានកម្រិតក្នុងការអនុវត្តដំណើរការសម្ភាស និងការប្រមូលទិន្នន័យ។ ឧទាហរណ៍ ពួកគេពុំអាចស្វែងរកមេខ្យល់ឃើញនោះទេ លុះត្រាតែមេខ្យល់នោះស្ថិតនៅក្នុងសហគមន៍របស់ពួកគេ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ដូច្នេះ សមាសធាតុ និងបញ្ហាប្រឈមសំខាន់មួយនៃការស៊ើបអង្កេតនេះ គឺជាការស៊ើបអង្កេតអំពីតួនាទីជាក់ស្តែងរបស់ជនល្មើសដែលបានចោទប្រកាន់នៅក្នុងការជួញដូរមនុស្ស។ នគរបាល បានរាយការណ៍ថា ការស៊ើបអង្កេតរបស់ពួកគេ ជាទូទៅចាប់ផ្តើមពីសមាជិកគ្រួសារ ដោយសារតែជាក់ស្តែង "មេខ្យល់" ជាច្រើន គឺជាសមាជិកគ្រួសារ ឬអ្នកជិតខាងដែល

ជួយពលករឱ្យទទួលបានការងារនៅក្រៅប្រទេស។ ស្របពេលជាមួយគ្នានេះ ប្រតិបត្តិការជួញដូរមនុស្សមានអង្គភាពចាត់តាំង ក៏អាចនឹងរួមបញ្ចូលទាំងសមាជិកគ្រួសារ និងប្រជាសហគមន៍ដែលទុកចិត្ត ដែលពួកគេល្បួងជនរងគ្រោះផងដែរ។

"នគរបាល គឺជាអ្នកសិក្សាសំណុំរឿង។ ឧទាហរណ៍ សេណារីយ៉ូ មានដូចជា៖ (១) បុគ្គលម្នាក់អាចនឹងត្រៀមខ្លួនរួចរាល់ក្នុងការចំណាកស្រុកដោយខ្លួនឯង (២) បុគ្គលម្នាក់ត្រូវគេបញ្ចុះបញ្ចូលឱ្យចំណាកស្រុក (៣) បុគ្គលម្នាក់បំពានកិច្ចសន្យា (៤) បុគ្គលម្នាក់ស្នើសុំឱ្យនរណាម្នាក់ទៅជាមួយ ដើម្បីស្វែងរកឱកាសការងារ។ សេណារីយ៉ូទាំងអស់នេះ គឺជាចំណាកស្រុកដែលមានការព្រមព្រៀង។ ប្រការនេះ គឺពុំមែនជាការជួញដូរមនុស្សនោះឡើយ។"

ព្រះរាជអាជ្ញា

ក្នុងករណីជាច្រើន នគរបាលយល់ដឹងអំពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស តាមរយៈទស្សនៈរបស់សន្តិសុខព្រំដែន និងស្ថានភាពផ្លូវច្បាប់នៃចំណាកស្រុក។ ចំណុចនេះ ដាក់ការសង្កត់ធ្ងន់លើថាតើពលករបានអនុវត្តតាមបណ្តាញចំណាកស្រុកដែលបានចុះអនុស្សារណៈនៃការយោគយល់ដែរឬទេ ដែលមិនមែនជាសូចនាករពិសេសនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ លំនាំនេះ គឺមិនសមស្របសម្រាប់ការសម្រិតសម្រាំងយកព័ត៌មានពាក់ព័ន្ធនឹងករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សនោះទេ៖

"នៅពេលយើងចុះទីតាំងផ្ទាល់ យើងមើលឃើញតែករណីចំណាកស្រុកខុសច្បាប់ប៉ុណ្ណោះ ពុំមែនជាការជួញដូរមនុស្សនោះឡើយ។"

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

នគរបាលមូលដ្ឋាន ក៏ពុំមានការយល់ដឹងច្បាស់លាស់អំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សដែរសូចនាករស្តីពីពលកម្មដោយបង្ខំ និងភាពបិទបាំងនៃពលកម្មដោយបង្ខំពាក់ព័ន្ធនឹងបំណុលនោះទេ។ ដោយសារតែបំណុល ជាសមាសធាតុបង្កិតសំខាន់នៃការរំលោភបំពានពលកម្មចំពោះពលករចំណាកស្រុកកម្ពុជានៅក្នុងប្រទេសថៃ ប្រការនេះដាក់កម្រិតទៅលើវិធីសាស្ត្រស៊ើបអង្កេតដែលនគរបាលអនុវត្ត។ នគរបាលមូលដ្ឋាន មានការយល់ដឹងមានកម្រិតអំពីពលកម្មដោយបង្ខំនៅក្នុងប្រទេសថៃជាក់ស្តែង (ជាបញ្ហាប្រឈមសម្រាប់អាជ្ញាធរថៃផងដែរ)។

"ចំពោះយើង ពលកម្មដោយបង្ខំគឺសំដៅជាចម្បងលើការធ្វើការងារលើទូកនេសាទ។ ពលករជាទូទៅគឺត្រូវបានដាក់ឱ្យធ្វើការនៅលើទូកនេសាទ។"

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

កាលពីពេលថ្មីៗកន្លងទៅនេះ មេខ្យល់ និង អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស មានការយល់ដឹងកាន់តែច្រើនអំពីលក្ខណៈបច្ចេកទេសផ្នែកច្បាប់ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ជាលទ្ធផល វិធីសាស្ត្រសម្របសម្រួលការធ្វើដំណើរ និងការទំនាក់ទំនង គឺមានការវិវត្តន៍។ ភាគច្រើន ប្រការនេះ មានន័យថា ជាការប្រាស្រ័យទាក់ទងលើអ៊ីនធឺណិត និងការរៀបចំការធ្វើដំណើរ ជាជាងការអមដំណើរពលករដែលត្រូវធ្វើចំណាកស្រុក។ ជារួម កត្តានេះ គឺកាន់តែបង្កការលំបាកដល់នគរបាលក្នុងការស៊ើបអង្កេតករណី ស្របពេលដែលបង្កលក្ខណៈងាយស្រួលឱ្យជនល្មើសគេចវេសពីបទដ្ឋានផ្លូវច្បាប់។

"បច្ចុប្បន្ននេះ ឧក្រិដ្ឋជនបានអភិវឌ្ឍបច្ចេកទេស និងដំណើរការឧក្រិដ្ឋកម្មរបស់ពួកគេ។ ពួកគេរៀបចំឱ្យពលករធ្វើដំណើរដោយខ្លួនឯងទៅកាន់ចំណុចឆ្លងព្រំដែនខុសច្បាប់ និងឆ្លងដែនដោយខ្លួនឯងទៅកាន់ប្រទេសថៃ។ បន្ទាប់មក នឹងមានអ្នកមកទទួលពលករទាំងនោះ និងនាំយកពួកគេទៅធ្វើការនៅចម្ការ។"

ចៅក្រម

## ៥.២.៤ ជនរងគ្រោះមានបំណងរាយការណ៍

បញ្ហាប្រឈមសំខាន់មួយសម្រាប់ការស៊ើបអង្កេត គឺថាជនរងគ្រោះជារឿយៗពុំចង់រាយការណ៍អំពីករណី ឬប្តឹងផ្តល់លើមិត្តភក្តិ និងសាច់ញាតិនោះទេ។ នៅក្នុងករណីជាច្រើន មិត្តភក្តិ និងសាច់ញាតិទាំងនេះ សម្របសម្រួលដល់ការស្វែងរកការងារ ដោយមានកម្រិតកេងប្រវ័ញ្ច ចំណេះដឹង និងចេតនាខុសៗគ្នា។ ជារឿយៗ បុគ្គលទំនាក់ទំនងគឺគ្រាន់តែព្យាយាមជួយដល់អ្នកស្វែងរកការងារក្នុងការរកការងារធ្វើតាមមធ្យោបាយសាមញ្ញបំផុត ឬល្អបំផុតដែលពួកគេអាចផ្តល់ជូន។ នៅក្នុងករណីផ្សេងទៀត អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សដែលមានអង្គភាពចាត់តាំង អាចប្រើប្រាស់បុគ្គលទំនាក់ទំនងដែលទុកចិត្តទាំងនេះ ឱ្យបញ្ចុះបញ្ចូលជនរងគ្រោះឱ្យធ្វើដំណើរទៅក្រៅប្រទេស ឬចាកចេញពីភូមិស្រុក។ ករណីទាំងនេះ បុគ្គលទំនាក់ទំនងអាចមានកម្រិតនៃការចូលរួម និងការយល់ដឹងខុសៗគ្នាអំពីស្ថានភាពកេងប្រវ័ញ្ច។ ករណីមួយចំនួនអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សកេងប្រវ័ញ្ច គឺជួញដូរជនរងគ្រោះដែលពួកគេស្គាល់។

ទោះជាយ៉ាងនេះក្តី នៅក្នុងករណីទាំងអស់នេះ ជនរងគ្រោះមានការស្ទាក់ស្ទើរក្នុងការប្តឹងចោទប្រកាន់។ ប្រការនេះ ជាទូទៅ គឺដោយសារទំនាក់ទំនងជាបន្តបន្ទាប់ ទំនុកចិត្ត និងការពឹងពាក់គ្នាទៅវិញទៅមករវាងជនរងគ្រោះ និងជនល្មើស ទោះបីជាមានករណីមួយចំនួនអាចមកពីការភ័យខ្លាចការធ្វើទុក្ខបុកម្នេញ៖

"បញ្ហាប្រឈមមួយក្នុងអំឡុងពេលសម្ភាសន៍ គឺជនរងគ្រោះធ្វើដំណើរទៅប្រទេសថៃតាមសាច់ញាតិរបស់ពួកគេ។ បន្ទាប់មក ក្នុងអំឡុងពេលសម្ភាសន៍នោះដែរ ចម្លើយរបស់ពួកគេបានបង្ហាញថា សាច់ញាតិរបស់ពួកគេជាមេខ្យល់។ ពួកគេបានភាន់ច្រលំ និងពុំចង់បន្តដំណើរការនីតិវិធីផ្លូវច្បាប់ទៀតនោះទេ ដោយសារតែសាច់ញាតិរបស់ពួកគេបានក្លាយពីជនរងគ្រោះទៅជាមេខ្យល់នៅចំណុចណាមួយ"។

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

មូលហេតុមួយទៀតសម្រាប់ការចូលរួមកម្រិតទាប គឺជនរងគ្រោះជារឿយៗ មានមន្ទិលសង្ស័យលើប្រព័ន្ធយុត្តិធម៌ និងពុំមានការជំរុញទឹកចិត្តឱ្យចូលរួម ដូច្នេះប្រការនេះបានដាក់កម្រិតទៅលើព័ត៌មានដែលពួកគេផ្តល់ជូន។ ពួកគេបានយល់ឃើញថា ដំណើរការតុលាការ គឺមានតម្លៃថ្លៃ ចំណាយពេលយូរ និងមានផលប្រយោជន៍តិចតួច។ អ្នកផ្តល់សម្ភាសន៍ជាច្រើនបាននិយាយថា ពួកគេមានអារម្មណ៍ថាប្រព័ន្ធយុត្តិធម៌ គឺមានផ្តល់ជូនតែសម្រាប់មនុស្សមានឥទ្ធិពលប៉ុណ្ណោះ។

"មន្ត្រីនគរបាលមានសមត្ថភាពក្នុងការស៊ើបអង្កេតសំណុំរឿង។ ប៉ុន្តែ ដំណើរការនៅដំណាក់កាលនគរបាល និងអាជ្ញាធរ គឺមានភាពស្មុគស្មាញ និងចាំបាច់ត្រូវមានឯកសារច្រើនពីគ្រួសារ និងជនរងគ្រោះបន្ទាប់ពីដាក់ពាក្យបណ្តឹងរួចរាល់ និងករណីមួយចំនួនចំណាយពេលយូរ ឬពុំដំណើរការបន្តដោយនគរបាល ដោយសារតែប្រធាននគរបាលពុំអនុម័តឱ្យបន្តនីតិវិធី និងករណីនេះពុំបានផ្តល់អត្ថប្រយោជន៍អ្វីដល់ពួកគេឡើយ។ ជួនកាល សហគមន៍ពុំចង់រាយការណ៍ទៅកាន់អាជ្ញាធរ និងនគរបាលដោយសារតែបញ្ហាបែបនេះ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

បញ្ហានេះ បានគូសបញ្ជាក់នៅក្នុងរបាយការណ៍របស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) នៅឆ្នាំ ២០១៦ និងយោងតាមអ្នកផ្តល់ព័ត៌មានការយល់ឃើញអំពីដំណើរការនីតិវិធីការតុលាការ គឺមានភាពល្អប្រសើរ។

"ទំនុកចិត្តក្នុងចំណោមសាធារណជនចំពោះដំណើរការនីតិវិធីតុលាការ ហាក់បីដូចជាមានលក្ខណៈល្អប្រសើរ។ ឧទាហរណ៍ ប្រជាជនធ្លាប់គិតថាប្រសិនបើគ្មានប្រាក់ ពួកគេពុំអាចទទួលបានយុត្តិធម៌ឡើយ ដូច្នេះពួកគេពុំដាក់ពាក្យបណ្តឹងនោះទេ។ ទោះជាយ៉ាងនេះក្តី ផ្នត់គំនិតបែបនេះហាក់បីដូចជាមានការកែលម្អប្រសើរជាងមុននាពេលបច្ចុប្បន្ន។ ពួកគេនឹងទៅរកនគរបាល និងដាក់ពាក្យបណ្តឹង។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

នគរបាល ក៏បាបបង្ហាញអំពីការខកចិត្តចំពោះករណីនានាដែលជនរងគ្រោះផ្តល់ព័ត៌មានពុំពិត ឬតាមទស្សនៈរបស់នគរបាល ជនរងគ្រោះបានរាយការណ៍ ដើម្បីសម្របសម្រួលឱ្យពួកគាត់ធ្វើមាតុភូមិនិវត្តន៍។ នគរបាលបានប្រាប់ថា ពេលវេលា និងធនធានច្រើនត្រូវបានចំណាយទៅលើករណីនានាដែលអ្នករាយការណ៍សម្រេចចិត្តថាពុំចូលរួម ដែលទោះជាយ៉ាងនេះក្តី មូលហេតុអំពីការពុំចូលរួម គឺនៅពុំទាន់ដឹងច្បាស់នៅឡើយ។

"ករណីមួយទៀតគឺថា ជនរងគ្រោះបាននិយាយថាគាត់នឹងសហការនៅពេលដែលគាត់មកដល់ផ្ទះនៅកម្ពុជាវិញ។ គាត់នឹងប្រាប់យើងថាអ្នកណាជាជនល្មើស។ ប៉ុន្តែ ពេលគាត់មកដល់ប្រទេសកំណើតវិញ គាត់បានប្រាប់ថាគាត់ពុំដឹងថាជនល្មើសនោះជាអ្នកណាទេ។"

អ្នកផ្តល់ព័ត៌មាននគរបាល

## ៥.២.៥ សម្ភាសន៍

កចសម្ភាសន៍ជនរងគ្រោះក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត គឺត្រូវបានគូសបញ្ជាក់ដោយភាគីពាក់ព័ន្ធទាំងអស់ថាជាចំណុចត្រូវកែលម្អ ដោយសារមូលហេតុមួយចំនួន។

ទី១ នីតិវិធីសម្ភាសន៍ខុសៗគ្នាមួយចំនួនត្រូវបានយកមកប្រើប្រាស់ ដែលបង្កើតបានជាការភាន់ច្រលំ និងប៉ះពាល់ដល់ការអនុវត្តការសម្ភាសន៍ស្តង់ដារ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអភិវឌ្ឍទម្រង់ស្តង់ដារចំនួន ២ សម្រាប់សម្ភាសន៍ជនរងគ្រោះមានឈ្មោះថា ទម្រង់សម្ភាសន៍ "ខ្លី" និងទម្រង់សម្ភាសន៍ "វែង ឬ "លម្អិត"។ គណៈកម្មាធិការ

ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាននិងកំពុងបណ្តុះបណ្តាលនគរបាលឱ្យប្រើប្រាស់ទម្រង់ទាំងនេះអស់រយៈពេល ៧ ឬ ៨ ឆ្នាំ មកហើយ។ បន្ទាប់មក មានទម្រង់សម្ភាសន៍ផ្សេងៗទៀតដែលប្រើប្រាស់ដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សេវាសង្គមកិច្ច និងព្រះរាជអាជ្ញា។ ទោះបីជាទម្រង់ជាច្រើនសួរសំណួរស្រដៀងគ្នាក៏ដោយ ក៏ទម្រង់ទាំងនេះ ពុំមានសង្គតិភាពនោះទេ។

ទី២ មានការរាយការណ៍ជាទូទៅថា ការសម្ភាសដែលយកចិត្តទុកដាក់លើជនរងគ្រោះ គឺកម្រនឹងអនុវត្តដោយនគរបាលស៊ើបអង្កេតណាស់។ ការសម្ភាសន៍នេះ មានឥទ្ធិពលរារាំងដល់ជនរងគ្រោះពីការចូលរួមនៅក្នុងប្រព័ន្ធយុត្តិធម៌ ស្របពេលដែលពង្រីកផលប៉ះពាល់ផ្លូវចិត្តពីការជួញដូរមនុស្ស។ វាជាការសំខាន់ណាស់ដែលត្រូវប្រព្រឹត្តចំពោះជនរងគ្រោះដោយយកចិត្តទុកដាក់នៅពេញមួយដំណើរការនៃការស៊ើបអង្កេតព្រហ្មទណ្ឌ។ ប្រការនេះ គឺជាបញ្ហាមួយដែលគូសបញ្ជាក់ដោយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងត្រូវបានណែនាំថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនគួររួមបញ្ចូលការអនុវត្តងាយស្រួលដល់ជនរងគ្រោះនៅក្នុងគោលការណ៍ណែនាំ និងការបណ្តុះបណ្តាលអំពីការសម្ភាសន៍។

"នគរបាលយុត្តិធម៌ ពុំប្រើប្រាស់វិធីសាស្រ្តផ្តោតលើជនរងគ្រោះនោះទេ។ ផ្ទុយទៅវិញ នគរបាលប្រើប្រាស់វិធីសាស្រ្តព្រហ្មទណ្ឌ ដោយពុំគិតអំពីសម្ភាសន៍ជនរងគ្រោះ និងជនល្មើសឡើយ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ទី៣ អ្នកឆ្លើយតបបានកត់សម្គាល់ថា នគរបាលពុំបានចូលរួមជាប្រចាំក្នុងសេវាសង្គមកិច្ច ក្នុងអំឡុងពេលសម្ភាសន៍ជនរងគ្រោះនោះទេ និងពុំបានផ្តល់ឱកាស និងគាំទ្រដល់ជនរងគ្រោះក្នុងអំឡុងពេលនៃដំណើរការស៊ើបអង្កេតឡើយ។

"... ពុំមានការអញ្ជើញមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ឬបុគ្គលិកសង្គមកិច្ចឱ្យចូលរួមឱ្យបានគ្រប់គ្រាន់នៅក្នុងអំឡុងពេលសម្ភាសន៍ជនរងគ្រោះ ដែលជនរងគ្រោះភាគច្រើន គឺជាកុមារ ទោះបីជាមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានព្យាយាមប្រើប្រាស់លិខិតមានស្រាប់ពីក្រសួងសង្គមកិច្ច ផ្ញើជូនស្នងការដ្ឋាននគរបាលជាតិក៏ដោយ។"

មន្ត្រីរដ្ឋាភិបាល

ទី៤ ជារឿយៗ មន្ត្រីនគរបាល គឺពុំមានវត្តមានគ្រប់គ្រាន់ក្នុងការរៀបចំសម្ភាសន៍នោះទេ។ ជាក់ស្តែង ទោះបីជាអត្ថប្រយោជន៍នៃការរួមបញ្ចូលនគរបាលស្ត្រីនៅក្នុងការសម្ភាសន៍ជនរងគ្រោះ គឺត្រូវបានបង្ហាញជាភស្តុតាងយ៉ាងច្បាស់លាស់ក៏ដោយ ជាពិសេសចំពោះស្ត្រី និងកុមារ នគរបាលស៊ើបអង្កេតមិនមានអារម្មណ៍ថា ការមានមន្ត្រីនគរបាលស្ត្រីគឺជាការសំខាន់នោះទេ ដរាបណាអនុវត្តតាមនីតិវិធីសីលធម៌។

ចុងក្រោយ ជនរងគ្រោះត្រូវឆ្លងកាត់ដំណើរការសម្ភាសន៍ដ៏ស្មុគស្មាញជាច្រើន ដែលអាចប៉ះទង្គិចផ្លូវចិត្ត និងអាចនាំឱ្យមានការផ្តល់ភស្តុតាងពុំបានល្អក្នុងអំឡុងពេលសម្ភាសន៍វិវត្តន៍ទៅមុខ។ អ្នកផ្តល់ព័ត៌មានមួយចំនួនបានណែនាំថា សម្ភាសន៍ជនរងគ្រោះមួយអាចធ្វើឡើងបានពេលចាប់ផ្តើមដំបូងជាមួយក្រុមអ្នកសម្ភាសន៍ពីទីភ្នាក់ងារខុសៗគ្នា។ សម្ភាសន៍បច្ចុប្បន្ន គឺពុំមានប្រសិទ្ធផលនោះទេ ប៉ុន្តែបានដើរតួជាឧបសគ្គរារាំងដល់ជនរងគ្រោះក្នុងការចូលរួមនៅក្នុងប្រព័ន្ធយុត្តិធម៌ទៅវិញ។

"ជនរងគ្រោះមួយចំនួន ត្រូវឆ្លងកាត់សម្ភាសន៍ខុសៗគ្នាចំនួន ១០ សម្រាប់សំណុំរឿងរករណីរបស់ពួកគេ។ ឧទាហរណ៍ ពេលដែលសំណុំរឿងត្រូវបានបញ្ជូនបន្តទៅកាន់អង្គការមិនមែនរដ្ឋាភិបាល អង្គការ អង្គការនោះ នឹងសម្ភាសជនរងគ្រោះ។ បន្ទាប់មក នគរបាលយុត្តិធម៌នឹងចាំបាច់ត្រូវសម្ភាសជនរងគ្រោះផងដែរ។ សម្ភាសន៍ធ្វើឡើងដោយនគរបាល គឺកំណត់អាទិភាព និងចាត់ថ្នាក់បទល្មើសជាជាងការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ជនរងគ្រោះក៏អាចនឹងត្រូវបានសាកសួរចម្លើយនៅសភាស៊ើបសួរផងដែរ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

## ៥.២.៦ សមត្ថភាពស៊ើបអង្កេត

ភាគីពាក់ព័ន្ធបានលើកឡើងថា សមត្ថភាពស៊ើបអង្កេតលើករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស គឺនៅមានកម្រិតទាបនៅឡើយនៅថ្នាក់មូលដ្ឋាន ដែលនគរបាលពុំបានចំណេះដឹង និងការបណ្តុះបណ្តាលជំនាញស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនោះទេ។ ទោះជាយ៉ាងនេះក្តី សមត្ថភាពស៊ើបអង្កេតគឺមានសម្រាប់តែតួនាទីជំនាញ ដូចជា នគរបាលប្រឆាំងការជួញដូរមនុស្ស ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ដែលជាអ្នកដឹងថាភស្តុតាងណាចាំបាច់ដើម្បីដំណើរការជំនុំជម្រះរឿងក្តី។

"នៅកម្រិតសហគមន៍ យើងមាននគរបាលទូទៅ ប៉ុន្តែពុំមែនជានគរបាលយុត្តិធម៌ដែលទទួលបាន ការបណ្តុះបណ្តាលនោះទេ។ ដូច្នេះ ចំណេះដឹង និងជំនាញរបស់ពួកគេនៅមានកម្រិតក្នុងការទទួលបានព័ត៌មានពីជនរងគ្រោះ ហើយផ្ទុយទៅវិញ នគរបាលយុត្តិធម៌ដែលទទួលបានការបណ្តុះបណ្តាល មានចំណេះដឹង និងជំនាញក្នុងការស៊ើបអង្កេត ដើម្បីទទួលបានការឆ្លើយតបស៊ីជម្រៅជាងនេះ គឺពុំមានវត្តមាននោះទេ។"

មន្ត្រីរដ្ឋាភិបាល

គុណភាពនៃការស៊ើបអង្កេតរបស់នគរបាលមូលដ្ឋាន ត្រូវបានលើកឡើងថាជាមានកង្វះខាតសមត្ថភាពពិសេស និងសមាជិកតុលាការបានលើកឡើងដែរថា ការស៊ើបអង្កេត គឺជារឿយៗខ្វះខាតការបង្ហាញច្បាស់លាស់ថាតើបញ្ហានេះជាករណីជួញដូរមែន ឬពុំមែន។ ដូចគ្នានេះដែរ ករណីពលកម្មដោយបង្ខំគឺពុំមានភាពច្បាស់លាស់នោះទេក្នុងការប្រៀបធៀបនឹងករណីជួញដូរមនុស្សផ្សេងទៀត ដែលត្រូវគ្នានឹងលំនាំជនរងគ្រោះ ជនល្មើសដែលនគរបាលបានដឹង។

"ចំណេះដឹងរបស់នគរបាល ដែលត្រូវធ្វើការងារកំណត់អត្តសញ្ញាណ គឺនៅមានកម្រិត។ ពេលដែលពួកគេពុំមានជំនាញ ពួកគេពុំអាចសរសេរ ឬផលិតរបាយការណ៍បានល្អត្រឹមត្រូវដែលអាចធ្វើឱ្យអ្នកដទៃជឿបានថាមានសំណុំរឿងសម្រាប់ការស៊ើបអង្កេតបន្តនោះទេ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

បច្ចុប្បន្ន សមត្ថភាពរបស់នគរបាលមូលដ្ឋាន និងនគរបាលយុត្តិធម៌នៅមានគម្លាតឆ្ងាយណាស់ មានន័យថា ពួកគេមានការលំបាកក្នុងការធ្វើការងារលើសំណុំរឿងក្តីជាមួយគ្នា។ នគរបាលមូលដ្ឋាន និងនគរបាលខេត្ត ជារឿយៗត្រូវពឹងផ្អែក

យ៉ាងខ្លាំងលើនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅរាជធានីភ្នំពេញ ដើម្បីដឹកនាំការស៊ើបអង្កេតឱ្យកាន់តែមានប្រសិទ្ធផល។

"ក្នុងចំណោមនគរបាល គឺនៅមានកង្វះខាតសមត្ថភាព (ចំណេះដឹង និងជំនាញ) យ៉ាងខ្លាំង។ ពួកគេអាចត្រឹមតែអនុវត្តភារកិច្ច ឬកិច្ចការសាមញ្ញមួយចំនួនតែប៉ុណ្ណោះ។ ចំពោះសំណុំរឿងបច្ចេកទេសជាងនេះ ពួកគេចាំបាច់ត្រូវទៅកាន់ថ្នាក់ជាតិដើម្បីសុំជំនួយ។ បច្ចុប្បន្ន ពួកគេពុំដឹងថាត្រូវស្វែងរក ឬតាមដានហេតុការណ៍ និងករណីដូចម្តេចនោះទេ។ ទោះបីជាមានឧបករណ៍ និងបរិក្ខារសម្រាប់ឱ្យពួកគេប្រើប្រាស់ក៏ដោយ ក៏ពួកគេពុំដឹងអំពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនោះដែរ។ ខ្ញុំសំដៅលើមន្ត្រីថ្នាក់ខេត្តចុះទៅដល់ថ្នាក់មូលដ្ឋានដែលសមត្ថភាពនៅមានកម្រិត។"

ចៅក្រម

បញ្ហាទូទៅ គឺការរក្សាសមត្ថភាពបុគ្គលិកក្នុងអំឡុងពេលមានការលាឈប់ពីបុគ្គលិក។ ប្រការនេះ នៅតែបន្តជាបញ្ហាអស់រយៈពេល ៥ឆ្នាំ មកហើយ និងនៅពុំទាន់បានដោះស្រាយពេញលេញនៅឡើយទេ។ ការបណ្តុះបណ្តាលត្រូវធ្វើឡើងជាទៀងទាត់ដើម្បីធានាបានថាបុគ្គលិកទាំងអស់មានសមត្ថភាពធ្វើការងារ។

"ការផ្លាស់ប្តូរមន្ត្រី គឺជាបញ្ហាជានិច្ច។ អ្នកមានជំនាញផ្លាស់ប្តូរទៅរកវិស័យផ្សេងៗ ឬចូលនិវត្តន៍។ បុគ្គលិកថ្មី (មន្ត្រីថ្មី) ខ្វះជំនាញក្នុងការបំពេញ ឬអនុវត្តការងាររបស់ពួកគេ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

តម្រូវការបណ្តុះបណ្តាលជាក់លាក់ស្តីពីការកសាងសមត្ថភាពស៊ើបអង្កេត ត្រូវបានស្នើឡើង រួមមាន៖

- **ជំនាញស៊ើបអង្កេតស្នូល៖** នីតិវិធីស៊ើបអង្កេត របៀបបើកការស៊ើបអង្កេត អ្នកដែលត្រូវសួរ និងសហការជាមួយ និងការរៀបចំផែនការសម្រាប់ការអន្តរាគមន៍។
- **ការប្រមូលភស្តុតាង៖** ភស្តុតាងណាដែលត្រូវការចាំបាច់នូវរបៀបប្រមូលភស្តុតាង រក្សាទុក និងថែទាំភស្តុតាង។
- **បច្ចេកវិទ្យា៖** ជំនាញស្រាវជ្រាវ និងបច្ចេកវិទ្យាសម្រាប់នគរបាលយុត្តិធម៌នៅស្នងការដ្ឋាននគរបាលខេត្តនគរបាលនៅថ្នាក់ស្រុក ការតាមដានការផ្ទេរប្រាក់ និងការស៊ើបអង្កេតតាមអ៊ីនធឺណិត។
- **ការវិវត្តន៍ និងបច្ចុប្បន្នភាពអំពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស៖** ការបណ្តុះបណ្តាលដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់មន្ត្រីនគរបាល ដើម្បីតាមឱ្យទាន់ការវិវត្តន៍នៃការអនុវត្តពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ការយល់ដឹងកាន់តែទូលំទូលាយអំពីការប្រើប្រាស់បច្ចេកវិទ្យា និងបណ្តាញអ៊ីនធឺណិតសម្រាប់ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។

## ៥.២.៧ ការកសាងសមត្ថភាព និងកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលបច្ចុប្បន្ន

នៅឆ្នាំ ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២៥៦ វគ្គ សម្រាប់នគរបាលអំពីច្បាប់ស្តីពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សនិងការប្រមូលភស្តុតាង ដែលមានចំនួនអ្នកចូលរួមបានកើនឡើងដល់ ១២.៨១៤ នាក់ ដូចបានបង្ហាញក្នុងតារាងខាងក្រោម ។ លើសពីនេះ រដ្ឋាភិបាលក៏បានលើកឡើងដែរអំពីការរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលចំនួន ៧ ដែលបានបណ្តុះបណ្តាលនគរបាល និងអាជ្ញាធរចំនួន ២៨៦ នាក់ស្តីពីការកំណត់អត្តសញ្ញាណ និងការការពារជនរងគ្រោះ និង ១៥៦ វគ្គដែលបានបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលចំនួន ៥.៧២០ នាក់ អំពីច្បាប់ស្តីពីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស និងវិធានការប្រឆាំងអំពើជួញដូរមនុស្ស។

### តារាង ៣ ៖ វគ្គបណ្តុះបណ្តាលរៀបចំដោយរដ្ឋាភិបាលស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

| ឆ្នាំ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ចំនួនវគ្គបណ្តុះបណ្តាល | មិនមានរបាយការណ៍ | ៦៦ | ២៣៨ | ១១៣ | ១៩២ | ២៥៦ |
| ចំនួនអ្នកចូលរួម | ៧.៦៨០ | ១.៥៧៧ | ៦.៣២១ | ៣.៧១២ | ៧.៩៩១ | ១២.៨១៨ |
| | *ដូចដែលបានរាយការណ៍នៅក្នុង របាយការណ៍ស្តីពីការជួញដូរមនុស្សសហរដ្ឋអាមេរិក* | | | | | |

មជ្ឈមណ្ឌលបណ្ឌិត្យសភានគរបាលកម្ពុជា (PAC) ទទួលខុសត្រូវលើការរៀបចំផ្តល់វគ្គបណ្តុះបណ្តាលដល់សមាជិកទាំងអស់នៃនគរបាលកម្ពុជានៅទូទាំងប្រទេស។ មជ្ឈមណ្ឌលនេះ គ្រប់គ្រងតំបន់សាលារៀនចំនួន ៦ ទីតាំង នៅទូទាំប្រទេស និងមាននិស្សិតបញ្ចប់ការសិក្សាចំនួន ១២ ក្រុមក្នុងមួយឆ្នាំ។ ជាមធ្យម ចំនួនសិស្សដែលបានបញ្ចប់ការសិក្សាជារៀងរាល់ឆ្នាំ គឺប្រហែលស្មើនឹង ២០០ នាក់។ មជ្ឈមណ្ឌលនេះផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេល ៨ ខែ សម្រាប់នគរបាលដែលមានរួមបញ្ចូលសញ្ញាបត្រកម្រិតបរិញ្ញាបត្រសម្រាប់ជំនាញកិច្ចការនគរបាល និងបរិញ្ញាបត្របណ្ឌិតផ្នែកវិទ្យាសាស្រ្តនគរបាល។

កាលពីពេលថ្មីៗនេះ មជ្ឈមណ្ឌលបានកែទម្រង់កម្មវិធីសិក្សារបស់ខ្លួន បន្ទាប់ពីបានទទួលការគាំទ្រពីប្រទេសអាល្លឺម៉ង់។ អ្នកវាយតម្លៃឯករាជ្យបានលើកឡើងថាបានត្រួតពិនិត្យលើកម្មវិធីសិក្សារបស់មជ្ឈមណ្ឌល និងបានដាក់ពិន្ទុកម្រិតខ្ពស់ដល់កម្មវិធីសិក្សានេះ បើធៀបនឹងបណ្តាប្រទេសផ្សេងទៀត។ កម្មវិធីសិក្សារួមមាន ការបណ្តុះបណ្តាលស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ការគ្រប់គ្រងការស៊ើបអង្កេត ការអនុវត្តច្បាប់ និងគោលការណ៍ណែនាំជាច្រើនស្តីពីការស៊ើបអង្កេត។ មជ្ឈមណ្ឌលបណ្ឌិត្យសភានគរបាលបានបញ្ជាក់ថា កម្មវិធីសិក្សារបស់ខ្លួនគ្របដណ្តប់លើជំនាញពិសេសៗចំនួន ៨ ដែលពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស រួមទាំងច្បាប់ស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និង "ទ្រឹស្តីមូលដ្ឋានអំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស" ផងដែរ។

យោងតាមការលើកឡើងរបស់មជ្ឈមណ្ឌលនេះ ការកែលម្អកម្មវិធីឱ្យបានប្រសើរឡើងគឺអាចធ្វើឡើងបានតាមរយៈ៖

- ការផ្តល់ធនធានសំខាន់ៗកាន់តែច្រើន ដូចជា ឧបករណ៍បញ្ចាំងស្លាយដ៍ LCD កុំព្យូទ័រ និងបរិក្ខារ។
- ការផ្តល់ធនធានមនុស្សបន្ថែម។
- ការផ្តល់ឯកសារអានស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងឯកសារធនធាន។
- ការកសាងចំណេះដឹង និងជំនាញស្តីពីការជួញដូរមនុស្សតាមប្រព័ន្ធអ៊ីនធឺណិត និងឌីជីថល។
- ការរៀបចំការបណ្តុះបណ្តាល និងឯកសារធនធានពាក់ព័ន្ធនឹងការប្រឆាំងបទល្មើសបច្ចេកវិទ្យា និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត។

ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស មជ្ឈមណ្ឌលបណ្ឌិត្យសភានគរបាលផ្តោតលើការពង្រឹងសមត្ថភាពប៉ុស្តិ៍នគរបាលមូលដ្ឋាន ដូច្នេះហើយទើបពេលមានករណីកើតឡើងនៅថ្នាក់ឃុំ នគរបាលមូលដ្ឋានអាចចាត់វិធានការមួយចំនួនបាន។ មជ្ឈមណ្ឌលបណ្ឌិត្យសភានគរបាលក៏បានព្យាយាមពង្រឹងតួនាទីរបស់នគរបាលមូលដ្ឋានក្នុងការអប់រំដល់សហគមន៍អំពីការធ្វើចំណាកស្រុក និងសុវត្ថិភាពនៅថ្នាក់ភូមិ។

## ៥.២.៨ ធនធានស៊ើបអង្កេត

ភាគីពាក់ព័ន្ធ ជារឿយៗបានបង្ហាញអំពីតម្រូវការបង្កើនមូលនិធិប្រតិបត្តិការសម្រាប់ការស៊ើបអង្កេតករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ នគរបាលបានលើកឡើងថា ពួកគេខ្វះខាតធនធានក្នុងការបើកការស៊ើបអង្កេតឱ្យបានគ្រប់គ្រាន់ស្របតាមបទដ្ឋានដែលតម្រូវចាំបាច់។ ខាងក្រោមនេះ រៀបរាប់អំពីគម្លាតធនធាន៖

### › ចំនួនមន្ត្រីនគរបាល

យោងតាមអ្នកផ្តល់ព័ត៌មាននគរបាល មន្ត្រីនគរបាលនៅកម្ពុជាដែលមើលការខុសត្រូវលើអ្នកភូមិ គឺមានចន្លោះប្រមាណពី២០០០ ទៅ ៣០០០ នាក់។ នៅរាជធានីភ្នំពេញ មន្ត្រីត្រួតពិនិត្យមើលប្រជាជនប្រមាណជា ៥០០០ នាក់។ នៅប៉ុស្តិ៍នគរបាល ជារឿយៗមានមន្ត្រីនគរបាលពី ៣ ទៅ ៥ នាក់ ដែលមានឋានន្តរស័ក្តិខុសគ្នាៗ និងប៉ុស្តិ៍នគរបាលអាចមើលការខុសត្រូវលើប្រជាជនជាង ១០ ភូមិ។ បើធៀបនឹងបណ្តាប្រទេសផ្សេងទៀត អ្នកផ្តល់ព័ត៌មានបានលើកឡើងថា អនុបាតនេះបង្ហាញថា នគរបាលមានចំនួនតិចតួចណាស់បើធៀបនឹងចំនួនប្រជាជន។

ជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ កងកម្លាំងនគរបាល បានពង្រឹងតាមរយៈកម្មាភិបាលបណ្តុះបណ្តាលជំនួយការនគរបាលស្ម័គ្រចិត្តនៅថ្នាក់ភូមិ (សន្តិសុខភូមិស្ម័គ្រចិត្ត "ប្រជាការពារ") និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅថ្នាក់ស្រុក។ សន្តិសុខទាំងនេះ អាចនឹងមានឱកាសចូលរួមក្នុងយន្តការការពារតាមសហគមន៍សម្រាប់បង្ការ និងកំណត់រកហានិភ័យនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។

> "មានមន្ត្រីនគរបាលតែ ៣ នាក់ប៉ុណ្ណោះដែលប្រចាំការនៅប៉ុស្តិ៍នគរបាល ហើយពួកគេត្រូវបានចាត់ឱ្យមើលខុសត្រូវចំនួន ១០ភូមិ។ ចំណុចនេះគឺមានការលំបាកណាស់។ បច្ចុប្បន្ន យើងមានសន្តិសុខភូមិស្ម័គ្រចិត្ត (ប្រជាការពារ) ដើម្បីជួយដល់នគរបាល។ ភូមិមួយចំនួនមានប្រជាការពារប្រហែល ៥០ នាក់។"
>
> អ្នកផ្តល់ព័ត៌មាននគរបាល

### › ការផ្តល់មូលនិធិដល់ការស៊ើបអង្កេត

សកម្មភាពស៊ើបអង្កេត ទាមទារការចំណាយលើមុខចំណាយនានា ដូចជាការស្នាក់នៅ និងការធ្វើដំណើរ។ ពេលដែលនគរបាល និងព្រះរាជអាជ្ញាខេត្តបើកការស៊ើបអង្កេត ពួកគេរំពឹងថានឹងទូទាត់ថ្លៃចំណាយទាំងនេះដោយប្រើថវិកាផ្ទាល់ខ្លួន និងបន្ទាប់មកនឹងបើកប្រាក់សំណងមកវិញ។ ប្រការនេះ អាចនឹងបង្អាក់ទឹកចិត្តដល់នគរបាលក្នុងការចុះស៊ើបអង្កេត។ កង្វះធនធានភ្លាមៗ ក៏អាចមានន័យថា ការស៊ើបអង្កេត គឺត្រូវបានពន្យារពេល ដែលកត្តានេះនាំឱ្យប៉ះពាល់ដល់ការស៊ើបអង្កេត។

> "ចំពោះការបង្ក្រាប ឬអន្តរាគមន៍នានា យើងចាំបាច់ត្រូវចំណាយលើសកម្មភាពនានាដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន។ ពុំមានសម្ភារៈ និងឧបករណ៍គ្រប់គ្រាន់ដើម្បីគាំទ្រដល់ការងារចុះទីតាំងរបស់យើងនោះទេ។ ឧទាហរណ៍ ពេលមានបេសកកម្មសម្រាប់ឱ្យយើងបំពេញ យើងប្រើប្រាស់ប្រាក់កាក់ខ្លួនឯងសម្រាប់ប្រតិបត្តិការនេះ។ យើងប្រើប្រាស់ម៉ូតូ ឬរថយន្តផ្ទាល់ខ្លួន និងចេញប្រាក់លើថ្លៃអាហារដោយខ្លួនឯង។ ពុំមានប្រាក់ឧបត្ថម្ភលើការធ្វើដំណើរ ឬថ្លៃអាហារសម្រាប់ពួកយើងនោះទេ។ ដូច្នេះ យើងបាន និងកំពុងបម្រើការងារចេញពីឆន្ទៈរបស់យើង។ យើងមានតែបេះដូង និងកម្លាំងដើម្បីចូលរួម និងរក្សាការជំរុញទឹកចិត្តខ្លួនឯងឱ្យធ្វើការងារនេះ។"
>
> អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

## › ការគ្រប់ដណ្តប់លើភូមិសាស្ត្រ

កង្វះថវិកាឧបត្ថម្ភលើការធ្វើដំណើរ បានរួមចំណែកដល់ចន្លោះប្រហោងលើការគ្រប់ដណ្តប់ភូមិសាស្ត្រនៃសកម្មភាពនគរបាល។ ស្របពេលដែលក្រសួងយុត្តិធម៌បានខិតខំផ្តល់ការគាំទ្រនេះកាលពីពេលកន្លងទៅ កត្តានេះនៅតែជាបញ្ហាប្រឈមដល់ការអនុវត្តការស៊ើបអង្កេតនៅជនបទដែរ។

"តំបន់គ្រប់ដណ្តប់ទទួលខុសត្រូវនៅថ្នាក់មូលដ្ឋានដែលបានចាត់តាំងឱ្យនគរបាល គឺមានទំហំធំ និងពិបាកគ្រប់គ្រង។ មានការឧបត្ថម្ភម៉ូតូមួយគ្រឿង (ឌ្រីមសង់ ២០១១) ជូនដល់ប៉ុស្តិ៍នគរបាលនៅឆ្នាំ២០១១ មួយគ្រឿងនៅឆ្នាំ ២០១២ និងពីរគ្រឿងទៀតនៅពេលក្រោយ។ យ៉ាងតិចមានម៉ូតូសរុបចំនួនបួនគ្រឿង ដែលបានផ្តល់ជូនដល់ប៉ុស្តិ៍នគរបាលនាពេលបច្ចុប្បន្ន។ នៅថ្នាក់មូលដ្ឋាន ក្នុងឃុំមួយចំនួន នគរបាលប្រើប្រាស់កង់ជំនួយឱ្យម៉ូតូដែលបានផ្តល់ជូន។ ប្រការនេះ បណ្តាលមកពីគ្រឿងបន្លាស់ពុំមានក្នុងតំបន់របស់ពួកគេនោះទេ។ ការថែទាំ គឺជាបញ្ហា។"

មន្ត្រីរដ្ឋាភិបាល

## › ការថែទាំ ជាបញ្ហា

នគរបាលនៅតំបន់ខេត្ត បានលើកឡើងថា ពួកគេខ្វះខាតបន្ទប់សម្ភាសន៍ ឬពុំមានបន្ទប់សម្ភាសន៍ទាល់តែសោះ។ កង្វះខាតនេះ បានធ្វើឱ្យប៉ះពាល់ដល់ការស៊ើបអង្កេត ដោយសារតែជនរងគ្រោះ និងជនសង្ស័យពុំបានទទួលការរក្សាព័ត៌មានសម្ងាត់ និងឯកជនភាព ដែលរារាំងពួកគេពុំឱ្យពិភាក្សាបានដោយបើកចំហ និងដោយត្រង់បាននោះទេ។ កង្វះឯកជនភាពនេះ ក៏អាចនាំឱ្យមានការពិភាក្សាអំពីព័ត៌មាននៅក្នុងសហគមន៍ និងការផ្តល់ដំណឹងដល់ជនល្មើសអំពីការស៊ើបអង្កេតនេះផងដែរ។ កង្វះការរក្សាព័ត៌មានសម្ងាត់ ក៏អាចធ្វើឱ្យជនរងគ្រោះប្រឈមមុខនឹងគ្រោះថ្នាក់នៃការផ្ចាញ់ផ្ចាល ឬការគំរាមកំហែងពីសំណាក់ជនល្មើស ជាពិសេសស្ត្រី និងកុមារ។

បញ្ហាទាំងនេះ គឺត្រូវបានលើកឡើងដោយអង្គការ IJM នៅឆ្នាំ ២០១៦ និងក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកមួយចំនួនកាលពីឆ្នាំកន្លងទៅថ្មីៗនេះ បានអំពាវនាវឱ្យមានការបង្កើនការផ្តល់ថវិកាសម្រាប់អង្គភាពអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងសម្រាប់ការផ្តល់ថវិកាដែលនឹងត្រូវផ្តល់ជូននៅមុនពេលស៊ើបអង្កេតជាជាងចេញប្រាក់មុនហើយសុំបើកសងត្រលប់តាមក្រោយ ដើម្បីទប់ស្កាត់ការចេញថវិកាផ្ទាល់ខ្លួនរបស់អ្នកស៊ើបអង្កេត។

## ៥.២.៩ ការចាប់ខ្លួនជនល្មើស

យោងតាមទិន្នន័យនៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក ជនសង្ស័យពីបទពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សសរុបចំនួន ៣៧០ នាក់ គឺត្រូវបានចាប់ខ្លួននៅឆ្នាំ ២០២១ ក្នុងនោះ មានជនសង្ស័យចំនួនត្រឹមតែ ៣៨ នាក់ប៉ុណ្ណោះដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងផ្លូវភេទ។ ប្រការនេះ បានបង្ហាញអំពីជនជនសង្ស័យជាច្រើននាក់ផ្សេងទៀត គឺជាប់ពាក់ព័ន្ធនឹងសំណុំរឿងការងារ។ ចំនួននេះ គឺមានចំនួនខ្ពស់ជាងចំនួនដែលបានរាយការណ៍កាលពីឆ្នាំកន្លងទៅ ទោះបីជាទិន្នន័យអំពីការចាប់ខ្លួននេះគឺមិនអាចទុកចិត្តបានក៏ដោយ។

*តារាង ៥៖ ការចាប់ខ្លួនពីបទពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស*

| ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| សំណុំរឿងផ្លូវភេទ | ២១ | ១៤ | ២១ | មិនមានរបាយការណ៍ |
| សំណុំរឿងមិនមែនផ្លូវភេទ | ៣៩ | ២១ | ៣៧ | មិនមានរបាយការណ៍ |
| ជនសង្ស័យសរុប | ១៥០ | ៥៣ | ៩៤ | ៣៧០ |
| ជនសង្ស័យពីបទអំពើផ្លូវភេទ | មិនមានរបាយការណ៍ | ២៧ | ៤៦ | ៣៨ |
| ជនសង្ស័យពីបទមិនមែនអំពើផ្លូវភេទ | មិនមានរបាយការណ៍ | ២៦ | ៤៨ | ៣៣២ |
| | *ដូចដែលបានរាយការណ៍នៅក្នុង របាយការណ៍ស្តីពីការជួញដូរមនុស្សសហរដ្ឋអាមេរិក* | | | |

ក្នុងករណីជាច្រើន ការចាប់ខ្លួនគឺផ្តោតលើពលករឆ្លងដែន។ ករណីទាំងនេះ គឺត្រូវបានលើកឡើងថាជាការ "បង្ក្រាប" ករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ប៉ុន្តែជាក់ស្តែង ករណីទាំងនេះ គឺគ្រាន់តែជាពលករឆ្លងដែនខុសច្បាប់ប៉ុណ្ណោះ។ ក្នុងករណីផ្សេងទៀត សកម្មភាពចុះបង្ក្រាប គឺត្រូវបានគេលើកឡើងថាធ្វើឡើងនៅពេលបានចាប់ខ្លួន ស្របពេលដែលស្ថានភាពពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សកំពុងកើតឡើង។

នគរបាលបានប្រាប់ថា តាមការអនុវត្តជាក់ស្តែង គឺវាអាចមានការលំបាកក្នុងការប្រមូលភស្តុតាងគ្រប់គ្រាន់ ពេលដែលពួកគេអាចត្រឹមតែឃាត់ខ្លួនជនសង្ស័យបានត្រឹម ៤៨ ម៉ោងប៉ុណ្ណោះ។ ក្នុងករណីរំលោភបំពានផ្លូវភេទ អាចចំណាយពេលយូរជាង ៤៨ ម៉ោង ដើម្បីទទួលបានលទ្ធផលកោសល្យវិច្ច័យពីសេវាសុខភាព។ លើសពីនេះ ពេលជនសង្ស័យត្រូវបានដោះលែងទៅវិញ គឺវាមានការលំបាកណាស់ក្នុងការតាមដានទីតាំងរបស់ជនសង្ស័យ និងទប់ស្កាត់ពួកគេកុំឱ្យចាកចេញពីទីតាំងមូលដ្ឋាន។ ដោយសារមូលហេតុនេះហើយ ទើបវាអាចមានប្រយោជន៍ក្នុងការផ្តល់ឱ្យនគរបាលនូវសិទ្ធិឃាត់ខ្លួនជនសង្ស័យរយៈពេលយូរជាងមុនសម្រាប់កាលៈទេសៈពិសេស។

## ៥.២.១០ ការប្រមូលភស្តុតាងសម្រាប់សវនាកា

ក្នុងអំឡុងពេលស៊ើបអង្កេត នគរបាលយុត្តិធម៌ គឺទទួលខុសត្រូវលើការប្រមូលភស្តុតាង ដើម្បីកសាងសំណុំរឿង ដែលត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញា។ បន្ទាប់មក ព្រះរាជអាជ្ញាអាចណែនាំនគរបាលយុត្តិធម៌អំពីការរៀបចំសំណុំរឿង រួមទាំងការប្រមូលភស្តុតាងបន្ថែមសម្រាប់សវនាការ។ ជួនកាល នគរបាលយុត្តិធម៌នឹងទទួលបានសំណើពីចៅក្រមស៊ើបសួរឱ្យអនុវត្តការស៊ើបអង្កេតបន្ថែម។

ដើម្បីចាប់ផ្តើមការស៊ើបអង្កេតបាន ជាទូទៅនគរបាលចាប់ផ្តើមពីការសម្ភាសសាច់ញាតិរបស់ជនរងគ្រោះ និងសាក្សីដែលមានសក្តានុពល។ ប្រសិនបើជនរងគ្រោះស្គាល់មេខ្យល់ ជាទូទៅគឺដោយសារតែពួកគេជាសាច់ញាតិ ឬមិត្តភក្តិរបស់ជនរងគ្រោះ។ ទោះជាយ៉ាងនេះក្តី នៅក្នុងករណីទាំងនេះ ជនរងគ្រោះជារឿយៗ គឺបដិសេធមិនសហការជាមួយនគរបាលក្នុងការកំណត់អត្តសញ្ញាណមេខ្យល់នោះទេ។

ប្រសិនបើមេខ្យល់នោះពុំមែនជាសមាជិកសហគមន៍ ឬជាមនុស្សដែលជនរងគ្រោះពុំស្គាល់ ជារឿយៗ គឺមានការលំបាកណាស់សម្រាប់នគរបាលក្នុងការកំណត់អត្តសញ្ញាណមេខ្យល់ ដោយសារតែពួកគេពុំផ្តល់ព័ត៌មានពិតប្រាកដដល់ជនរងគ្រោះនោះទេ។ សំណុំរឿងទាំងនេះ គឺត្រូវព្រះរាជអាជ្ញាបដិសេធ ដោយសារពុំមានការកំណត់អត្តសញ្ញាណច្បាស់លាស់។

"ចំពោះមេខ្យល់ យើងពុំដឹងថាពួកគេមកពីណានោះទេ។ ពួកគេបានប្រើប្រាស់ឈ្មោះហៅក្រៅ ហើយពួកគេមិនមានអាស័យដ្ឋានឬអត្តសញ្ញាណច្បាស់លាស់ឡើយ។ ពេលនគរបាលបញ្ជូនបន្តសំណុំរឿងជូនដល់ព្រះរាជអាជ្ញា តើយើងអាចបន្តនីតិវិធីបានយ៉ាងដូចម្តេចចំពោះសំណុំរឿងដែលពុំមានព័ត៌មានគ្រប់គ្រាន់បែបនេះ?"

**អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត**

យោងតាមព្រះរាជអាជ្ញា បញ្ហាប្រឈមមួយទៀតនៅដំណាក់កាលរៀបចំសំណុំរឿង ជារឿយៗគឺរៀបចំពុំទាន់បានល្អ និងខ្វះភស្តុតាងដែលត្រូវការចាំបាច់ក្នុងការបន្តនីតិវិធីសំណុំរឿងឬដើម្បីរក្សាបាននូវការផ្តន្ទាទោស។

"ចំណេះដឹងរបស់នគរបាល ដែលត្រូវធ្វើការងារលើការកំណត់អត្តសញ្ញាណ គឺនៅមានកម្រិត។ នៅពេលដែលពួកគេពុំមានជំនាញ នោះពួកគេពុំអាចសរសេររបាយការណ៍ ឬផលិតរបាយការណ៍បានល្អ ដែលកត្តានេះអាចធ្វើឱ្យជឿបានថាមានសំណុំរឿងសម្រាប់ការស៊ើបអង្កេតបន្ត។"

**អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល**

ទោះបីជាព្រះរាជអាជ្ញា និងចៅក្រមអាចត្រួតពិនិត្យមើលសំណុំរឿង និងអនុវត្តការស៊ើបអង្កេតបន្ថែមក៏ដោយ ក៏តាមការអនុវត្តជាក់ស្តែង ពួកគេកម្រនឹងធ្វើការស៊ើបអង្កេតបន្ថែមដែលត្រូវការចាំបាច់សម្រាប់សំណុំរឿងណាស់។

"ផ្អែកលើការអង្កេត នៅដំណាក់កាលតុលាការគឺពុំមានការស៊ើបអង្កេតឬសម្ភាសន៍ស៊ីជម្រៅនោះទេពីសំនាក់ណាក់ព្រះរាជអាជ្ញា ឬចៅក្រមបន្ទាប់ពីបានទទួលឯកសារពីនគរបាល..."

**អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល**

ភស្តុតាងមួយទៀតជាបញ្ហាប្រឈមដែរ យោងតាមព្រះរាជអាជ្ញា គឺការទទួលរបាយការណ៍កោសល្យវិច្ច័យ និងរបាយការណ៍ជំនាញការដែលអាចចំណាយពេលយូរ និងទាមទារការចំណាយថវិកាបន្ថែម។

## ៥.២.១១ បញ្ហាប្រឈមសម្រាប់ការស៊ើបអង្កេតសំណុំរឿងក្រៅប្រទេស

ការស៊ើបអង្កេតពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ជារឿយៗគឺមានការលំបាក ដោយសារការស៊ើបអង្កេតនេះរួមបញ្ចូលទំនាក់ទំនងជាមួយដែនយុត្តាធិការបរទេស។ ប្រការនេះ បង្កើតជាបញ្ហាប្រឈមច្រើនអនេកសម្រាប់អ្នកស៊ើបអង្កេត។ ទី១ ជនរងគ្រោះអាចនឹងរាយការណ៍អំពីករណីដែលបានកើតឡើងនៅក្រៅប្រទេស ដែលកត្តានេះធ្វើឱ្យមានការលំបាកផ្នែកធ្វើដំណើរក្នុងការរៀបចំការសម្ភាសន៍ ការប្រមូលភស្តុតាង និងអនុវត្តការស៊ើបអង្កេត ដែលស្ថិតនៅក្រោមដែនយុត្តាធិការនគរបាលបរទេស។

" ជាទូទៅ បណ្តឹងគឺរៀបចំឡើងពីខាងប្រទេសគោលដៅ។ យើងមានការលំបាកណាស់ក្នុងការចុះស៊ើបអង្កេត ដោយសារវាស្ថិតនៅក្រៅសិទ្ធិអំណាច និងតំបន់ត្រួតត្រារបស់យើង។ យើងចាំបាច់ត្រូវអនុវត្តតាមច្បាប់ប្រទេសនោះ។ វា ជាដែនដីរបស់ពួកគេ។"

**អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត**

ទី២ បញ្ហាប្រឈមផ្នែកដែនយុត្តាធិការ។ ច្បាប់ស្តីពីការជួញដូរមនុស្សកម្ពុជា អាចអនុវត្តបានតែនៅក្នុងដែនដីកម្ពុជា ឬចំពោះប្រជាជនកម្ពុជានៅក្រៅប្រទេសប៉ុណ្ណោះ។ ចំពោះពលរដ្ឋកម្ពុជានៅក្រៅប្រទេស បញ្ហាប្រឈមនោះ គឺការរក្សាឱ្យបាននូវកិច្ចសហការជាមួយអ្នកស៊ើបអង្កេតបរទេស។

"ច្បាប់របស់យើងជាក់ស្តែងអាចអនុវត្តបានតែនៅក្នុងប្រទេស និងក្រៅប្រទេសពេលជនរងគ្រោះ និងជនល្មើស គឺជាជនជាតិខ្មែរ។ ក្រសួងយុត្តិធម៌ មានសិទ្ធិអំណាចកណ្តាល។ ចៅក្រមអាចចេញដីកាចាប់ខ្លួន។ ក្រសួងយុត្តិធម៌ នឹងចេញដីកាចាប់ខ្លួនដល់ស្ថានទូត ស្នើសុំឱ្យភាគីថៃចាប់ខ្លួនជនល្មើស។ ទោះជាយ៉ាងនេះក្តី យើងពុំធ្វើដូច្នេះ (នៅក្នុងការអនុវត្តជាក់ស្តែង) នោះទេ។"

មន្ត្រីរដ្ឋាភិបាល

ចំពោះជនល្មើសដែលជាជនបរទេស ប៉ុន្តែបានប្រព្រឹត្តបទល្មើសក្នុងប្រទេសកម្ពុជា ច្បាប់ជាតិកម្ពុជាអាចអនុវត្តចំពោះតែមេខ្យល់នៅកម្ពុជា ដែលជួយក្នុងការបញ្ជូនពលករនៅក្រៅប្រទេសប៉ុណ្ណោះ។ ប្រការនេះ អាចដាក់កម្រិតលើការស៊ើបអង្កេតចំពោះសកម្មភាពរបស់មេខ្យល់នៅក្នុងប្រទេសកម្ពុជាជាជាងជនល្មើសចម្បង។

បញ្ហាប្រឈមទី ៣ គឺថាប្រទេសខុសគ្នាអាចមានបទដ្ឋានច្បាប់ខុសៗគ្នា។ ជាពិសេស ការកំណត់អត្តសញ្ញាណជនរងគ្រោះនៅក្រៅប្រទេស អាចមានការលំបាក ដោយសារតែគោលការណ៍គោរពច្បាប់ខុសៗគ្នា។

"...បណ្តាប្រទេសមួយចំនួនពុំប្រើប្រាស់ពិធីសារ Palermo។ ដូច្នេះ គឺមានការលំបាកណាស់ពេលអនុវត្តការងាររបស់យើងក្នុងការកំណត់អត្តសញ្ញាណ ហើយប្រទេសគោលដៅបែរជាបដិសេធលទ្ធផលដែលបានរកឃើញ និងអះអាងថាករណីនេះពុំមែនជាករណីជួញដូរមនុស្សទៅវិញ។"

នគរបាលខេត្ត



បញ្ហាប្រឈមទី ៤ គឺថាជនល្មើសកាន់តែងាយស្រួលក្នុងការគេចខ្លួន នៅពេលដែលមានបទល្មើសកើតឡើងនៅក្រៅប្រទេស។

"ចំពោះឧក្រិដ្ឋកម្មឆ្លងដែន ជនសង្ស័យ និងជនរងគ្រោះនឹងគ្រាន់តែធ្វើចំណាកស្រុក ប្រសិនបើមានបញ្ហា។"

អ្នកផ្តល់ព័ត៌មាននគរបាល

ចុងក្រោយ ការស៊ើបអង្កេតឆ្លងដែនជាទូទៅពឹងផ្អែកលើការសហការឆ្លងដែនរវាងនគរបាលសមភាគី។ ប្រការនេះ អាចជាបញ្ហាប្រឈមមួយ ដូចមានពិភាក្សាបន្ថែមនៅក្នុងផ្នែក ៧។

## ៥.៣ ការផ្តន្ទាទោសលើករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

### ៥.៣.១ ការយល់ដឹងអំពីករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

ជាទូទៅ តួអង្គតុលាការបានរៀបរាប់ថា ពួកគេមានអារម្មណ៍ថាមានទំនុកចិត្តលើការយល់ដឹងរបស់ពួកគេអំពីករណីពលកម្មដោយបង្ខំ ហើយជំនាញនេះត្រូវបានបង្ហាញក្នុងអំឡុងពេលសម្ភាសន៍។ ទោះជាយ៉ាងនេះក្តី តួអង្គតុលាការបានគូសបញ្ជាក់អំពីភាពស្មុគស្មាញចំនួន៣ ដែលជារឿយៗបង្កបញ្ហាប្រឈមក្នុងការផ្តន្ទាទោសលើករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។

ទី១ គឺភាពខុសច្បាប់ពាក់ព័ន្ធជាមួយនឹងការឆ្លងដែនខុសច្បាប់ អាចធ្វើឱ្យតួអង្គប្រព័ន្ធយុត្តិធម៌ដើម្បីសង្កត់ធ្ងន់ហួសកម្រិតទៅលើសន្តិសុខព្រំដែន និងចាត់ទុកការឆ្លងដែនខុសច្បាប់ដោយមានជំនួយថាស្មើទៅនឹងការជួញដូរមនុស្ស។ វិធីសាស្ត្រនេះ ពុំទទួលស្គាល់ថាការកេងប្រវ័ញ្ច និងការរំលោភបំពានជារឿយៗស្ថិតនៅលើនិយោជក និងពុំមែនពាក់ព័ន្ធទៅនឹងអ្នកដែលជួយពលករក្នុងការឆ្លងដែននោះទេ។ ចៅក្រមមួយរូបបានបរិយាយសង្ខេបអំពីភាពស្មុគស្មាញនេះយ៉ាងមានប្រសិទ្ធភាព៖

"ការឆ្លងដែនខុសច្បាប់ អាចត្រូវបានគេមើលឃើញក្នុងទម្រង់ខុសៗគ្នា។ ប្រជាជនមួយចំនួនមានសាច់ញាតិធ្វើការងារនៅក្នុងប្រទេសថៃ។ ពួកគាត់ទាក់ទងសាច់ញាតិរបស់ពួកគេឱ្យមកយកពួកគេនៅទីនោះ។ ប្រជាជនមួយចំនួនធ្លាប់មានបទពិសោធន៍ឆ្លងដែនទៅថៃពីរបីដង ដូច្នេះពួកគាត់ស្គាល់ផ្លូវ។ បន្ទាប់មក អ្នកជិតខាងរបស់ពួកគាត់បានពឹងឱ្យពួកគាត់យកពលករទៅជាមួយ ដោយសារតែពួកគាត់ស្គាល់ផ្លូវស្រាប់។ ពួកគាត់មិនយល់ច្បាប់។ ពលករមិនគិតថាការនាំយកមនុស្សផ្សេងទៀតទៅជាមួយ ដើម្បីស្វែងរកការងារនៅក្រៅប្រទេសគឺជាអំពើខុសច្បាប់នោះទេ។ ពួកគាត់គ្រាន់តែផ្តល់ជំនួយ ឬជួយដល់ពួកគេប៉ុណ្ណោះ។ ពលករមួយចំនួនថែមទាំងមិនចេះអាន និងសរសេរអក្សរទៀតផង។ ពួកគាត់ចង់រកប្រាក់ដើម្បីចិញ្ចឹមជីវិត។"

ចៅក្រម

បញ្ហាប្រឈមទីពីរគឺថា មេខ្យល់ដឹងកាន់តែច្រើនអំពីច្បាប់ស្តីពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងមិនសូវដើរតួនាទីជាក់ស្តែងនៅក្នុងការដឹកជញ្ជូនពលករដោយផ្ទាល់នោះទេ។ ប្រការនេះ គឺកាន់តែធ្វើឱ្យមានការលំបាកក្នុងការផ្តន្ទាទោសមេខ្យល់នៅក្រោមច្បាប់បច្ចុប្បន្ន។ លើសពីនេះ ការរីកចម្រើននៃបច្ចេកវិទ្យា បានផ្លាស់ប្តូរវិធីសាស្ត្រដែលមេខ្យល់ទំនាក់ទំនង និងធ្វើប្រតិបត្តិការ ដែលកាន់តែធ្វើឱ្យមានការលំបាកកាន់តែខ្លាំងក្នុងការកំណត់អត្តសញ្ញាណមេខ្យល់ និងកសាងសំណុំរឿងដែលអាចបញ្ជូនទៅតុលាការបាន។

"ជាមួយនឹងបច្ចេកវិទ្យាទំនើប មេខ្យល់ធ្វើការប្រាស្រ័យទាក់ទងតាមកម្មវិធីតេឡេក្រាម (Telegram) ឬកម្មវិធីស្រដៀងគ្នាផ្សេងទៀត។ ពួកគេគ្រាន់តែរៀបចំកន្លែងណាត់ជួប ហើយពលករធ្វើដំណើរទៅកាន់កន្លែងនោះដោយខ្លួនឯង ដោយរង់ចាំគេមកទទួល។ វាមើលទៅហាក់បីដូចជាពួកគេរង់ចាំរថយន្តឈ្នួល...កន្លងមកមានការលំបាកជាខ្លាំងក្នុងការស្វែងរកនិងកំណត់អត្តសញ្ញាណមេខ្យល់។ យើងអាចត្រឹមតែតាមដានអ្នករត់ម៉ូតូឌុប ដែលដឹកពលករពីកន្លែងមួយទៅកន្លែងមួយប៉ុណ្ណោះ ប៉ុន្តែមិនមែនជាមេខ្យល់ពិតប្រាកដ ឬជាមេក្លោងនៅពីក្រោយការរៀបចំឧក្រិដ្ឋកម្មនេះនោះទេ។"

ចៅក្រម

ភាពស្មុគស្មាញទី៣ គឺថា ករណីពលកម្មដោយបង្ខំ ជារឿយៗកើតឡើងនៅពេលដែលពលករជំពាក់ប្រាក់មេខ្យល់ ឬ

និយោជក។ បំណុលនេះ អាចចងភ្ជាប់កាតព្វកិច្ចពលករទៅនឹងកន្លែងធ្វើការរបស់ពួកគេយ៉ាងមានប្រសិទ្ធភាព ដោយសារតែការធ្វើបែបនេះ គឺជាមធ្យោបាយតែមួយគត់ក្នុងការទូទាត់សងបំណុល។ អាជ្ញាធរ គឺមិនបានទទួលព័ត៌មានអំពីបញ្ហានេះទេ ហើយករណីនានាដែលពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុល គឺស្ទើរតែមិនដែលបន្តនីតិវិធីតាមរយៈការស៊ើបអង្កេត ឬបញ្ជូនទៅតុលាការឡើយ។

ដូចដែលបានកត់សម្គាល់ដោយអង្គការ IJM នៅឆ្នាំ ២០១៦ ពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មស្មុគស្មាញ។ ចាប់តាំងពីពេលនោះមក អង្គការ IJM បានធ្វើការងារជាមួយក្រសួងមហាផ្ទៃ ដើម្បីរៀបចំគោលការណ៍ណែនាំសម្រាប់ការយល់ដឹង និងការអនុវត្តច្បាប់ស្តីពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ដែលត្រូវបានចាត់ទុកថាមានប្រយោជន៍សម្រាប់តួអង្គតុលាការ។

> កាលពីមុន យើងមានតែច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សប៉ុណ្ណោះ។ ការបកស្រាយច្បាប់នេះគឺមានការលំបាកខ្លាំងណាស់។ ប៉ុន្តែ ក្រោយមករដ្ឋាភិបាលបានចេញសៀវភៅពន្យល់បកស្រាយអំពីច្បាប់ដែលមានផ្តល់ឧទាហរណ៍ជាក់ស្តែងមួយចំនួនផងដែរ។”
>
> ចៅក្រម

## ៥.៣.២ ការសម្រេចចិត្តលើការផ្តន្ទាទោសករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

នគរបាលយុត្តិធម៌ កសាងសំណុំរឿងសម្រាប់ព្រះរាជអាជ្ញា ដែលពួកគេផ្តល់ជូនអមជាមួយនឹងបទចោទប្រកាន់ដែលបានណែនាំ។ ប្រសិនបើពុំមានភស្តុតាងគ្រប់គ្រាន់ទេនោះ ព្រះរាជអាជ្ញាអាចស្នើសុំឱ្យនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតបន្ថែម។ ពេលមានភស្តុតាងគ្រប់គ្រាន់ដើម្បីដំណើរការនីតិវិធីហើយ ព្រះរាជអាជ្ញារៀបចំសំណុំរឿងសម្រាប់បញ្ជូនទៅតុលាការ។

ក្នុងការវាយតម្លៃភស្តុតាង ព្រះរាជអាជ្ញាបានប្រាប់ថា ពួកគេអនុវត្តតាមដំណើរការជាប្រចាំផ្អែកលើពិធីសារ Palermo និងគោលការណ៍ដែលបានកំណត់តាមច្បាប់ ហើយការអនុវត្តនេះនៅតែបន្តដល់បច្ចុប្បន្ន។ ព្រះរាជអាជ្ញាមួយរូបបានគូសបញ្ជាក់អំពីភាពស្មុគស្មាញ ដែលពាក់ព័ន្ធនឹងការសម្រេចចិត្តផ្តន្ទាទោស៖

> “មានធាតុផ្សំជាច្រើនដើម្បីសន្និដ្ឋានឧក្រិដ្ឋកម្ម។ ជួនកាល ប្រជាជនគ្រាន់តែឆ្លងដែន និងបង់ថ្លៃដឹកជញ្ជូនខុសច្បាប់ដោយខ្លួនឯង។ នៅក្រោមទិដ្ឋភាពនេះ យើងពុំអាចធ្វើសេចក្តីសន្និដ្ឋានថាជាករណីជួញដូរមនុស្សបានឡើយ។ ទង្វើនេះ គឺគ្រាន់តែជាសកម្មភាពធ្វើចំណាកស្រុកខុសច្បាប់ប៉ុណ្ណោះ។ នេះហើយជាមូលហេតុដែលពេលខ្លះទាមទារឱ្យព្រះរាជអាជ្ញា ចុះធ្វើការស៊ើបអង្កេតដោយផ្ទាល់នៅកន្លែងកើតហេតុជាមួយអង្គភាពអនុវត្តច្បាប់។”
>
> ព្រះរាជអាជ្ញា

*តារាង ៥៖ ការផ្តន្ទាទោស លកម្មដោយបង្ខំនិងការជួញដូរមនុស្សនៅកម្ពុជា*

| ឆ្នាំ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ករណីសរុបដែលបានរាយការណ៍ | ៥៣ | ២០៧ | ៤២១ | ១៩៩[២៦] | ៣៩៨ | ៦៤ |
| នៃសំណុំរឿងការងារ | មិនមាន របាយការណ៍ | មិនមាន របាយការណ៍ | ១៥០ | ៣២១ | មិនមាន របាយការណ៍ | ៣៧ |
| | *ដូចដែលបានរាយការណ៍នៅក្នុង របាយការណ៍ស្តីពីការជួញដូរមនុស្សសហរដ្ឋអាមេរិក* | | | | | |

ពេលដាក់សំណុំរឿងនៅតុលាការ សំណុំរឿងនោះគឺត្រូវបានបញ្ជូនទៅកាន់ចៅក្រមស៊ើបសួរ (IVJ) អមជាមួយនឹងបទចោទប្រកាន់ដែលបានកំណត់។ ចៅក្រមស៊ើបសួរអនុវត្តការសាកសួរបឋម និងកំណត់សវនាការតុលាការអន្តរការដូចជាសវនាការដោះលែងនៅក្រៅឃុំជាដើម។ ចៅក្រមស៊ើបសួរ អាចស្នើសុំព័ត៌មាន ឬភស្តុតាងបន្ថែមពីព្រះរាជអាជ្ញា។ អ្នករិះគន់បានកត់សម្គាល់ថា តុលាការកំណត់អាទិភាពសំណុំរឿងមួយចំនួនសម្រាប់សវនាការលើសំណុំរឿងផ្សេងទៀត។

ពេលសំណុំរឿងរៀបចំរួចរាល់ វានឹងត្រូវបានបញ្ជូនបន្តទៅឱ្យចៅក្រម។ ចៅក្រមនឹងដឹកនាំសវនាការសំណុំរឿងពេលជំនុំជម្រះ។ មេធាវីការពារក្តី ព្រះរាជអាជ្ញានិង (ជាការល្អ) អ្នកតំណាងជនរងគ្រោះ នឹងមានវត្តមានពេលអនុវត្តសំណុំរឿង។

ចៅក្រម និងព្រះរាជអាជ្ញាបានពន្យល់ថា ពួកគេមានស្វយភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តលើសំណុំរឿង ប៉ុន្តែមានកិច្ចប្រជុំរួមគ្នាប្រចាំខែ ដើម្បីពិភាក្សាអំពីសំណុំរឿងនានា។

"ចំពោះសំណុំរឿងជួញដូរមនុស្ស យើងមានព្រះរាជអាជ្ញារងជាអ្នកទទួលបន្ទុក។ យើងបានផ្តល់ទំនួលខុសត្រូវច្បាស់លាស់ដល់គាត់។ គាត់ដឹងដំណើររឿងពីដើមដល់ចប់សម្រាប់សំណុំរឿងនីមួយៗ និងវឌ្ឍនភាពធ្វើឡើងអំពីសំណុំរឿងនេះនៅថ្នាក់ខេត្ត។"

ចៅក្រម

## ៥.៣.៣ ការជម្រះសំណុំរឿងដែលពុំទាន់ដោះស្រាយ

ចាប់តាំងពីខែឧសភា ឆ្នាំ ២០២០ ដល់ខែមិថុនា ឆ្នាំ ២០២១ ក្រសួងយុត្តិធមិបានធ្វើប្រតិបត្តិការយុទ្ធនាការមួយ ដើម្បីជម្រះការកកស្ទះសំណុំរឿងនៅតុលាការ ទាំងនៅតុលាការក្រុង និងខេត្ត ក្នុងគោលបំណងពន្លឿនដំណើរការតុលាការ និងធ្វើឱ្យប្រតិបត្តិការដំណើរការទៅរលូន។[២៧] យោងតាមក្រសួងមហាផ្ទៃ យុទ្ធនាការនេះ បាននាំឱ្យមានការដោះស្រាយសំណុំរឿង ៩៦% នៃសំណុំរឿងព្រហ្មទណ្ឌកកស្ទះសរុបជាង ៣៧.៩០០ សំណុំរឿងនៅដំណាក់កាលផ្តន្ទាទោស ដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ។ លើសពីនេះ សំណុំរឿងជាង ១២.៦០០ គឺត្រូវបានជំនុំជម្រះ ដែលស្មើនឹង ៩៧% នៃសំណុំរឿងជាង ១៣.០០០ ដែលស្ថិតក្នុងដំណាក់កាលជំនុំជម្រះ។

ជារួម រដ្ឋាភិបាល ភាគីពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល បានលើកឡើងថា យុទ្ធនាការនេះបានទទួលជោគជ័យ និងបានពន្លឿនដំណើរការផ្តន្ទាទោស។

"កាលពីមុន មានសំណុំរឿងពុំទាន់ដោះស្រាយឡើងគរ។ ប៉ុន្តែ ដោយមានយុទ្ធនាការដើម្បីពន្លឿនដំណើរការនីតិវិធីផ្លូវច្បាប់នៃសំណុំរឿងតុលាការ សំណុំរឿងច្រើនបានជំនុំជម្រះ និងបានបញ្ចប់។ យើងបានកាត់បន្ថយ និងជម្រះសំណុំរឿងដែលបានកកស្ទះបានយ៉ាងច្រើន។"

ព្រះរាជអាជ្ញា

ជាលទ្ធផលនៃការជម្រះសំណុំរឿង មានការរាយការណ៍យ៉ាងទូលំទូលាយថា សំណុំរឿងនានាត្រូវបានដំណើរការនីតិវិធីលឿនជាងមុនឆ្ងាយ។ តួអង្គតុលាការបានលើកឡើងថា តាមទស្សនៈរបស់ពួកគេ វាជាការសំខាន់ណាស់ក្នុងការរក្សាសុចរិតភាពប្រព័ន្ធយុត្តិធម៌ ដែលសំណុំរឿងនានាអាចដោះស្រាយបានទាន់ពេលវេលា។

"ពេលមានសំណុំរឿងនៅកកស្ទះច្រើន យើងក្នុងនាមជាចៅក្រម ទទួលរងការស្តីបន្ទោស ការរិះគន់ និងការប្តឹងតវ៉ាមកលើពួកយើង។ ពួកគេបានចោទប្រកាន់យើងថាមិនស្វែងរកយុត្តិធម៌ឱ្យពួកគេ។"

ចៅក្រម

ទោះជាយ៉ាងនេះក្តី មានការរិះគន់អំពីយុទ្ធនាការនេះ ដោយអង្គការសង្គមស៊ីវិលរាយការណ៍ថា សំណុំរឿងមួយចំនួនបានដោះស្រាយដោយតក់ក្រហល់ ដែលចុងក្រោយរារាំងជនរងគ្រោះមិនឱ្យទទួលបានលទ្ធផលល្អ។ ទោះជាយ៉ាងនេះក្តី មន្ត្រីតុលាការរក្សាការពារថា សំណុំរឿងដែលអាចទទួលបានលទ្ធផលល្អ គឺចុងក្រោយត្រូវបានពន្លឿននីតិវិធី និងបានជំនុំជម្រះដោយសារតែមានយុទ្ធនាការនេះ។

## ៥.៣.៤ គ្រោងពេលវេលានៃសំណុំរឿង

ទោះបីជាសំណុំរឿងដំណើរការបានលឿនជាងពីមុនក៏ដោយ ក៏អ្នកផ្តល់ព័ត៌មានមួយចំនួនបានប្រាប់ថា តុលាការបានចំណាយពេលរហូតដល់២ឆ្នាំ គិតចាប់ពីការដាក់បញ្ជូនសំណុំរឿង រហូតដល់បញ្ចប់ការជំនុំជម្រះ។ មូលហេតុមួយដែលតួអង្គតុលាការផ្តល់ឱ្យចំពោះគ្រោងពេលវេលាទាំងនេះ គឺជាការលំបាកក្នុងការស្វែងរកព័ត៌មានពីជនរងគ្រោះ។ តួអង្គតុលាការ ក៏បានលើកឡើងអំពីកង្វះបុគ្គលិកជំនាញ ដូចជាអ្នកចិត្តសាស្រ្តដើម្បីផ្តល់ភស្តុតាង ជាលទ្ធផលមួយទៀតសម្រាប់ការពន្យារពេលនេះ។

"យើងពុំចង់ឱ្យមានការយឺតយ៉ាវនោះទេ។ ប៉ុន្តែ យើងចាំបាច់ត្រូវប្រមូលភស្តុតាង និងព័ត៌មានឱ្យបានគ្រប់គ្រាន់ជាមុនសិន មុននឹងយើងអាចបន្តទៅជំហានបន្ទាប់ និងធ្វើសេចក្តីសម្រេចចិត្ត។ ការប្រមូលភស្តុតាង និងព័ត៌មាន គឺត្រូវចំណាយពេលយូរ។"

ចៅក្រម

មូលហេតុមួយទៀតដែលបានផ្តល់ជូនចំពោះការយឺតយ៉ាវនេះ គឺឧបសគ្គសមត្ថភាព។ នគរបាលបានរាយការណ៍ថា សំណុំរឿងអាចបញ្ជូនត្រលប់មកពួកគេវិញដើម្បីធ្វើការស៊ើបអង្កេតបន្ថែម ដោយសារតែតុលាការរវល់ខ្លាំងពេកក្នុងការជំនុំជម្រះសំណុំរឿងនោះ។

"យើងបានបញ្ជូនសំណុំរឿងទៅកាន់តុលាការ។ ពួកគេទទួលយកសំណុំរឿង។ ប៉ុន្តែ នៅពេលដែលពួកគេមិនមានពេលវេលាធ្វើការងារលើសំណុំរឿងនោះ ពួកគេបញ្ជូនសំណុំរឿងមកពួកយើងវិញ។ ការធ្វើបែបនេះបង្កឱ្យមានការពន្យារពេល។"

អ្នកផ្តល់ព័ត៌មាននគរបាល

ក្នុងការអនុវត្តជាក់ស្តែង កាលវិភាគពេលវេលារបស់តុលាការ ជារឿយៗគឺយឺតយ៉ាវពេកសម្រាប់ជនរងគ្រោះ និងបានបង្អាក់ទឹកចិត្តពួកគេក្នុងដំណើរការនីតិវិធីសំណុំរឿង។

"ដំណើរការនីតិវិធីតុលាការ និងផ្លូវច្បាប់អាចចំណាយពេលយូរដើម្បីបញ្ចប់។ ជនរងគ្រោះមួយចំនួនពុំមានការអត់ធ្មត់ ក៏ដូចជាពេលវេលាដើម្បីរង់ចាំលទ្ធផលនោះទេ ដូច្នេះចុងក្រោយទៅ ពួកគេច្រានចោលសំណុំរឿង។"

មន្ត្រីរដ្ឋាភិបាល

អង្គការសង្គមស៊ីវិលមួយចំនួនបានស្នើឡើងថា តុលាការគួរតែមានការដាក់កាលបរិច្ឆេទកំណត់នៅតាមជំហាននានានៃដំណើរការនីតិវិធី ដើម្បីធានាបាននូវការបំពេញតាមគ្រោងពេលវេលាទាំងនោះ។ ទោះជាយ៉ាងនេះក្តី ការធ្វើបែបនេះអាចនឹងប៉ះពាល់ដល់ដំណើរការជំនុំជម្រះ។ លើសពីនេះ ការសង្កត់ធ្ងន់ទៅលើការពន្លឿនសំណុំរឿង អាចលើកទឹកចិត្តឱ្យតួអង្គតុលាការ ផ្តោតលើតែសំណុំរឿង ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សសាមញ្ញ និងរហ័សដែលមិនរួមបញ្ចូលជនល្មើសចម្បងប៉ុណ្ណោះ។

## ៥.៣.៥ ធនធានតុលាការ

អ្នកផ្តល់ព័ត៌មានបានលើកឡើងថា ចៅក្រមមួយរូបៗអាចកាន់កាប់រហូតដល់ ៥០០ សំណុំរឿងក្នុងមួយឆ្នាំ ស្របពេលដែលព្រះរាជអាជ្ញារងទទួលរហូតដល់ ២០០ សំណុំរឿងក្នុងមួយឆ្នាំ។ ទោះជាយ៉ាងនេះក្តី ចំនួនចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការនៅតាមស្ថាប័នតុលាការនីមួយៗនៅកម្ពុជា គឺខុសគ្នាឆ្ងាយណាស់ ដែលកត្តានេះជះឥទ្ធិពលដោយផ្ទាល់ទៅលើចំនួនសំណុំរឿងដែលពួកគេអាចទទួលបាន។

ភាគីពាក់ព័ន្ធតុលាការ បានរៀបរាប់ថា មានកំនើនធនធានជារួមក្នុងរយៈពេល ៥ ឆ្នាំកន្លងមក ដោយសំអាងជាពិសេសទៅលើការគាំទ្រដល់បុគ្គលិក ប្រាក់ឧបត្ថម្ភការធ្វើដំណើរ និងហេដ្ឋារចនាសម្ព័ន្ធ។

"កាលពីមុន គឺពុំមានវត្តមានលេខាធិការដ្ឋានដើម្បីគាំទ្រការងាររបស់យើងនោះ រួមទាំង ផ្នែករដ្ឋបាល តុលាការ និងអយ្យការ។ យើងខ្វះធនធានមនុស្ស។ ឥឡូវនេះ យើងពុំមានធនធានគ្រប់គ្រាន់។ យើងមានបុគ្គលិកដែលអាចគាំទ្រនៅក្នុងការផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនៃសំណុំរឿងតុលាការ នៅពេលដែលយើងស្នើសុំព័ត៌មាន។ ចំណុចនេះគឺមានប្រយោជន៍សម្រាប់យើង។"

ព្រះរាជអាជ្ញា

"ហេដ្ឋារចនាសម្ព័ន្ធមានការកែលម្អ និងមានភាពល្អប្រសើរជាងមុន។ បន្ទប់សវនាការ គឺបានរៀបចំមានរបៀបរៀបរយ។ ក្រសួងយុត្តិធម៌បែងចែកថវិកាសម្រាប់យើងធ្វើកិច្ចការងារនេះ។ រដ្ឋាភិបាលបានកំណត់គំរូរួមមួយសម្រាប់តុលាការនៅទូទាំងប្រទេស។ ដូច្នេះ យើងមានការរៀបចំដូចគ្នា។ សាលាដំបូងខេត្តនីមួយៗចាំបាច់ត្រូវតែមានអន្តេវាសិកដ្ឋានសម្រាប់បុគ្គលិកតុលាការ និងផ្នែកអយ្យការ។ អគារ គឺអាចទទួលយកបាន។"

ព្រះរាជអាជ្ញា

ទោះបីជាមានកំណើនសំវិធានធនក្តី មានមតិត្រលប់ចម្រុះលើកឡើងថាតើធនធានទាំងនេះគ្រប់គ្រាន់ដែរឬយ៉ាងណា។ ជាពិសេសនោះ ចៅក្រមគឺពុំទាន់យល់ស្របថាធនធានមានគ្រប់គ្រាន់នោះទេ ដោយលើកឡើងថា ប្រាក់ឧបត្ថម្ភលើការធ្វើដំណើរ គឺពុំគ្រប់គ្រាន់ ហើយពួកគេពុំមានក្រឡាបញ្ជីគ្រប់គ្រាន់ជួយការងាររបស់ពួកគេនោះទេ។

## ៥.៣.៦ ការចេញដីកា

មានដីកាជាច្រើនដែលអាចចេញដោយតុលាការ ដើម្បីបង្ខំឱ្យជនរងគ្រោះ និងជនល្មើសចូលខ្លួនមកក្នុងតុលាការ ឬដើម្បីអនុញ្ញាតឱ្យនគរបាលចាប់ខ្លួនជនសង្ស័យ។ ការចេញដីការហ័ស និងមានប្រសិទ្ធភាព គឺមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យសំណុំរឿងទទួលបានជោគជ័យ។ ភាគីពាក់ព័ន្ធបានរាយការន៍ថា ដំណើរការនេះកាលពីមុនអាចចំណាយពេលយូរ មិនថាផ្ញើតាមសំបុត្រ ឬតាមនគរបាលយុត្តិធម៌ក្តី។ ជួនកាល ការពន្យារពេលនេះ មានន័យថា ជនសង្ស័យមានពេលវេលាដើម្បីចាកចេញពីអាសយដ្ឋានដែលបានចុះបញ្ជី និងមិនអាចទាក់ទងបាន។

"ឥឡូវនេះ យើងអាចផ្ញើដីកាតាមកម្មវិធីទំនាក់ទំនងបាន។ កាលពីមុន មានបញ្ហាជាច្រើនក្នុងការផ្ញើដីកា។ ឥឡូវនេះ យើងគ្រាន់តែផ្ញើតាមកម្មវិធីទៅកាន់បុគ្គលទទួលបន្ទុល គឺរួចជាស្រេច។ ការផ្ញើបែបនេះគឺជួយយើងបានច្រើនណាស់។"

ព្រះរាជអាជ្ញា

ជាការឆ្លើយតប ឥឡូវនេះតុលាការអាចចេញដីកាតាមកម្មវិធីតេឡេក្រាម (Telegram) និងកម្មវិធីផ្សេងៗទៀត។ តួអង្គតុលាការបានរាយការណ៍អំពីចំណុចនេះថា ជាការកែលម្អដ៏ចម្បងក្នុងន័យប្រសិទ្ធភាព ថ្លៃចំណាយ ភាពងាយស្រួល និងល្បឿន។ វិធានការនេះ ក៏បាននាំមកនូវអត្ថប្រយោជន៍តម្លាភាពកាន់តែខ្ពស់ ដោយសារតុលាការកាន់តែមានភាពសកម្មក្នុងការផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងដំណើរការនីតិវិធីតុលាការទៅកាន់ភាគីពាក់ព័ន្ធ។

## ៥.៣.៧ ការដោះស្រាយក្រៅផ្លូវការ

វាជារឿងទូទៅហើយដែលសាក្សីបដិសេធពុំនផ្តល់សក្ខីកម្ម នៅពេលដែលបានរៀបចំសំណុំរឿងរួច និងជាលទ្ធផលធ្វើឱ្យការផ្តន្ទាទោសពុំបានសម្រេច។ មានភស្តុតាងមួយចំនួនបង្ហាញអំពីមូលហេតុដែលរឿងនេះកើតឡើង។

ទី១គឺថា ករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ជួនកាលត្រូវបានប្តឹងទៅលើមិត្តភក្តិ និងសមាជិកគ្រួសាររបស់ជនរងគ្រោះ ហើយជនរងគ្រោះមិនចង់ឱ្យពួកគេទទួលរងពិន័យ។ នៅក្នុងករណីជាច្រើន មេខ្យល់ជាប់ចោទ គឺត្រូវបានគេមើលឃើញថាមានទំនាក់ទំនងជិតស្និទ្ធជាមួយជនរងគ្រោះ ដែលបានធ្វើសកម្មភាពជួយដល់ជនរងគ្រោះក្នុងការស្វែងរកការងារ។ ជាការសំខាន់ណាស់ដែលត្រូវគូសបញ្ជាក់ថា នៅក្នុងករណីជាច្រើនចំណុចនេះគឺជាការពិត ហើយបុគ្គលនោះមិនបានប្រព្រឹត្តខុសសីលធម៌ ឬមានការកេងប្រវ័ញ្ច និងមិនមែនជាផ្នែកមួយនៃប្រតិបត្តិការមេខ្យល់ផ្លូវការនោះទេ។

មូលហេតុទី២នោះគឺថា សំណុំរឿងភាគច្រើន គឺត្រូវបានដោះស្រាយក្រៅផ្លូវការតាមរយៈការបង់សំណងដោយផ្ទាល់ទៅឱ្យជនរងគ្រោះ។ ជនរងគ្រោះ ជារឿយៗគឺសប្បាយចិត្តក្នុងការទទួលយកទឹកប្រាក់សំណង និងពុំឆ្លងកាត់ដំណើរការនីតិវិធីផ្លូវច្បាប់ដែលចំណាយពេលយូរ ទោះបីជាពួកគាត់ទទួលបានត្រឹមតែចំណែកតូចមួយនៃសំណងដែលពួកគេអាចទទួលបានតាមផ្លូវច្បាប់ក្តី។ នៅក្នុងករណីមួយចំនួន ការទូទាត់សំណងទាំងនេះពីប្រតិបត្តិករ ដូចជា ទីភ្នាក់ងារជ្រើសរើសពលករ ដែលដឹងថាពួកគេអាចចៀសវាងផលវិបាកផ្លូវច្បាប់បាន ដោយគ្រាន់តែផ្តល់សំណង "ក្រោមតុ" ដល់ជនរងគ្រោះ ដើម្បីបញ្ចុះបញ្ចូលជនរងគ្រោះ ឬគ្រួសាររបស់ពួកគេឱ្យដកពាក្យបណ្តឹង។

"នៅក្នុងសំណុំរឿងភាគច្រើនដែលយើងទទួលបាន ជនរងគ្រោះដកសំណុំរឿងវិញពីតុលាការ នៅពេលដែលពួកគេទៅដល់ផ្ទះវិញ។ ពួកគេភាគច្រើនស្នើសុំឱ្យយើងជួយពួកគេត្រលប់ទៅផ្ទះវិញហើយបន្ទាប់មក ពួកគេមិនចង់ចំណាយពេលវេលាលើដំណើរការនីតិវិធីផ្លូវច្បាប់នោះទេ។ ប្រការនេះគឺដោយសារតែមេខ្យល់គឺជាសាច់ញាតិរបស់ពួកគេ ឬពួកគេមានការព្រួយបារម្ភអំពីពេលវេលា និងការចំណាយលើដំណើរការតុលាការ។ អាទិភាពរបស់ពួកគេ គឺការរកចំណូល ជាជាងការរកយុត្តិធម៌នៅតុលាការ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ស្របពេលដែលតួអង្គប្រព័ន្ធយុត្តិធម៌ និង អង្គការសង្គមស៊ីវិល អាចបង្ហាក់ដល់ករដោះស្រាយក្រៅប្រព័ន្ធតុលាការ ឬសាកសួរសកម្មអំពីមូលហេតុដែលជនរងគ្រោះដកពាក្យបណ្តឹងវិញ ការពិតគឺថា ជនរងគ្រោះនឹងមិនចូលរួមនៅក្នុងដំណើរការនីតិវិធីតុលាការនោះទេ ប្រសិនបើពួកគេជឿថា ការធ្វើបែបនេះប្រឆាំងទៅនឹងឧត្តមប្រយោជន៍របស់ពួកគេ។ ដើម្បីដោះស្រាយបញ្ហានេះ ប្រព័ន្ធតុលាការគឺចាំបាច់ត្រូវតែមានលទ្ធភាពផ្តល់លទ្ធផលល្អប្រសើរជាងនេះដល់ជនរងគ្រោះ និងដាក់ការពិន័យដល់អ្នកដែលប៉ុនប៉ងដាក់ឥទ្ធិពលពុំត្រឹមត្រូវមកលើជនរងគ្រោះ។ បញ្ហានេះ គឺកាន់តែយ៉ាប់យ៉ឺនទៅ ដោយសារតែការពឹងផ្អែកខ្លាំងពេកទៅលើសក្ខីកម្មរបស់សាក្សីនៅសវនាការ ដែលទំនងជាដោយសារតែការប្រើប្រាស់បច្ចេកទេសប្រមូលភស្តុតាងមូលដ្ឋានប៉ុណ្ណោះ។ បញ្ហាទាំងនេះ គឺត្រូវបានអង្គការ IJM បាន លើកឡើងនៅក្នុងការសិក្សាឆ្នាំ ២០១៦ ប៉ុន្តែមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះចំពោះចំណុចនេះ។

## ៥.៣.៨ ការប្រព្រឹត្តទៅលើជនរងគ្រោះ និងសាក្សី

ភាគីពាក់ព័ន្ធបានរាយការណ៍ថា តុលាការមិនបានយល់ដឹងអំពីរបៀបដែលតុលាការជះឥទ្ធិពលលើជនរងគ្រោះ និងកុមារនោះទេ។ អ្នកផ្តល់ព័ត៌មានសង្គមស៊ីវិលលើកឡើងថា ព្រះរាជអាជ្ញា និងចៅក្រមមួយចំនួន មិនបានប្រើប្រាស់នីតិវិធីងាយស្រួលសម្រាប់ជនរងគ្រោះ និងគិតគូរលើការប៉ះទង្គិចផ្លូវចិត្ត ដើម្បីការពារ និងពង្រឹងសិទ្ធិអំណាចរបស់ជនរងគ្រោះនោះទេ នៅពេលដែលពួកគេឆ្លងកាត់ដំណើរការនីតិវិធីតុលាការ។ ទោះបីជាធ្លាប់មានការលើកឡើងអំពីបញ្ហានេះកាលពីមុនរួចហើយក៏ដោយ ក៏ការអនុវត្តដែលយកចិត្តទុកដាក់លើជនរងគ្រោះ គឺមិនទាន់បានបញ្ចូលទៅក្នុងនីតិវិធី និងដំណើរការតុលាការនៅឡើយទេ។

"ក្នុងអំឡុងពេលជំនុំជម្រះ ចៅក្រមពេលខ្លះគំរាមកំហែងដល់ជនរងគ្រោះ និងភាគីពាក់ព័ន្ធតាមរយៈការសួរចម្លើយ។ អ្វីគ្រប់យ៉ាងគឺស្ថិតក្នុងដៃពួកគេ។ ពួកគេជាអ្នកទទួលបន្ទុក។ អ្វីគ្រប់យ៉ាងគឺស្រេចទៅលើគេលើកឡើងតាមចិត្ត។"

មន្ត្រីរដ្ឋាភិបាល

"ស្របពេលដែលខ្ញុំចំណាយពេលមួយឆ្នាំនៅតុលាការ ខ្ញុំបានសង្កេតឃើញថា ជនរងគ្រោះគឺមាន

ការភ័យខ្លាចស្រាប់ទៅហើយ នៅពេលដែលពួកគេឃើញចៅក្រមពាក់ឯកសណ្ឋាន។"

មន្ត្រីរដ្ឋាភិបាល

ចៅក្រមក៏មើលរំលងជាប្រចាំទៅលើសារៈសំខាន់នៃការផ្ដល់ការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះ នៅពេលដែលពួកគេឆ្លងកាត់ដំណើរការនីតិវិធីតុលាការ។ ជារឿយៗ សំណុំរឿងដំណើរការទៅដោយមិនមានការផ្ដល់ការគាំទ្រដល់ជនរងគ្រោះពីសំណាក់អង្គការសង្គមស៊ីវិល ឬ មន្ត្រីសង្គមកិច្ចឡើយ។

"ការមានមន្ត្រីសង្គមកិច្ចប្រចាំការនៅតុលាការ គឺមានសារៈសំខាន់ណាស់ ប៉ុន្តែមនុស្សមួយចំនួនហាក់បីដូចជាមើលរំលងលើគុណតម្លៃនៃចំណុចនេះ។ ជនរងគ្រោះជាទូទៅមិនយល់ ឬមិនដឹងអំពីដំណើរការនីតិវិធីផ្លូវច្បាប់នោះទេ។ ពួកគេត្រូវការការគាំទ្រចំពោះរឿងនេះ ... ខាងសង្គមកិច្ចអាចពិភាក្សាជាមួយព្រះរាជអាជ្ញានៅបេលដែលមានសំណុំរឿង និងអ្វីដែលត្រូវធ្វើដែលសមស្របនៅក្នុងដំណើរការនីតិវិធីផ្លូវច្បាប់។ ពួកគេអាចផ្ដល់ការណែនាំដល់ជនរងគ្រោះបាន។"

មន្ត្រីរដ្ឋាភិបាល

នៅក្នុងករណីមួយចំនួន សំណុំរឿងដំណើរការទៅដោយមិនមានការគាំទ្រជនរងគ្រោះដែលជាអនីតិជនឡើយ។ ប៉ុន្តែមន្ត្រីតុលាការបានគូសបញ្ជាក់អំពីតម្រូវការក្នុងការអនុវត្តវិធីសាស្ត្រកុមារមេត្រី នៅក្នុងការងាររបស់ពួកគេ។

"យើងបានប្រព្រឹត្តចំពោះជនរងគ្រោះជាអនីតិជន ដោយប្រើប្រាស់វិធីសាស្ត្រកុមារមេត្រី។ យើងផ្ដល់ពេលវេលាឱ្យពួកគេសម្រួលចិត្ត និងអារម្មណ៍។ សំណុំរឿងកុមារ ត្រូវបានកំណត់ជាអាទិភាពជានិច្ច និងដំណើរការតាមល្បឿនដែលយើងអាចធ្វើទៅបាន។"

ព្រះរាជអាជ្ញា

កាលពីមុន មានការណែនាំថា ក្រសួងយុត្តិធម៌គួរតែអនុវត្តតាមការអនុវត្តល្អសម្រាប់ការប្រព្រឹត្តចំពោះជនរងគ្រោះ និសាក្សីនៅក្នុងសាលាដំបូងទាំងអស់ ហើយការបណ្ដុះបណ្ដាលស្ដីពីការគិតគូរដល់ជនរងគ្រោះ និងការប៉ះទង្គិចផ្លូវចិត្ត គួរតែផ្ដល់ជូនដល់ព្រះរាជអាជ្ញា ចៅក្រម និងអ្នកហាត់ការទាំងអស់។ តម្រូវការនេះនៅមិនទាន់បានដោះស្រាយនៅឡើយទេ។

## ៥.៣.៩ ការចូលរួមរបស់ជនរងគ្រោះ និងសាក្សីនៅក្នុងការជំនុំជម្រះ

តួអង្គតុលាការកត់សម្គាល់ថា ជាការសំខាន់ណាស់សម្រាប់ជនរងគ្រោះ និងសាក្សីក្នុងការចូលខ្លួនមកក្នុងសវនាការ និងផ្ដល់ភស្តុតាង។

"ខ្ញុំពេញចិត្តនឹងឱ្យជនរងគ្រោះចូលរួមនៅគ្រប់ជំហានទាំងអស់នៃនីតិវិធីតុលាការ។ ពួកគេចាំបាច់ត្រូវតែមានវត្តមាននៅសវនាកា និងការពារខ្លួនឯង ដើម្បីជួយយើងឱ្យស្វែងរកការពិត។ ប្រសិនបើពួកគេអវត្តមាន ការជំនុំជម្រះគឺមិនពេញលេញនោះទេ ដោយសារតែចម្លើយរបស់ពួកគេមិនគ្រប់គ្រាន់។ យើងត្រូវការសក្ខីកម្មរបស់ពួកគេនៅក្នុងសវនាការ។"

ចៅក្រម

ទោះជាយ៉ាងនេះក្ដី តុលាការមានការលំបាកក្នុងការគាំទ្រដល់ជនរងគ្រោះ ក្នុងការជម្នះលើឧបសគ្គបេលវេលា និង

ធនធាន ដើម្បីជំរុញឱ្យពួកគេចូលរួមនៅក្នុងសវនាការ។ ឧទាហរណ៍ ជនរងគ្រោះជាច្រើនរស់នៅឆ្ងាយ និងទីទ័លក្រ។ ពួកគេត្រូវការនគរបាលយុត្តិធម៌ ដើម្បីអមដំណើរមកតុលាការ និងគាំទ្រពួកគេក្នុងការរ៉ាប់រងលើថ្លៃចំណាយលើការធ្វើដំណើរ ការស្នាក់នៅ និងចំណាយលើការរស់នៅ។ លើសពីនេះ ជនរងគ្រោះត្រូវផ្អាកការងារ ដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីផ្លូវច្បាប់ ដែលធ្វើឱ្យបាត់បង់ចំណូលយ៉ាងច្រើន។ ប្រការនេះ អាចជាឧបសគ្គរាំងដំធមមួយសម្រាប់សាក្សី និងជនរងគ្រោះជាច្រើន ហើយនៅក្នុងករណីខ្លះ ពួកគេទទួលបានដីកា ប៉ុន្តែមិនមានលទ្ធភាពធ្វើដំណើរទៅតុលាការ ដើម្បីផ្តល់សក្ខីកម្មបាន។

នៅក្នុងករណីជាច្រើន សាក្សីមិនចង់ផ្តល់ភស្តុតាងអ្វីនោះទេ ដោយសារតែត្រូវមានការប្តេជ្ញាចិត្តខ្ពស់។ ភាគីពាក់ព័ន្ធបានចង្អុលបង្ហាញថា ជាការសំខាន់ណាស់ដែលប្រព័ន្ធតុលាការធានាបាននូវការលើកទឹកចិត្តត្រឹមត្រូវដើម្បីឱ្យសាក្សីចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

## ៥.៣.១០ សមត្ថភាព និងវិជ្ជាជីវៈរបស់តួអង្គតុលាការ

តួអង្គតុលាការមានអារម្មណ៍ថា ពួកគេមានសមត្ថភាពខ្ពស់ និងមានជំនាញទូលំទូលាយនៅក្នុងការដំណើរការការជំនុំជម្រះសំណុំរឿងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ប្រការនេះបានបង្ហាញឡើងនៅក្នុងការសម្ភាសន៍ជាមួយតួអង្គតុលាការ នៅពេលដែលពួកគេពិភាក្សាអំពីភាពល្អិតល្អន់នៃស្ថានភាពសំណុំរឿង។ ការបណ្តុះបណ្តាលជាក់លាក់ស្តីពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ត្រូវបានផ្តល់ជូនជាទូទៅក្នុងចំណោមតួអង្គតុលាការ។

> "ជំនាញបច្ចេកទេសពាក់ព័ន្ធនឹងការជួញដូរមនុស្ស គឺមានកម្រិតខ្ពស់ក្នុងចំណោមចៅក្រម និងព្រះរាជអាជ្ញា។ សមាជិកម្នាក់យ៉ាងតិចនៅក្នុងខេត្តនីមួយៗ ទទួលបានការបណ្តុះបណ្តាលអំពីប្រធានបទនេះ។ សមាជិកនោះមិនត្រឹមតែមានចំណេះដឹងប៉ុណ្ណោះទេ តែថែមទាំងយកចំណេះដឹងនោះទៅអនុវត្តទៀតផង។"
>
> មន្ត្រីរដ្ឋាភិបាល

> អង្គការសង្គមស៊ីវិលបានលើកឡើងថាម្តងម្កាលស្របពេលដែលពួកគេត្រូវបានអញ្ជើញឱ្យចូលរួមការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់មន្ត្រីតុលាការដែលរៀបចំឡើងដោយរដ្ឋាភិបាល ពួកគេពុំទទួលបានការពិគ្រោះយោបល់ស៊ីជម្រៅអំពីការរៀបចំសិក្ខាសាលានោះទេ។ ពួកគេមានអារម្មណ៍ថា សិក្ខាសាលាខ្វះប្រសិទ្ធភាព និងមើលរំលងអំពីទស្សនៈរបស់អង្គការសង្គមស៊ីវិល។
>
> ចៅក្រម

## ៥.៣.១១ ការផ្តន្ទាទោស

ចាប់តាំងពីឆ្នាំ ២០២០ មក កម្ពុជាបានពង្រីកទិន្នន័យស្តីពីការផ្តន្ទាទោសសំណុំរឿងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ដើម្បីគ្របដណ្តប់នៅទូទាំងប្រទេស គឺពុំត្រឹមតែតុលាការនៅរាជធានីភ្នំពេញប៉ុណ្ណោះទេ។ ជាលទ្ធផល ការផ្តន្ទាទោសបានរាយការណ៍ថាកើនឡើងរហូតដល់ ៣៨៨ នាក់។ ទោះជាយ៉ាងនេះក្តី នៅឆ្នាំ ២០២១ ដោយសារជំងឺកូវីដ-១៩ កាត់បន្ថយការធ្វើដំណើរយ៉ាងខ្លាំង តួលេខនៃការជួញដូរមនុស្សបានធ្លាក់ចុះ និងការផ្តន្ទាទោសក៏មានការថមថយចុះយ៉ាងខ្លាំងដែរ។

*តារាង ៦៖ ការផ្ដន្ទាទោសពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស*

| ការផ្ដន្ទាទោសពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ចំនួននៃការផ្ដន្ទាទោស | ១០០* | ១២៩* | ១២៥* | ១៤០* | ៣៤៨* | ៣៨* |
| | *ទិន្នន័យនៅរាជធានីភ្នំពេញប៉ុណ្ណោះ ដូចបានរៀបរាប់ក្នុងរបាយការណ៍ស្ដីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក | | | | | |

ជាទូទៅ សវនាការមានគោលបំណងផ្ទៀងផ្ទាត់អំពីការពិតនៃសំណុំរឿងក្ដីដែលបានផ្ដល់ជូន និងផ្ទៀងផ្ទាត់ភស្ដុតាង ដើម្បីបញ្ជាក់ថាបានបំពេញតាមការជំនុំជម្រះផ្លូវច្បាប់ ដើម្បីរក្សាបាននូវការផ្ដន្ទាទោស។

"ក្នុងអំឡុងពេលសវនាការ តុលាការបានរកឃើញថា អ្វីគ្រប់យ៉ាងគឺត្រូវគ្នាជាមួយនឹងសំណុំរឿង និងរបាយការណ៍ និងភស្ដុតាង។ ដូច្នេះ ពួកគេត្រូវតុលាការបានរកឃើញថាពួកគេមានពិរុទ្ធភាព និងត្រូវដាក់ពន្ធនាគារ។"

ចៅក្រម

ទោះបីជាអនុវត្តតាមនីតិវិធីតុលាការក៏ដោយ ក៏ភាគីពាក់ព័ន្ធមានអារម្មណ៍ថា អ្នកមានអំណាច និងមន្ត្រីរដ្ឋាភិបាល គឺនៅពីលើច្បាប់។ ពួកគេមានអារម្មណ៍ថា តុលាការគឺមិនមែនមិនលម្អៀងនោះទេ ហើយប្រជាជនខ្វះការជឿទុកចិត្តលើដំណើរការ ទោះបីជាមានការលើកឡើងថាដំណើរការមានការកែលម្អប្រសើរជាងមុនក្ដី។

"ប្រសិនបើមានរឿងក្ដីតុលាការរវាងមនុស្សធម្មតាម្នាក់ និងអ្នកមាន អ្នកមានអំណាច នោះអ្នកក្រគឺទំនងជាចាញ់ក្ដី និងពុំទទួលបានយុត្តិធម៌នោះទេ។ ទោះជាយ៉ាងនេះក្ដី ប្រសិនបើរឿងក្ដីតុលាការពាក់ព័ន្ធនឹងអ្នកគ្មានទោសកំហុស សាមញ្ញជនដែលដាក់ពាក្យបណ្ដឹងប្ដឹងគ្នាទៅវិញទៅមក នោះអាចមានយុត្តិធម៌ខ្លះ។"

អ្នកផ្ដល់ព័ត៌មានអង្គការសង្គមស៊ីវិល

នៅក្នុងរឿងក្ដីពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានលើពលករ អំណាចមិនស្មើគ្នាក៏ជះឥទ្ធិពលលើសមត្ថភាពរបស់ពលករក្នុងការចាត់វិធានការផ្លូវច្បាប់ផងដែរ។ ពេលខ្លះ ពលករខ្វះឯកសារការងារ និងភស្ដុតាងលាយលក្ខណ៍អក្សរផ្សេងទៀត ស្របពេលដែលនិយោជករក្សាទុកកំណត់ត្រានានា ដើម្បីការពារខ្លួនឯង ប៉ុន្តែឯកសារទាំងនេះមិនបានចែករំលែកជាមួយពលករនោះទេ។ ជួនកាល និយោជកថែមទាំងថតសំឡេងរបស់ពលករទុកដែលព្រមព្រៀងទៅលើកិច្ចព្រមព្រៀងដែលមិនបានផ្ដល់ជូនច្បាស់លាស់ដល់ពលករផង។ ជាលទ្ធផល និយោជកមានភស្ដុតាងល្អប្រសើរជាងពលករនៅពេលដែលយកសំណុំរឿងមកជំនុំជម្រះ។ និយោជក ក៏ទំនងជាមានលទ្ធភាពច្រើនក្នុងការជួលមេធាវីឱ្យការពារក្ដីឱ្យពួកគេ ដែលធ្វើឱ្យមានការលំបាកដល់ពលករ និងព្រះរាជអាជ្ញាក្នុងការផ្ដន្ទាទោសដល់និយោជកពីបទរំលោភបំពានពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។

## ៥.៣.១២ ការវិនិច្ឆ័យទោស

យុទ្ធនាការមួយកាលពីពេលថ្មីៗពាក់ព័ន្ធនឹងការកាត់បន្ថយចំនួនអ្នកជាប់ពន្ធនាគារ និងការទប់ស្កាត់ភាពចង្អៀតណែនក្នុងពន្ធនាគារដោយហេតុផលជំងឺកូវីដ-១៩នោះ គឺជាកត្តាជំរុញមួយ។ ប្រការនេះ បាននាំឱ្យមានការដោះលែងអ្នកទោស

ចូលទៅក្នុងសហគមន៍វិញ តាមរយៈការដោះលែងដោយមានលក្ខខណ្ឌ និងការព្យួរទោស។ យោងតាមព្រះរាជអាជ្ញាដែលបានសម្ភាសន៍ អ្នកទោសប្រហែល ៤០.០០០ នាក់ គឺត្រូវបានដោះលែងដោយសារតែយុទ្ធនាការនេះ។ ដូចគ្នានេះដែរ តុលាការបានបង្ហាញអំពីទំនោរក្នុងការរុញជនល្មើសទៅក្នុងកម្មវិធីបម្លែង ដែលរារាំងពួកគេមិនឱ្យជាប់ពន្ធនាគារ។

"ច្បាប់មានចែងអំពីនីតិវិធីបម្លែង។ ក្នុងករណីដែលមិនមានកម្មវិធីបម្លែង យើងបានដោះលែងពួកគេទៅក្នុងសហគមន៍វិញ ដោយមានការត្រួតពិនិត្យពីសំណាកប៉ុស្ដិ៍នគរបាល។ ការធ្វើបែបនេះនឹងជៀសវាងការចង្អៀតណែនក្នុងពន្ធនាគារផងដែរ ហើយជនល្មើសអាចនៅផ្ទះបាន។"

មន្ត្រីរដ្ឋាភិបាល

ស្របពេលអាជ្ញាធរ និងព្រះរាជអាជ្ញាបាន និងកំពុងជំរុញឱ្យមានការផ្អាកផ្តន្ទាទោសដាក់ពន្ធនាគារ និងជំរុញទៅរកកម្មវិធីបម្លែង ប្រការនេះធ្វើឱ្យអ្នកអង្កេតការណ៍មួយចំនួនមានការងឿងឆ្ងល់ថាតើធ្វើឱ្យធ្លាក់ចុះសុពលភាពនៃការផ្តន្ទាទោសដែរឬទេ។ ពួកគេលើកទឡ្ហីករណ៍ថា តាមវិធីសាស្ត្រទាំងនេះ មានការធានាតិចតួចអំពីការអនុលោមតាមលក្ខខណ្ឌ និងមានយន្តការត្រួតពិនិត្យតិចតួចប៉ុណ្ណោះ។

ពេលការផ្តន្ទាទោសពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សដាក់ពន្ធនាគារ ការវិនិច្ឆ័យទោសរយៈពេលវែង គឺកម្រនឹងអនុវត្តណាស់។ ព្រះរាជអាជ្ញារាយការណ៍ថា កម្រណាស់ដែលពួកគេផ្តន្ទាទោសអ្នកដឹកនាំប្រតិបត្តិការជួញដូរមនុស្សទ្រង់ទ្រាយធំ និងពួកគេទំនងជាផ្តន្ទាទោសលើមេខ្យល់តូចតាចច្រើនជាង។

"ចំពោះករណីនេះ មូលហេតុនៃការធ្វើចំណាកស្រុក អ្នកភូមិគ្រាន់តែទៅស្វែងរកការងារតាមគ្នាប៉ុណ្ណោះ។ ប្រការនេះ ពុំចាត់ទុកថាជាការជួញដូរមនុស្សទេ។ មូលហេតុនេះហើយទើបពួកគេជាប់ពន្ធនាគារតែ ៣ ឆ្នាំ ដែលជាការផ្តន្ទាទោសសមរម្យសម្រាប់មេខ្យល់។ យើងពុំដឹងថាតើត្រូវឱ្យជនល្មើសសងសំណងដូចម្តេចនោះទេចំពោះករណីនេះ។"

ចៅក្រម

ប្រសិនបើគូក្តីពុំពេញចិត្តនឹងលទ្ធផលជំនុំជម្រះទេ ពួកគេអាចដាក់បណ្តឹងនៅសាលាឧទ្ធរណ៍ ដើម្បីប្តឹងជំទាស់នឹងរឿងក្តីរបស់ពួកគេបាន។ អ្នកឆ្លើយតបមិនបានរាយការណ៍អំពីមតិត្រលប់ជាក់លាក់ពាក់ព័ន្ធនឹង សាលាឧទ្ធរណ៍ និងយន្តការបណ្តឹងឧទ្ធរណ៍នោះទេ។

## ៥.៣.១៣ ទិន្នន័យរឿងក្តី

ក្នុងអំឡុងពេលនៃការស៊ើបអង្កេតចុងក្រោយរបស់អង្គការ IJM ទៅលើប្រព័ន្ធយុត្តិធម៌សាធារណៈកម្ពុជានៅឆ្នាំ ២០១៦ អង្គការបានកំណត់ថា ចាំបាច់ត្រូវចាប់យក និងតាមដានទិន្នន័យសវនាការឱ្យបានសុក្រឹត។ តម្រូវការជាក់លាក់រួមមានទិន្នន័យអំពីការចាប់ខ្លួន ការចោទប្រកាន់ និងការផ្តន្ទាទោស និងការឱ្យរួចទោសលើរឿងក្តីពលកម្មដោយបង្ខំ និងករណីជួញដូរមនុស្ស។ លើសពីនេះ ទិន្នន័យនេះអាចប្រមូលបានសម្រាប់តុលាការខេត្តនីមួយៗ និងចែករំលែកជាមួយភាគីពាក់ព័ន្ធនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។

ក្នុងរយៈពេល ៥ឆ្នាំ កន្លងមកនេះ តួអង្គតុលាការបានរាយការណ៍ថា ពួកគេបានលើកកម្ពស់ការប្រមូលទិន្នន័យ និងពេញចិត្តលើទិន្នន័យដែលបានប្រមូល និងបានចែករំលែកទិន្នន័យទាំងនោះនៅក្នុងដំណើរការតុលាការ។ សម្រាប់គោលបំណងរបស់ពួកគេ ពួកគេមានអារម្មណ៍ថាទិន្នន័យដែលពួកគេត្រូវការ គឺបានផ្តល់ដល់ពួកគេ។ ការកែលម្អជាក់លាក់មួយ

ដែលបានកំណត់ឃើញ គឺការប្រមូលទិន្នន័យពីតុលាការខេត្ត ដែលបច្ចុប្បន្នពង្រីកហួសពីតុលាការនៅរាជធានីភ្នំពេញទៅទៀត។ ទោះជាយ៉ាងនេះក្តី តួអង្គថ្នាក់ខេត្តបាននិយាយថា ពួកគេចង់កែលម្អប្រព័ន្ធរបស់ពួកគេបន្ថែមទៀត។

ដោយពិនិត្យមើលទៅលើទិន្នន័យដែលបានផ្តល់ជូនដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកកាលពីរយៈពេល ៥ឆ្នាំ កន្លងមក បានបង្ហាញថា ទិន្នន័យដែលប្រមូលបាន គឺពុំមានសង្គតិភាព និងពុំបានផ្តល់ជូនទូលំទូលាយនោះទេ។ ទិន្នន័យថ្នាក់ខេត្ត គឺមិនបានរាយការណ៍ជានិច្ចនោះទេ និងពុំមានការបែងចែកច្បាស់លាស់ឡើយ។ ប្រភេទរឿងក្តីក៏មិនបានបែងចែកឱ្យច្បាស់លាស់ និងមិនច្បាស់ថាតើរឿងក្តីណាបានដោះស្រាយ ឬកំពុងដំណើរការដល់ដំណាក់កាលណានៅក្នុងប្រព័ន្ធនោះទេ។ តម្រូវការឱ្យមានការរាយការណ៍ទិន្នន័យឱ្យបានច្បាស់ គឺនៅមិនទាន់បានដោះស្រាយនៅឡើយទេ។ លើសពីនេះ ប្រព័ន្ធច្បាស់លាស់សម្រាប់ការប្រមូល ការចែករំលែក និងការរាយការណ៍ទិន្នន័យ ចាំបាច់ត្រូវបង្កើតឡើងនៅទូទាំងប្រព័ន្ធទាំងមូល។



# ៦ ការគាំទ្រជនរងគ្រោះ និងសាក្សី

# ៦ ការគាំទ្រជនរងគ្រោះ និងសាក្សី

## ៦.១ ការកំណត់អត្តសញ្ញាណជនរងគ្រោះ

### ៦.១.១ សកម្មភាពទប់ស្កាត់ និងការយល់ដឹង

ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺជាដំណើរការដែលបុគ្គលម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ហើយជាលទ្ធផលផ្ដល់សិទ្ធដល់ពួកគេទទួលបានសេវាគាំទ្រសិទ្ធិ និងការការពារ។ ការកំណត់អត្តសញ្ញាណផ្លូវការ គួរតែផ្ដល់ឱកាសសម្រាប់ជនរងគ្រោះដើម្បីបញ្ជូនទៅរកជំនួយ និងទទួលយុត្តិធម៌។

ចំពោះជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណដោយប្រព័ន្ធយុត្តិធម៌ តួអង្គចំនួនពីរ ត្រូវតែមកជាមួយគ្នា៖ (១) ជនរងគ្រោះដែលចង់បង្ហាញអត្តសញ្ញាណ និង (២) អ្នកកាន់តួនាទីដែលមានសិទ្ធិអំណាចកំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ចូលពួកគេទៅក្នុងប្រព័ន្ធបញ្ជូនជនរងគ្រោះ។ ដូចនេះ ឆន្ទៈរបស់ជនរងគ្រោះដើម្បីចូលទៅក្នុងប្រព័ន្ធនេះ គឺជាជំហានសំខាន់ដំបូងដើម្បីសម្រេចបាននូវប្រព័ន្ធយុត្តិធម៌ជាមួយនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។

ដូចដែលបានពិភាក្សាក្នុងផ្នែក ៥.២.៤ (ជនរងគ្រោះមានបំណងរាយការណ៍) មានហេតុផលគួរឱ្យកត់សម្គាល់ដែលជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ពុំចង់ឱ្យប្រព័ន្ធយុត្តិធម៌កំណត់អត្តសញ្ញាណពួកគេនោះទេ។ បន្ថែមពីលើហេតុផលទាំងនេះទៀត ជនរងគ្រោះទំនងជាពុំដឹងថាមានសេវានោះទេ។ ដូចគ្នានេះដែរ ជនរងគ្រោះប្រហែលជាពុំអាចកំណត់អត្តសញ្ញាណរបស់ពួកគេដោយខ្លួនឯងបានថាពួកគេស្ថិតក្នុងស្ថានភាពជាពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនោះទេ ដោយហេតុតែពួកគេពុំយល់ដឹងពីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស សិទ្ធរបស់ពួកគេ និងអ្វីដែលត្រូវធ្វើក្នុងកាលៈទេសៈទាំងនេះ។

មកទល់នឹងពេលនេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានលើកឡើងពីការផ្ដល់ការតម្រង់ទិសមុនពេលចេញដំណើរដល់ពលករខ្មែរចំនួន ២០.៣៦០ នាក់នៅឆ្នាំ ២០២០។ ដូចគ្នានេះដែរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើសកម្មភាពបញ្ជ្រាបការយល់ដឹងជាច្រើនដូចជាវេទិកាពិភាក្សាសាធារណៈ វេទិកាពិភាក្សាតាមប្រព័ន្ធអ៊ីនធឺណិត សិក្ខាសាលា កម្មវិធីជជែកតាមវិទ្យុ និងកម្មវិធីទូរទស្សន៍។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា កាលពីពេលថ្មីៗនេះបានធ្វើការរួមគ្នាជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអនុវត្តកម្មវិធីសិក្សារបស់សាលាក្នុងការអប់រំសិស្សានុសិស្ស និងគ្រូបង្រៀនអំពីអំពើជួញដូរមនុស្ស។

ការបណ្ដុះបណ្ដាលទាំងនេះ គឺមានគុណភាពខុសៗគ្នា។ ការបណ្ដុះបណ្ដាលដែលគ្រាន់តែប្រាប់ដល់ពលករទេសន្តរប្រវេសន៍ឱ្យអនុវត្ត "ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពប៉ុណ្ណោះ" ដោយប្រើប្រាស់បណ្ដាញចំណាកស្រុកដែលបានចុះអនុស្សារណៈនៃការយោគយល់ គឺគ្រប់គ្រាន់ ដោយក្របខណ្ឌអនុស្សារណៈនៃការយោគយល់មិនផ្ដល់នូវការធានាសុវត្ថិ

ភាពរបស់ពលករចំណាកស្រុកឡើយ។ ពលករក៏ត្រូវតែរៀនអំពីសិទ្ធការងារ សេណារីយ៉ូទូទៅនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស របៀបសម្គាល់ស្ថានភាពនិងនិយោជកដែលរំលោភបំពាន និងអ្វីដែលត្រូវធ្វើនៅក្នុងស្ថានភាពជាក់ស្តែង។

ទោះជាយ៉ាងណាក៏ដោយ ការបណ្តុះបណ្តាលផ្តល់ព័ត៌មានដល់ពលករ និងសហគមន៍អំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងជាទូទៅផ្តល់ជូនពលករចំណាកស្រុកនូវព័ត៌មានទំនាក់ទំនងលម្អិតអំពី អង្គការមិនមែនរដ្ឋាភិបាល និងខ្សែទូរស័ព្ទបន្ទាន់របស់រដ្ឋាភិបាលជាច្រើន ដែលអាចពិគ្រោះយោបល់សុំជំនួយបាន។ គួរកត់សម្គាល់ផងដែរថា ពលករចំណាកស្រុកជាច្រើនកាលពីពេលថ្មីៗនេះ ទំនងជាមានព័ត៌មានជាច្រើនអំពីកន្លែងទទួលជំនួយ ដោយបង្ហាញថាមានការកែលម្អលើចំណុចនេះ។

*តារាង ៧៖ ចំនួនអ្នកចូលរួមការបណ្តុះបណ្តាលមុនពេលចេញដំណើររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

| ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|
| ៦៩.០០០ | ៨៨.០០០ | ២០.៣៦០ | មិនមានរបាយការណ៍ |
| *ប្រភព៖ របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក* | | | |

## ៦.១.២ បណ្តាញរាយការណ៍ជូរមុខ

ការកំណត់អត្តសញ្ញាណអាចកើតឡើងនៅពេលបុគ្គលម្នាក់ត្រូវបានគេគេងប្រវ័ញ្ច និងនាំឱ្យមានការបញ្ឈប់ការជួញដូរកេងប្រវ័ញ្ច។ ក្នុងករណីផ្សេងទៀត អាចកើតឡើងនៅពេលបុគ្គលម្នាក់បានគេចខ្លួន ឬចាកចេញពីស្ថានភាពជួញដូរមនុស្ស។ បណ្តាញរាយការណ៍ទូទៅរួមមាន៖

- **អង្គការមិនមែនរដ្ឋាភិបាល៖** ធ្វើប្រតិបត្តិការ ខ្សែទូរស័ព្ទបន្ទាន់ ឬអនុវត្តសកម្មភាពចុះផ្តល់សេវាតាមមូលដ្ឋាន
- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖** ទទួលបណ្តឹងតាមរយៈគេហទំព័រ ហ្វេសប៊ុក (Facebook) និងធ្វើប្រតិបត្តិការខ្សែទូរសព្ទបន្ទាន់ ២៤ ម៉ោង រួមគ្នាជាមួយក្រសួងមហាផ្ទៃ។ ខ្សែទូរស័ព្ទបន្ទាន់នេះគឺត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយ ប៉ុន្តែយោងតាមរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក ខ្សែទូរស័ព្ទនេះបានទទួលការហៅចូលត្រឹមតែ ២១ ប៉ុណ្ណោះនៅឆ្នាំ ២០២១ និងពុំមានការហៅចូលណាពាក់ព័ន្ធនឹងករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សនោះទេ។
- **ក្រសួងកិច្ចការនារី៖** ធ្វើប្រតិបត្តិការខ្សែទូរស័ព្ទបន្ទាន់ និងបណ្តាញរាយការណ៍តាមអ៊ីនធឺណិត។ ពេលដែលក្រសួងកិច្ចការនារីទទួលបានរបាយការណ៍ ក្រសួងបញ្ជូនករណីទៅកាន់នគរបាលយុត្តិធម៌ ចែករំលែកព័ត៌មានជាមួយស្នងការដ្ឋាននគរបាលជាតិ ដែលបញ្ជូនករណីទៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងស្ថានទូត។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** មិនមានការិយាល័យ ដើម្បីទទួលបណ្តឹងនោះទេ។ ក្រសួងលើកឡើងថា ប្រសិនបើក្រសួងទទួលព័ត៌មានពាក់ព័ន្ធនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សនៅកន្លែងធ្វើការ ក្រសួងនឹងបញ្ជូនព័ត៌មាននោះបន្ត។
- **ក្រុង និងខេត្ត៖** ធ្វើប្រតិបត្តិការខ្សែទូរស័ព្ទបន្ទាន់របស់ខ្លួនសម្រាប់ការរាយការណ៍ និងជំនួយ។
- **ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងស្ថានទូត៖** បណ្តាស្ថានទូតនៅក្រៅប្រទេសមានអនុព័ន្ធការងារមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអ្នកតំណាងមកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ ស្ថានទូតកម្ពុជាជាមួយនឹងប្រទេសគោលដៅ ធ្វើប្រតិបត្តិការខ្សែទូរស័ព្ទបន្ទាន់សម្រាប់ពលករខ្មែរធ្វើការងារនៅក្រៅប្រទេសក្នុងការស្វែងរកជំនួយ និងរាយការណ៍អំពីករណីជួញដូរមនុស្ស។ នៅឆ្នាំ២០២១ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ បានទទួលការហៅទូរស័ព្ទចូល ១.១០៩ ស្ថានទូតប្រចាំនៅ

កូរ៉េខាងត្បូងបានទទួលការហៅចូលទូរស័ព្ទ ១៨៦ និងស្ថានទូតប្រចាំនៅប្រទេសជប៉ុនបានទទួលការហៅចូលទូរសព្ទ ៥៨០។

- **នគរបាលមូលដ្ឋាន៖** ធ្វើប្រតិបត្តិការខ្សែទូរស័ព្ទបន្ទាន់របស់ខ្លួនសម្រាប់ការរាយការណ៍ និងជំនួយ។
- **មជ្ឈមណ្ឌលសំចត៖** ជាពិសេស មជ្ឈមណ្ឌលសំចតនៅប៉ោយប៉ែត និងកំរៀង។

ជាទូទៅ បណ្តាញរាយការណ៍ទាំងនេះ គឺត្រូវបានគេរាយការណ៍ថាមានការពេញនិយមនៅក្នុងសហគមន៍ជាច្រើន។

## ៦.១.៣ ការកំណត់អត្តសញ្ញាណជនរងគ្រោះបឋម

ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺត្រូវបានចាត់ទុកថា "ក្រៅផ្លូវការ" ប្រសិនបើការកំណត់អត្តសញ្ញាណនេះធ្វើឡើងដោយអ្នកដែលមិនមានសិទ្ធិអំណាចផ្លូវច្បាប់ក្នុងការធ្វើការកំណត់ផ្លូវការ។ នៅក្នុងការអនុវត្តជាក់ស្តែង ប្រការនេះកើតឡើងជារឿយៗដោយសារតែ ការកំណត់អត្តសញ្ញាណបឋមនឹងធ្វើឡើងដោយ អង្គការមិនមែនរដ្ឋាភិបាល ឬអ្នកផ្តល់សេវា បន្ទាប់ពីកំណត់អត្តសញ្ញាណហើយ ជនរងគ្រោះត្រូវបានបញ្ជូនទៅកាន់ការកំណត់អត្តសញ្ញាណផ្លូវការ និងជំនួយ។ លំនាំនៃការកំណត់អត្តសញ្ញាណនេះ គឺជារឿងទូទៅដោយសារតែវាមានភាពងាយស្រួលជាង ហើយជនរងគ្រោះមានផាសុកភាពក្នុងការរាយការណ៍ដល់អង្គការមិនមែនរដ្ឋាភិបាលជាងរាយការណ៍ទៅមន្ត្រី។

ជាទូទៅ នគរបាលមូលដ្ឋាន គឺជាអ្នកឆ្លើយតបជួរមុខផ្សេងទៀតចំពោះករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សដែលអនុវត្តការស៊ើបអង្កេតបឋមមុនពេលការកំណត់អត្តសញ្ញាណជនរងគ្រោះផ្លូវការ និងបញ្ជូនករណី។ ក្នុងន័យសមត្ថភាពនគរបាលមូលដ្ឋានក្នុងការអនុវត្តការកំណត់អត្តសញ្ញាណជនរងគ្រោះ ភាគីពាក់ព័ន្ធបានផ្តល់មតិត្រលប់ចម្រុះ។ ឧទាហរណ៍ ភាគីពាក់ព័ន្ធខ្លះបានលើកឡើងថា សមត្ថភាពមានកម្រិតទាប។ ភាគីពាក់ព័ន្ធខ្លះទៀតបានរាយការណ៍ថាសមត្ថភាពនៅថ្នាក់មូលដ្ឋានគឺមានការកែលម្អ។

"ជាទូទៅ នគរបាលមូលដ្ឋានហាក់បីដូចជាមានចំណេះដឹងនៅមានកម្រិតណាស់។ ពេលយើងត្រូវការការគាំទ្រក្នុងការកំណត់អត្តសញ្ញាណ ពួកគាត់ថែមទាំងពុំស្វែងរកព័ត៌មានឱ្យពួកយើងផង។ ពួកគាត់ពុំអាចទាំងសរសេរឈ្មោះបានត្រូវផង។"

ចៅក្រម

មធ្យោបាយមួយទៀតក្នុងការកសាងសមត្ថភាពកំណត់អត្តសញ្ញាណកាលពីឆ្នាំកន្លងទៅនេះ គឺតាមរយៈការកសាងចំណេះដឹង និងការយល់ដឹងអំពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សនៅក្នុងសហគមន៍។ ការធ្វើបែបនេះជួយឱ្យប្រជាជនក្នុងសហគមន៍ចេះកំណត់អត្តសញ្ញាណ និងរាយការណ៍អំពីស្ថានភាពពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សណាមួយដែលអាចកើតមាន។ ការយល់ដឹងក្នុងសហគមន៍ ក៏អាចធ្វើឱ្យទៅជាផ្លូវការបានតាមរយៈគំនិតផ្តួចផ្តើមរៀបចំយន្តការការពារតាមសហគមន៍បានផងដែរ។ យុទ្ធសាស្ត្រនេះត្រូវបានរាយការណ៍ពីសំណាក់ភាគីពាក់ព័ន្ធថាមានប្រសិទ្ធភាព ដោយសារតែវិធីសាស្ត្រនេះពង្រឹងសិទ្ធិអំណាចសហគមន៍ឱ្យសម្របសម្រួលដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ឧទាហរណ៍ នៅក្នុងភូមិមួយ កម្មាភិបាលនៃជំនួយការនគរបាល ត្រូវបានរៀបចំឡើងដោយមានតួនាទីជាច្រើន ដែលក្នុងនោះគឺមានតួនាទីកំណត់រកពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សនៅក្នុងសហគមន៍។

### ៦.១.៤ ការកំណត់អត្តសញ្ញាណជនរងគ្រោះផ្លូវការ

អ្នកមានសិទ្ធិអនុវត្តកំណត់អត្តសញ្ញាណជនរងគ្រោះផ្លូវការ មានដូចខាងក្រោម៖

- អាជ្ញាធរមូលដ្ឋាននៅថ្នាក់ឃុំ ស្រុក ទីរួមខេត្តនិងក្រុង
- នគរបាលយុត្តិធម៌
- មន្ត្រីសង្គមកិច្ច
- មន្ត្រីទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ
- បុគ្គលិកអង្គការសង្គមស៊ីវិលដែលធ្វើការងារលើផ្នែកការពារជនរងគ្រោះ
- មន្ត្រីប្រឆាំងការជួញដូរមនុស្សនៃកងរាជអាវុធហត្ថ
- បេសកកម្មការទូតគាំទ្រជនរងគ្រោះ
- ទីភ្នាក់ងារគាំទ្រនៅក្រៅប្រទេស

សម្រាប់ការស៊ើបអង្កេតផ្លូវការ នគរបាល និងភាគីពាក់ព័ន្ធផ្សេងទៀត នឹងត្រូវបានអំពាវនាវឱ្យជួយដល់នគរបាលយុត្តិធម៌ ដែលជាអ្នកផ្តល់ទិសដៅសម្រាប់ការស៊ើបអង្កេតរឿងក្តី និងការកំណត់អត្តសញ្ញាណជនរងគ្រោះ។ មន្ត្រីសង្គមកិច្ច នឹងធ្វើការងារជាមួយនគរបាលមូលដ្ឋាន និងពិគ្រោះយោបល់ជាមួយ អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីសង្គមកិច្ច ដើម្បីជួយដល់ការកំណត់អត្តសញ្ញាណផ្លូវការ។ ប្រសិនបើករណីនេះកើតឡើងនៅក្រៅប្រទេស ចាំបាច់ត្រូវទំនាក់ទំនងទៅកាន់ស្ថានទូតកម្ពុជាផងដែរ។ តួអង្គសំខាន់ៗទាំងនេះបានរៀបរាប់ថា ពួកគេទុកចិត្តលើសមត្ថភាពរបស់ពួកគេក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងមានទំនុកចិត្តលើសមភាគី។ កិច្ចពិភាក្សារវាងតួអង្គទាំងនេះជួយដល់ការស្វែងរកវិធីសាស្ត្ររួម។

"កិច្ចប្រជុំទៀតទាត់របស់គណៈកម្មាធិការខេត្តប្រឆាំងអំពើជួញដូរមនុស្ស គឺមានប្រយោជន៍ក្នុងពិភាក្សាក្នុងចំណោមសមាជិកស្តីពីការកំណត់អត្តសញ្ញាណករណី ។ នគរបាល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត តួអង្គតុលាការ និងអ្នកពាក់ព័ន្ធផ្សេងទៀតបានចូលរួមក្នុងការបណ្តុះបណ្តាល និងសិក្ខាសាលាជាមួយគ្នាស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការកំណត់ករណី។"

មន្ត្រីរដ្ឋាភិបាល

យោងតាមអ្នកផ្តល់សម្ភាសន៍មួយចំនួន បញ្ហាប្រឈមចម្បងចំពោះការកំណត់អត្តសញ្ញាណបានដោយជោគជ័យ គឺកង្វះព័ត៌មាននៅមូលដ្ឋាន ដែលកើតចេញពីសមត្ថភាពនៅមានកម្រិតរបស់នគរបាលមូលដ្ឋាន។

*តារាង ៨ ៖ ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក*

| ជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណ របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| បានកំណត់អត្តសញ្ញាណសរុប | ៣២៦ | ១៧៩ | ២៣៥ | ១៤២ | ៤១៧ | ៣៦៤ |
| ពុំមែនផ្លូវភេទ | | | | ៦៦ | ៣២២ | |
| ការជួញដូរផ្លូវភេទ | | | | ៧៦ | ៩៥ | |

## ៦.១.៥ ការប្រើប្រាស់គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ

នៅដើមឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។ គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការចូលរួមពីសំណាក់ក្រសួងស្ថាប័ន និងមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើស្តង់ដារនីយកម្មការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរមនុស្ស និងដើម្បីធានាបាននូវការផ្តល់សេវាជូនដល់ជនរងគ្រោះ។

ក្នុងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ មានទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះចំនួនពីរដែលបានផ្តល់ជូន៖ ទម្រង់ខ្លី (ឧបសម្ព័ន្ធ ២) ឬទម្រង់សម្ភាសន៍លម្អិត (ឧបសម្ព័ន្ធ ៣) (ជារឿយៗហៅថា "ទម្រង់លម្អិត" ឬ "ទម្រង់វែង")។ លក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរមនុស្ស គឺមានចែងនៅក្នុងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមរយៈបណ្តុំសូចនាករគ្រោះថ្នាក់ពាក់ព័ន្ធនឹងទិដ្ឋភាពផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងហិរញ្ញវត្ថុ។ សេណារីយ៉ូជាក់លាក់ ក៏មានផ្តល់ជូនដើម្បីជាជំនួយដល់ការកំណត់អត្តសញ្ញាណផងដែរ។ ទោះជាយ៉ាងនេះក្តី មានព័ត៌មានលម្អិតតិចតួចបំផុតដែលផ្តល់ជូនអំពីរបៀបប្រើប្រាស់សូចនាករជាមូលដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណ។

ភាគីពាក់ព័ន្ធបានផ្តល់មតិត្រលប់ចម្រុះអំពី គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយបង្ហាញថា គោលការណ៍ទាំងនេះគឺត្រូវបានយកមកប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែចាំបាច់ត្រូវមានមតិត្រលប់ និងការកែលម្អដើម្បីធានាបានថាគោលការណ៍នេះគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ប្រើប្រាស់នៅពេលអនាគតផងដែរ។ ការធ្វើបច្ចុប្បន្នភាពនេះ បច្ចុប្បន្នគឺកំពុងតែអនុវត្តដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានមតិត្រលប់ពីភាគីពាក់ព័ន្ធ។

ផលវិបាកមួយកើតមានដោយសារតែអង្គការមិនមែនរដ្ឋាភិបាល ក្រសួងស្ថាប័ន និងនគរបាលយុត្តិធម៌ ពុំបានប្រើប្រាស់គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណដូចគ្នា និងពុំមានអារម្មណ៍ថាគោលការណ៍ណែនាំនេះអនុវត្តចំពោះគ្រប់កាលៈទេសៈទាំងអស់នោះទេ។ នគរបាលបញ្ជាក់ថា ពួកគេពុំបានប្រើប្រាស់ទម្រង់នេះទេ ដោយសារតាមការយល់ឃើញរបស់ពួកគេ ទម្រង់នេះមិនសមស្របតាមគោលបំណង ស្របពេលដែលតួអង្គថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្តមួយចំនួនមានអារម្មណ៍ថា គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ អនុវត្តតែចំពោះតួអង្គថ្នាក់ជាតិប៉ុណ្ណោះ។

"របៀបកំណត់ឧក្រិដ្ឋកម្ម គឺមានភាពចំរូងចំរាស់។ នគរបាលមាននីតិវិធី និងលក្ខណៈវិនិច្ឆ័យផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការកំណត់អត្តសញ្ញាណ និងចាត់ថ្នាក់ករណី។ ពួកគេពុំប្រើប្រាស់ទម្រង់កំណត់អត្តសញ្ញាណដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនោះទេ។ ពួកគេបង្កើតទម្រង់កំណត់អត្តសញ្ញាណផ្ទាល់ខ្លួន។ ពួកគេនិយាយថា បើពួកគេអនុវត្តតាមទម្រង់របស់គណៈកម្មាធិការជាតិ នោះពួកគេពុំអាចកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មណាមួយបានឡើយ។ ចំពោះវិស័យតុលាការ ពួកគេមាននីតិវិធី និងលក្ខណៈវិនិច្ឆ័យផ្ទាល់ខ្លួនដែរ។ ពួកគេប្រើប្រាស់នីតិវិធី និងលក្ខណៈវិនិច្ឆ័យរបស់ខ្លួនដើម្បីចាត់ថ្នាក់ឧក្រិដ្ឋកម្ម។ឯកសារផ្លូវច្បាប់មានស្រាប់របស់ក្រសួងពាក់ព័ន្ធនីមួយៗ គឺពុំមានភាពបន្សុីគ្នា និងសង្គតិភាពនោះទេ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ជារួម ស្របពេលភាគីពាក់ព័ន្ធបានរាយការណ៍អំពីការយល់ដឹងរួមនៅក្នុងការកំណត់អត្តសញ្ញាណករណីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សក្តី ពួកគេមានអារម្មណ៍ថា ភាពមិនស្របគ្នានៅក្នុងទម្រង់ និងនីតិវិធីកំណត់អត្តសញ្ញាណរវាងភាគីពាក់ព័ន្ធ នៅតែបន្តជាឧបសគ្គរាំងដល់ការសហការណ៍ និងដំណើរការការងាររលូន។

## ៦.១.៦ មជ្ឈមណ្ឌលសំចត និងការនិរទេសពលករពីប្រទេសថៃ

មជ្ឈមណ្ឌលសំចត ក៏ហៅម្យ៉ាងទៀតថា "មជ្ឈមណ្ឌលទទួលពលករ" មានទីតាំងស្ថិតនៅតាមបណ្តោយព្រំដែនថៃ-កម្ពុជា សម្រាប់ទទួល និងត្រួតពិនិត្យពលករត្រលប់វចូលមកវិញភ្លាមៗ (ខុសប្រក្រតី) ដែលបានបណ្តេញចេញពីប្រទេសថៃ។ មជ្ឈមណ្ឌលទាំងនេះ ត្រូវបានរៀបចំឡើងសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ វាយតម្លៃតម្រូវការ ផ្តល់ជំនួយត្រលប់ទៅស្រុកកំណើត ឆ្លើយតបបន្ទាន់ និងផ្តល់សេវាជូរមុខ។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាតួអង្គរដ្ឋាភិបាលសំខាន់ផ្តល់ការគាំទ្រដល់ជនរងគ្រោះ មិនថាពួកគេចង់ស្នាក់ក្នុងមណ្ឌល ឬត្រលប់ទៅផ្ទះវិញភ្លាមៗនោះទេ ក្នុងនោះពួកគេភាគច្រើននិយមទៅផ្ទះវិញ។

ដំណើរការមាតុភូមិនិវត្តន៍ គឺត្រូវបានដាក់បញ្ចូលក្នុងអនុស្សារណៈនៃការយោគយល់រវាងកម្ពុជា និងថៃ។ ពេលដែលអនុវត្តតាមអនុស្សារណៈនេះ ភាគីខាងថៃ និងផ្តល់ការជូនដំណឹងជាមុនដល់មជ្ឈមណ្ឌលសំចត និងជូនដំណឹងមជ្ឈមណ្ឌលអំពីពលករដែលនឹងត្រូវមកដល់។ ការជូនដំណឹងនេះ ផ្តល់ពេលវេលាឱ្យមជ្ឈមណ្ឌលសំចតតាមដានស្វែងរកគ្រួសារ ប្រមូលភស្តុតាង និងកំណត់សេវាគាំទ្រសម្រាប់ពលករទាំងនោះ ដែលត្រូវបានធ្វើឡើងដោយមានការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។ មជ្ឈមណ្ឌលសំចត ក៏នឹងសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនផងដែរ ដើម្បីស៊ើបអង្កេត និងប្រមូលភស្តុតាងបន្ថែម បើចាំបាច់។

ក្នុងការអនុវត្តជាក់ស្តែង ភាគីពាក់ព័ន្ធលើកឡើងថា ថៃអាចនឹងមិនមានការរើសអើងនោះទេនៅក្នុងការបណ្តេញពលករ។ ពលករដែលបានបណ្តេញចេញ ជាទូទៅត្រូវបានប្រព្រឹត្តចំពោះដូចគ្នាទៅនឹងពលករស្របច្បាប់ដែរពីសំណាក់អាជ្ញាធរថៃ ដោយមានការត្រួតពិនិត្យ និងការស៊ើបអង្កេតគ្រប់គ្រាន់។ នៅក្នុងករណីភាគច្រើន ពលករដែលបានបណ្តេញចេញ ត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះប៉ុណ្ណោះ នៅពេលដែលពួកគេត្រលប់មកកម្ពុជាវិញ។ ការអនុវត្តរបស់មន្ត្រីថៃនៅក្នុងការចុះចាប់ពលករខ្មែរដោយមិនមានការត្រួតពិនិត្យគ្រប់គ្រាន់ និងដឹកមកទម្លាក់នៅព្រំដែន ជាទូទៅនៅព្រំដែនប៉ោយប៉ែត ទុកឱ្យអាជ្ញាធរកម្ពុជាជាអ្នករ៉ាប់រង គឺមានលក្ខណៈធ្ងន់ធ្ងរនៅក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ នៅពេលដែលរថយន្តដឹកពលករដែលបណ្តេញចេញបើកសំដៅមកកាន់មជ្ឈមណ្ឌលសំចតប៉ោយប៉ែតនៅពេលល្ងាច និងបុគ្គលិកចាំបាច់ត្រូវធ្វើការងារដល់យប់ ដើម្បីសម្ភាសពលករម្នាក់ៗ។

*រូបភាព ៨៖ សំណៅបកប្រែខិត្តប័ណ្ណផ្សព្វផ្សាយអំពីដំណើរការមាតុភូមិនិវត្តន៍ និងការបញ្ជូនមាតុភូមិនិវត្តន៍ដែលតាំងបង្ហាញនៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត*




## › មជ្ឈមណ្ឌលសំចតប៉ោយប៉ែត (PTC)

តួនាទីចម្បងរបស់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត (PTC) នៅព្រំដែនថៃ កម្ពុជា គឺដើម្បីដំណើរការពលករខ្មែរពេលដែលពួកគេត្រូវបានបណ្ដេញចេញពីប្រទេសថៃ។ នៅពេលដែលពលករត្រូវបានបណ្ដេញចេញចូលមក មជ្ឈមណ្ឌលសំចតប៉ោយប៉ែតពួកគេ គឺត្រូវបានបុគ្គលិកត្រួតពិនិត្យ ជាជនរងគ្រោះនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សតាមរយៈសម្ភាសន៍។ មជ្ឈមណ្ឌលសំចតប៉ោយប៉ែតប្រើប្រាស់ទម្រង់ខ្លីដើម្បីអនុវត្តការសម្ភាសន៍ និងរៀបចំព័ត៌មានជាមួយនឹងទិន្នន័យមាតុភូមិនិវត្តន៍ ដែលត្រូវបានផ្ដល់ជូនដោយភាគីខាងថៃ។ ភាគីពាក់ព័ន្ធនៃមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានលើកឡើងថា ទោះបីជាពួកគេប្រឹងប្រែងអស់ពីសមត្ថភាពក៏ដោយ ក៏ជំនាញសម្ភាសន៍របស់បុគ្គលិកមជ្ឈមណ្ឌលសំចតគឺនៅមានកម្រិត ប៉ុន្តែអាចជួយបង្កើនសមត្ថភាពបានតាមរយៈការកសាងសមត្ថភាពក្នុងផ្នែកនេះ។ តម្រូវការជាក់លាក់ គឺជំនាញសម្ភាសន៍កុមារ។

មជ្ឈមណ្ឌលសំចតប៉ោយប៉ែត មានទាំងការិយាល័យសង្គ្រោះ និងការិយាល័យគ្រប់គ្រងករណី ដោយការិយាល័យនេះប្រើប្រាស់នៅពេលកំណត់អត្តសញ្ញាណជនរងគ្រោះដែលសង្ស័យ។ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ក៏អាចកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះទៅកាន់សេវាគាំទ្រ ក៏ដូចជាអនុវត្តសកម្មភាពចុះផ្តល់សេវាតាមមូលដ្ឋាននៅក្នុងតំបន់ជុំវិញ។ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត កាលពីមុនត្រូវបានរៀបចំឡើងដើម្បីគាំទ្រតែស្ត្រី និងកុមារដែលបានបណ្តេញចេញពីប្រទេសថៃ ដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ទោះជាយ៉ាងនេះក្តី ដោយមានអ្នកនេសាទជាច្រើនត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះកាលពីឆ្នាំកន្លងទៅ បុរសគឺត្រូវបានដំណើរការឆ្លងកាត់មជ្ឈមណ្ឌលនេះផងដែរ។

ភាគីពាក់ព័ន្ធលើកឡើងថា មជ្ឈមណ្ឌលសំចតប៉ោយប៉ែត គឺពុំមានធនធានគ្រប់គ្រាន់ទេ។ មជ្ឈមណ្ឌលនេះ ពុំមានថវិកាគ្រប់គ្រាន់អនុវត្តគ្រប់គ្រងករណីពាក់ព័ន្ធនឹងការចុះផ្តល់សេវាតាមមូលដ្ឋានដល់តំបន់លំនៅដ្ឋានរបស់ពលករដែលត្រូវបានបណ្តេញចេញនោះទេ។ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ក៏ខ្វះបន្ទប់សម្ភាសន៍ផងដែរ ហើយមន្ត្រីទាំងប្រាំបួននាក់របស់មជ្ឈមណ្ឌលអនុវត្តការសម្ភាសន៍តំណាលពេលជាមួយគ្នានៅក្នុងសាលរង់ចាំ។ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺមានពលករច្រើនដែលតំរូវឱ្យត្រូវសម្ភាសន៍នៅខាងក្រៅ។ ទោះបីជាបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការរក្សាការសម្ងាត់ក្តី ក៏ប្រការនេះគឺជាបញ្ហាប្រឈមដ៏លំបាក។ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ក៏មានបន្ទប់មួយដែលប្រើប្រាស់ជាជម្រកបណ្តោះអាសន្នសម្រាប់ជនរងគ្រោះ និងអ្នកដែលខ្វះខាត។ បន្ទប់នេះ គឺមិនបានរចនាឡើងសម្រាប់គោលបំណង និងមានទំហំតូចមិនសមស្របតាមតម្រូវការនោះទេ។

សេវាភាគច្រើននៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត គឺផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាលដែលមានការិយាល័យប្រតិបត្តិនៅទីនោះ។ អង្គការមិនមែនរដ្ឋាភិបាល ដូចជា អង្គការ សាម៉ារីតាន់ ភឹស និងអង្គការតំណក់ទឹក បានធ្វើប្រតិបត្តិការការិយាល័យតូចៗនៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីជួយដល់ពលករដែលបានបណ្តេញចេញនូវការថែទាំវេជ្ជសាស្ត្រមូលដ្ឋាន សម្លៀកបំពាក់ អាហារ និងប្រាក់កាស ដើម្បីឱ្យពលករទាំងនោះត្រលប់ទៅស្រុកកំណើតវិញ។

## › មជ្ឈមណ្ឌលសំចតកំរៀង (KTC)

មជ្ឈមណ្ឌលសំចតកំរៀង នៅក្នុងខេត្តបាត់ដំបង គឺមានទីតាំងស្ថិតនៅក្បែរព្រំដែនកម្ពុជា-ថៃ នៅក្នុងស្រុកកំរៀង និងត្រូវបានបើកដំណើរការដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងខែធ្នូ ឆ្នាំ២០២១។[២៨] មជ្ឈមណ្ឌលសំចតកំរៀងផ្តោតលើ ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការបញ្ជូន ការធ្វើសមាហរណកម្ម និងការផ្តល់សេវាឆ្លើយតបដំបូងដល់ពលករដែលរងការកេងប្រវ័ញ្ចនៅក្រៅប្រទេស។ មជ្ឈមណ្ឌលនេះ គឺដំណើរការដោយមានជំនួយពីអង្គការសង្គមស៊ីវិល ពោលគឺអង្គការ A២១ ដែលមានភារកិច្ចអភិវឌ្ឍន៍ធនធានដែលសម្របតាមការកំណត់អត្តសញ្ញាណជនរងគ្រោះ ការសម្ភាសន៍កុមារ និងការត្រួតពិនិត្យកុមារ។ អង្គការ A២១ បាន និងកំពុងដឹកនាំកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតបន្ទប់សម្ភាសន៍កោសល្យវិច្ច័យកុមារ និងបណ្តុះបណ្តាលបុគ្គលិករដ្ឋាភិបាលស្តីពីវិធីសាស្ត្រយកចិត្តទុកដាក់លើកុមារដែលមានព័ត៌មានអំពីការប៉ះទង្គិចផ្លូវចិត្ត។ ដោយសារតែមជ្ឈមណ្ឌលនេះជាមជ្ឈមណ្ឌលថ្មី ភាគីពាក់ព័ន្ធលើកឡើងថា ចាំបាច់ត្រូវមានការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពបុគ្គលិកនៅគ្រប់ទិដ្ឋភាពទាំងអស់ នៃការធ្វើប្រតិបត្តិការមជ្ឈមណ្ឌលសំចតកំរៀង។

ជារួម មានការលើកទឹកចិត្តឱ្យបើកដំណើរការមជ្ឈមណ្ឌលថ្មីនេះ ដោយសារកិច្ចខិតខំរបស់គណៈកម្មាធិការជាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ នៅឆ្នាំ២០១៦ អង្គការ IJM បានណែនាំឱ្យមជ្ឈមណ្ឌលថ្មីបើកដំណើរការជាការបន្ថែមពីលើមជ្ឈមណ្ឌលសំចតប៉ោយប៉ែត។ ការពង្រីកបណ្តាញនេះ នឹងបង្កើនលទ្ធភាពនៃការកំណត់រកពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងការផ្តល់សេវាដល់ជនរងគ្រោះ។

## ៦.១.៧ ទិន្នន័យអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ

ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺពុំអាចទុកចិត្តបាន ដោយសារការរាប់ស្ទួនទិន្នន័យរវាងអ្នកផ្តល់សេវាជាច្រើន។ ប្រការនេះ ធ្វើឱ្យមានការលំបាកក្នុងការតាមដានត្រួតពិនិត្យវឌ្ឍនភាព និងតម្រូវការនៅក្នុងសហគមន៍ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ បច្ចុប្បន្ន បញ្ហានេះគឺត្រូវបានដោះស្រាយដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ពាក់ព័ន្ធនឹងកំណត់ត្រារបស់នាយកដ្ឋានផ្ទាល់ ប៉ុន្តែចាំបាច់ត្រូវតែពង្រីកឱ្យដល់ភាគីពាក់ព័ន្ធទាំងអស់។

"ឆ្នាំនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានសហការជាមួយ អង្គការរតនៈអន្តរជាតិ ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងទិន្នន័យ។ ប្រព័ន្ធនេះ គឺសម្រាប់តែនាយកដ្ឋានរបស់ខ្ញុំប៉ុណ្ណោះ។ យើងព្យាយាមកាត់បន្ថយហានិភ័យនៃការស្ទួនគ្នានៅលើប្រតិបត្តិការ។ ឧទាហរណ៍ ខ្ញុំបានកត់ត្រាករណី ក ហើយខេត្តពាក់ព័ន្ធបានកត់ត្រាករណីដដែលក្នុងប្រព័ន្ធកត់ត្រារបស់ពួកគេ។ ដូច្នេះ ពេលយើងដាក់បញ្ចូលទិន្នន័យជាមួយគ្នា ករណីជាក់លាក់នេះគឺទំនងជារាប់ពីរដង។"

មន្ត្រីរដ្ឋាភិបាល



## ៦.២ ការការពារ និងការគាំទ្រជនរងគ្រោះ

### ៦.២.១ ការឆ្លើយតប ការគាំទ្រ និងការបញ្ជូនដំបូង

ការឆ្លើយតបដំបូងសម្រាប់ករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះបឋម និងការផ្តល់សេវាបន្ទាន់។ ការឆ្លើយតបនេះរួមបញ្ចូលការធានាថាពលករមានសុវត្ថិភាព និងមានសុខភាពល្អតាមរយៈការផ្តល់អាហារ ជម្រក និងការពិគ្រោះយោបល់បន្ទាន់ មុនពេលដែលជនរងគ្រោះត្រូវបានសម្ភាសន៍ជាផ្លូវការពីសំណាក់មន្ត្រីដែលមានគុណវុឌ្ឍិ។

*តារាង ៩៖ ចំនួននៃការបញ្ជូនជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក*

| ចំនួនជនរងគ្រោះនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សដែលបានបញ្ជូនទៅរកសេវាគាំទ្រនៅក្នុងប្រទេសកម្ពុជា របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | ៦២ | មិនមានរបាយការណ៍ | ២២២ | ២៦២ | ៣៧១ | ៤០៤ |
| ទៅអង្គការមិនមែនរដ្ឋាភិបាល | | ២៤៣ | ២២២ | ២៩០ | ២២០ | |
| ពលកម្មដោយបង្ខំ | | | ១០៩ | | ៥៤ | |

ពេលជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការហើយ មានការបញ្ជូនជាក់លាក់ដែលបានចែងក្នុងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះរបស់កម្ពុជា ដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះ។ ដើម្បីអាចបញ្ជូនទៅបាន គេត្រូវបំពេញទម្រង់បញ្ជូនដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនទម្រង់នេះអមជាមួយនឹងទម្រង់កំណត់អត្តសញ្ញាណទៅកាន់មន្ត្រីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីផ្តល់សេវា ឬស្វែងរកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាដែលអាចជួយផ្តល់សេវាបាន។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាអ្នកទទួលបន្ទុកផ្តល់សេវាបណ្តោះអាសន្នដល់ជនរងគ្រោះ ក៏ដូចជាការពិគ្រោះយោបល់ ការស្តារនីតិសម្បទា និងសេវាសមាហរណកម្ម ការតាមដានស្វែងរកគ្រួសារ និងការវាយតម្លៃជនរងគ្រោះជាកុមារ។ ជាទូទៅ អង្គការមិនមែនរដ្ឋាភិបាល ជាអ្នកទទួលបន្ទុករៀបចំជម្រក ថែទាំសុខភាព ជំនួយផ្នែកច្បាប់ ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងផ្តល់ជម្រក ការងារ ការអប់រំ ការពិគ្រោះយោបល់ និងអាហារ។ សេវាទាំងនេះគ្របដណ្តប់លើតម្រូវការជាច្រើនរបស់ជនរងគ្រោះ មានចាប់ពីពេលកំណត់អត្តសញ្ញាណរហូតដល់ការធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ។ (គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ក៏ចែងអំពីតួនាទីជាក់លាក់សម្រាប់ភាគីពាក់ព័ន្ធ ដូចជា នគរបាលយុត្តិធម៌ មន្ត្រីសង្គមកិច្ច និងអ្នកផ្តល់សេវា ដូចមានចែងនៅក្នុងផ្នែក ៣។) បើការកំណត់អត្តសញ្ញាណធ្វើឡើងនៅក្រៅប្រទេស ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងស្ថានទូតកម្ពុជានឹងជួយដល់ការរៀបចំការការពារ ការគាំទ្រ និងមាតុភូមិនិវត្តន៍ជនរងគ្រោះ ក៏ដូចជាការរៀបចំទិដ្ឋាការស្នាក់នៅបណ្តោះអាសន្នផងដែរ។ ក្នុងការអនុវត្តជាក់ស្តែង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ទទួលបន្ទុកសម្របសម្រួលការគាំទ្រជាបន្តបន្ទាប់សម្រាប់ជនរងគ្រោះនៅថ្នាក់សហគមន៍ រួមទាំងការគ្រប់គ្រងករណី និងការតាមដានស្វែងរកគ្រួសារ។ ទោះបីជាមានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលផ្តល់សេវាថែទាំក៏ដោយ ក៏អាចមានការលំបាកក្នុងកា

ស្វែងរកអ្នកផ្តល់សេវានៅទីតាំងជាក់លាក់ឬប្រភេទជនរងគ្រោះជាក់លាក់។

ជាទូទៅ មានការផ្តល់មតិត្រលប់ថា មន្ត្រីសង្គមកិច្ចមានការយល់ដឹងល្អប្រសើរអំពី ពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការជួយដល់ជនរងគ្រោះ។ កាលពីមុន មន្ត្រីធ្លាប់តែធ្វើការងារជាមួយស្ត្រី និងកុមារពាក់ព័ន្ធនឹងការជួញដូរមនុស្ស ប៉ុន្តែក្នុងរយៈពេល ៥ឆ្នាំ កន្លងមកនេះ មន្ត្រីបានដឹងអំពីការគាំទ្រជនរងគ្រោះជាបុរសដោយសារតែមានករណីមួយចំនួនពាក់ព័ន្ធនឹងអ្នកនេសាទ។ ទោះបីជាបុគ្គលិកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានការយល់ដឹងអំពីករណីបុរសទាំងនេះល្អប្រសើរជាងមុនក៏ដោយ ក៏នៅតែមានសេវាតិចតួចណាស់សម្រាប់បុរសដែលត្រូវបានគេជួញដូរ។

តាមរយៈគំរូនេះ គេបានកត់សម្គាល់ផងដែរថា មានការពឹងផ្អែកជាខ្លាំងទៅលើអង្គការមិនមែនរដ្ឋាភិបាល ដែលជាអ្នកផ្តល់សេវាយ៉ាងធំដល់ជនរងគ្រោះ។ ដូចគ្នានេះដែរ មានការកត់សម្គាល់ថា ទោះបីជាមានគោលនយោបាយស្តីពីការការពារជនរងគ្រោះ[២៩] ដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានចែងអំពីគោលការណ៍ និងនីតិវិធីសម្រាប់ការការពារ និងការគាំទ្រជនរងគ្រោះក៏ដោយ ក៏ពុំមានយន្តការសម្រាប់ការតាមដានត្រួតពិនិត្យ និងការធានាថាបាននូវការផ្តល់សេវាសមស្របតាមស្តង់ដារនៅឡើយទេ។

ភាគីពាក់ព័ន្ធក៏បានលើកឡើងផងដែរថា តួអង្គមូលដ្ឋានជារឿយៗមិនដឹងអំពីអ្នកផ្តល់សេវាក្នុងមូលដ្ឋាន និងសេវាបញ្ជូននោះទេ ដោយសារតែពួកគេមិនបានទទួលបន្ទុកកិច្ចការនេះ។ ប្រការនេះអាចធ្វើឱ្យមានការលំបាកក្នុងការផ្តល់សេវាដល់ជនរងគ្រោះនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ស្របពេលដែលបញ្ហានេះកើតឡើង ដូច្នេះអាជ្ញាធរមូលដ្ឋាន គួរតែស្វែងយល់អំពីជម្រើសសេវាគាំទ្រដែលមានផ្តល់ជូន។

## ៦.២.២ មាតុភូមិនិវត្តន៍

ចំពោះជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណថានៅក្រៅប្រទេស ស្ថានទូតទទួលបានការជូនដំណឹង ហើយស្ថានទូតមានតួនាទីជួយដល់ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។ ការធ្វើមាតុភូមិនិវត្តន៍នេះ ជាទូទៅធ្វើឡើងភ្លាមៗដោយមានការផ្តល់ជូនថវិកាសម្រាប់ការធ្វើដំណើរតាមជើងហោះហើរពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល។ ដូចគ្នានេះដែរ នៅក្នុងប្រទេសកម្ពុជា ក្រសួងមហាផ្ទៃនឹងសម្របសម្រួលដល់ជនបរទេសក្នុងប្រទេសក្នុងការធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ ទោះបីជាមានការកត់សម្គាល់ឃើញថា ជនបរទេសជាច្រើនគឺត្រូវបានធ្វើមាតុភូមិនិវត្តន៍ ដោយពុំបានឆ្លងកាត់ការត្រួតពិនិត្យរកពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សពីសំណាក់អាជ្ញាធរកម្ពុជា។

បញ្ហាប្រឈមមួយទៀតគឺថា ពលករជាទូទៅធ្វើមាតុភូមិនិវត្តន៍លឿន និងពុំស្ថិតក្នុងប្រទេសបានយូរគ្រប់គ្រាន់ដើម្បីជំនួយដល់ការស៊ើបអង្កេតព្រហ្មទណ្ឌអំពី ករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ពលករចំណាកស្រុកជាទូទៅពុំមានថវិកាក្នុងការបន្តរស់នៅក្រៅប្រទេស ដោយពុំធ្វើការតាមការតម្រូវឱ្យសម្របសម្រួលដល់ការស៊ើបអង្កេតនោះទេ។ ពុំមានការអនុវត្តវិធានការជាក់លាក់ដើម្បីអនុញ្ញាតឱ្យពលករដែលត្រូវធ្វើមាតុភូមិនិវត្តន៍បន្តចូលរួមនៅក្នុងការស៊ើបអង្កេតបានដោយងាយស្រួលនោះទេ។ លើសពីនេះ បើជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស មានបំណងបន្តស្នាក់នៅក្រៅប្រទេស ពុំមានសេវាជួយពួកគេក្នុងការធ្វើនិយ័តកម្មស្ថានភាពចំណាកស្រុករបស់ពួកគេ និងជួយស្វែងរកការងារឡើយ។

*តារាង ១០៖ ចំនួនពលករដែលបានធ្វើមាតុភូមិនិវត្តន៍ដោយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក*

| ចំនួនពលករដែលបានធ្វើមាតុភូមិនិវត្តន៍ដោយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក | | | | | |
|---|---|---|---|---|---|
| ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ៨១៥ | ៩៨៦ | ៨.៨៨៩ | ៣២.២៣៥ | ១០.៥៧៤ | ១០.៤០៦ |

## ៦.២.៣ កង្វះខាតសេវាគាំទ្រ និងធនធាន

### ជម្រក

ភាគីពាក់ព័ន្ធ ជាទូទៅទទួលស្គាល់ថា ខ្វះខាតជម្រកសម្រាប់ការពារ ថែទាំបន្ទាន់ និងសេវាក្រោយការថែទាំ។ រដ្ឋាភិបាលពុំបានផ្តោតលើការផ្តល់កន្លែងស្នាក់នៅ និងទុកកិច្ចការនេះឱ្យអង្គការមិនមែនរដ្ឋាភិបាលជាអ្នករ៉ាប់រងទាំងស្រុង។ ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនជួយគាំទ្រផ្នែកជម្រកក៏ដោយ ក៏ធនធាន និងជម្រកសម្រាប់ស្នាក់នៅគឺមានកម្រិត។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនមានលក្ខណៈវិនិច្ឆ័យជាក់លាក់សម្រាប់អ្នកដែលអាចចូលមកស្នាក់នៅ និងសេវាទូទៅសម្រាប់តែស្ត្រី និងកុមារ។ ជាលទ្ធផល បុរសពុំមានលទ្ធភាពទទួលបានជម្រកនោះទេ។

"កង្វះការគាំទ្រ និងកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ជនរងគ្រោះជាបុរស។ បច្ចុប្បន្ន យើងប្រើប្រាស់មជ្ឈមណ្ឌលនៅអង្គការការីតាស ដែលមានទីតាំងស្ថិតនៅខេត្តកណ្តាលសម្រាប់ការស្នាក់នៅរយៈពេលខ្លីសម្រាប់តែជនរងគ្រោះជាបុរសប៉ុណ្ណោះ។"

មន្ត្រីរដ្ឋាភិបាល

ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ពលករចំណាកស្រុកជាច្រើនបានត្រលប់មកកម្ពុជាវិញដោយឆ្លងកាត់ពីព្រំដែនថៃ។ ពលករចំណាកស្រុកទាំងនេះ គឺតម្រូវឱ្យធ្វើចត្តាឡីស័កនៅមូលដ្ឋានដាច់ដោយឡែករបស់រដ្ឋាភិបាល។ មានការរាយការណ៍ថា មូលដ្ឋានទាំងនេះមានសមត្ថភាពពុំគ្រប់គ្រាន់ និងប្រការនេះបាននាំឱ្យមានពលករដែលត្រលប់មកវិញជាច្រើនមិនបានឆ្លងកាត់ការត្រួតពិនិត្យរក ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ឬតម្រូវការថែទាំនោះទេ។ លើសពីនេះ មូលដ្ឋានចត្តាឡីស័ក គឺត្រូវបានប្រព័ន្ធផ្សព្វផ្សាយរាយការណ៍ថាមិនមានសុវត្ថិភាពសម្រាប់ស្ត្រី ដោយសារតែមានស្ត្រីជាច្រើនបានជួបប្រទះនឹងការបៀតបៀននៅពេលធ្វើចត្តាឡីស័ក។ ចំពោះពលករចំណាកស្រុកជាច្រើន លទ្ធផលនៃការបៀតបៀននេះ គឺជាបញ្ហាសុខភាពផ្លូវចិត្តជាបន្តបន្ទាប់។

"ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ មជ្ឈមណ្ឌលចត្តាឡីស័កទាំងអស់គឺពេញ។ ប្រការនេះ មានការលំបាកខ្លាំងណាស់សម្រាប់យើង។ ពលករដែលត្រលប់មកវិញមួយចំនួនមានបញ្ហាសុខភាពផ្លូវចិត្តផងដែរ។ យើងពុំមានកន្លែងសមស្របសម្រាប់ពួកគេនោះទេ។"

មន្ត្រីរដ្ឋាភិបាល

## > ការពិគ្រោះយោបល់

ស្របពេលដែលផ្តល់ជម្រក អង្គការមិនមែនរដ្ឋាភិបាលក៏ដឹកនាំដោយផ្តល់ការគាំទ្រផ្លូវចិត្ត ការពិគ្រោះយោបល់ និងការថែទាំសុខភាពផ្លូវចិត្តផងដែរ។ ចន្លោះខ្វះខាតជាក់លាក់ដែលបានគូសបញ្ជាក់ គឺកង្វះការពិគ្រោះយោបល់ និងការគាំទ្រផ្លូវចិត្តនៅតំបន់ឆ្លងដែន មានន័យថា ការពិគ្រោះយោបល់ ជារឿយៗពុំអាចផ្តល់ជូនបាននោះទេនៅដំណាក់កាលឆ្លើយតបដំបូងសម្រាប់ពលករដែលគេបណ្តេញចេញ។ ដូចគ្នានេះដែរ ការគាំទ្រផ្លូវចិត្តផ្តោតលើបុរសគឺពុំសូវមាននោះទេ។

ការណែនាំដ៏ល្អមួយលើកឡើងថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាចាំបាច់ត្រូវវាយតម្លៃឱ្យបានកាន់តែល្អិតល្អន់ទៅលើតម្រូវការគាំទ្រផ្លូវចិត្តរបស់ជនរងគ្រោះ។ ការស្រាវជ្រាវ និងការពិគ្រោះយោបល់បន្ថែមអំពីប្រធានបទនេះហាក់បីដូចជាមានសារៈសំខាន់ណាស់។

"ខ្ញុំពុំដែលឃើញក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ធ្វើរបាយការណ៍ដែលសង្កត់ធ្ងន់លើជំងឺផ្លូវចិត្តនោះទេ។ សម្រាប់យើង យើងសហការគ្នាសម្រាប់សេវាគាំទ្រផ្លូវចិត្ត។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

## > ការថែទាំសុខភាព

បុគ្គលិកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាយការណ៍ថា ពួកគេសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល ដើម្បីផ្តល់សេវាសុខភាព។ បញ្ហាមួយដែលបានរាយការណ៍នោះគឺថា ជារឿយៗមានការយឺតយ៉ាវនៅក្នុងការស្វែងរកសេវាថែទាំសុខភាព។

"ពួកគេក៏ជួបប្រទះនឹងបញ្ហាប្រឈមផងដែរពេលបញ្ជូនជនរងគ្រោះទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យ ដោយសារតែបើសិនជាពុំមានវត្តមានវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកទទួលបន្ទុក ករណីនេះនឹងត្រូវពន្យារពេលដោយហេតុតែពុំមានអ្នកដទៃអាចរ៉ាប់រងការងារនេះបាន។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ស្រដៀងគ្នានេះដែរ ភាគីពាក់ព័ន្ធមានការលំបាកក្នុងការស្វែងរកអ្នកជំនាញថែទាំសុខភាពដែលទំនេរ និងមានឆន្ទៈផ្តល់សេវា។ មកទល់ពេលនេះ អ្នកឆ្លើយតបមួយចំនួនបានលើកឡើងថា វាអាចនឹងមានប្រយោជន៍ បើមានបញ្ជីទំនាក់ទំនងអ្នកផ្តល់សេវាសុខភាព។ បញ្ហាមួយទៀតដែលបានលើកឡើងថា វាអាចចំណាយរយៈពេលយូរ ដើម្បីទទួលបានរបាយការណ៍សុខភាព ដែលត្រូវការចាំបាច់ក្នុងការប្រើប្រាស់ជាភស្តុតាងក្នុងរឿងក្តី។

## > សេវាផ្លូវច្បាប់

ជនរងគ្រោះ គឺពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការគាំទ្រផ្លូវច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានលើកឡើងថា ពួកគេអាចផ្តល់ការគាំទ្រផ្លូវច្បាប់ដោយផ្ទាល់អមជាមួយនឹងការកំណត់អត្តសញ្ញាណ និងសេវាផ្សេងៗ។ ប៉ុន្តែ នៅតែមានចន្លោះខ្វះខាតលើធនធានសម្រាប់ជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះ ជាពិសេសនៅក្នុងតំបន់មូលដ្ឋាន ដូចជាប៉ោយប៉ែតជាដើម។

នាយកដ្ឋានរដ្ឋាភិបាល បានរាយការណ៍ថា ជារឿយៗពួកគេសម្របសម្រួលមេធាវីតំណាងផ្នែកច្បាប់ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស។ ប្រសិនបើនៅក្រៅប្រទេស ពួកគេបានទំនាក់

ទំនងជាមួយមេធាវីក្រៅប្រទេសសម្រាប់កិច្ចការនេះ។

"យើងផ្តល់ការគាំទ្រផ្លូវច្បាប់សម្រាប់ជនរងគ្រោះ តាមរយៈការផ្តល់សេវាមេធាវី។ យើងយកមេធាវីពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីគាំទ្រដល់ជនរងគ្រោះ។ មេធាវីធ្វើការងារ និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលជួយសង្គ្រោះ និងគាំទ្រដល់ជនរងគ្រោះនៅក្នុងប្រទេសគោលដៅ។ ឬយើងយកមេធាវីពីក្រៅប្រទេស (ប្រទេសគោលដៅ) ដើម្បីគាំទ្រដល់ជនរងគ្រោះ។"

មន្ត្រីរដ្ឋាភិបាល

ការរិះគន់មួយដែលបានលើកឡើងដោយភាគីពាក់ព័ន្ធនៅក្នុងវិស័យច្បាប់គឺថា មានការផ្តល់ជូនសេវាផ្លូវច្បាប់កាន់តែច្រើន ដើម្បីការពារជនល្មើសជាប់ចោទ ដូចជាពីសំនាក់ គណៈមេធាវី ពោលគឺច្រើនជាងផ្តល់ជូនដល់ជនរងគ្រោះ។

## › សេវាសង្គមកិច្ច និងការស្តារនីតិសម្បទា

ជារួម សេវាគាំទ្រសង្គមកិច្ច ជារឿយៗត្រូវបានគេនិយាយថាមិនគ្រប់គ្រាន់ ដែលភាគច្រើនគឺដោយសារតែកង្វះធនធាន។ គេបានកត់សម្គាល់ឃើញថាសេវាសង្គមកិច្ច បុគ្គលិកសង្គមកិច្ច និងសេវាស្តារនីតិសម្បទា គឺមិនគ្រប់គ្រាន់ ជាថ្មីម្តងទៀតដោយមានភាពខុសគ្នាលើសេវាដែលមានផ្តល់ជូនសម្រាប់បុរស និងស្ត្រី។

"សេវាគាំទ្រសម្រាប់មនុស្សពេញវ័យ ជាពិសេសបុរស គឺមិនមានផ្តល់ជូននោះទេ។ ការផ្តល់សេវាគឺមានផ្តល់ជូនច្រើនសម្រាប់ជនរងគ្រោះជាស្ត្រី ស្របពេលដែលជនរងគ្រោះជាបុរសមានការលំបាកក្នុងការទទួលសេវា មិនថានៅក្នុងប្រទេសគោលដៅក៏ដោយ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

មានការកត់សម្គាល់ផងដែរថា សេវាសង្គមកិច្ចគឺមិនមិនបានផ្តល់ជូនគ្រប់គ្រាន់សម្រាប់សមាជិកគ្រួសារទាំងមូលនោះទេ។ ជាការសំខាន់ណាស់ដែលមិនត្រឹមតែព្យាបាលពលករនោះទេ ប៉ុន្តែក៏ត្រូវគាំទ្រពួកគេក្នុងនាមជាបុគ្គលដែលត្រូវបានបញ្ចូលទៅក្នុងរចនាសម្ព័ន្ធគ្រួសារ ឬរចនាសម្ព័ន្ធសង្គមផ្សេងទៀត។ មិនមានការផ្តល់ជូនសេវាសម្រាប់ពលករនៅក្នុងកម្លាំងពលកម្មដែលជាប្តីប្រពន្ធ ឬគ្រួសារដែលមានកូនតូចៗ។ សេវាមានស្រាប់ គឺអាចមានសម្រាប់ស្ត្រី និងកុមារ និងពលករដែលជាអនីតិជនប៉ុណ្ណោះ។ នៅ ចំណុចនេះ ហាក់បីដូចជាត្រូវការធនធានបន្ថែមជាចាំបាច់។

## › ជំនាញវិជ្ជាជីវៈ ការបណ្តុះបណ្តាល ការអប់រំ និងការងារ

បញ្ហាប្រឈមចម្បងមួយសម្រាប់ការធ្វើសមាហរណកម្ម គឺជាការជួយជនរងគ្រោះ និងពលករត្រលប់មកវិញ ក្នុងការកសាងជីវិតរស់នៅប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។ ពលករភាគច្រើនធ្វើចំណាកស្រុក គឺដោយសារតែកង្វះឱកាសក្នុងការបង្កើតប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពនៅក្នុងប្រទេសកម្ពុជា និងជាពិសេសនៅក្នុងតំបន់កំណើតរបស់ពួកគេ។ ពលករជាច្រើនជាប់បំណុលច្រើន ហើយប្រាក់ចំណូលនៅក្នុងប្រទេសកម្ពុជាមិនគ្រប់គ្រាន់ក្នុងការរ៉ាប់រងលើបន្ទុកបំណុលនេះទេ។ ដូចគ្នានេះដែរ ការព្យាយាមជំរុញលើជីវភាពពឹងផ្អែកលើកសិកម្មគឺមិនមានលក្ខណៈជាក់ស្តែងនៅក្នុងអំឡុងពេលនៃការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គមនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំកន្លងមកនោះទេ។

ភាគច្រើន ការធ្វើសមាហរណកម្មគឺមិនអាចអនុវត្តបាននោះទេ លើកលែងតែសម្រេចបាននូវជីវភាពជំនួសដែលមាននិរន្តភាព។ មកទល់ពេលនេះ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលគឺមានការគាំទ្រនៅក្នុងការផ្តល់ការបណ្តុះបណ្តាល និងការអប់រំ

វិជ្ជាជីវៈ។ ទោះជាយ៉ាងនេះក្តី លើកលែងតែឱកាសទាំងនេះផ្សារភ្ជាប់គ្នាដោយផ្ទាល់នឹងលំនាំការងាររឹងមាំ ដែលអំណោយផល និងមានចីរភាពជនរងគ្រោះ គឺទំនងជានឹងធ្វើចំណាកស្រុកឡើងវិញ ដោយមានហានិភ័យអមជាមួយ។ ក្នុងករណីជាច្រើនឱកាសទាំងនេះគឺមិនមាននោះទេ។

"នៅឆ្នាំ២០២១ មានជនរងគ្រោះចំនួន ២៦ នាក់ ពីករណីជួញដូរមនុស្សទទួលបានការគាំទ្រ។ បញ្ហាប្រឈមមួយដែលបានសង្កេតឃើញ គឺប្រសិទ្ធភាពនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ជនរងគ្រោះ។ ជនរងគ្រោះភាគច្រើនចង់បានការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប៉ុន្តែ បន្ទាប់ពីការធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ ពួកគេពុំអាចប្រើប្រាស់ជំនាញ ដើម្បីរកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីអាចរស់រានបាននោះទេ ដូច្នេះពួកគេធ្វើចំណាកស្រុកឡើងវិញ។"

មន្ត្រីរដ្ឋាភិបាល

ដូចគ្នានេះដែរ ជនរងគ្រោះជាច្រើនជួបប្រទះនឹងតម្រូវការហិរញ្ញវត្ថុបន្ទាន់ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ដែលបង្ខំឱ្យពួកគេលះបង់ការធ្វើសមាហរណកម្ម និងសេវាក្រោយការថែទាំ។ កត្តារួមចំណែកមួយក្នុងបញ្ហានេះ គឺការដែលពុំមានលទ្ធភាពទទួលបានសេវាសង្គមកិច្ចក្នុងប្រទេសកម្ពុជា ដែលកតត្តានេះ គឺលំបាកខ្លាំងក្នុងការទទួលបានសេវាសម្រាប់ពលករដែលត្រលប់មកវិញ។

"ជនរងគ្រោះនៃការជួញដូរកម្លាំងពលកម្មដែលត្រលប់មកវិញភាគច្រើន ជាជនក្រីក្រ។ ពួកគេត្រូវបានគេផាត់ចេញពីកម្មវិធីគាំពារសង្គម។ ពលករមួយចំនួនពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីគាំពារសង្គមផង។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

កង្វះការគាំទ្រហិរញ្ញវត្ថុពីរដ្ឋ ធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំ របស់ពួកគេក្នុងការសម្រេចបាននូវការធ្វើសមាហរណកម្ម និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យត្រលប់មកកម្ពុជាវិញ។

## ការធ្វើសមាហរណកម្ម

បន្ថែមពីលើឧបសគ្គរាំងក្នុងការធ្វើសមាហរណកម្មដែលបានរៀបរាប់ពីខាងលើ ជនរងគ្រោះជាច្រើនទទួលរងការមាក់ងាយ ការពុំមានអ្នករាប់រក និងការផាត់ចេញពីសង្គមនៅពេលពួកគេត្រលប់មកស្រុកកំណើតវិញ។ ជនរងគ្រោះជាច្រើន មានអារម្មណ៍ថាទទួលរងសម្ពាធពីការចំណាកស្រុកដោយជោគជ័យ និងរំពឹងថានឹងត្រលប់មកផ្ទះវិញដោយនាំយកទ្រព្យសម្បត្តិ និងអាចមានលទ្ធភាពសាងសង់ផ្ទះរស់នៅបាន។ ផ្ទុយមកវិញ ជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សអាចត្រលប់មកវិញដោយមានការប៉ះទង្គិចផ្លូវចិត្ត និងកាន់តែក្រីក្រជាងមុនពេលដែលពួកគេចាប់ផ្តើមធ្វើចំណាកស្រុក ដូច្នេះ ពួកគេមានអារម្មណ៍ខ្មាស់គេក្នុងសង្គមជាខ្លាំង។

លើសពីនេះ មានការកត់សម្គាល់ផងដែរថា សេវាតាមដានស្វែងរកគ្រួសារ គឺនៅមានកម្រិត ដែលមានន័យថា ជនរងគ្រោះជាច្រើនពុំបានត្រលប់មកផ្ទះវិញនោះទេ។

*តារាង ១១៖ ចំនួនពលករដែលបានធ្វើសមាហរណកម្ម របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក*

| ចំនួនពលករដែលបានធ្វើសមាហរណកម្ម របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក | | | |
|---|---|---|---|
| ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ៣០៣. (+៨៤៨ ទៅអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការធ្វើសមាហរណកម្ម | ៩៦៨ | ១០៤ | មិនមានរបាយការណ៍ |

## ៦.២.៤ មជ្ឈមណ្ឌលធនធានពលករចំណាកស្រុក

ការអភិវឌ្ឍន៍វិជ្ជមានដែលមានសក្តានុពលមួយ គឺជាការបើកដំណើរការមជ្ឈមណ្ឌលថ្មីសម្រាប់ការថែទាំ នៅស្រុកកណ្តាលស្ទឹង ដែលនឹងត្រូវធ្វើប្រតិបត្តិការដោយ នាយកដ្ឋានស្តារនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានរាយការណ៍ថា ពួកគេចង់បើកមជ្ឈមណ្ឌលនេះបន្ថែមទៀត ដែលអាចរៀបចំឡើងដើម្បីសម្របសម្រួលដល់ពលករចំណាកស្រុកដែលត្រលប់មកវិញ និងផ្តោតលើការងារគាំទ្រជនរងគ្រោះ។

"យើងមានគោលនយោបាយ និងស្តង់ដារដែលបានរៀបចំ និងអនុម័ត។ ប៉ុន្តែ យើងពុំមានមជ្ឈមណ្ឌលសម្រាប់ធ្វើការងារនេះនៅឡើយទេ។ បើមានមជ្ឈមណ្ឌល យើងអាចកសាងធនធានមនុស្ស និងជ្រើសរើសបុគ្គលិកដើម្បីគ្រប់គ្រងមជ្ឈមណ្ឌល។ អ្វីដែលមាននាពេលបច្ចុប្បន្ន គឺមានកម្រិតណាស់។"

មន្ត្រីរដ្ឋាភិបាល

ដូចគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាលធ្វើប្រតិបត្តិការមជ្ឈមណ្ឌលធនធានពលករចំណាកស្រុកមួយចំនួន ដោយមានការគាំទ្រគម្រោងពី អង្គការពលកម្មអន្តរជាតិ និងដៃគូផ្សេងៗ។ មជ្ឈមណ្ឌលធនធានពលករចំណាកស្រុក គឺមានទីតាំងស្ថិតនៅក្នុងខេត្តព្រៃវែង កំពង់ចាម កំពត និងបន្ទាយមានជ័យ[៣០]។ មជ្ឈមណ្ឌលធនធានពលករចំណាកស្រុកថ្មីមួយនៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ គឺបានបើកដំណើរការនៅខែឧសភា ឆ្នាំ២០២២។ មជ្ឈមណ្ឌលនេះគឺដំណើរការដោយ អង្គការពលកម្មអន្តរជាតិ និង អង្គការសង្គមស៊ីវិល ពោលគឺ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (អង្គការសង់ត្រាល់)។ មុខងារចម្បងនៃមជ្ឈមណ្ឌលនេះ គឺដើម្បីផ្តល់ការពិគ្រោះយោបល់ ព័ត៌មាន និងការបណ្តុះបណ្តាលដល់ពលករចំណាកស្រុក អំពីប្រធានបទស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិរបស់ពលករចំណាកស្រុក។ ជារួម មជ្ឈមណ្ឌលផ្តោតលើពលករប្រភេទទាំងនេះ គឺត្រូវបានគូសបញ្ជាក់ដោយភាគីពាក់ព័ន្ធថាជា មជ្ឈមណ្ឌលមានប្រយោជន៍សម្រាប់ពលករក្នុងការរៀនសូត្រអំពីការធ្វើចំណាកស្រុក និងបង្ការពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ប៉ុន្តែក៏សម្រាប់ស្វែងរកសេវាគាំទ្រនៅពេលដែលពលករត្រលប់មកវិញ និងធ្វើសមាហរណកម្មផងដែរ។

## ៦.៣ ដំណោះស្រាយ និងសំណង

### ៦.៣.១ នីតិវិធីសម្រាប់សំណងផ្លូវការ

នៅពេលដែលជនល្មើសត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ពួកគេនឹងត្រូវតុលាការស្នើឱ្យទទួលស្គាល់លទ្ធផល និងយល់ព្រមទូទាត់សំណងដល់ជនរងគ្រោះ ក៏ដូចជាប្រាក់ពិន័យជូនដល់រដ្ឋាភិបាលផងដែរ។ យោងតាមមន្ត្រីតុលាការដែលបានសម្ភាសន៍ សំណងនេះគឺធ្វើឡើងលើ "មូលដ្ឋានស្ម័គ្រចិត្ត" ក្នុងវិសាលភាពខ្លះ។

ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង បើជនល្មើសពុំយល់ស្រប នោះលទ្ធផលនៃការជំនុំជម្រះនឹងត្រូវអនុវត្ត ហើយជនល្មើសនឹងត្រូវបង្គាប់ឱ្យទូទាត់សំណង។ ពេលតុលាការបង្គាប់ឱ្យទូទាត់សំណង តុលាការនឹងត្រួតពិនិត្យលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ជនល្មើស និងអាចបង្គាប់ឱ្យលក់ទ្រព្យសម្បត្តិទាំងនោះ ដើម្បីទូទាត់សំណងជូនដល់ជនរងគ្រោះ។ ពេលធ្វើការសម្រេចចិត្តជំនុំជម្រះស្ថាពរហើយ តុលាការអាចបង្កកទ្រព្យសម្បត្តិរបស់ជនល្មើសបានហើយ។

ប្រសិនបើជនល្មើសពុំមានទ្រព្យសម្បត្តិ និងលទ្ធភាពទូទាត់សំណងទេ នោះនឹងអនុវត្តដីកា "ការទណ្ឌកម្មលើរាងកាយ"។ នៅក្រោម "ការទណ្ឌកម្មលើរាងកាយ" ជនល្មើសអាចនឹងត្រូវជាប់ពន្ធនាគារសម្រាប់រយៈពេលបន្ថែមពីលើរយៈពេលជាប់ពន្ធនាគារសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត (សូមមើលការពិភាក្សាបន្ថែមនៅក្រោមផ្នែក ៧.៣.៣)។

ចំពោះសំណងដែលទូទាត់ទៅឱ្យជនរងគ្រោះ ជនរងគ្រោះមានកាតព្វកិច្ចដាក់ពាក្យបណ្តឹងទាមទារចំនួនទឹកប្រាក់សំណងដែលពួកគេចង់ស្នើសុំ។ ដូច្នេះ វាជាការសំខាន់ណាស់ដែលជនរងគ្រោះត្រូវមានមេធាវីតំណាងផ្នែកច្បាប់នៅដំណាក់កាលនេះ ដូចដែលតុលាការបានកត់សម្គាល់នៅក្នុងអំឡុងពេលសម្ភាសន៍។

បើជនល្មើសមិនទូទាត់សំណងទេ ជនរងគ្រោះចាំបាច់ត្រូវដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីទៅកាន់ព្រះរាជអាជ្ញា ដើម្បីស្នើសុំការទូទាត់។ បណ្តឹងទាំងនេះ អាចចំណាយរយៈពេលបន្ថែមដើម្បីសម្រេចបានលទ្ធផល ដោយសារតែជនល្មើសចាំបាច់ត្រូវបញ្ចប់ការវិនិច្ឆ័យទោសជាមុនសិន ទើបជនល្មើសត្រូវបានតម្រូវឱ្យទូទាត់សំណង។

ចំពោះការទូទាត់ប្រាក់ពិន័យជូនរដ្ឋាភិបាល ទឹកប្រាក់នឹងត្រូវផ្ទេរទៅកាន់រតនាគារខេត្ត។ ទោះជាយ៉ាងនេះក្តី រតនាគារខេត្តជានិច្ចកាលមិនស្នើសុំការទូទាត់នេះទេ។

### ៦.៣.២ ការគណនាសំណង

ក្នុងសំណុំរឿងព្រហ្មទណ្ឌ សំណងមានពីរប្រភេទ[៣១] ដូចជា "បណ្តឹងរដ្ឋប្បវេណី" ដែលផ្តោតលើសំណងសម្រាប់ជំងឺចិត្ត និង "បណ្តឹងអាជ្ញា"។ សំណង នឹងត្រូវគណនាដោយផ្អែកលើប្រភេទសំណងទាំងពីរ ដូច្នេះសំណងដល់ជនរងគ្រោះនឹងផ្តល់ជូននៅក្រោមប្រភេទនៃការខូចខាតចំនួនពីរ - ការខាតបង់ប្រាក់ចំណូល សម្ភារៈ និងទ្រព្យសម្បត្តិ និងសំណងជំងឺចិត្តដែលមានតម្លៃជាហិរញ្ញវត្ថុ។ នៅក្នុងការអនុវត្តជាក់ស្តែង សំណងនៅក្នុងសំណុំរឿងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ជាទូទៅគឺគណនាដោយផ្អែកលើប្រាក់បៀវត្សដែលខាតបង់ បូករួមនឹងជំងឺចិត្ត។

ជារួម អ្នកផ្តល់ព័ត៌មានលើកឡើងថា នៅពេលដែលសំណងត្រូវបានផ្តល់ជូននៅក្នុងសំណុំរឿងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស សំណងនោះគឺកម្រផ្តល់ជូនក្នុងទឹកប្រាក់សមរម្យណាស់។ ជារឿយៗ តុលាការទុកឱ្យជនរងគ្រោះជា

អ្នកសម្រេចលើសំណងខូចខាតរបស់ខ្លួន ប៉ុន្តែពេលខ្លះមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញផងដែរ។ យោងតាមអ្នកផ្តល់សម្ភាសន៍ តុលាការខ្វះជំនាញក្នុងការវាយតម្លៃសំណងខូចខាតលើជំងឺចិត្ត និងផ្លូវចិត្ត។

"យើងមិនប្រាកដថាសំណងមានលក្ខណៈដូចម្តេចនោះទេពាក់ព័ន្ធទៅនឹងពិការភាព។ យើងគ្រាន់តែដឹងថា សំណងមានពីរប្រភេទ។ មួយជាសំណងរដ្ឋប្បវេណី និងមួយទៀតជាសំណងជំងឺចិត្ត។"

ព្រះរាជអាជ្ញា

## ៦.៣.៣ ការអនុវត្តសាលដីកាស្តីពីសំណង

ទោះបីជាមានការផ្តន្ទាទោសជោគជ័យដែលនៅក្នុងនោះជនរងគ្រោះ បានទទួលសំណងតាមរយៈសាលក្រមពេញចិត្តក្តី ក៏មានការលំបាកណាស់ក្នុងការអនុវត្តសាលក្រមនោះនៅក្នុងការអនុវត្តជាក់ស្តែង។ ជាលទ្ធផល មានការបង្ខំតិចតួចលើជនល្មើសឱ្យទូទាត់សំណងដល់ជនរងគ្រោះ ដោយមានការតាមដានត្រួតពិនិត្យ ឬការគ្រប់គ្រងតិចតួចពីសេចក្តីសម្រេចរបស់តុលាការ។

"សំណង គឺមានលក្ខណៈស្មុគស្មាញ។ ពុំមានអាជ្ញាសាលានៅគ្រប់ខេត្តទាំងអស់នោះទេ។ នៅទូទាំងប្រទេស គឺមានតែព្រះរាជអាជ្ញាប៉ុណ្ណោះ។ យើងពុំមានប្រព័ន្ធ ក្នុងការវាយតម្លៃទ្រព្យ ឬទ្រព្យសម្បត្តិរបស់នរណាម្នាក់ឡើយ។ នៅពុំទាន់មានការចុះបញ្ជីនៅក្រសួងយុត្តិធម៌នៅឡើយទេ ដើម្បីសាកសួរអំពីសំណង។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ក្នុងរឿងក្តីភាគច្រើន ជនល្មើសគឺជាជនក្រីក្រ ហើយមិនមានលទ្ធភាពទូទាត់សំណងនោះទេ។ ដូច្នេះ ជនរងគ្រោះពុំបានទទួលសំណង ហើយជនល្មើសអាចនឹងត្រូវជាប់ពន្ធនាគារយូរជាងមុន។

បើជនល្មើសបដិសេធពុំទូទាត់សំណង ជនរងគ្រោះត្រូវបញ្ជូននីតិវិធីទៅតុលាការ ដើម្បីបង្ខំឱ្យធ្វើការទូទាត់ ដែលគេហៅថា ដំណើរការនីតិវិធី "បង្ខំ" ដែលតាមវិធីនេះ ជនរងគ្រោះត្រូវឆ្លងកាត់តាមដំណើរការតុលាការសារឡើងវិញម្តងទៀត។ លើសពីនេះ ជនល្មើសដែលពុំជាប់ពន្ធនាគារ ជារឿយៗចាកចេញពីតំបន់មូលដ្ឋាន ដែលបង្កការលំបាកក្នុងការស្វែងរក និងបន្តនីតិវិធីផ្លូវច្បាប់ណាស់។

បញ្ហាមួយទៀតដែលបានលើកឡើងក្នុងសម្ភាសន៍ដែរគឺថា សំណងជារឿយៗគឺគ្រាន់តែប្រើប្រាស់ក្នុងការទូទាត់ដល់ព្រះរាជអាជ្ញា និងនគរបាលប៉ុណ្ណោះ ដែលធ្វើឱ្យជនរងគ្រោះពុំទទួលបានសំណង៖

"អំពើពុករលួយ ក៏ជាបញ្ហាឈឺក្បាលខ្លាំងផងដែរពេលនិយាយពីសំណង។ ឧទាហរណ៍ មានសំណងចំនួន ២ លានរៀល[៣២] ។ ចំនួនទឹកប្រាក់នេះត្រូវបែងចែកទៅជាចំណែកខុសៗគ្នាសម្រាប់នគរបាល និងព្រះរាជអាជ្ញា (ការទូទាត់ក្រោមតុជាការអរគុណដល់ពួកគេ) និងចំនួនទឹកប្រាក់អាចមានរហូតដល់ ៣ លានរៀល។ ប្រការនេះមានន័យថា មិនមានអ្វីនៅសល់នោះទេ ហើយជនរងគ្រោះថែមទាំងបានទូទាត់ ១ លានរៀលថែមពីលើចំនួនទឹកប្រាក់សំណងទៀត ដូច្នេះតើការទាមទារសំណងមានន័យអ្វីទៅ?"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ក្នុងសំណុំរឿងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សទៅប្រទេសថៃ និងប្រទេសគោលដៅផ្សេងទៀត គឺមានការកត់សម្គាល់ឃើញថា ភ្នាក់ងារជ្រើសរើសពលករតម្រូវឱ្យទូទាត់ប្រាក់កក់ធានាក្នុងចំនួនច្រើនសន្ធឹកសន្ធាប់រហូតដល់ ១០០.០០០ ដុល្លារអាមេរិក សម្រាប់រ៉ាប់រងលើសំណង។ អ្នកឆ្លើយតបបានស្នើឡើងថា ក្នុងការអនុវត្តជាក់ស្តែង គឺពុំមានដូច្នេះរឿងនោះទេ ដូចនេះហើយទើបពុំមានការជួយក្នុងការទាមទារប្រឆាំងទៅនឹងភ្នាក់ងារជ្រើសរើសពលករ។

ការណែនាំមួយ គឺត្រូវដាក់គ្រោងពេលវេលាសម្រាប់ការអនុវត្ត ឬការអនុវត្តសំណង។

## ៦.៣.៤ អាទិភាពរបស់ជនរងគ្រោះ និងការដោះស្រាយក្រៅផ្លូវការ

ផ្អែកលើការអនុវត្តជាក់ស្តែង ការស្វែងរកដំណោះស្រាយតាមរយៈប្រព័ន្ធយុត្តិធម៌ ជារឿយៗគឺពុំអាចអនុវត្តទៅបាននោះទេសម្រាប់ជនរងគ្រោះនៃពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ ជនរងគ្រោះជាច្រើនជួបប្រទះនឹងស្ថានភាពដែលពួកគេត្រូវការរកប្រាក់ចិញ្ចឹមជីវិតជាចាំបាច់បំផុត ដែលកត្តានេះរារាំងពួកគេពុំឱ្យចូលរួមក្នុងប្រព័ន្ធតុលាការដែលចំណាយពេលយូរនោះទេ។ សម្រាប់ពលករធ្វើការងារនៅក្រៅស្រុក ការបន្តស្នាក់នៅក្រៅប្រទេស គឺត្រូវចំណាយច្រើន និងមានហានិភ័យ ដើម្បីគ្រាន់តែបន្តនីតិវិធីតុលាការ។ ដូចដែលបានពិភាក្សានៅក្នុងផ្នែកទី ៥ ជនរងគ្រោះជារឿយៗមើលឃើញដំណើរការនីតិវិធីតុលាការថាមានការបំភិតបំភ័យ ទាមទារខ្ពស់ និងមានរយៈពេលយូរពេក។ ផ្ទុយមកវិញ ជនរងគ្រោះជារឿយៗពេញចិត្តនឹងលទ្ធផលរហ័សតាមរយៈការដោះស្រាយក្រៅផ្លូវការជាមួយជនល្មើស ឬនិយោជក។

ក្នុងករណីភាគច្រើន ជនរងគ្រោះនៃការអនុវត្តការងារកេងប្រវ័ញ្ច គឺបានត្រៀមខ្លួនក្នុងការទទួលចំនួនទឹកប្រាក់ដោះស្រាយកម្រិតទាប ដោយសារតែដំណោះស្រាយទាំងនេះមានភាពរហ័ស និងលទ្ធផលមួយចំនួន អនុញ្ញាតឱ្យជនរងគ្រោះចាប់ផ្តើមបន្តជីវភាពរស់នៅ ស្វែងរកការងារធ្វើ ឬត្រលប់ទៅស្រុកកំណើតវិញបានលឿន។

"ដំណោះស្រាយរវាងគ្រួសារជនរងគ្រោះ និងមេខ្យល់ ឬជនល្មើសនៅក្រៅប្រព័ន្ធតុលាការ គឺនៅតែជម្រើសពេញនិយមសម្រាប់រាល់គ្រប់រឿងក្តីទាំងអស់ ដែលសូម្បីរឿងក្តីព្រហ្មទណ្ឌក៏ដោយ។"

មន្ត្រីរដ្ឋាភិបាល

អ្នកឆ្លើយតបម្នាក់ក៏បានស្នើឡើងដែរថា ការភ័យខ្លាច គឺជាកត្តារួមចំណែកមួយដល់ការដោះស្រាយរឿងក្តីនៅក្រៅប្រព័ន្ធយុត្តិធម៌ផ្លូវការផងដែរ។

"បើវាពាក់ព័ន្ធនឹងទិដ្ឋភាពអារម្មណ៍ និងផ្លូវចិត្ត សំណងគឺពុំមែនជាមូលហេតុចម្បងដែលមនុស្សដកពាក្យបណ្ដឹងឡើយ។ ទោះជាយ៉ាងនេះក្ដី ពួកគេដកពាក្យបណ្ដឹង គឺដោយសារតែពួកគេភ័យខ្លាច។"

ព្រះរាជអាជ្ញា

ជាការសំខាន់ណាស់ក្នុងការទទួលស្គាល់ថា នៅក្នុងបរិបទនៃដំណើរការតុលាការរយៈពេលយូរ នឹងមិនច្បាស់លាស់ ការដោះស្រាយក្រៅប្រព័ន្ធតុលាការ អាចតំណាងឱ្យជម្រើសល្អបំផុតសម្រាប់ជនរងគ្រោះ ទោះបីជាសំណងដែលបានទទួលគឺទាប់ជាងសំណងដែលអាចនឹងទទួលបានប្រព័ន្ធច្បាប់ក៏ដោយ។ ទោះជាយ៉ាងនេះក្ដី ដូចដែលបានកត់សម្គាល់នៅក្នុងរបាយការណ៍ប្រទេសថៃ ដំណើរការនេះផ្តល់ការបង្អាក់ទឹកចិត្តតិចតួចដល់ជនល្មើសក្នុងការប្រព្រឹត្តការកេងប្រវ័ញ្ច។

## ៦.៣.៥ មូលនិធិជនរងគ្រោះ និងវឌ្ឍនភាពថ្មីៗ

បញ្ហាប្រឈមនានាក្នុងការទទួលបានសំណងសម្រាប់ជនរងគ្រោះ នៃពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស គឺពុំមែនជារឿងថ្មីនោះទេ។ នៅក្នុងការសិក្សារបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិនៅឆ្នាំ២០១៦ ការសិក្សានេះបានបង្ហាញថា ជនរងគ្រោះកម្រនឹងទទួលបានសំណងគ្រប់គ្រាន់ណាស់។ ភាគីពាក់ព័ន្ធទាំងអស់បានគូសបញ្ជាក់អំពីតម្រូវការក្នុងការដោះស្រាយបញ្ហា ដើម្បីធានាបាននូវការជាសះស្បើយសម្រាប់ជនរងគ្រោះ ធ្វើដូច្នេះទើបជនរងគ្រោះអាចចូលរួមក្នុងសំណុំរឿងផ្តន្ទាទោសបាន។ គួរឱ្យសោកស្ដាយណាស់ មានការអនុវត្តតិចតួចក្នុងរយៈពេលជាច្រើនឆ្នាំបន្ទាប់មក ហើយដីកាសំណងរបស់តុលាការនៅតែពិបាកក្នុងការអនុវត្តដដែរ។

ដើម្បីដោះស្រាយបញ្ហានេះ អ្នកតស៊ូមតិបានស្នើឡើងថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គួរតែផ្ដល់មូលនិធិដល់ជនរងគ្រោះនៃការជួញដូរមនុស្ស ដោយមានដំណើរការច្បាស់លាស់សម្រាប់ជនរងគ្រោះក្នុងការទទួលបានមូលនិធិនេះ។ ភាគីពាក់ព័ន្ធដែលបានសម្ភាសន៍បានទទួលស្គាល់ថា គម្រោងប្រភេទមួយចំនួនដើម្បីធានបាននូវសំណង គឺត្រូវការចាំបាច់ណាស់។

"ការទាមទារសំណង គឺមានការលំបាកណាស់។ រដ្ឋាភិបាល គួរតែបង្កើតមូលនិធិបម្រុងមួយប្រភេទ ឬមូលនិធិជនរងគ្រោះ ដែលពុំមានជាសំណង ប៉ុន្តែជាប្រាក់ឧបត្ថម្ភដើម្បីគាំទ្រជនរងគ្រោះក្នុងអំឡុងពេល និងបន្ទាប់ពីរឿងក្ដីតុលាការ។ នៅប្រទេសថៃ មូលនិធិរងគ្រោះទទួលបានប្រាក់ពីឆ្នោត។ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គួរតែមានមូលនិធិជំនួយសង្គមផងដែរ។

អ្នកផ្ដល់ព័ត៌មានអង្គការសង្គមស៊ីវិល

គំនិតមួយទៀតដែលបានស្នើឡើងដោយភាគីពាក់ព័ន្ធ គឺការអភិវឌ្ឍបន្ថែមទៅលើលទ្ធភាពក្នុងការទទួលបានប្រាក់កក់របស់និយោជក និងភ្នាក់ងារជ្រើសរើសពលករ។ ដោយលើកឡើងអំពីប្រព័ន្ធក្នុងបណ្ដាប្រទេសដទៃទៀត ដូចជាសិង្ហបុរីជាដើម និយោជកចាំបាច់ត្រូវតែដាក់ទុនបម្រុងក្នុងធនាគារ ដើម្បីអាចចូលប្រើប្រាស់បាននៅពេលដែលមានរឿងក្ដី និងការទាមទារសំណង។ ប្រការនេះពុំត្រឹមតែគាំទ្រដល់លទ្ធភាពរបស់ជនរងគ្រោះក្នុងការទទួលបានមូលនិធិប៉ុណ្ណោះទេ គឺថែមទាំងលើកកម្ពស់អនុលោមភាពតាមច្បាប់ផងដែរ។



# ៧ ការសហការជាមួយភាគីពាក់ព័ន្ធ

# ៧ ការសហការជាមួយភាគីពាក់ព័ន្ធ

## ៧.១ ការសម្របសម្រួលអន្តរទីភ្នាក់ងារ

### ៧.១.១ ទិដ្ឋភាពទូទៅ

ដូចដែលបានរៀបរាប់លម្អិតក្នុងផ្នែក ៣ ការផ្តន្ទាទោសទាមទារឱ្យមានការសហការគ្នា និងការបញ្ជូនរវាងអង្គការមិនមែនរដ្ឋាភិបាល នគរបាល នគរបាលយុត្តិធម៌ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចៅក្រមស៊ើបសួរ ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីតំណាងផ្លូវច្បាប់។ ដូចគ្នានេះដែរ ការថែទាំជនរងគ្រោះអាចទាមទារឱ្យមានការសហការគ្នា និងការបញ្ជូនរវាង អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលសំចតពលករ សង្គមកិច្ច (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត) ក្រសួងកិច្ចការនារី នគរបាលយុត្តិធម៌ និងអ្នកផ្តល់សេវាជាច្រើន (រួមទាំងសេវាសុខភាព ការស្តារនីតិសម្បទា ការងារ ការអប់រំ និងជំនាញវិជ្ជាជីវៈ)។

ភាគីពាក់ព័ន្ធក្នុងស្រុកទាំងអស់យល់ស្របថា កិច្ចសហប្រតិបត្តិការភាគីពាក់ព័ន្ធ គឺមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យនៃការឆ្លើយតបនឹងករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សដោយជោគជ័យ ពាក់ព័ន្ធនឹងការផ្តន្ទាទោស និងការគាំទ្រជនរងគ្រោះ។ ភាគីពាក់ព័ន្ធបានលើកឡើងថា ការសហការបាន និងកំពុងមានការល្អប្រសើរតាមពេលវេលា ហើយពួកគេបានកំណត់ឃើញផ្នែកមួយចំនួនដែលអាចកែលម្អបន្ថែមទៅលើការសហការអន្តរទីភ្នាក់ងារ។ ពួកគេបានគូសបញ្ជាក់ជាពិសេសអំពីការមានការយល់ដឹងរួមគ្នាអំពីតួនាទី និងអាទិភាពរបស់គ្នាទៅវិញទៅមក។

> "ការប្រឆាំងអំពើជួញដូរមនុស្ស គឺជាការអន្តរាគមន៍ពីអន្តរក្រសួង។ ទោះបីជា ទំនាក់ទំនងរបស់យើងជាមួយភាគីពាក់ព័ន្ធផ្សេងទៀតល្អហើយក៏ដោយ ក៏ការយល់ដឹងអំពីការអន្តរាគមន៍ក្នុងចំណោមពួកយើងនៅមានកម្រិតខុសៗគ្នាផងដែរ។ ដូច្នេះហើយ យើងចាំបាច់ត្រូវសហការគ្នាឱ្យបានជិតស្និទ្ធ។"
>
> មន្ត្រីរដ្ឋាភិបាល

### ៧.១.២ គោលការណ៍ណែនាំសម្រាប់ការសម្របសម្រួល

ភាគីពាក់ព័ន្ធបានយល់ស្របថា តួនាទី និងទំនួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនីមួយៗ ចាំបាច់ត្រូវតែចែងឱ្យបានច្បាស់ និងព្រមព្រៀងដោយភាគីទាំងអស់។

"យើងបាននិងកំពុងអភិវឌ្ឍន៍យន្តការច្បាស់លាស់មួយ ដើម្បីឱ្យមានការសហការគ្នាកាន់តែល្អប្រសើរក្នុងចំណោមក្រសួងសំខាន់ៗ។ យើងមានអនុស្សារណៈនៃការយោគយល់ហើយ។ ឥឡូវនេះយើងត្រូវការនីតិវិធីអនុវត្តដើម្បីជាជំនួយដល់ការអនុវត្តការងាររបស់យើង និងលើកកម្ពស់ការសហការ។ នីតិវិធីនេះ គួរតែចែងអំពីតួនាទី និងទំនួលខុសត្រូវកំណត់ថាអ្នកណាត្រូវធ្វើកិច្ចការអ្វីខ្លះ។"

មន្ត្រីរដ្ឋាភិបាល

គោលការណ៍ណែនាំនេះ ក៏នឹងធានាបាននូវនិរន្តរភាពនៃការសហការផងដែរ។ បច្ចុប្បន្ន ការសហការនេះជារឿយៗពឹងផ្អែកលើទំនាក់ទំនងការងារ និងចំណេះដឹងសហការដែលបានកសាងឡើងពីពេលមួយទៅពេលមួយ។ ទោះជាយ៉ាងនេះក្តី មានការគូសបញ្ជាក់ថា ការសហការរវាងនាយកដ្ឋាន គឺពុំបានធ្វើទៅជាផ្លូវការតាមរយៈកិច្ចព្រមព្រៀង និងកិច្ចសន្ទនាទៀងទាត់នោះទេ ដែលកត្តាធ្វើឱ្យការសហការគ្នាបន្តមានការលំបាកបន្ទាប់ពីការផ្លាស់ប្តូរបុគ្គលិកនៅកម្រិតនាយកដ្ឋាន។

## ៧.១.៣ ការយល់ដឹងខុសៗគ្នាអំពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស

ភាគីពាក់ព័ន្ធបានបង្ហាញថាក្រសួង និងស្ថាប័នខុសៗគ្នា បកស្រាយអំពីក្របខណ្ឌច្បាប់ស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សតាមមធ្យោបាយខុសៗគ្នា។

"នៅកម្រិតប្រទេស ការបកស្រាយក្របខណ្ឌច្បាប់នៅស្ថាប័នខុសៗគ្នា ដូចជានគរបាល មន្ទីរសង្គមកិច្ចខេត្ត និងតុលាការ គឺមានលក្ខណៈខុសគ្នា សម្រាប់ករណីមួយចំនួន ដោយសារតែការយល់ដឹងរបស់ពួកគេអំពីច្បាប់ និងនីតិវិធីគឺមានលក្ខណៈខុសគ្នា និងស្ថាប័ននីមួយៗមិនមានការអនុញ្ញាតឱ្យផ្តល់មតិត្រលប់ទៅគ្នាទៅវិញទៅមកនោះទេ។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការខេត្តប្រឆាំងអំពើជួញដូរមនុស្ស មានយន្តការដ៏ល្អសម្រាប់ការសម្រេចបាននូវការសហការ និងសម្រាប់ការធ្វើការងារឆ្ពោះទៅរកវិធីសាស្ត្រសហការចំពោះពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ទោះជាយ៉ាងនេះក្តី ការកែលម្អទាំងនោះជានិច្ចកាលមិនត្រូវបានសម្រិតសម្រាំងឱ្យដល់ថ្នាក់ក្រោមនោះទេ។ ក្រសួងសំខាន់ៗដូចជា ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ខ្វះវិធីសាស្ត្រដែលមានឯកសណ្ឋានភាពចំពោះច្បាប់ស្តីពីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ ភាគីពាក់ព័ន្ធ និងមន្ត្រីរដ្ឋាភិបាលនៅកម្រិតប្រតិបត្តិការអាចមានការយល់ដឹងខុសគ្នាអំពី ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងចាំបាច់ត្រូវមានវេទិកាមួយ ដើម្បីធ្វើការងារជាមួយគ្នាលើភាពខុសគ្នាទាំងនេះ។

ឧទាហរណ៍ នគរបាលស៊ើបអង្កេត មានការលំបាកក្នុងការស្វែងយល់អំពីរបៀបដែលព្រះរាជអាជ្ញានឹងបកស្រាយករណីទាំងនេះ។

"ឧទាហរណ៍ យើងអាចសន្និដ្ឋានអំពីរឿងក្តី និងណែនាំអំពីប្រភេទបទល្មើសជូនដល់ព្រះរាជអាជ្ញា។ ទោះជាយ៉ាងនេះក្តី ព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការបដិសេធការសន្និដ្ឋាននេះ និងធ្វើការសន្និដ្ឋានដោយខ្លួនឯង។ ព្រះរាជអាជ្ញាផ្លាស់ប្តូរប្រភេទបទល្មើសពីប្រភេទដែលយើងបានស្នើឡើងទៅជាប្រភេទបទល្មើសផ្សេងទៀត។"

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

## ៧.១.៤ ការប្រមូលទិន្នន័យ និងការចែករំលែកព័ត៌មាន

ដូចបានកត់សម្គាល់ដោយអង្គការ IJM នៅឆ្នាំ២០១៦ និងរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកជាច្រើន ការប្រមូលទិន្នន័យពាក់ព័ន្ធនឹងករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស គឺនៅខ្សោយណាស់ និងពុំមានលក្ខណៈជាប្រព័ន្ធនោះទេ។ លើសពីនេះ ទិន្នន័យរឿងក្តីដែលមាន គឺពុំបានចែករំលែកទូលំទូលាយនោះទេ។

"យើងនៅខ្វះប្រព័ន្ធទិន្នន័យ។ ដូច្នេះ យើងចាំបាច់ត្រូវប្រមូលទិន្នន័យពីសហការីរបស់យើងនៅថ្នាក់ខេត្ត។"

មន្ត្រីរដ្ឋាភិបាល

វាជាការចាំបាច់ដែលត្រូវមានការណែនាំច្បាស់លាស់អំពីរបៀបប្រមូល និងតាមដានត្រួតពិនិត្យទិន្នន័យ ដើម្បីធានាបាននូវការប្រមូលទិន្នន័យដែលមានលក្ខណៈដូចគ្នា។

"ជូនកាល រឿងក្តីពុំពាក់ព័ន្ធនឹងរឿងក្តីជួញដូរមនុស្សនោះទេ ប៉ុន្តែត្រូវបានកត់ត្រាជារឿងក្តីជួញដូរមនុស្សទៅវិញ ដោយសារមន្ត្រីចង់បង្ហាញក្នុងកំណត់ត្រារបស់ពួកគេថា ពួកគេកំពុងតែធ្វើការងារលើរឿងក្តីដោយផ្អែកលើគោលដៅដែលបានកំណត់។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ទោះជាយ៉ាងណាក៏ដោយ មានវឌ្ឍនភាពមួយចំនួនដែលបញ្ជាក់ជាភស្តុតាងតាមរយៈការកែលម្អទិន្នន័យរឿងក្តីជួញដូរមនុស្ស ដែលរាយការណ៍ទៅកាន់របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកកាលពីឆ្នាំកន្លងទៅនេះ។ បច្ចុប្បន្ន ទិន្នន័យគឺត្រូវបានរាយការណ៍នៅទូទាំងប្រទេស មិនមែនត្រឹមតែតុលាការនៅរាជធានីភ្នំពេញប៉ុណ្ណោះទេ។ ការកែលម្អមួយទៀតដែលល្អប្រសើរនោះគឺ ទិន្នន័យរឿងក្តីត្រូវតែតម្កល់នៅតុលាការផ្ទាល់តែម្តង។

## ៧.១.៥ ការស៊ើបអង្កេតសម្របសម្រួល

ក្នុងរបាយការណ៍ឆ្នាំ២០១៦ របស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានកត់សម្គាល់ថា ករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សជារឿយៗគឺត្រូវបានពន្យារពេល ដោយសារតែការសហការមិនមានប្រសិទ្ធភាពរវាងនគរបាល ព្រះរាជអាជ្ញា និង ចៅក្រមស៊ើបសួរ។ នៅក្នុងដំណើរការនៃការស្រាវជ្រាវនេះ ភាគីពាក់ព័ន្ធពុំបានបង្ហាញថាបញ្ហានេះ ជាបញ្ហាបច្ចុប្បន្នឡើយ។ ទោះបីជាការសហការអាចធ្វើឡើងបានល្អប្រសើរក៏ដោយក៏ តួអង្គស៊ើបអង្កេតជាទូទៅរាយការណ៍ថាការវាយតម្លៃលើកិច្ចខិតខំប្រឹងប្រែងសហប្រតិបត្តិការគឺមានលក្ខណៈវិជ្ជមាន។

"យើងសហការជាមួយព្រះរាជអាជ្ញា និងស្ថាប័នតុលាការ។ យើងក៏ធ្វើការងារជាមួយនាយកដ្ឋានសង្គមកិច្ចផងដែរ។ យើងសហការជាមួយមន្ទីរខេត្តពាក់ព័ន្ធ។"

អ្នកផ្តល់ព័ត៌មាននគរបាលយុត្តិធម៌

ភាគីពាក់ព័ន្ធជាទូទៅយល់ដឹងអំពីតួនាទីរបស់ពួកគេបានយ៉ាងល្អប្រសើរ ហើយនគរបាលខេត្តជាទូទៅពឹងផ្អែកលើនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសម្រាប់ផ្តល់ការណែនាំ។ បញ្ហាមួយបានលើកឡើងថា ការប្រមូលភស្តុតាងអាចមានការយឺតយ៉ាវ ពេលដែលអ្នកផ្តល់សេវា និងជំនាញការចូលរួម។

"ការទទួលរបាយការណ៍កោសល្យវិច្ច័យពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទពីក្រសួងសុខាភិបាល (MOH) សម្រាប់រឿងក្តីផ្សេងៗគឺមានលក្ខណៈយឺតយ៉ាវ។ យើងពុំទទួលបានលទ្ធផលពីក្រសួងសុខាភិបាលទាន់ពេលវេលានោះទេ។ ពួកគេប្រហែលជាខ្វះថវិកាក្នុងការដំណើរការការងារនេះឱ្យយើង។ ជួនកាល លទ្ធផលរបស់ពួកគេ គឺពុំអាចប្រើប្រាស់បានសម្រាប់សវនាការនោះឡើយ។ ការពឹងផ្អែក និងការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើលទ្ធផលនេះ គឺមានការលំបាកណាស់សម្រាប់គោលបំណងជំនុំជម្រះ។ ចំពោះបទល្មើសរំលោភបំពានផ្លូវភេទ យើងត្រូវការភស្តុតាង។ បើមិនដូច្នោះទេ ជនល្មើសអាចនឹងត្រូវបានដោះលែងទៅវិញបន្ទាប់ពីរយៈពេលឃាត់ខ្លួនជាក់លាក់។"

ចៅក្រម

## ៧.១.៦ ការស៊ើបអង្កេតសម្របសម្រួល

នគរបាល និងមន្ត្រីរដ្ឋាភិបាល បានរាយការណ៍ដូចគ្នាថា ទំនាក់ទំនងទៅកាន់តួអង្គតុលាការ អាចនឹងមានការលំបាក ហើយពួកគេមានការយល់ដឹងមានកម្រិតប៉ុណ្ណោះអំពីដំណើរការនីតិវិធីតុលាការ និងនីតិវិធីផ្លូវច្បាប់។ លើសពីនេះ ពួកគេដឹងឮតិចតួចណាស់អំពីរឿងក្តីនៅពេលដែរឿងក្តីនោះត្រូវបានបញ្ជូនទៅកាន់តុលាការ។

លើសពីនេះ នគរបាលនិយាយថា ពេលខ្លះពួកគាត់មានអារម្មណ៍ថាត្រូវបានតុលាកការមើលងាយ ហើយប្រការនេះនាំឱ្យមានការស្ទាក់ស្ទើរនៅក្នុងការធ្វើការងារជាមួយគ្នា។ ទោះជាយ៉ាងនេះក្តី កាលពីពេលថ្មីៗនេះ ទំនាក់ទំនងត្រូវបានគេសង្កេតឃើញថាមានការល្អប្រសើរឡើងក្នុងការសហការគ្នារវាងព្រះរាជអាជ្ញា និងនគរបាល។

"ការសហការរបស់យើងជាមួយព្រះរាជអាជ្ញា និងនគរបាល (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន) គឺមានភាពរលូនជាងមុន។ កាលពីមុន ការសហការពុំសូវរលូនដូចឥឡូវនោះទេ។ ពួកគេសម្តែងអាកប្បកិរិយាប្រៀបបីដូចជាពួកគេជាថ្នាក់លើរបស់យើង និងមានចំណេះដឹងខ្ពស់ជាងយើង។

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

ការកែលម្អមួយទៀតលើការប្រាស្រ័យទាក់ទង គឺតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ដោយប្រើប្រាស់កម្មវិធីនានាដើម្បីពិភាក្សាអំពីសំណុំរឿងដោយមានការពន្យារពេលតិចជាងមុន ងាយស្រួលជាងមុន និងឆ្លើយតបបានរហ័សជាងមុន។

"កាលពីមុន គឺមានការលំបាកណាស់ ... បើយើងចង់និយាយជាមួយពួកគាត់ (ព្រះរាជអាជ្ញា និងភាគីពាក់ព័ន្ធតុលាការ) យើងចាំបាច់ត្រូវទៅជួបផ្ទាល់។ ឥឡូវនេះ ជាមួយនឹងបច្ចេកវិទ្យាទំនើប យើងអាចប្រាស្រ័យទាក់ទងគ្នាតាមរយៈការហៅទូរស័ព្ទ និងកម្មវិធីទំនាក់ទំនងតាមទូរស័ព្ទដៃ។ យើងមានអារម្មណ៍កាន់តែមានសេរីភាពក្នុងការប្រាស្រ័យទាក់ទង។ យើងពុំសូវមានអារម្មណ៍ស្ទាក់ស្ទើរដូចមុននោះទេ។"

អ្នកផ្តល់ព័ត៌មាននគរបាលខេត្ត

## ៧.១.៧ ការសម្របសម្រួលការគាំទ្រជនរងគ្រោះ

យន្តការបញ្ជូនសម្រាប់គាំទ្រជនរងគ្រោះ គឺដំណើរការបានល្អ ទោះបីជាភាគីពាក់ព័ន្ធបានកត់សម្គាល់ថាពេលខ្លះ ជនរងគ្រោះអាចនឹង "ធ្លាក់ចូលទៅក្នុងគម្លាត" ដោយសារអ្នកផ្តល់សេវាជាច្រើនមានលក្ខណៈវិនិច្ឆ័យលើការទទួលយកការបញ្ជូនខុសៗគ្នា។

"មានករណីមួយដែលជនរងគ្រោះទទួលរងបញ្ហាសុខភាពផ្លូវចិត្ត។ យើងបានពិនិត្យជាមួយនាយកដ្ឋានសង្គមកិច្ច ដើម្បីស្វែងរកសេវាគាំទ្រពីពួកគេ ឬថាតើពួកគេមានមជ្ឈមណ្ឌលដែលជនរងគ្រោះអាចស្នាក់នៅបានដែរឬទេ។ បើពុំមានទេ យើងអាចបញ្ជូនជនរងគ្រោះទៅកាន់មជ្ឈមណ្ឌលថ្មីនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលជំនួសវិញ។ ចំពោះករណីនេះ មិនមានសេវាសម្រាប់ជនរងគ្រោះនៅតំបន់របស់ពួកគាត់នោះទេ។ ដូច្នេះ យើងបានបញ្ជូនពួកគាត់ទៅកាន់មជ្ឈមណ្ឌលថ្មី។"

ព្រះរាជអាជ្ញា

ដូចដែលបានគូសបញ្ជាក់ពីខាងលើ ភាគីពាក់ព័ន្ធបានរាយការណ៍ថា សង្គមកិច្ច និងសេវាសង្គមកិច្ចគឺមិនបានរួមបញ្ចូលឱ្យបានគ្រប់គ្រាន់នៅក្នុងដំណើរការស៊ើបអង្កេត និងដំណើរការតុលាការនោះទេ។ អ្នកតំណាងផ្នែកសង្គមកិច្ច អង្គការសង្គមស៊ីវិល និងអ្នកផ្តល់សេវាសុខុមាលភាពសង្គម គឺមិនបានទទួលការជូនដំណឹងពីនគរបាល និងមន្ត្រីតុលាការអំពីដំណើរការនីតិវិធីរឿងក្តីនោះទេ ហើយប្រការនេះមានន័យថា សុខុមាលភាពរបស់ជនរងគ្រោះគឺមិនបានការពារបានគ្រប់គ្រាន់នៅទូទាំងសវនាការតុលាការនោះទេ។ ដូចគ្នានេះដែរ ក្នុងអំឡុងពេលនៃការស៊ើបអង្កេត ការគាំទ្រជនរងគ្រោះគឺមិនមានការជូនដំណឹងនោះទេ មានន័យថាការសម្ភាសន៍ដែលគិតគូរលើជនរងគ្រោះ គឺមិនបានធ្វើឡើងជានិច្ចនោះទេ។ តួអង្គសុខុមាលភាពសង្គម ចាំបាច់ត្រូវតែរួមបញ្ចូលឱ្យបានល្អប្រសើរនៅក្នុងដំណើរការទាំងនេះ និងនៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី។ ជូនកាល ភាគីពាក់ព័ន្ធគិតថា សេវាគាំទ្រគឺត្រូវការចាំបាច់តែសម្រាប់ករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សប្រភេទជាក់លាក់ប៉ុណ្ណោះ។

បញ្ហាជាបន្តបន្ទាប់មួយដែលបានគូសបញ្ជាក់គឺថា កង្វះការតាមដានឱ្យបានជិតដល់បន្ទាប់ពីការរាយការណ៍ ឬការបញ្ជូនរឿងក្តី។ អ្នកចូលរួមដែលបានចូលរួមនៅក្នុងដំណាក់កាលដំបូងនៃរឿងក្តី មិនស្ថិតនៅក្នុងរឿងក្តីនោះទេ នៅពេលដែលរឿងក្តីនោះត្រូវបានបញ្ជូនរួចរាល់។ ប្រការនេះរារាំងដល់ការសហការ និងការកសាងសមត្ថភាពរឿងក្តីពីពេលមួយទៅពេលមួយ និងពុំមានការផ្តល់មតិត្រលប់ដល់ភាគីពាក់ព័ន្ធឱ្យរៀនសូត្រអំពីដំណើរការនេះនោះទេ។

"រឿងក្ដីដែលបញ្ជូនទៅតុលាការ ពុំបានជូនដំណឹងដល់ភាគីផ្សេងទៀតនោះទេ និងបានផាត់ពួកចេញពី "ការរក្សាព័ត៌មានសម្ងាត់។"

អ្នកផ្ដល់ព័ត៌មាននគរបាល

ជារួម ភាគីពាក់ព័ន្ធបានលើកឡើងថា នៅកម្រិតសហគមន៍ ការសហការត្រូវបានកែលម្អពីពេលមួយទៅពេលមួយ នៅពេលដែលភាគីពាក់ព័ន្ធធ្វើការងារជាមួយគ្នា កសាងទំនាក់ទំនង និងពង្រឹងបណ្ដាញប្រាស្រ័យទាក់ទង។

"ការកែលម្អមួយក្នុងចំណោមការកែលម្អធំបំផុតក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនោះ គឺការកែលម្អការសហការក្នុងចំណោម អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរកាន់តែល្អប្រសើរជាងមុន។ ការសហការដំណើរការកាន់តែលឿនជាងមុន។"

អ្នកផ្ដល់ព័ត៌មានអង្គការសង្គមស៊ីវិល

## ៧.២ កិច្ចសហប្រតិបត្តិការឆ្លងដែន

### ៧.២.១ ការធ្វើប្រតិបត្តិការក្របខណ្ឌសហការ

ទោះបីជាមានអនុស្សារណៈនៃការយោគយល់លេចធ្លោរស្រាប់ដែលអំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការរវាងប្រទេសថៃ និងកម្ពុជាក៏ដោយ ក៏ចាំបាច់ត្រូវមានភាពជាក់លាក់បន្ថែមទៀតដើម្បីអនុវត្តគោលដៅ និងផ្ដួចផ្ដើមឱ្យមានការសហការគ្នានៅក្នុងការអនុវត្តជាក់ស្ដែង។ អ្នកឆ្លើយតបរដ្ឋាភិបាលបង្ហាញថា អនុស្សារណៈនៃការយោគយល់ផ្ដល់នូវទិដ្ឋភាពទូទៅអំពីយន្តការបញ្ជូន ប៉ុន្តែតួអង្គរដ្ឋាភិបាល និងមន្ត្រីខ្លួនឯងផ្ទាល់មិនមានការយល់ដឹងច្បាស់លាស់អំពីតួនាទីជាក់លាក់របស់ខ្លួននោះទេ។ ពួកគេនិយាយថា យន្តការកិច្ចសហប្រតិបត្តិការចាំបាច់ត្រូវតែកំណត់ឱ្យបានច្បាស់អំពីតួនាទីរបស់តួអង្គនានាពាក់ព័ន្ធនឹងដំណើរការផ្លូវច្បាប់ និងការឆ្លើយតបនឹងរឿងក្ដី ដោយយោងទៅលើស្ថាប័នជាក់លាក់។

"អនុស្សារណៈនៃការយោគយល់ គ្រាន់តែចែងអំពីយន្តការបញ្ជូន និងការឆ្លើយតបផ្លូវច្បាប់ទូទៅប៉ុណ្ណោះសម្រាប់ប្រទេសនីមួយៗ ប៉ុន្តែមិនមានចែងជាក់លាក់សម្រាប់ស្ថាប័ននីមួយៗឡើយ។"

អ្នកផ្ដល់ព័ត៌មាននគរបាល

មកទល់ពេលនេះ គោលការណ៍ណែនាំ និងស្តង់ដារនីតិវិធីប្រតិបត្តិ ដើរតួនាទីសំខាន់ណាស់នៅក្នុងការផ្ដល់នីតិវិធីច្បាស់លាស់សម្រាប់ការសហការគ្នាតាមរយៈការណែនាំលម្អិតតាមជំហាន។ កាលពីពេលថ្មីៗនេះ រដ្ឋាភិបាលថៃ និងកម្ពុជាបានឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ តាមរយៈការផលិតស្តង់ដារនីតិវិធីប្រតិបត្តិ ពាក់ព័ន្ធនឹងសេវាជនរងគ្រោះនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងការអនុវត្តច្បាប់ស្ដីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ នៅឆ្នាំ២០២១ រដ្ឋាភិបាលថៃ និងកម្ពុជាបានបញ្ចប់ស្ថាពរនូវកិច្ចព្រមព្រៀងបង្កើតស្តង់ដារនីតិវិធីប្រតិបត្តិស្ដីពីមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករខ្មែរដែលជាជនរងគ្រោះនៃការជួញដូរមនុស្ស។ នៅខែសីហា ឆ្នាំ២០២២ រដ្ឋាភិបាលថៃ និង

កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីដាក់ឱ្យប្រើប្រាស់ស្តង់ដារនីតិវិធីប្រតិបត្តិស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស (ដែលបានចុះហត្ថលេខារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខប្រជាជននៃប្រទេសថៃ)។[៣៣] ការត្រួតពិនិត្យឡើងវិញឆ្នាំ២០១៦ របស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក បានអំពាវនាវឱ្យមានការដាក់ចេញគោលការណ៍ណែនាំ និង ស្តង់ដារនីតិវិធីប្រតិបត្តិបន្ថែមទៀតសម្រាប់ការសហការ។

## ៧.២.២ ការស៊ើបអង្កេតរួម

ផ្នែកមួយដែលការសហការត្រូវបានកំណត់នោះគឺ កង្វះការសហការនៅក្នុងការស៊ើបអង្កេត។ ជារឿយៗ ជនល្មើសដែលនៅក្រៅប្រទេសអាចគេចផុតពីផលវិបាកនានា ទោះបីជាបានប្រមូលលភស្តុតាងអំពីរឿងក្តីបានយ៉ាងច្រើនក្នុងកម្ពុជាក្តី។

"ជនសង្ស័យគឺស្ថិតនៅក្រៅឃុំ ដោយសារបទល្មើសកើតឡើងនៅក្នុងប្រទេសចិន។ ជនរងគ្រោះ គឺត្រូវបានគេជួញដូរទៅប្រទេសចិន។ យើងអាចត្រឹមតែសម្ភាសន៍ជនរងគ្រោះប៉ុណ្ណោះ។ មិនការស៊ើបអង្កេតបន្ថែមឡើយ។ យូរៗទៅ យើងអាចត្រឹមតែចាប់ខ្លួនមេខ្យល់ប៉ុណ្ណោះ ពុំមែនជនល្មើសឡើយ។ ប្រការនេះមានន័យថា អ្នកដែលទទួលជនរងគ្រោះនៅប្រទេសគោលដៅ គឺពុំត្រូវបានចាប់ខ្លួននោះទេ និងនៅតែរួចផុតពីបទល្មើសដែលពួកគេបានប្រព្រឹត្ត។ ការសហការសម្រាប់ការស៊ើបអង្កេតគឺនៅមានការខ្វះខាត។"

ចៅក្រម

ស្របពេលដែលស្តង់ដារនីតិវិធីប្រតិបត្តិ អាចនឹងគ្របដណ្តប់លើការស៊ើបអង្កេតក្នុងវិសាលភាពមួយ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ជាក់លាក់អំពីរបៀបដែលប្រទេសអាចធ្វើការងារជាមួយគ្នា នៅក្នុងការស៊ើបអង្កេតករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។

"គួរតែមានអនុស្សារណៈនៃការយោគយល់ សម្រាប់ការស៊ើបអង្កេតឆ្លងប្រទេស។ អនុស្សារណៈនៃការយោគយល់ដែលមានស្រាប់ គឺផ្តោតលើតែមាតុភូមិនិវត្តន៍ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ពុំមានអនុស្សារណៈនៃការយោគយល់ពាក់ព័ន្ធនឹងការស៊ើបអង្កេតរួមគ្នានោះទេ។ ដូចគ្នានេះដែរ ការកំណត់អត្តសញ្ញាណក៏គួរតែមានលក្ខណៈរួម។"

អ្នកផ្តល់ព័ត៌មានអង្គការសង្គមស៊ីវិល

ភាគីពាក់ព័ន្ធមួយចំនួនស្នើឡើងថា សកម្មភាពចាំបាច់ត្រូវតែបន្តឱ្យហួសពីសេចក្តីបង្គាប់ប្រតិបត្តិការ និងរួមបញ្ចូលការរៀបចំក្រុមស៊ើបអង្កេតរួមគ្នា។ នាពេលបច្ចុប្បន្ន ការសហការពឹងផ្អែកលើទំនាក់ទំនងការងាររវាងបុគ្គលមកពីប្រទេសនានា ប៉ុន្តែទំនាក់ទំនងទាំងនេះមិនមានស្ថិរភាព ឬចីរភាពឡើយ។ ទំនាក់ទំនងការងារទាំងនេះ ចាំបាច់ត្រូវតែពង្រឹងតាមរយៈបណ្តាញផ្លូវការ ដែលរួមបញ្ចូលទំនាក់ទំនងទៀងទាត់ ការធ្វើការងាររួមគ្នា ការពិភាក្សា និងការប្រជុំ ដើម្បីឱ្យការសហការមានប្រសិទ្ធភាព។

## ៧.២.៣ ការសហការអន្តរក្រសួង

កិច្ចប្រជុំអន្តរក្រសួងស្តីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ជារឿយៗពុំកើតឡើងលើសពីការប្រជុំរវាងគណៈកម្មាធិការជាតិប្រឆាំងអំពើជួញដូរមនុស្ស និងភាគីខាងថៃឡើយ។ ភាគីដែលចូលរួមនៅក្នុងកិច្ចប្រជុំចាំបាច់ត្រូវតែពង្រីក និងផ្តោតលើប្រធានបទនៃការសហការជាក់លាក់។ មធ្យោបាយមួយដែលអាចដោះស្រាយបញ្ហានេះបាន គឺតាមរយៈក្រុមការងារអន្តរក្រសួង រវាងកម្ពុជា និងថៃ។

ឧទាហរណ៍ ជាការឆ្លើយតបទៅនឹងការរីកសាយភាយនៃពលកម្មដោយបង្ខំ និងការរំលោភបំពានការងារលើពលករចំណាកស្រុកនៅក្នុងប្រទេសថៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរាយការណ៍ថា ក្រសួងមានបំណងចង់ដឹកនាំក្រុមការងារអន្តរក្រសួង ដែលបានបង្កើតឡើងនៅក្រោមសេចក្តីសម្រេចលេខ ៩៧។ មធ្យោបាយមួយដែលអាចធ្វើឱ្យបណ្តាញនេះមានប្រសិទ្ធភាព គឺត្រូវរៀបចំកិច្ចប្រជុំសម្របសម្រួលរវាងភាគីក្រសួងថៃ និងកម្ពុជា ដូចជាក្រសួងយុត្តិធម៌ ក្រសួងការងារ ក្រសួងសង្គមកិច្ច និងមន្ត្រីអនុវត្តច្បាប់។

បន្ថែមលើឧទាហរណ៍នេះ អង្គការ IJM បានកត់សម្គាល់នៅឆ្នាំ ២០១៦ ថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចាំបាច់ត្រូវដើរតួនាទីឱ្យបានកាន់តែសកម្មជាងមុននៅក្នុងការធានាឱ្យបានថា បទល្មើសជួញដូរពលកម្ម គឺត្រូវបានបង្ការ កំណត់ និងដំណើរការតាមរយៈប្រព័ន្ធយុត្តិធម៌សាធារណៈ។ គំនិតផ្តួចផ្តើមប្រភេទនេះ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការងារកាន់តែជិតស្និទ្ធជាមួយក្រសួងផ្សេងទៀត គួរតែជាវេទិកាមួយសម្រាប់ឱ្យក្រសួងធ្វើការពិភាក្សាអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីចំណាកស្រុក និងច្បាប់ស្តីពីការជ្រើសរើសពលករ អាចបង្កើត និងធ្វើនិយ័តកម្មឱ្យបានកាន់តែប្រសើរ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះទៅនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងធ្វើប៉ះពាល់ដល់ "បរិយាកាសអំណោយផល" ដែលពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សអាចកើតឡើង។

## ៧.២.៤ ការកំណត់អត្តសញ្ញាណជនរងគ្រោះនៅក្នុងដែនយុត្តាធិការខុសៗគ្នា

បញ្ហាប្រឈមសំខាន់មួយចំពោះការសហការ អាចមានភាពខុសគ្នាចំពោះច្បាប់នៅទូទាំងដែនយុត្តាធិការ ជាពិសេសពាក់ព័ន្ធនឹងការកំណត់ ពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងការកំណត់អត្តសញ្ញាណជនរងគ្រោះ។

> "កម្ពុជាអនុលោមតាមពិធីសារប៉ាឡឺម៉ូ (Palermo) ខណៈពេលដែលប្រទេសមួយចំនួនមិនអនុវត្តតាម។ ដូច្នេះ នៅពេលដែលពាក់ព័ន្ធនឹងការសហការអន្តរជាតិ គឺជាបញ្ហាប្រឈម។ ជប៉ុន ពុំអនុវត្តតាមពិធីសារ Palermo នោះទេ។ បណ្តាប្រទេសទាំងនោះ ប្រើប្រាស់ច្បាប់មូលដ្ឋានរបស់ពួកគេ ដែលបង្ហាញអំពីធាតុផ្សំដែលត្រូវពិចារណាថាជាករណីជួញដូរមនុស្ស។ បន្ទាប់មក បណ្តាប្រទេសទាំងនោះធ្វើអន្តរាគមន៍តាមការសមស្រប។"
>
> អ្នកផ្តល់ព័ត៌មាននគរបាល

ភាពខុសគ្នានៅក្នុងច្បាប់ អាចមានន័យថាជនល្មើស ឬជនរងគ្រោះ ដែលនឹងជួបប្រទះនឹងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា អាចនឹងពុំបានកំណត់អត្តសញ្ញាណនៅក្រៅប្រទេសឡើយ។ ប្រការនេះ អាចដោយសារតែបណ្តាប្រទេសនៅក្រៅប្រទេសជានិច្ចកាល មិនបានផ្តល់ការលើកទឹកចិត្តដល់ការកំណត់អត្តសញ្ញាណ ករណីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្សកើតឡើងចំពោះពលករចំណាកស្រុក ឬជនបរទេសក្នុងប្រទេសរបស់ពួកគេឡើយ។ ភាពខុសគ្នាលើច្បាប់ទាំងនេះ ក៏អាច

រារាំងដល់ការសហការផងដែរ ដោយសារតែមានការភាន់ច្រលំ និងមតិយោបល់ខុសៗគ្នារវាងមន្ត្រីនៃប្រទេសពាក់ព័ន្ធ។

"យើងពុំអាចបង្ខំ (ប្រទេស) ផ្សេងឱ្យចាប់ខ្លួនប្រជាជនរបស់ពួកគេនោះទេ ឬធ្វើវិសោធនកម្មច្បាប់ដើម្បីសម្របសម្រួលតាមយើងបានឡើយ។ យើងអាចត្រឹមស្នើឱ្យមានការបង្កើនការសហការប៉ុណ្ណោះ។"

អ្នកផ្តល់ព័ត៌មាននគរបាល

## ៧.២.៦ ការសហការនៅព្រំដែនជាមួយប្រទេសថៃ

អាជ្ញាធរនៅតាមខេត្តព្រំដែន បានបង្កើតនីតិវិធីផ្លូវការជាច្រើនសម្រាប់ការសហការគ្នា រួមទាំងប្រព័ន្ធឆ្លងព្រំដែនក្រៅផ្លូវការដើម្បីជាជំនួយដល់សហគមន៍នៅតាមព្រំដែនក្នុងការធ្វើការងារនៅក្នុងប្រទេសថៃ។ ដោយសារតែអាជ្ញាធរទាំងនេះចំណាយពេលវេលាធ្វើការងារនៅទីតាំងផ្ទាល់ ពួកគាត់ឆ្លើយតបកាន់តែរហ័សទៅនឹងក្តីបារម្ភ និងការផ្លាស់ប្តូរភ្លាមៗលើការធ្វើចំណាកស្រុក។ ដូច្នេះ អាជ្ញាធរទាំងនេះបង្ហាញអំពីកម្រិតសហការគ្នាបានយ៉ាងល្អ និងបានបង្កើតទំនាក់ទំនងការងារ។ អាជ្ញាធរអាចទំនាក់ទំនងគ្នាទៅវិញទៅមកបានយ៉ាងរហ័ស និងរៀបចំកិច្ចប្រជុំទៀងទាត់ តាមការចាំបាច់ ដើម្បីឆ្លើយតបទៅនឹងករណីនានា និងអនុវត្តប្រតិបត្តិការព្រំដែន។ ដំណើរការទាំងនេះ ភាគច្រើនគឺជាដំណើរការក្រៅផ្លូវការ។

"ពុំមានអនុស្សារណៈនៃការយោគយល់សម្រាប់ការសហការឆ្លងដែននៅតំបន់ព្រំដែននោះទេ។ ប៉ុន្តែ យើងមានរបាយការណ៍រួមក្នុងការសរសេរ។ ឧទាហរណ៍ សម្រាប់ការយាមល្បាតវិញ នគរបាលចំណាកស្រុកថៃ នឹងសួរថាតើនគរបាលខ្មែរចង់ចូលរួមក្នុងការល្បាតព្រំដែនរួមគ្នាជាមួយនគរបាលថៃដែរឬទេតាមរយៈការដើរមើលតាមដែនដីរៀងៗខ្លួន"។

មន្ត្រីរដ្ឋាភិបាល

ការសហការក្នុងចំណោមអាជ្ញាធរនៅតំបន់ព្រំដែន ទំនងជាផ្តោតទៅលើសន្តិសុខព្រំដែន និងបែងចែកឱ្យបានដាច់ពីគ្នារវាងការឆ្លងដែនធម្មតា និងការឆ្លងដែនខុសច្បាប់។ ក្នុងករណីជាច្រើន កិច្ចខិតខំអនុវត្តកិច្ចការនគរបាលនៅតាមព្រំដែន និងការបង្ក្រាបពលករដែលឆ្លងដែនខុសច្បាប់ គឺត្រូវបានបង្ហាញជាកិច្ចប្រឹងប្រែងប្រឆាំងការជួញដូរមនុស្សប្រកបដោយជោគជ័យ។ ក្នុងការអនុវត្តជាក់ស្តែង ប្រការនេះមិនមែនជាការជោគជ័យអ្វីនោះទេ ដោយសារការឆ្លងដែនខុសច្បាប់ គឺធ្វើឡើងជាទូទៅដោយពលករចំណាកស្រុកជាច្រើន និងអាចពាក់ព័ន្ធជាមួយនឹងបទពិសោធន៍ចំណាកស្រុកវិជ្ជមាន។

ដូចដែលបានពិភាក្សានៅក្នុងចំណុចផ្សេង ការសង្កត់ធ្ងន់ខ្លាំងពេកទៅលើសន្តិសុខព្រំដែនជាការឆ្លើយតបទៅនឹងការជួញដូរមនុស្ស អាចជះឥទ្ធិពលដល់ការផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្សពីសំណាក់ "មេខ្យល់" ដែលមិនមានចេតនាធ្វើដូច្នោះ (ឧ. សមាជិកគ្រួសារ និងបុគ្គលទំនាក់ទំនងក្នុងមូលដ្ឋាន) និងធ្វើឱ្យមានភាពស្រពិចស្រពិលទៅលើសារៈសំខាន់នៃការផ្តោតលើកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្សមកលើនិយោជក និង អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សមានអង្គភាពចាត់តាំង ដែលទទួលខុសត្រូវចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពាន។

## ៧.២.៧ ការចែករំលែកព័ត៌មាន

បញ្ហាដែលបានលើកឡើងជាទូទៅគឺថា ភាគីខាងថៃ មិនងាយចែករំលែកព័ត៌មានជាមួយភាគីពាក់ព័ន្ធកម្ពុជានោះទេ។ បញ្ហានេះ គឺសង្ឃឹមថានឹងដោះស្រាយឱ្យបានគ្រប់គ្រាន់នៅក្នុងស្តង់ដារនីតិវិធីប្រតិបត្តិដែលបានបង្កើតឡើងកាលពីពេលថ្មីៗនេះ ប៉ុន្តែមានកិច្ចការច្រើនណាស់ដែលត្រូវធ្វើ ដើម្បីកំណត់រកព័ត៌មានណាដែលគួរតែចែករំលែក ចែករំលែកដោយអ្នកណា និងចែករំលែកដោយរបៀបណា។ កាតព្វកិច្ច និងភារកិច្ចច្បាស់លាស់សម្រាប់ការចែករំលែកព័ត៌មានអំពីករណីនានា នឹងបង្កើនសមត្ថភាពសម្រាប់តួអង្គទាំងអស់ក្នុងការសហការគ្នា និងកសាងសមត្ថភាពតាមពេលវេលា។

> "ចំពោះការតាមដាន អ្វីក៏ដោយដែលភាគីខាងថៃធ្វើ គឺយើងពុំដឹងអ្វីទាំងអស់។ ពុំមានយន្តការច្បាស់លាស់ណាមួយក្នុងការផ្តល់ការឆ្លើយតបមកយើងវិញនោះទេ។ ពេលដែលយើងចង់តាមដានដើម្បីសុំបច្ចុប្បន្នភាព ពុំមានអ្វីឱ្យយើងអាចយោងបាន ដែលពួកគេចាំបាច់ត្រូវឆ្លើយតបមកយើងវិញនោះទេ។"
>
> ព្រះរាជអាជ្ញា

បន្ថែមពីលើចំណុចនេះ ការប្រមូលទិន្នន័យចាំបាច់ត្រូវតែកែលម្អផងដែររវាងកម្ពុជា និងថៃ ដើម្បីចាប់ឱ្យបាននូវភាពងាយរងគ្រោះទៅនឹងពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស ការសាយភាយនៃបញ្ហាដែលពលករចំណាកស្រុកជួបប្រទះ លក្ខខណ្ឌការងារ លទ្ធភាពទទួលបានសេវា និងសម្រាប់ការវាស់វែងការកែលម្អលើសុខុមាលភាពរបស់ពួកគេ។ ទិន្នន័យមានស្រាប់ គឺពុំបានចែករំលែកជាទៀងទាត់រវាងបណ្តាប្រទេសឡើយ។ ទិន្នន័យរបស់ប្រទេសថៃអំពីចំណាកស្រុកធម្មតារបស់ពលករខ្មែរ គឺមានសារៈសំខាន់ណាស់ ប៉ុន្តែដោយសារពលករមួយចំនួនធំគឺជាពលករខុសច្បាប់ ពលករទាំងនេះពុំត្រូវបានកត់ត្រានៅក្នុងទិន្នន័យនេះឡើយ។ នៅខាងកម្ពុជាវិញ មានការប្រមូលទិន្នន័យតិចតួចបំផុតអំពីពលករចំណាកស្រុក។

## ៧.២.៨ មាតុភូមិនិវត្តន៍ និងការគាំទ្រជនរងគ្រោះ

ផ្នែកនៃការសហការដ៏រឹងមាំបំផុត គឺបានបង្ហាញថាជា ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ និងការបញ្ជូនពលកររងគ្រោះខ្មែរទៅកាន់អ្នកផ្តល់សេវា។

ភាគីពាក់ព័ន្ធផ្នែកសុខុមាលភាពសង្គមបានបង្ហាញថា ក្រសួងនិងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងភាគីខាងថៃធ្វើការងារជាមួយគ្នាបានយ៉ាងល្អក្នុងការសម្របសម្រួលមាតុភូមិនិវត្តន៍ និងការតាមដានស្វែងរកគ្រួសារ។ ទោះបីជាអាជ្ញាធរថៃជានិច្ចកាលពុំជូនដំណឹងជាមុនអំពីពលករដែលនឹងត្រូវបណ្តេញចេញ (ផ្នែក ៦.១.៧) ក៏ដោយ ក៏មានការប្រាស្រ័យទាក់ទងល្អប្រសើរជាមួយនឹងមជ្ឈមណ្ឌលសំចតប៉ោយប៉ែត អំពីការត្រលប់មកវិញនៃពលករដែលត្រូវបានគេជួញដូរ។ ការទំនាក់ទំនងនេះធានាថា បុគ្គលិកមជ្ឈមណ្ឌលសំចតប៉ោយប៉ែត អាចអនុវត្តការតាមដានស្វែងរកគ្រួសារសម្រាប់ជនរងគ្រោះនៅមុនពួកគេមកដល់។ បន្ទាប់មក បុគ្គលិកមជ្ឈមណ្ឌលសំចតប៉ោយប៉ែត នឹងធ្វើបច្ចុប្បន្នភាពដល់ភាគីខាងថៃអំពីថាបានកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះរួចរាល់ហើយឬនៅ ឬថាតើត្រូវការពេលវេលាបន្ថែមនៅមុនពេលពួកគេមកដល់ដែរឬទេ ដែលអាចនឹងចាំបាច់ត្រូវការពន្យារពេល។ ភាគីនានារាយការណ៍អំពីបណ្តាញប្រាស្រ័យទាក់ទងដ៏ល្អ។

ពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ ស្ថានទូត និងអង្គការមិនមែនរដ្ឋាភិបាល គឺត្រូវបានគេរាយការណ៍ថាមានបទពិសោធន៍

និងផ្តល់ជំនួយនៅក្នុងការរៀបចំសម្រាប់ឱ្យជនរងគ្រោះនៃពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ត្រលប់ទៅប្រទេសកម្ពុជាវិញ។ អង្គការមិនមែនរដ្ឋាភិបាល ដើរតួនាទីឈានមុខគេនៅក្នុងដំណើរការឆ្លងដែននេះ។ បណ្តាញនៃការសហការរវាងអង្គការមិនមែនរដ្ឋាភិបាល- បណ្តាញនីមួយៗមានទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិ - គឺមានភាពរឹងមាំ ដែលធានាបានថាជនរងគ្រោះត្រលប់មកកម្ពុជាវិញដោយមានការគាំទ្រ។

"ខ្ញុំបានសង្កេតឃើញថា ក្នុងអំឡុងពេលមាតុភូមិនិវត្តន៍ ជនរងគ្រោះគឺអាចទទួលបានការថែទាំបានល្អប្រសើរ។ មុនពេលមាតុភូមិនិវត្តន៍ ពួកគេ (ភាគីថៃ) ផ្តល់ព័ត៌មានដល់ក្រសួងពាក់ព័ន្ធដូចជាក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងក្រសួងផ្សេងៗ។ បន្ទាប់មក យើងស្វែងរកកន្លែងសុវត្ថិភាពសម្រាប់ពលករ និងផ្តល់សេវាសង្គមកិច្ចមូលដ្ឋាន។ ជាទូទៅ មានការផ្តល់ព័ត៌មានច្បាស់លាស់មកឱ្យយើងពីសំណាក់ប្រទេសគោលដៅ និងប្រទេសកំណើត។"

មន្ត្រីរដ្ឋាភិបាល

មានការរាយការណ៍ថា កិច្ចខិតខំប្រឹងប្រែងមាតុភូមិនិវត្តន៍ គឺមានភាពល្អប្រសើរនៅតាមបណ្តាប្រទេសក្រៅពីប្រទេសថៃ។



# ៨ ទំនុកចិត្តរបស់ភាគីពាក់ព័ន្ធលើប្រព័ន្ធយុត្តិធម៌

# ៨ ទំនុកចិត្តរបស់ភាគីពាក់ព័ន្ធនៅលើប្រព័ន្ធយុត្តិធម៌

ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងដំណើរសម្ភាសន៍ ត្រូវបានស្នើឱ្យបំពេញកម្រងសំណួរស្តីពីទំនុកចិត្តរបស់ភាគីពាក់ព័ន្ធផងដែរ។ ភាគីពាក់ព័ន្ធសរុបចំនួន ៣២ នាក់ ដែលបានឆ្លើយតប គឺជាអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបម្រើការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល នគរបាល រដ្ឋាភិបាល និងតុលាការ។ ផ្នែកនេះ សង្ខេបអំពីការឆ្លើយតបចំពោះកម្រងសំណួរនេះ។

*រូបភាព ៩៖ ការស្ទង់មតិរបស់អ្នកឆ្លើយតបតាមវិស័យ*

| អង្គការមិនមែនរដ្ឋាភិបាល | នគរបាល | រដ្ឋាភិបាល | តុលាការ | សរុប |
|---|---|---|---|---|
| ៨ | ៥ | ១៣ | ៦ | ៣២ |

កម្រងសំណួររួមបញ្ចូលសេចក្តីថ្លែងការណ៍ចំនួន ៧ ដែលអ្នកចូលរួមត្រូវឆ្លើយតប ដោយប្រើប្រាស់កម្រិត Likert ស្តីពីការយល់ព្រម ដែលតម្រូវឱ្យជ្រើសរើសជម្រើសមួយក្នុងចំណោមជម្រើសផ្តល់ជូនសម្រាប់សំណួរនីមួយៗ៖ (១) មិនយល់ស្របទាំងស្រុង (២) មិនយល់ស្រប (៣) ធម្មតា (៤) យល់ស្រប ឬ (៥) យល់ស្របទាំងស្រុង។

សេចក្តីថ្លែងការណ៍ទាំងនេះ ធ្វើការវាយតម្លៃទៅលើភាគីពាក់ព័ន្ធ ថាតើពួកគេមានទំនុកចិត្ត៖

១. ប្រព័ន្ធយុត្តិធម៌សម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងការក្សាបាននូវយុត្តិធម៌ សម្រាប់ប្រជាជនដែលងាយរងគ្រោះ ពីពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស។
២. ប្រព័ន្ធយុត្តិធម៌ជារួម គឺមានប្រសិទ្ធភាពក្នុងការរារាំងពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស និងកាត់បន្ថយការរីកសាយភាយនៃពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស ដោយអាស្រ័យលើការអនុវត្តប្រព័ន្ធយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព។
៣. ស្ថាប័នរបស់ពួកគេ គឺឯករាជ្យក្នុងការធ្វើការងារពាក់ព័ន្ធនឹងយុត្តិធម៌ ទាក់ទងនឹងបញ្ហាពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស។
៤. ស្ថាប័នរបស់ពួកគេផ្តល់សេវាទាន់ពេលវេលា ក្នុងការបន្តនីតិវិធីយុត្តិធម៌ទៅលើបញ្ហាពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស។
៥. ស្ថាប័នរបស់ពួកគេ គឺបង្កភាពងាយស្រួលដល់សាធារណជនក្នុងការទទួលបាននូវសេវា និងអ្នកដែលមានបំណងឱ្យស្ថាប័នជួយ ទាក់ទងនឹងបញ្ហាពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស អាចទទួលបានសេវាបានយ៉ាងងាយស្រួល។
៦. ស្ថាប័នរបស់ពួកគេទទួលបានការគាំទ្រលើផ្នែកនយោបាយយ៉ាងល្អប្រសើរពីសំណាក់រដ្ឋាភិបាល និងអ្នកនយោបាយនៅក្នុងការបំពេញការងារ។

## ៧. ស្ថាប័នរបស់ពួកគេប្រព្រឹត្តចំពោះមនុស្សគ្រប់រូបដោយស្មើភាពគ្នា និងពុំមានការរើសអើសក្នុងទម្រង់ណាមួយឡើយ ពេលដែលជនរងគ្រោះទាក់ទងមកកាន់ស្ថាប័នទាំងនេះអំពីបញ្ហាពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស ។

សំណួរពីរដំបូងគេ មានគោលបំណងវាយតម្លៃលើទំនុកចិត្តរបស់ភាគីពាក់ព័ន្ធទៅលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជារួម ក្នុងន័យរក្សាបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះ និងរារាំងដល់ការប្រព្រឹត្តបទល្មើស។ ការវិភាគទិន្នន័យ ដែលបានបង្ហាញក្នុងតារាងខាងក្រោម គូសបញ្ជាក់ពីទស្សនៈយល់ឃើញខុសៗគ្នាគួរឱ្យកត់សម្គាល់ អំពីទំនុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីរក្សាបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះ និងរារាំងដល់ការប្រព្រឹត្តល្មើស។[៣៤] គួរកត់សម្គាល់ផងដែរថា មានសំណាកគំរូតូចមួយប៉ុណ្ណោះសម្រាប់អ្នកឆ្លើយតបម្នាក់ៗ ជាពិសេស នគរបាល និងមន្ត្រីតុលាការ។ ប្រការនេះបានដាក់កំហិតទៅលើរបកគំហើញ ដូច្នេះត្រូវតែអនុវត្តតែអនុវត្តរបកគំហើញនេះ ប្រៀបដូចជាការណែនាំទូទៅប៉ុណ្ណោះ។

ពាក់ព័ន្ធនឹងទំនុកចិត្តរបស់ភាគីពាក់ព័ន្ធទៅលើប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការរក្សាបាននូវយុត្តិធម៌សម្រាប់ប្រជាជនងាយរងគ្រោះ ដោយ ពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស នគរបាលមានសុទិដ្ឋិនិយម ដែលទទួលបានពិន្ទុវាយតម្លៃមធ្យមស្មើនឹង ៤.៦ បន្ទាប់មកមន្ត្រីតុលាការ ទទួលបានពិន្ទុវាយតម្លៃស្មើនឹង ៤.១៧ ដែលបង្ហាញអំពីការទុកចិត្តជាមធ្យម នៅចន្លោះកម្រិត "យល់ស្រប" (៤) និង "យល់ស្របទាំងស្រុង" (៥)។ មន្ត្រីរដ្ឋាភិបាល ទទួលបានពិន្ទុវាយតម្លៃអំពីទំនុកចិត្តជាមធ្យមស្មើនឹង ៣.៨៥ និងអ្នកឆ្លើយតបនៃអង្គការមិនមែនរដ្ឋាភិបាល ទទួលបានពិន្ទុវាយតម្លៃអំពីទំនុកចិត្តជាមធ្យមស្មើនឹង ៣.៣៨ ដែលបង្ហាញអំពីទំនុកចិត្តជាមធ្យមនៅចន្លោះកម្រិត "យល់ស្រប" (៤) និង "ធម្មតា" (៣)។

ពាក់ព័ន្ធនឹងទំនុកចិត្តរបស់ភាគីពាក់ព័ន្ធទៅលើប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងការរារាំងពលកម្មដោយបង្ខំ និងការជួញដូរមនុស្សបានបង្ហាញថា មន្ត្រីរដ្ឋាភិបាល និងមន្ត្រីតុលាការ មានសុទិដ្ឋិនិយមគួរឱ្យកត់សម្គាល់ ដែលមានពិន្ទុ ៤.១៥ និង ៤.០០ រៀងគ្នា។ ទន្ទឹមនឹងនេះ នគរបាល និង អង្គការមិនមែនរដ្ឋាភិបាល គឺមានសុទិដ្ឋិនិយមធម្មតាប៉ុណ្ណោះនៅក្នុងការឆ្លើយតបរបស់ពួកគេ (ត្រឹម ៣.០០)។ ប្រការនេះអាចបណ្តាលមកពីអ្នកដែលធ្វើការងារនៅជួរមុខ និងនៅទីតាំងផ្ទាល់ បានមើលឃើញពីកត្តាជំរុញស្មុគស្មាញជាច្រើននៃពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស ដែលមិនពាក់ព័ន្ធនឹងការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌។

*រូបភាព ១០៖ ការឆ្លើយតបរបស់ភាគីពាក់ព័ន្ធទៅលើប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ - ពិន្ទុទំនុកចិត្តមធ្យម*

### ប្រព័ន្ធយុត្តិធម៌ ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស គឺ៖



សំណួរនៅសល់ទាំង ៥ គឺវាយតម្លៃពីទំនុកចិត្តរបស់អ្នកឆ្លើយតបទៅលើសកម្មភាព និងការអនុវត្តការងារនៅក្នុងស្ថាប័នរបស់ពួកគេផ្ទាល់។ ចំណុចមួយចំនួនតូច ដែលគួរតែកត់សម្គាល់ មានដូចខាងក្រោម៖

- មន្ត្រីរដ្ឋាភិបាល មានអារម្មណ៍ថា ស្ថាប័នរបស់ពួកគេគឺពុំសូវបានបំពេញការងារទាន់ពេលវេលា បើធៀបនឹងតួអង្គផ្សេងៗទៀត។
- អង្គការមិនមែនរដ្ឋាភិបាល មានអារម្មណ៍ថា ពួកគេពុំសូវទទួលបានការគាំទ្រផ្នែកនយោបាយច្រើនដូចតួអង្គផ្សេងទៀត នៅក្នុងការបំពេញការងារឆ្លើយតបទៅនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។
- មន្ត្រីរដ្ឋាភិបាល មានអារម្មណ៍ថា ពួកគេមានភាពឯករាជ្យ អាចពឹងពាក់បាន និងប្រព្រឹត្តចំពោះមនុស្សគ្រប់រូបប្រកបដោយយុត្តិធម៌។
- មន្ត្រីនគរបាល និងមន្ត្រីរដ្ឋាភិបាលបានយល់ស្របក្នុងកម្រិតបង្គួរថា ពួកគេអាចឱ្យសាធារណៈជនពឹងពាក់បាន។

គួរកត់សម្គាល់ផងដែរថា ការឆ្លើយតបរបស់មន្ត្រីរដ្ឋាភិបាល គឺស្របគ្នាជាមួយនឹងមន្ត្រីដែលបម្រើការងារនៅនគរបាល និងតុលាការ។ ទោះបីជាការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាលមានសារៈសំខាន់ជាងគេក្តី ក៏ការឆ្លើយតបនេះមានភាពលម្អៀងគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងសំណួរមួយចំនួន។ ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល បានបង្ហាញអំពីទំនុកចិត្តកម្រិតទាបជាងគេលើប្រព័ន្ធយុត្តិធម៌ទាំងមូល។

*រូបភាព ១១៖ ការឆ្លើយតបរបស់ភាគីពាក់ព័ន្ធអំពីតួនាទីរបស់ស្ថាប័នពួកគេ - ពិន្ទុទំនុកចិត្តមធ្យម*

## ស្ថាប័នរបស់ខ្ញុំ ព្យាយាមប្រឆាំងនឹងពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស៖





# ៩ សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

# ៩ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជារួម របកគំហើញនៃការសិក្សានេះ បានបង្ហាញអំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយចំនួន ពាក់ព័ន្ធនឹងការឆ្លើយតបរបស់ប្រទេសកម្ពុជាទៅនឹងពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស នៅក្នុងរយៈពេល ៦ (ប្រាំមួយ) ឆ្នាំកន្លងមក។ ស្របពេលជាមួយគ្នានេះ ក៏នៅមានផ្នែកផ្សេងៗជាច្រើនទៀតដែរដែលត្រូវដោះស្រាយ។ ផ្នែកនេះ បង្ហាញពីការណែនាំសង្ខេបអំពីអនុសាសន៍ និងបន្ទាប់មកទៀតរៀបរាប់អំពីអនុសាសន៍នានាដែលសំយោគបានពីរបកគំហើញនៃរបាយការណ៍នេះ។

## ៩.១ សេចក្តីសន្និដ្ឋាន

ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សឆ្លងដែននៃពលករខ្មែរទៅកាន់ប្រទេសថៃ ប្រធានបទសំខាន់មួយនៅទូទាំងការស្រាវជ្រាវនេះ ដែលស្របគ្នាជាមួយនឹងរបកគំហើញនៃការសិក្សានៅប្រទេសថៃ គឺថា បញ្ហានេះកើតឡើងជាចម្បងពីភាពងាយរងគ្រោះដែលមានលក្ខណៈជាប្រព័ន្ធ ដែលធ្វើឱ្យពលករចំណាកស្រុកពុំមានលទ្ធភាពពេញលេញក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ស្របតាមច្បាប់ប្រទេសថៃបាននោះទេ។ ប្រការនេះ គឺបណ្តាលមកពីចំណាកស្រុកឆ្លងដែន គឺពុំស្ថិតក្នុងគំរូជនល្មើស-ជនរងគ្រោះនោះទេ ពោលគឺការបង្ខិតបង្ខំ គឺបានប្រព្រឹត្តលក្ខណៈជាប្រព័ន្ធ និងតាមមធ្យោបាយជាច្រើន ដែលមានការសម្របសម្រួលពីក្របខណ្ឌច្បាប់ និងគោលនយោបាយផ្ទាល់តែម្តង។

ទោះបីជាប្រព័ន្ធយុត្តិធម៌ មានគោលបំណងដើរតួនាទីសំខាន់ក្នុងការរារាំងជនល្មើសក៏ដោយ ក៏តួនាទីនេះដែរត្រូវបានចុះអន់ថយក្នុងប្រព័ន្ធអនុស្សារណៈនៃការយោគយល់ ដែលមិនសមស្របតាមគោលបំណង និងបរិយាកាសផ្លូវច្បាប់របស់ថៃ ដែលមិនគិតគូរអំពី ពលករចំណាកស្រុក ជាអ្នកដែលមានសិទ្ធទទួលបានការគាំទ្រ ឬស្វ័យភាព។ ដូច្នេះ ដើម្បីរក្សាបាននូវដំណោះស្រាយពលកម្មដោយបង្ខំក្នុងចំណោមពលករចំណាកស្រុកនៅប្រទេសថៃប្រកបដោយអត្ថន័យ នោះឥទ្ធិពលនៃការផ្លាស់ប្តូរដែលកើនឡើងតាមដំណាក់កាល គឺត្រូវតែរក្សានៅកម្រិតកំណត់ណាមួយ ។ កំណែទម្រង់ជាប្រព័ន្ធ គឺត្រូវការចាំបាច់ក្នុងការលុបបំបាត់នូវបរិយាកាសអំណោយផល ដែលបច្ចុប្បន្ននេះបានអនុញ្ញាតឱ្យមានការកេងប្រវ័ញ្ច។

ចំពោះករណីផ្សេងទៀត ដូចជា ពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សទៅកាន់បណ្តាប្រទេសផ្សេងទៀត តួនាទីរបស់ប្រព័ន្ធយុត្តិធម៌គឺនៅតែសំខាន់ក្នុងការរារាំងជនល្មើស។ ស្រដៀងគ្នានេះដែរ សម្រាប់ករណីកម្រិតខ្ពស់ជាច្រើនពាក់ព័ន្ធនឹងជនបរទេសដែលត្រូវបានជួញដូរមកប្រទេសកម្ពុជាកាលពីពេលថ្មីៗនេះ ដែលការជួញដូរនេះមានលក្ខណៈជាការជួញដូរឧស្សាហកម្មប្រព្រឹត្តដោយក្រុមជនល្មើស។ ចំពោះករណីទាំងនេះ ភាគីពាក់ព័ន្ធបានកំណត់ផ្នែកមួយចំនួន រួមមាន ការអនុវត្តអធិការកិច្ច ការស៊ើបអង្កេត និងការផ្តន្ទាទោស ដែលប្រព័ន្ធយុត្តិធម៌អាចកែលម្អបាន ដែលការកែលម្អនេះរួមចំណែកដល់ការរារាំងករណីនេះមិនឱ្យកើតឡើង។

ចំពោះរាល់ករណីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សទាំងអស់ ប្រព័ន្ធយុត្តិធម៌ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ជនរងគ្រោះ។ អាជ្ញាធរនៅកម្ពុជា បង្ហាញឆន្ទៈយ៉ាងច្បាស់ក្នុងការអនុវត្តភារកិច្ចរបស់ពួកគាត់ក្នុងកិច្ចការនេះ បើ

ទោះបីជាពួកគាត់ទទួលបានធនធានមានកម្រិតក្តី។ ដូច្នេះ អាជ្ញាធរ គឺត្រូវពឹងផ្អែកខ្លាំងទៅលើជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែតួនាទីរបស់អាជ្ញាធរគឺមានសារៈសំខាន់ណាស់ ហើយជនរងគ្រោះអាចទទួលបានអត្ថប្រយោជន៍ពីការផ្តល់ធនធានច្រើនជាងមុន និងការពង្រីកសេវាដែលផ្តល់ជូនដោយសេវាសង្គមកិច្ច និង អង្គការមិនមែនរដ្ឋាភិបាលប៉ុណ្ណោះ។

## ៩.២ អនុសាសន៍

តាមរយៈរបកគំហើញនៃការសិក្សានេះ ដូចបានបង្ហាញជាសង្ខេបក្នុងសេចក្តីសង្ខេបប្រតិបត្តិខាងលើ ក្រុមសិក្សាស្រាវជ្រាវ និងទំនាក់ទំនង (RGC) សូមបង្ហាញអនុសាសន៍ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌កម្ពុជា ជាការឆ្លើយតបទៅនឹងករណីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សដូចខាងក្រោម។ អនុសាសន៍ទាំងនេះ គឺពុំត្រូវបានចាត់តាមលំដាប់លំដោយអាទិភាពនោះទេ ប៉ុន្តែត្រូវបានចាត់ថ្នាក់តាមប្រធានបទ ដែលគ្របដណ្តប់លើប្រធានបទចំនួន ៤ (បួន)៖

| | |
|---|---|
| ១ | **ការជំរុញលទ្ធភាពរបស់ពលករចំណាកស្រុក តាមរយៈការដោះស្រាយចំណុចខ្វះខាតទៅលើរចនាប្រព័ន្ធចំណាកស្រុក ដែលរារាំងពលករពីការការពារខ្លួនឯង។** ប្រការនេះរួមបញ្ចូលការកាត់បន្ថយការពឹងផ្អែកលើផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់របស់ពលករលើនិយោជក អ្នកជ្រើសរើសពលករ អាជ្ញាធររដ្ឋាភិបាល និងការិយាធិបតេយ្យ និងលុបបំបាត់ឧបសគ្គនានាដែលរារាំងពលករចំណាកស្រុក ពីការចាកចេញពីស្ថានភាពការងារដែលមានការរំលោភបំពាន និងគ្រោះថ្នាក់។ ជារួម អន្តរាគមន៍ទាំងនេះ នឹងកាត់បន្ថយឱកាសនៃការកេងប្រវ័ញ្ចលើពលករ នៅពេលធ្វើចំណាកស្រុកយក និងធ្វើឱ្យពួកគាត់ពុំសូវងាយរងគ្រោះទៅនឹងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។ |
| ២ | **ពង្រឹងកិច្ចខិតខំប្រឹងប្រែងលើការកំណត់អត្តសញ្ញាណ តាមរយៈការជំរុញទឹកចិត្តឱ្យតួអង្គប្រព័ន្ធយុត្តិធម៌ត្រួតពិនិត្យពលករដែលប្រឈមនឹងហានិភ័យខ្ពស់ជាងគេ កំណត់អត្តសញ្ញាណករណី និងតាមដានត្រួតពិនិត្យទីតាំងហានិភ័យបន្ថែម។** ការសិក្សានេះ បានរកឃើញថា ជារួម មានករណីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សតិចតួចណាស់ដែលត្រូវបានកំណត់រកឃើញ ទាំងមុនពេលដែលករណីទាំងនេះបានចូលទៅក្នុងដំណើរការប្រព័ន្ធយុត្តិធម៌ទៅទៀត។ កត្តានេះ គឺដោយសារតែនៅក្នុងកន្លែងជាច្រើន ពុំមានការធ្វើអធិការកិច្ច ការតាមដានត្រួតពិនិត្យ ឬការត្រួតពិនិត្យរកពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សសោះឡើយ ហើយថែមទាំងពុំតម្រូវឱ្យអនុវត្តទៀតផង។ ដើម្បីកំណត់រកករណីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សបន្ថែមទៀត ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យរកពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សបន្ថែមទៀតនៅក្នុងចំណោមក្រុមប្រជាជន និងកន្លែងធ្វើការ ដោយប្រើប្រាស់វិធានការតាមដានត្រួតពិនិត្យ រាយការណ៍ និងអធិការកិច្ច ដែលរួមបញ្ចូលការត្រួតពិនិត្យទៅលើពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សដែលមានប្រសិទ្ធភាព។ បើទោះបីជានៅមានបញ្ហាចំពោះផ្នែកសមត្ថភាពក្តី ក៏ក្រុមការងារចាត់ទុកថា បើមានការលើកទឹកចិត្តបានត្រឹមត្រូវ នោះបញ្ហាជាច្រើនគឺអាចដោះស្រាយបាន។ ផ្ទុយមកវិញ បើគ្មានការលើកទឹកចិត្តត្រឹមត្រូវដើម្បីឱ្យអនុវត្តសកម្មភាពទេ ការកសាងសមត្ថភាពបន្ថែម គឺទំនងជាពុំមានឥទ្ធិពលពិតប្រាកដឡើយ។ |
| ៣ | **លើកទឹកចិត្តឱ្យមានការចូលរួមពីជនរងគ្រោះ ដើម្បីឱ្យពួកគេចូលប្រើប្រាស់ និងស្ថិតនៅក្នុងប្រព័ន្ធយុត្តិធម៌ តាមរយៈការលុបបំបាត់ឧបសគ្គនានា ដោយផ្តល់ការគាំទ្រ និងលទ្ធភាពក្នុងការទទួលបាននូវដំ ណោះស្រាយ។** ការសិក្សានេះ បានកំណត់រកឧបសគ្គរារាំងជាច្រើន ដែលបង្អាក់ទឹកចិត្តជនរងគ្រោះពីការចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ដែលនៅតែបន្តកើតមាននៅគ្រប់ដំណើរការតុលាការ។ ការចូលរួមរបស់ពួកគេ គឺមានឧបសគ្គរារាំងច្រើនណាស់ និងមានអត្ថប្រយោជន៍តិចតួចពេក នេះបើយោងតាមទស្សនៈយល់ឃើញរបស់ជនរងគ្រោះ។ ផ្ទុយមកវិញ ជនរង |

| | |
|---|---|
| | គ្រោះជាទូទៅស្វែងរកមធ្យោបាយដោះស្រាយក្រៅផ្លូវការ ដូចជា ការសម្រុះសម្រួល ការបោះបង់ចោលការទាមទារ និងការទូទាត់ក្រៅផ្លូវការ។ |
| ៤ | **បង្កើតបណ្ដាញសម្រាប់តួអង្គប្រព័ន្ធយុត្តិធម៌ដើម្បីសម្របសម្រួលជាមួយគ្នា ក្នុងការអនុវត្តភារកិច្ចរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។** ការសិក្សានេះបានរកឃើញថា កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមតួអង្គនានា បច្ចុប្បន្នគឺនៅមានកម្រិត ពោលគឺនៅកម្រិតឆ្លងដែន។ ដើម្បីដោះស្រាយបញ្ហានេះ បណ្ដាញនានាសម្រាប់ការសហការ ចាំបាច់ត្រូវតែបង្កើតឡើងក្នុងស្ថាប័នតាមរយៈស្ថាប័នការងារទៀងទាត់ គោលការណ៍ណែនាំសម្រាប់ការអនុវត្ត និងតាមរយៈការពង្រឹងបណ្ដាញនៃការជួយគ្នាទៅវិញទៅមក។ តាមការប្រៀបធៀប ការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារនៅក្នុងប្រទេសកម្ពុជា បានផ្ដល់វេទិកាមួយសម្រាប់កិច្ចសហប្រតិបត្តិការអន្តរក្រសួង និងកិច្ចពិភាក្សាទៀងទាត់ស្ដីពីពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស។ វិធានការនេះ មានប្រសិទ្ធភាព ដោយសារតែកិច្ចសហប្រតិបត្តិការ គឺត្រូវបានរួមបញ្ចូលទៅក្នុងស្ថាប័ន និងត្រូវបានពង្រឹងពីខណៈមួយទៅខណៈមួយ ហើយវិធានការនេះដែរលុបបំបាត់នូវការប៉ះពាល់នានា នៅពេលអ្នកចូលរួមចង់ធ្វើការទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ ដូចគ្នានេះដែរ បណ្ដាញសម្រាប់ការសហការចាំបាច់គឺត្រូវតែបង្កើតឡើងនៅកម្រិតប្រតិបត្តិការ ទាំងក្នុងកម្ពុជា និងឆ្លងដែនទៅថៃផងដែរ។ |

## ៩.២.១ ការបង្ការនិង ការកាត់បន្ថយឱកាសអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស

១. **ការដោះស្រាយចំណុចខ្វះខាតនៃការរៀបចំបណ្ដាញចំណាកស្រុកដែលបានចុះអនុស្សារណៈនៃការយោគយល់៖** ប្រព័ន្ធអនុស្សារណៈនៃការយោគយល់ គឺពុំមានភាពទាក់ទាញចំពោះពលករចំណាកស្រុកជាច្រើននោះទេ ដោយសារប្រព័ន្ធនេះមានតម្លៃថ្លៃ ពិបាកចូលប្រើប្រាស់ និងពុំធានាបាននូវសុវត្ថិភាពនៃការធ្វើចំណាកស្រុកនោះទេ។ ដើម្បីឱ្យបណ្ដាញដែលបានចុះអនុស្សារណៈនៃការយោគយល់នេះមានប្រសិទ្ធភាព ចាំបាច់គឺត្រូវតែបំពេញទៅតាមតម្រូវការចំណាកស្រុករបស់ពលករនៅគ្រប់មជ្ឈដ្ឋានទាំងអស់។ ដើម្បីឱ្យអនុស្សារណៈនៃការយោគយល់មានការផ្លាស់ប្ដូរទៅបាន គឺចាំបាច់ត្រូវមានឆន្ទៈខ្ពស់ពីសំណាក់រដ្ឋាភិបាលថៃ និងកម្ពុជា ដោយសង្កត់ធ្ងន់ជាពិសេសទៅលើការត្រៀមរៀបចំរបស់រដ្ឋាភិបាលថៃ ក្នុងការផ្ដល់ជូនដល់ពលករខ្មែរនូវសិទ្ធិពេញលេញនៅក្នុងប្រទេសថៃ។ យន្តការបណ្ដឹងតវ៉ា គឺចាំបាច់ត្រូវតែកែលម្អ និងពលករត្រូវការស្វ័យភាពបន្ថែមទៀតដើម្បីធ្វើការសម្រេចចិត្ត មានជាអាទិ៍ ការធ្វើឱ្យមានភាពងាយស្រួលជាងមុនក្នុងការផ្លាស់ប្ដូរនិយោជក។ រដ្ឋាភិបាលពាក់ព័ន្ធ គួរតែអនុញ្ញាតឱ្យពលករចំណាកស្រុក និងអ្នកតំណាងពលករចូលរួមនៅក្នុងដំណើរបង្កើតគោលនយោបាយ។

២. **ធ្វើនិយ័តកម្មលើការគិតថ្លៃសេវាពីពលករចំណាកស្រុក និងលុបបំបាត់ការទូទាត់ថ្លៃសេវាជាមុន៖** អនុស្សារណៈនៃការយោគយល់ ជារឿយៗធ្វើឱ្យពលករជាច្រើនជាប់របំណុលក្នុងចំនួនច្រើនដែលពួកគេត្រូវជំពាក់និយោជក និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូច្នេះពលករមានអារម្មណ៍ថាពួកគេមានជម្រើសតិចតួចបំផុត ដោយត្រូវទ្រាំទ្រនឹងល័ក្ខខណ្ឌការងារដែលមានការរំលោភបំពាន។ ទោះបីជាមានការជំរុញនៅក្នុងតំបន់ខ្លះដោយពុំគិតកម្រៃពីពលករក៏ដោយ ក៏ទង្វើបែបនេះទំនងជាពុំអាចពង្រីកឱ្យបានទូលំទូលាយ នោះដែរ ដោយសារ៖ (១) មានការងារជាច្រើនដែលត្រូវប្រមូលថ្លៃសេវាពីពលករ ក្នុងនោះរួមទាំងការពាក់ព័ន្ធនឹងការហាមឃាត់របស់ថៃលើថ្លៃសេវាជ្រើសរើសពលករ និង (២) លំហាបទល្មើសដែលត្រូវបានបង្កើតឡើងដោយសារតែបញ្ហាការផ្គត់ផ្គង់ និងតម្រូវការមូលដ្ឋានចំពោះពលករដែលស្ម័គ្រចិត្តឱ្យថ្លៃសេវា ជាជាងជ្រើសរើសពលករដែលមានជំនាញទាប និង (៣) កង្វះគំរូអាជីវកម្មដែលអាចផ្ដល់ប្រាក់ចំណេញសម្រាប់អ្នកជ្រើសរើសពលករ ដោយពុំគិតថ្លៃសេវាពីពលករ។

ជំហានបណ្ដោះអាសន្ននោះគឺដូចមាន ប្រទេសមីយ៉ាន់ម៉ា ជាឧទាហរណ៍ ដែលប្រទេសនេះកំពុងតែធ្វើនិយ័តកម្ម លើថ្លៃសេវាដែលមិនត្រឹមតែកាត់បន្ថយថ្លៃសេវាសម្រាប់ពលករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យមានតម្លាភាព ចំពោះថ្លៃចំណាយពេញលេញពីសំណាក់អ្នកជ្រើសរើសពលករ រួមទាំង ប្រាក់សគុណផងដែរ។ វិធានការ បំពេញបន្ថែម នឹងលុបបំបាត់ថ្លៃចំណាយលើការទូទាត់មុនទាំងអស់ និងការថ្លៃសេវាដែលគិតគូរពីពលករខ្មែរ ដើម្បីឱ្យពួកគេអាចទទួលបាននូវឯកសារចំណាកស្រុក និងធ្វើឱ្យមានការទូទាត់ប្រាក់ឈ្នួលរបស់ពលករតាម រយៈដំណើរការដែលមានការចងក្រងច្បាស់លាស់។

៣. **តស៊ូមតិសម្រាប់បទដ្ឋានអប្បបរមានៅប្រទេសគោលដៅ៖** ដោយសហការជាមួយបណ្ដាប្រទេសបញ្ជូនពលករ ផ្សេងទៀតក្នុងករណីដែលអាចអនុវត្តទៅបាន កម្ពុជាគួរតែគូសបញ្ជាក់អំពីបទដ្ឋានអប្បបរមា ដែលតម្រូវឱ្យ ប្រទេសភាគីធានាឱ្យបាន ចំពោះគ្រប់ពលករខ្មែរទាំងអស់ដែលធ្វើការងារនៅក្រៅប្រទេស។ បទដ្ឋានទាំងនេះគួរ តែគ្របដណ្ដប់លើសិទ្ធិរបស់ពលករ ដូចជា សិទ្ធិសម្រាប់ពលករក្នុងការជួបប្រជុំ និងបង្កើតសហជីព យន្តការ បណ្ដឹងតវ៉ា និងដំណោះស្រាយដោយឯករាជ្យ ដែលអាចផ្ដល់លទ្ធភាពងាយស្រួលឱ្យពួកគេចូលប្រើប្រាស់ តាម ដានត្រួតពិនិត្យ និងអធិការកិច្ចកន្លែងធ្វើការលក្ខណៈបុរេសកម្ម និងលទ្ធភាពក្នុងការផ្លាស់ប្ដូរការងារបានដោយ សេរី។

៤. **បង្កើនល័ក្ខខណ្ឌតម្រូវចំពោះទីភ្នាក់ងារជ្រើសរើសពលករក្នុងការតាមដានពិនិត្យសុខុមាលភាពរបស់ពលករនិង ដោះស្រាយក្ដីបារម្ភការងារ រួមទាំងតាមរយៈការប្រើប្រាស់ប្រាក់តម្កល់ដើម្បីផ្ដល់សំណងដល់ពលករ៖** កាតព្វ កិច្ចផ្លូវច្បាប់ គឺដាក់បន្ទុកទៅលើតែអ្នកជ្រើសរើសពលករ ក្នុងការធានាឱ្យបាននូវសុវត្ថិភាពរបស់ពលករ និង ដើរតួនាទីសកម្មក្នុងការធានាសុវត្ថិភាពរបស់ពលករនៅក្រៅប្រទេសប៉ុណ្ណោះ។ កិច្ចសន្យាការងារសម្រាប់ពល ករចំណាកស្រុក គួរតែផ្ដល់ដល់ពលករផងដែរនូវបទដ្ឋានអប្បបរមា។ ថ្លៃសេវាជ្រើសរើសពលករ គួរតែកាត់ បន្ថយធ្វើឱ្យមានស្តង់ដារ និងធ្វើនិយ័តកម្ម។ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួរតែដាក់ឱ្យប្រើប្រាស់ នូវបណ្ដាញសម្រាប់ការរាយការណ៍អំពីអាកប្បកិរិយាពុំសមរម្យ ត្រួតពិនិត្យលើទំនុកចិត្តនៃអ្នកជ្រើសរើសពល ករមានស្រាប់ និងផ្ដល់សំណងដល់ពលករ។

ជារួម ចាំបាច់គឺត្រូវបង្កើនការតាមដានត្រួតពិនិត្យលើភ្នាក់ងារជ្រើសរើសពលករ និងដាក់ចេញនូវផលវិបាក ដែលសមស្របសម្រាប់ការអនុវត្តការងារពុំបានល្អ។

៥. **លើកកម្ពស់ការតាមដានត្រួតពិនិត្យវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖** ទោះបីជាវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កំពុងអនុវត្តវិធានការស្វ័យនិយ័តកម្មក្ដី ក៏សកម្មភាពនេះពុំទាន់គ្រប់គ្រាន់ក្នុងការធានាបាននូវអាកប្បកិរិយាល្អ នោះដែរ។ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវហាមឃាត់ និងតាមដានត្រួតពិនិត្យការអនុវត្តបែបបង្ខំរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងការធានាថា បំណុលដែលកើតឡើងតាមរយៈការបង្ខិតបង្ខំ គឺពុំចងភ្ជាប់ កាតព្វកិច្ចផ្លូវច្បាប់ឡើយ។ រាជរដ្ឋាភិបាលកម្ពុជា ក៏គួរតែពិចារណាលើការកាត់បន្ថយការប្រាក់របស់គ្រឹះស្ថានមី ក្រូហិរញ្ញវត្ថុ ដើម្បីបង្ការកុំឱ្យបំណុលកើនឡើង។ លើសពីនេះ ភាគីពាក់ព័ន្ធមួយចំនួនបានស្នើឡើងថា ធនាគារ ជាតិនៃកម្ពុជា និងអ្នកតំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គួរតែចូលរួមនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលស្ដីពីការប្រឆាំង ការជួញដូរមនុស្សផងដែរ។

## ៩.២.២ ការស៊ើបអង្កេតករណីជួញដូរមនុស្ស ឬពលកម្មដោយបង្ខំនៅប្រទេសកម្ពុជា

១. **ធានាបាននូវការធ្វើអធិការកិច្ច និងការស៊ើបអង្កេតឧស្សាហកម្មដែលប្រឈមហានិភ័យ៖** កាស៊ីណូ ឡូតដូ និង មូលដ្ឋានឆបោកតាមអ៊ីនធឺណិត ទាំងអស់គឺត្រូវបានគូសបញ្ជាក់ថាជាចំណុចក្ដៅសម្រាប់ការជួញដូរមនុស្ស។ ការស៊ើបអង្កេតកន្លងមក បានឈានទៅដល់រឿងក្ដីតុលាការ និងការផ្ដន្ទាទោសមួយចំនួន។ ជាការសំខាន់ ណាស់ក្នុងការរក្សាបាននូវទំនុកចិត្តពីសំណាក់សាធារណជនទៅលើដំណើរការតុលាការ ដោយធ្វើការស៊ើប

អង្កេតកន្លែងធ្វើការទាំងនេះ និងដាក់ចេញនូវការចោទប្រកាន់សមស្រប។ អាជ្ញាធរ គួរតែមាននីតិវិធីក្នុងការកំណត់អត្តសញ្ញាណជាទៀងទាត់កន្លែងដែលប្រឈមហានិភ័យ ដែលត្រូវបានកំណត់សម្រាប់សកម្មភាពផ្តោតលើអធិការកិច្ច។

២. **ដោះស្រាយកង្វះខាតធនធាន៖** ទី១ (១) ផ្តល់ថវិកាដល់ការស៊ើបអង្កេតពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សតាមរយៈការទូទាត់ជាមុន ជាជាងការបើកប្រាក់សងវិញនៅពេលក្រោយ ដោយហេតុថាការធ្វើបែបនេះបង្កើតនូវការដាក់កម្រិតទៅលើការអនុវត្តភារកិច្ចរបស់នគរបាល។ ទី២ (២) ថវិកាជូនដល់អង្គភាពនគរបាលទទួលបន្ទុកពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស គឺត្រូវបានគេរាយការណ៍ថាពុំគ្រប់គ្រាន់ និងត្រូវតម្លើងបន្ថែមទៀត។ ទី៣ (៣) ចាំបាច់ត្រូវជ្រើសរើសមន្ត្រីនគរបាលជាស្ត្រីបន្ថែមទៀត និងបណ្តុះបណ្តាលស្តីពីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស ដែលនឹងជាជំនួយដល់សម្ភាសន៍ និងវិធីសាស្ត្រយកចិត្តទុកដាក់លើជនរងគ្រោះ។

៣. **ផ្នែកកសាងសមត្ថភាព៖** កង្វះខាតសមត្ថភាពរបស់នគរបាលមូលដ្ឋាន ជារឿយៗត្រូវបានគេលើកឡើងថាជាឧបសគ្គរាំងចំពោះដំណើរការនីតិវិធីយុត្តិធម៌នៃពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស។ ប្រធានបទមួយចំនួនដែលបានស្នើឱ្យមានការយកចិត្តទុកដាក់ មានដូចខាងក្រោម៖ (១) ការសម្ភាសដែលយកចិត្តទុកដាក់លើជនរងគ្រោះ (២) ទម្រង់ថ្មីនៃពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស – រួមទាំង ពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សផ្អែកលើបំណុល (៣) ជំនាញសម្រាប់ការធ្វើការងារជាមួយជនរងគ្រោះ និងគ្រួសារក្នុងអំឡុងពេលនៃដំណើរការយុត្តិធម៌ (៤) ការប្រមូលភស្តុតាងប្រកបដោយប្រសិទ្ធភាព និង (៥) ការកំណត់អត្តសញ្ញាណ និងការទទួលស្គាល់ពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សទូទៅនៅក្នុងសហគមន៍។ លើសពីនេះ វគ្គបណ្តុះបណ្តាលនឹងទទួលបានអត្ថប្រយោជន៍ពីការរួមបញ្ចូលពីភាគីពាក់ព័ន្ធជាច្រើន ដើម្បីពង្រឹងបណ្តាញ ការចែករំលែកព័ត៌មាន និងការសហការ។ ក្នុងនោះដែរ ក៏មានការលើកឡើងថា មន្ត្រីនគរបាលចាំបាច់ត្រូវតែទទួលវគ្គបណ្តុះបណ្តាលរំឭករៀងរាល់បីខែម្តង ហើយពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សអាចនឹងត្រូវបានលើកឡើងក្នុងវគ្គបណ្តុះបណ្តាលរំឭកទៀងទាត់នោះ។

៤. **បង្កើតគោលការណ៍ណែនាំស្តីពីវិធីសាស្ត្រយកចិត្តទុកដាក់លើជនរងគ្រោះ សម្រាប់ការស៊ើបអង្កេត និងដំណើរការផ្សេងៗ៖** គោលការណ៍យកចិត្តទុកដាក់លើជនរងគ្រោះ គឺត្រូវបានគេរាយការណ៍ថាពុំបានអនុវត្តនៅទូទាំងប្រព័ន្ធយុត្តិធម៌នោះទេ រួមទាំងការស៊ើបអង្កេត ការសម្ភាសជនរងគ្រោះ ការបង្ហាញខ្លួននៅតុលាការ និងការគាំទ្រជនរងគ្រោះ។ គោលការណ៍ណែនាំជាក់ស្តែង និងការបណ្តុះបណ្តាលសម្រាប់ការថែទាំជនរងគ្រោះ អាចជួយដល់អាជ្ញាធរក្នុងការអនុវត្តតួនាទីរបស់ពួកគេ ដោយយោងទៅលើសេណារីយ៉ូជាក់លាក់ដែលពួកគេបានជួបប្រទះនៅក្នុងការងារប្រចាំថ្ងៃ។

៥. **អភិវឌ្ឍន៍សមត្ថភាពជំនាញប្រឆាំងនឹងពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សតាមអ៊ីនធឺណិត៖** ការសិក្សានេះបានរកឃើញថា អ្នកប្រព្រឹត្តពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស ប្រើប្រាស់បច្ចេកវិទ្យាថ្មីៗកាន់តែច្រើនឡើង និងមានការជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពផ្សេងៗទៀតនៅលើប្រព័ន្ធអ៊ីនធឺណិត។ នគរបាលស៊ើបអង្កេតបានបង្ហាញថា ចាំបាច់ត្រូវមានការគាំទ្របន្ថែម ដើម្បីអនុវត្តការស៊ើបអង្កេតតាមអ៊ីនធឺណិត ប្រមូលភស្តុតាងលើអ៊ីនធឺណិត និងកំណត់អត្តសញ្ញាណបណ្តាញលើអ៊ីនធឺណិត។ សមត្ថភាពមន្ត្រីជំនាញ គួរតែអភិវឌ្ឍន៍ជាមួយនឹងជំនាញទាំងនៅក្នុងបច្ចេកវិទ្យាឌីជីថល និងពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស។

## ៩.២.៣ ការផ្តន្ទាទោសករណីជួញដូរមនុស្សនៅកប្រទេសកម្ពុជា

១. **លុបបំបាត់ឧបសគ្គនៅក្នុងការចូលរួមក្នុងដំណើរការផ្លូវច្បាប់កម្ពុជា៖** ពលករខ្មែររងគ្រោះ នៅតែបន្តជួបការលំបាក និងពុំចាប់អារម្មណ៍ចំពោះការបន្តនីតិវិធីផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជាឡើយ។ ពួកគេបានចាត់ទុកថាដំណើរការនេះមានលក្ខណៈយឺតយ៉ាវ មានការងារច្រើន និងមានសង្ឃឹមថាទទួលបានសំណងតិចតួចបំផុត។

ជនរងគ្រោះ ត្រូវការការគាំទ្របន្ថែម ដើម្បីលើកទឹកចិត្តពួកគេឱ្យបន្តការទាមទារតាមរយៈប្រព័ន្ធយុត្តិធម៌។ ការគាំទ្រនេះ រួមមាន ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ជនរងគ្រោះ សម្រាប់រ៉ាប់រងលើថ្លៃចំណាយលើការចូលក្នុងសវនាការ ការគាំទ្រផ្លូវច្បាប់ និងបង្កើនលទ្ធភាពប្រើប្រាស់សេវា។

២. **បង្កើតការណែនាំស្ដីពីដំណើរការប្រព័ន្ធយុត្តិធម៌សម្រាប់ជនរងគ្រោះ៖** ជនរងគ្រោះដែលចូលរួមនៅក្នុងការស៊ើបអង្កេត និងដំណើរការជំនុំជម្រះ គឺត្រូវបានគេរាយការណ៍ថាពុំបានផ្ដល់ការពន្យល់ច្បាស់លាស់អំពីអ្វីដែលពួកគេរំពឹងទុកពីដំណើរការតុលាការនោះទេ រួមទាំងជំហានជាច្រើន និងរយៈពេលដែលត្រូវចំណាយលើដំណើរការនេះ។ ប្រការនេះ បានធ្វើឱ្យជនរងគ្រោះទទួលនូវអារម្មណ៍លើសលុប ខកចិត្ត និងពុំមានម្ចាស់ការលើរឿងក្ដីរបស់ខ្លួន (ឧ. មានអារម្មណ៍ថាជារឿងក្ដីរបស់មេធាវីទៅវិញ)។ ជនរងគ្រោះ អាចទទួលបានការគាំទ្រដោយការណែនាំដែលថែងអំពីព័ត៌មាន និងការរំពឹងទុកពាក់ព័ន្ធ ដែលមានលក្ខណៈងាយស្រួលយល់ និងមានការយកចិត្តទុកដាក់លើជនរងគ្រោះ។ ការណែនាំនេះ គួរតែប្រើប្រាស់រឿងក្ដីមានប្រយោជន៍ជាគំរូ។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាលអាចឱ្យតួអង្គពីមុនចូលរួមនៅក្នុងការគាំទ្ររឿងក្ដីថ្មីៗ និងចែករំលែកបទពិសោធន៍ជោគជ័យ។

៣. **ទប់ស្កាត់ជនល្មើសពីការលួចរត់គេចខ្លួន៖** តួអង្គតុលាការបានបង្ហាញថា ជនល្មើសជារឿយៗរត់គេចខ្លួន បន្ទាប់ពីពួកគេត្រូវបានឃាត់ខ្លួនជាលើកដំបូង និងដោះលែងទៅវិញ និងពុំអាចរកឃើញដើម្បីឱ្យចូលបង្ហាញខ្លួន ក្នុងសវនាការបាននោះទេ។ តុលាការ គួរពិចារណាលើការដោះលែងនៅក្រៅឃុំ ឬការព្រមព្រៀងតម្កល់ធានា និងការដោះលែងដោយមានល័ក្ខខណ្ឌ ដោយតម្រូវឱ្យមានការចូលខ្លួនពីសំណាក់ជនល្មើស ដែលបានចោទប្រកាន់។

## ៩.២.៤ ការកំណត់អត្តសញ្ញាណជនរងគ្រោះ

១. **ត្រួតពិនិត្យឡើងវិញលើការប្រើប្រាស់ទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះ និងបន្តពង្រឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ៖** ការប្រើប្រាស់យ៉ាងទូលំទូលាយនៃទម្រង់កំណត់អត្តសញ្ញាណស្តង់ដារ ដែលបានផ្ដល់ជូននៅក្នុងគោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ បាននិងកំពុងក្លាយជាជំហានដ៏វិជ្ជមាន ប៉ុន្តែភាគីពាក់ព័ន្ធរាយការណ៍ថា ពុំមែនគ្រប់ស្ថាប័នទាំងអស់សុទ្ធតែប្រើប្រាស់គោលការណ៍ណែនាំទាំងនេះនោះទេ។ រដ្ឋាភិបាលគួរតែ៖ (១) ត្រួតពិនិត្យឡើងវិញលើភាពលម្អៀងបច្ចុប្បន្ន ដើម្បីកំណត់រកបញ្ហាលេចធ្លោរណាមួយ និងកែសម្រួលទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះឱ្យអាចប្រើប្រាស់បានសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ និង (២) ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តឱ្យបានពេញលេញនូវពិធីសារនៅទូទាំងប្រទេសសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះសកម្មក្នុងចំណោមក្រុមប្រជាជនងាយរងគ្រោះ និងបណ្ដុះបណ្ដាលមន្ត្រីនៅគ្រប់តំបន់ទាំងអស់ក្នុងប្រទេសអំពីបញ្ញត្តិនៃគោលការណ៍ណែនាំនេះ។

២. **បង្កើនការប្រើប្រាស់សូចនាករស្ដីពីពលកម្មដោយបង្ខំ ដើម្បីកំណត់រកកាតព្វកិច្ចបំណុល និងស្ថានភាពពលកម្មដោយបង្ខំ ទាំងនៅកម្ពុជា និងថៃ៖** ពលករចំណាកស្រុកកម្ពុជា ជាទូទៅយកប្រាក់កម្ចីពីនិយោជក ដើម្បីទូទាត់ថ្លៃចំណាយលើការធ្វើចំណាកស្រុក ដែលការយកកម្ចីនេះបង្កើតបានជាទំនាក់ទំនងពឹងពាក់។ ប្រការនេះ អាចធ្វើឱ្យទំនាក់ទំនងការងាររបស់ពួកគេមានលក្ខណៈបង្ខំ និងធ្វើឱ្យពលករមានអារម្មណ៍ថាពួកគេពុំមានជម្រើសអ្វីផ្សេងក្រៅពីទ្រាំទ្រនឹងការរំលោភបំពានការងារ។ នៅក្នុងប្រទេស កម្ចីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចជាកត្តាចម្បងមួយនៅក្នុងស្ថានភាពពលកម្មដែលមានការរំលោភបំពាន។ មានកិច្ចការច្រើនទៀតដែលត្រូវធ្វើ ដើម្បីកំណត់រកករណីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សទាំងនេះដែលផ្អែកលើបំណុល។ វិធីសាស្ត្រជាក់លាក់ដើម្បីកំណត់រកកាលៈទេសៈទាំងនេះ គួរតែបង្កើតឡើងដូចនៅក្នុងគោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។ កន្លងមក អធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ពុំ បានបញ្ជាក់ជាភស្តុតាងថាមានសមត្ថភាពក្នុងការកំណត់រកពលកម្មដោយបង្ខំនោះទេ ស្របពេលដែលយន្តការកំណត់ពលកម្ម

ដោយបង្ខំ ឬអំពើជួញដូរមនុស្ស គឺពុំបានផ្តោតជាពិសេសលើការកំណត់រកទំនាក់ទំនងបំណុលបង្ខិតបង្ខំនោះទេ។

៣. **បន្តពង្រឹងវិធីសាស្ត្រផ្អែកលើសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណ និងរាយការណ៍៖** ស្របពេលដែលជនរងគ្រោះនៃពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សខ្លួនឯងផ្ទាល់ពុំមែនជាអ្នកដំបូងដែលរាយការណ៍ ឬកំណត់អត្តសញ្ញាណខ្លួនឯង សមាជិកគ្រួសារ និងមិត្តភក្តិជារឿយៗ គឺមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះដែលអាចលើកទឹកចិត្តជនរងគ្រោះឱ្យធ្វើការរាយការណ៍។ កិច្ចខិតខំប្រឹងប្រែងពង្រឹងចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ស្តីពីការកំណត់អត្តសញ្ញាណពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស និងការប្រើប្រាស់យន្តការរាយការណ៍ គឺមានប្រសិទ្ធភាព។

៤. **ធានាបាននូវការត្រួតពិនិត្យពលករ និងជនបរទេសមុនពេលបណ្តេញចេញពីប្រទេស៖** ព័ត៌មានដែលមានផ្តល់ឱ្យលើកឡើងថា ពលករជាច្រើនដែលត្រូវបានបណ្តេញចេញពីប្រទេសថៃ គឺជាជនរងគ្រោះនៃពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស ឬទម្រង់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចពលកម្ម ដែលពុំបានកំណត់អត្តសញ្ញាណ។ ការពិនិត្យពលករទាំងនេះជាប្រព័ន្ធ គឺមិនត្រឹមតែជួយដល់ការកំណត់អត្តសញ្ញាណ និងគាំទ្រជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងផ្តល់ព័ត៌មានកាន់តែច្រើនអំពីករណីជួញដូរមនុស្ស ដែលអាចធ្វើការស៊ើបអង្កេតបន្ថែមទៀតផង។ ដូចគ្នានេះដែរ នៅកម្ពុជា មានជនបរទេសជាច្រើនដែលត្រូវបានបណ្តេញចេញដោយមន្ត្រីអន្តោប្រវេសន៍ ដោយពុំមានការត្រួតពិនិត្យរកមើលពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សឱ្យបានគ្រប់គ្រាន់នោះទេ។ មន្ត្រីអន្តោប្រវេសន៍ ពុំគួរអនុញ្ញាតឱ្យបណ្តេញជនបរទេសណាមួយចេញពីប្រទេសនោះឡើយ លុះត្រាណាតែមន្ត្រីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានត្រួតពិនិត្យរកពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សជាមុនសិន។

៥. **អភិវឌ្ឍន៍សម្ភាសន៍ពហុភ្នាក់ងារ៖** ការសិក្សានេះ បានរកឃើញថា ជនរងគ្រោះត្រូវតែឆ្លងកាត់សម្ភាសន៍ជាច្រើនតាមរយៈដំណើរការតុលាការ រួមទាំងការកំណត់អត្តសញ្ញាណ និងដំណាក់កាលបញ្ជូន។ ប្រការនេះអាចនាំឱ្យមានការនឿយហត់នឹងសម្ភាសន៍ ហើយជនរងគ្រោះផ្តល់ភស្តុតាងតិចជាងមុន និងការឆ្លើយតបដែលពុំសូវមានគុណភាពក្នុងសម្ភាសន៍មួយលើកៗ។ការធ្វើបែបនេះក៏មានលក្ខណៈច្រំដែលធ្វើឱ្យនឿយណាយ ចំណាយកម្លាំងច្រើន និងបង្អាក់ទឹកចិត្តជនរងគ្រោះក្នុងការចូលរួម។ ជំនួសមកវិញ ភាគីពាក់ព័ន្ធស្នើឡើងថា ភាគីពាក់ព័ន្ធជាច្រើន គួរតែរៀបចំសម្ភាសន៍រួមគ្នាតែម្តងនៅមុនពេលស៊ើបអង្កេត ដូចជា នគរបាល មន្ត្រីសង្គមកិច្ច អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីកុងស៊ុល និងអនុព័ន្ធការងារ។

៦. **គោលការណ៍មិនដាក់ទោសទណ្ឌលើជនរងគ្រោះ៖** ជនរងគ្រោះនៃការជួញដូរមនុស្ស អាចប្រឈមមុខនឹងការដាក់ពិន័យពីបទល្មើសអន្តោប្រវេសន៍ ការប្រើប្រាស់ឯកសារក្លែងក្លាយ ឬការចូលរួមនៅក្នុងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងស្ថានភាពកេងប្រវ័ញ្ចដែលពួកគេជួបប្រទះ។ ជាលទ្ធផល ជនរងគ្រោះជារឿយៗភ័យខ្លាចក្នុងការរាយការណ៍អំពីស្ថានភាពពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្ស ឬស្វែងរកជំនួយ។ គោលការណ៍មិនដាក់ទោសទណ្ឌ បានចែងថា ជនរងគ្រោះពុំត្រូវទទួលរងការផ្តន្ទាទោស ឬការពិន័យចំពោះអំពើខុសច្បាប់ដែលបានប្រព្រឹត្តជាលទ្ធផលនៃការជួញដូរមនុស្សឡើយ។ ការអនុវត្តគោលការណ៍មិនដាក់ទោសទណ្ឌ នឹងធានាថាជនរងគ្រោះរាយការណ៍កាន់តែច្រើនអំពីពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស និងពុំមានការបង្អាក់ទឹកចិត្តពីការចូលរួមនៅក្នុងប្រព័ន្ធយុត្តិធម៌ឡើយ។ ដូចគ្នានេះដែរ រាល់សេវារាយការណ៍ និងសេវាគាំទ្រទាំងអស់ គួរតែបញ្ជាក់ឱ្យបានច្បាស់លាស់ថា ពួកគេផ្តល់សេវាដល់ពលករដោយពុំគិតអំពីស្ថានភាពចំណាកស្រុករបស់ពួកគេនោះទេ។

### ៩.២.៥ ការគាំទ្រជនរងគ្រោះបន្ទាប់ពីការថែទាំ

១. **ដោះស្រាយកង្វះខាតធនធាន និងការគាំទ្រ៖** កង្វះខាតជាច្រើនក្នុងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណនៅក្នុងការសិក្សានេះ រួមមាន៖ (១) ជម្រកសម្រាប់ជនរងគ្រោះ ជាពិសេសបុរស (២) សេវាសុខភាពផ្លូវចិត្ត (៣) ការគាំទ្រផ្លូវច្បាប់សម្រាប់ករណីដែលកើតឡើងនៅក្រៅប្រទេស (៤) សេវាសមាហរណកម្មជោគជ័យ (៥) សេវាជំនាញសម្រាប់ជនរងគ្រោះជាបុរស (៦) សេវាផ្លូវច្បាប់នៅក្នុងតំបន់ព្រំដែន (៧) សេវាស្ត្រានីតិសម្បទា និងសេវាសង្គមកិច្ចផ្សេងៗ (៨) ចំនួនបុគ្គលិកសង្គមកិច្ច (៩) ការផ្តល់មូលនិធិបន្ទាប់ពីការថែទាំសម្រាប់ ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។ ស្ថាប័នទាំងអស់នេះ គឺសុទ្ធតែជាទីកន្លែងដែលអាចផ្តល់ធនធានបន្ថែម ដើម្បីផ្តល់លទ្ធភាពសម្រាប់ជនរងគ្រោះ។

២. **អភិវឌ្ឍន៍បន្ថែមលើមជ្ឈមណ្ឌលគាំទ្រ៖** ការរង់ចាំបើកដំណើរការមជ្ឈមណ្ឌលថ្មីមួយសម្រាប់ការថែទាំ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកណ្តាលស្ទឹង គឺជាជំហានដ៏វិជ្ជមានមួយ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានសមត្ថភាពក្នុងការធ្វើប្រតិបត្តិការមជ្ឈមណ្ឌលបែបនេះបន្ថែមទៀត ដែលអាចរៀបចំឡើងដើម្បីសម្របសម្រួលដល់ជនរងគ្រោះ និងពលករចំណាកស្រុកដែលត្រលប់មកវិញ និងផ្តោតលើការងារគាំទ្រជនរងគ្រោះ។ ធនធាននានា គួរតែបែងចែកដើម្បីបើកមជ្ឈមណ្ឌលសេវាកម្មបន្ថែមទៀត ដោយផ្អែកលើមតិត្រលប់ពីគំរូនេះ។

៣. **ស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃសេវាគាំទ្រ៖** ភាគីពាក់ព័ន្ធបានរាយការណ៍ថា ពួកគេមានការលំបាកដើម្បីដឹងថាតើសេវាគាំទ្រមានឥទ្ធិពលវិជ្ជមានគ្រប់គ្រាន់លើជីវិតរបស់ជនរងគ្រោះដែរឬទេ និងថាតើជនរងគ្រោះបានទទួលការគាំទ្រដែលពួកគេត្រូវការ និងការគាំទ្រនោះស្ថិតក្នុងស្តង់ដារដែលអាចទទួលយកបានដែរឬទេ។ ការស្រាវជ្រាវបន្ថែម (ដូចជា ការសិក្សារយៈពេលវែង) គឺត្រូវការចាំបាច់ ដើម្បីបង្កើតបាននូវតម្រូវការច្បាស់លាស់របស់ជនរងគ្រោះចាប់ពីការកំណត់អត្តសញ្ញាណ រហូតដល់ការធ្វើសមាហរណកម្ម ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីគំរូសមាហរណកម្មដែលល្អបំផុត។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវា គឺត្រូវការចាំបាច់ ដើម្បីវាស់ស្ទង់គុណភាព និងការកែលម្អលើការគាំទ្រជនរងគ្រោះ និងដើម្បីធានាបាននូវធនធានដែលមានកម្រិតត្រូវបានបែងចែកទៅកាន់សេវាដែលសំខាន់បំផុតសម្រាប់ជនរងគ្រោះ។

### ៩.២.៦ ដំណោះស្រាយ

១. **ធ្វើកំណែទម្រង់យន្តការសំណង៖** ប្រព័ន្ធយុត្តិធម៌ បច្ចុប្បន្នគឺពុំមានប្រសិទ្ធភាពក្នុងការផ្តល់សំណងដល់ជនរងគ្រោះនៃពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្សនោះទេ។ កំណែទម្រង់មួយចំនួនលើសំណង គឺត្រូវការចាំបាច់៖ (ក) គួរតែបង្កើតមូលនិធិសំណងជនរងគ្រោះ ដោយកត់សម្គាល់ថា មានជម្រើសជាច្រើនអំពីការរៀបចំមូលនិធិនេះ (ខ) សំណង គួរតែផ្សារភ្ជាប់ទៅនឹងប្រាក់កក់ធានាដែលទីភ្នាក់ងារជ្រើសរើសពលករបានបង់ និង (គ) យន្តការបច្ចុប្បន្ននៃការអនុវត្តសាលដីកាស្តីពីសំណងគួរតែផ្លាស់ប្តូរ។

២. **កែសម្រួលការគណនាសំណង៖** បង្កើនចំនួនទឹកប្រាក់សំណងនៅក្នុងដំណើរការតុលាការរដ្ឋប្បវេណី ដើម្បីរួមបញ្ចូល ការសងជំងឺចិត្ត។ ការធ្វើបែបនេះ នឹងផ្តល់ជនរងគ្រោះ និងបង្ខំឱ្យនិយោជកទូទាត់សងលើពីប្រាក់ឈ្នួលដែលត្រូវបង់ដល់ពលករ។ ការធ្វើបែបនេះនឹងលើកទឹកចិត្តដល់ជនរងគ្រោះឱ្យស្វែងរកសំណង ក៏ដូចជារារាំងដល់ជនល្មើសផងដែរ។

## ៩.២.៧ ការសហការអន្តរទីភ្នាក់ងារ

១. **ផ្តោតលើការបណ្តុះបណ្តាលរួម៖** ការសហការ គឺត្រូវការការអនុវត្ត។ ភាគីពាក់ព័ន្ធបានរាយការណ៍ថា ពួកគេនៅមានការយល់ដឹងខ្សោយនៅឡើយអំពីតួនាទីរបស់សមភាគីរបស់ពួកគេនៅក្នុងប្រព័ន្ធយុត្តិធម៌ទាំងមូល និងបានលើកឡើងថា កត្តានេះបានដាក់កម្រិតទៅលើការយល់ដឹង និងការសហការគ្នាទៅវិញទៅមក។ ភាគីពាក់ព័ន្ធបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការមានទំនាក់ទំនងការងារល្អ។ អនុសាសន៍ទូទៅក្នុងចំណោមអ្នកផ្តល់សម្ភាសន៍បានលើកឡើងថា គឺត្រូវរៀបចំវគ្គបណ្តុះបណ្តាលរួម ដោយមានអ្នកចូលរួមមកពីតួនាទីជាច្រើននៅទូទាំងប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស រួមទាំងនគរបាល អាជ្ញាធរមូលដ្ឋាន ចៅក្រម និង ព្រះរាជអាជ្ញា មន្ត្រីសង្គមកិច្ច និងអ្នកផ្តល់សេវា។ ទន្ទឹមនឹងនេះ ក៏មានការលើកឡើងដែរថា ដើម្បីអាចលើកកម្ពស់ការសហការបាន វាជាការសំខាន់ណាស់ដែលបុគ្គលកាន់តួនាទីទាំងនោះកសាងបណ្តាញ និងទំនុកចិត្តចំពោះគ្នាទៅវិញទៅមក។ គំនិតផ្តួចផ្តើមនេះ អាចរួមបញ្ចូលការធ្វើបច្ចុប្បន្នភាពទៅលើទម្រង់នៃការជួញដូរមនុស្ស និងការចែករំលែកព័ត៌មានទៅវិញទៅមក និងជំនាញបន្ថែមសម្រាប់ការគាំទ្រជនរងគ្រោះ។

២. **ឱ្យសេវាសង្គមកិច្ចចូលរួមនៅដំណាក់កាលដំបូងបំផុតនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ៖** បុគ្គលិកសេវាសង្គមកិច្ច គឺត្រូវបានគេរាយការណ៍ថាមិនបានទទួលការជូនដំណឹងអំពី ករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សបានទាន់ពេលវេលានោះទេ នៅក្នុងដំណើរការនីតិវិធីស៊ើបអង្កេត និងរឿងក្តីតុលាការ និងជូនកាលមិនបានទទួលការជូនដំណឹងទាល់តែសោះ។ ជាការសំខាន់ណាស់ដែលសេវាសង្គមកិច្ចទទួលបានការជូនដំណឹង ដើម្បីអាចគាំទ្រជនរងគ្រោះនៅគ្រប់ករណីទាំងអស់ និងនៅដំណាក់កាលដំបូងបំផុតតាមដែលអាចធ្វើទៅបាន។

៣. **បង្កើតពិធីសារប្រមូល និងចែករំលែកទិន្នន័យ៖** កាលពីឆ្នាំកន្លងទៅថ្មីៗនេះ មានការកែលម្អលើមធ្យោបាយនៃការប្រមូល និងរក្សាទុកទិន្នន័យរឿងក្តី ជាពិសេសក្នុងតុលាការផ្ទាល់ និងក្នុងគំនិតផ្តួចផ្តើមតាមស្ថាប័ន។ ប៉ុន្តែនៅទូទាំងប្រព័ន្ធតុលាការទាំងមូល ការប្រមូលទិន្នន័យគឺមានលក្ខណៈមិនទៀងទាត់ និងពុំអាចទុកចិត្តបានសម្រាប់គោលបំណងនៃការវាស់ស្ទង់ និងតាមដានត្រួតពិនិត្យលទ្ធផលបាននោះទេ។ ទិន្នន័យដែលប្រមូលបានអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺពុំមានការផ្ទៀងផ្ទាត់បានដោយងាយស្រួលនោះទេ ដោយហេតុថាជនរងគ្រោះជាច្រើនត្រូវបានរាប់ស្ទួនគ្នារវាងស្ថាប័ននានា។ ទិន្នន័យ គឺពុំបានត្រៀមសម្រាប់ការចែករំលែក និងការចូលប្រើប្រាស់រវាងស្ថាប័ន និងបច្ចុប្បន្នភាពស្តីពីរឿងក្តី គឺពុំបានរាយការណ៍ត្រលប់មកនគរបាលវិញឡើយនៅពេលដែលរឿងក្តីនោះបានបញ្ជូនទៅតុលាការរួចរាល់។ ពិធីសារប្រមូលទិន្នន័យទាំងមូល គួរតែបង្កើតឡើងដោយចែងឱ្យបានជាក់លាក់ថាតើទិន្នន័យស្តីពីពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្សណាមួយដែលត្រូវកត់ត្រា កត់ត្រាដោយអ្នកណា និងរក្សាទុកដូចម្តេច ប្រើប្រាស់ បង្ហាញ និងផ្តល់ជូនដូចម្តេច។ ពិធីសារនេះ គួរតែរៀបចំឡើងដោយមានធាតុចូលពីមន្ត្រី និងស្ថាប័នពាក់ព័ន្ធទាំងអស់ និងដកស្រង់ចេញពីធនធានណែនាំដែលបានរៀបចំឡើងស្រាប់ដោយអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងប្រធានបទនេះ។

## ៩.២.៨ ការសហការឆ្លងដែន

១. **បង្កើតក្រុមស៊ើបអង្កេតរួម៖** ភាគីពាក់ព័ន្ធ បានកត់សម្គាល់ថា ការសហការឆ្លងដែនបច្ចុប្បន្នគឺនៅមានកម្រិតនៅឡើងនៅក្នុងអំឡុងពេលស៊ើបអង្កេត។ ប្រទេសភាគីខ្វះបណ្តាញ និងទំនាក់ទំនងការងារ ដើម្បីសហការគ្នាប្រកបដោយប្រសិទ្ធភាព និងយន្តការដែលមានស្រាប់ជារឿយៗ គឺពុំបានយកមកប្រើប្រាស់ឡើយ។ ការណែនាំរួមមួយ គឺធ្វើយ៉ាងណារៀបចំបង្កើតក្រុមស៊ើបអង្កេតរួមមួយ ដែលមានភារកិច្ចស៊ើបអង្កេតឆ្លងដែនអំពីករណីពលកម្មដោយបង្ខំនិងអំពើជួញដូរមនុស្សជាបន្តបន្ទាប់។

២. **ដោះស្រាយឧបសគ្គនៅក្នុងការចូលរួមក្នុងដំណើរការផ្លូវច្បាប់របស់ប្រទេសថៃ៖** ពលករខ្មែររងគ្រោះ មានការលំបាក និងពុំចាប់អារម្មណ៍លើការបន្តដំណើរការនិតិវិធីរឿងក្តីនៅក្នុងប្រទេសថៃឡើយ។ ម្យ៉ាងវិញទៀត ជនរងគ្រោះដែលបានធ្វើមាតុភូមិនិវត្តន៍ មានបំណងចង់បន្តជីវិតរស់នៅរបស់ពួកគេ ដោយសារតែមានការលំបាកនៅក្នុងការបន្តចូលរួមនៅក្នុងដំណើរការយុត្តិធម៌នៅក្រៅប្រទេស ហើយសម្រាប់ជនរងគ្រោះដែលនៅក្រៅប្រទេស ពួកគេអាចមានការលំបាកក្នុងការបន្តស្នាក់នៅក្រៅប្រទេសដោយពុំមានចំណូល និងស្ថានភាពអន្តោប្រវេសន៍ស្របច្បាប់។ ក្នុងករណីទាំងពីរនេះ ជនរងគ្រោះត្រូវការការគាំទ្របន្ថែម ដើម្បីលើកទឹកចិត្តពួកគេឱ្យបន្តដំណើរការទាមទារតាមរយៈដំណើរការយុត្តិធម៌។ ការគាំទ្រនេះចាំបាច់ត្រូវរួមបញ្ចូលការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ជនរងគ្រោះ ក្នុងកំឡុងពេលដែលពួកគេរង់ចាំសវនាការ និងដើម្បីរ៉ាប់រងលើការចំណាយក្នុងការចូលក្នុងសវនាការ ការគាំទ្រផ្លូវច្បាប់ និងការបង្កើនលទ្ធភាពងាយស្រួល ដែលសម្មភាពគាំទ្រទាំងអស់នេះអាចជួយឱ្យជនរងគ្រោះអាចចូលរួមក្នុងសវនាការពីចម្ងាយពីប្រទេសកម្ពុជាបាន។

៣. **ពង្រឹងការគាំទ្ររបស់ស្ថានទូត៖** ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ អាចពង្រឹងបានតាមរយៈការមានក្រុមការងារដាច់ដោយឡែក រួមទាំងនគរបាលជាដើម ដែលមានភារកិច្ចដោះស្រាយបញ្ហាពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស។ ក្រុមការងារនេះគួរតែពង្រីកតួនាទីរបស់ខ្លួននៅក្នុងការជួយដល់ពលករនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការពលកម្មដោយបង្ខំឬអំពើជួញដូរមនុស្ស ជាពិសេសក្នុងការចូលប្រើប្រាស់យន្តការបណ្តឹងតវ៉ា ការផ្លាស់ប្តូរការងារ និងការជួយដល់ដំណើរការផ្លូវច្បាប់ឆ្លងដែន។ របាយការណ៍បច្ចុប្បន្នបានបង្ហាញថា ការគាំទ្ររបស់ស្ថានទូត គឺធ្វើឡើងពុំទាន់ពេលវេលា និងនៅមានកម្រិតតិចតួចនៅឡើយ ហើយចាំបាច់ត្រូវតែមានលក្ខណៈបុរេសកម្ម និងមានការជំរុញទឹកចិត្តច្រើនជាងមុន។

៤. **អនុវត្ត និងសម្រិតសម្រាំងស្តង់ដារនីតិវិធីប្រតិបត្តិថ្មីជាមួយប្រទេសថៃ៖** ស្តង់ដារនីតិវិធីប្រតិបត្តិថ្មី ដែលពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ឬអំពើជួញដូរមនុស្ស កាលពីពេលថ្មីៗនេះបានចុះហត្ថលេខាជាមួយប្រទេសថៃ។ វាជាការសំខាន់ណាស់ដែលត្រូវអនុវត្តស្តង់ដារទាំងនេះប្រកបដោយតម្លាភាព និងមានការចូលរួមជាមតិត្រលប់ពីសំណាក់ភាគីពាក់ព័ន្ធ ដើម្បីធានាថាស្តង់ដារទាំងនេះមានប្រសិទ្ធភាព និងមានឥទ្ធិពល។

# កំណត់សម្គាល់ចុងឯកសារ


១. *អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (ឆ្នាំ ២០១៦) ការជួញដូរពលកម្មនៅកម្ពុជា៖ ការត្រួតពិនិត្យការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌សាធារណៈ: អាចរកបាននៅ https://ijmstoragelive.blob. core.windows.net/ijmna/documents/ studies/labor_trafficking_in_cambodia_-_a_review_of_the_pjss_response_ijm_២០១៦. pdf*

២. *Miles. M. B.. & Huberman. A. M. (១៩៩៤). ការវិភាគទិន្នន័យបរិមាណវិស័យ៖ ឯកសារប្រភពទូលំទូលាយ។ Sage: Berkeley.*

៣. *Ibid.*

៤. *Brickell. K.. Parsons. L.. Natarajan. N... & Chann. S. (២០១៨). Blood bricks៖ រឿងរ៉ាវអាថ៌កំបាំងអំពីទាសភាពទំនើប និងការប្រែប្រួលអាកាសធាតុពីកម្ពុជា doi: ១០.១៣១៤០/ RG.២.២.២០៩៤២.១៨៨៨៩.*

៥. *Ratcliffe. R (២០២២) ' Sold https://www.theguardian.com/world/២០២២/oct/១០/ sold-to -gangs. -forced -to -run -online -scams: -inside Cambodia's -cambodias-cybercrime -crisis.' សារព័ត៌មាន The Guardian ថ្ងៃទី១០ ខែតុលា ឆ្នាំ ២០២២. បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២២.; Turton S. (២០២១) 'ទាសភាពបច្ចេកវិទ្យា៖ នៅក្នុងក្រុមឆបោកតាមអ៊ីនធឺណិតនៅកម្ពុជា' សារព័ត៌មាន The Nikkei Asia ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ បានចូលមើលនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២២។ https://asia.nikkei.com/Spotlight/The-Big-Story/Cyber-slavery-inside-Cambodia-s- online-scam-gangs*

៦. ក្រសួងការបរទេសសហរដ្ឋអាមេរិក (ឆ្នាំ ២០២១) របាយការណ៍ស្តីពីការជួញដូរមនុស្ស ឆ្នាំ២០២១៖ កម្ពុជា ការិយាល័យតាមដានត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២២ https://www.state.gov/reports/២០២១-trafficking-in-persons-report/cambodia/

៧. Licadho (២០១៩) ការខូចខាតទ្រព្យសម្បត្តិ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (អង្គការលីកាដូ) បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ https://www.licadho-cambodia.org/reports. php?perm=២២៨

៨. Ibid៧ https://www.licadho-cambodia.org/reports.php?perm=២២៨

៩. អង្គការពលកម្មអន្តរជាតិ (២០១៨) របកគំហើញនៃការស្រាវជ្រាវបន្ទាត់គោលពីការឡើងទូក រហូតដល់ចុះទូកវិញ ស្តីពីពលករនេសាទ និងពលករគ្រឿងសមុទ្រនៅប្រទេសថៃ។ អង្គការពលកម្មអន្តរជាតិ បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

១០. ក្រសួងការបរទេសសហរដ្ឋអាមេរិក (ឆ្នាំ ២០២១) របាយការណ៍ស្តីពីការជួញដូរមនុស្ស ឆ្នាំ២០២១៖ កម្ពុជា ការិយាល័យតាមដានត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលមើលនៅថ្ងៃទី១៣ ខែតុលា

១១. របាយការណ៍វឌ្ឍនភាពអាស៊ាន ឆ្នាំ២០១៨

១២. កថាខណ្ឌខាងលើ ត្រូវបានថតចម្លងចេញពីរបាយការណ៍មួយដែលបានរៀបចំឡើងដោយ ក្រុមស្រាវជ្រាវ និងទំនាក់ទំនងសម្រាប់កម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្ស។

១៣. អង្គការមូលនិធិសេរីភាព (ឆ្នាំ២០១៨)។ របាយការណ៍ប្រចាំឆ្នាំស្តីពីតំបន់ក្តៅរបស់ប្រទេសថៃ អង្គការមូលនិធិសេរីភាព បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

១៤. ព្រះរាជក្រឹត្យលេខ ០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤

១៥. គណៈមេធាវី គឺជាស្ថាប័នកំពូលសម្រាប់មេធាវី ព្រះរាជអាជ្ញា និងចៅក្រម។

១៦. ពី Johnson. LLaura S... Marika McAdam. M.Rebecca Surtees. R and Thaufiek Zulbahary. T (២០២០) ក្របខណ្ឌការពារជនរងគ្រោះនៃការជួញដូរមនុស្សនៅកម្ពុជា ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតឡាវ ថៃ និងវៀតណាម៖ ឯកសារធនធានសម្រាប់អ្នកអនុវត្ត។ ក្របខណ្ឌការពារជនរងគ្រោះនៃការជួញដូរមនុស្សនៅកម្ពុជា ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតឡាវ ថៃ និងវៀតណាម៖ ឯកសារធនធានសម្រាប់អ្នកអនុវត្ត។ រដ្ឋធានីវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក៖ វិទ្យាស្ថាន NEXUS Institute និងអង្គការ Winrock International បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ នៅ https://respect. international/wp-content/uploads/២០២១/០៣/Trafficking-Victim-Protection-Frameworks-in-Cambodia-Indonesia-Lao-PDR-Thailand-and-Viet-Nam-A-Resource-  for-Practitioners-.pdf

១៧. សូមមើលមាត្រា ៣០០ នៃច្បាប់ស្តីពីការងារកម្ពុជា ឆ្នាំ១៩៩៧ "វិវាទបុគ្គល គឺជាវិវាទដែលកើតមានឡើងរវាងនិយោជកនិងកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ឬអ្នករៀនធ្វើការម្នាក់ ឬច្រើននាក់ តាមរឿងរៀងៗខ្លួនហើយទាក់ទងនឹង ការបកស្រាយ ឬការអនុវត្តន៍បទប្បញ្ញត្តិនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកម្មករនិយោជិត ឬបទប្បញ្ញត្តិការងារនៃអនុសញ្ញារួមព្រមទាំងច្បាប់បញ្ញត្តិជាធរមានផង។" សម្គាល់៖ មាត្រា ៣០០ បច្ចុប្បន្នគឺកំពុងតែធ្វើវិសោធនកម្មដោយរដ្ឋាភិបាល។

១៨. ឧទាហរណ៍ នៅឆ្នាំ២០១៩ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំ សន្និសីទក្រសួងការងារ ដែលបានអញ្ជើញតំណាងមកពីរដ្ឋាភិបាលកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ដើម្បីពិភាក្សាអំពីសន្តិសុខសង្គមសម្រាប់ពលករចំណាកស្រុក។

១៩. សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ឆ្នាំ ២០២០) ក្រមប្រតិបត្តិសម្រាប់ ទីភ្នាក់ងារជ្រើសរើសពលករឯកជនកម្ពុជា សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២។

២០. ឧទាហរណ៍ សូមមើល Natarajan. N.. Brickell. K.. & Parsons. L. (២០២១)។ "កត្តាជំរុញនៃទាសភាពទំនើប៖ ពីមីក្រូហិរញ្ញវត្ថុទៅជាពលកម្មមិនមានសេរីភាពនៅកម្ពុជា ប្រទេសកម្ពុជា។ ការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរ ៥២(២).

២៤១-២៦៤. doi: https://doi.org/១០.១១១១/dech.១២៦២៣https://onlinelibrary. wiley.com/doi/full/១០.១១១១/dech.១២៦២៣

២១. Bliss. FFrank (២០២២)៖ "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍន៍ បញ្ហាប្រឈម និង អនុសាសន៍។ វិទ្យាស្ថានអភិវឌ្ឍន៍ និងសន្តិភាព "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍន៍ បញ្ហាប្រឈម និង អនុសាសន៍។ វិទ្យាស្ថានអភិវឌ្ឍន៍ និងសន្តិភាព (INEF) សាកលវិទ្យាល័យ University of Duisburg-Essen (ការសិក្សា AVE ៣០/២០២២. មធ្យោបាយចាកចេញពីភាពក្រីក្រ ភាពងាយរងគ្រោះ និងអសន្តិសុខស្បៀងអាហារ) បានចូលមើលនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២)។

https://www.uni-due.de/imperia/md/content/inef/bliss__២០២២ micro__finance_in_cambodia__ave ៣០_.pdf

២២. ឧទាហរណ៍ សូមមើលការងាររបស់ Maryanne Bylander ឬ W. Nathan Green

https://www.abc.org.kh/news/cambodia-launches-banking-and-financial- institutions-code-conduct

២៣. Brickell. K Parsons. L. Natarajan. N. & Chann. S (២០១៨). Blood bricks៖ រឿងរ៉ាវអាថ៌កំបាំងអំពីទាសភាពទំនើប និងការប្រែប្រួលអាកាសធាតុពីកម្ពុជា doi: ១០.១៣១៤០/RG.២.២.២០៤៤២.១៨៨៨៩ Parsons et al (២០១៨) របាយការណ៍ Blood Bricks

២៤. សារព័ត៌មាន Aljazeera (២០២២) គេបង្ខំឱ្យឆបោក៖ ទាសករអ៊ីនធឺណិតកម្ពុជា [វីដេអូ] ខែកក្កដា ឆ្នាំ២០២២ សារព័ត៌មាន Aljazeera បានចូលមើលនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ https://www.aljazeera.com/program/១០១-east/២០២២/៧/១៤/ forced-to-scam-cambodias-cyber-slaves

២៥. ជាការចាំបាច់ត្រូវកត់សម្គាល់ថា ការប្រមូលទិន្នន័យសម្រាប់របាយការណ៍នេះ មិនបានលើកឡើងអំពីទីតាំងពាក់ព័ន្ធនឹងការអនុវត្តនេះឡើយ និងមិនផ្តោតលើប្រធានបទនេះជាពិសេសនោះទេ។

២៦. (មានតែនៅរាជធានីភ្នំពេញ មិនរួមបញ្ចូលខេត្តទាំងអស់ទេ)

២៧. https://www.phnompenhpost.com/national/ministry-justice-wraps-case-backlog- clean-effort

២៨. សារព័ត៌មាន Cambodianess (ឆ្នាំ ២០២១) មជ្ឈមណ្ឌលពលករថ្មី បានបើកដំណើរការនៅក្នុងខេត្តបាត់ដំបង សារព័ត៌មាន Cambodianess ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២១ បានចូលមើលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២។

២៩. គោលនយោបាយស្តីពីការការពារសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរមនុស្ស (ប្រកាសលេខ ៨៥២) រួមទាំងបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរមនុស្ស (ប្រកាសលេខ ៨៥៧) (ឆ្នាំ ២០០៩) (គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការការពារ)។

៣០. សូ ជាតា (ឆ្នាំ ២០២២) 'មជ្ឈមណ្ឌលជួពលករចំណាកស្រុក ' សារព័ត៌មានខ្មែរថាមស៍ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០២២ បានចូលមើលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២ https://www.khmertimeskh.com/៥០១០៧៥៤៩៨/a-center-to-help- migrant-workers/

៣១. សូមមើលមាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ

៣២. ប្រហែល ៤៨៥ ដុល្លារអាមេរិក

៣៣. សារព័ត៌មាន ខ្មែរថាមស៍ (ឆ្នាំ២០២២) ' កម្ពុជា-ថៃចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការប្រឆាំងការជួញដូរមនុស្ស' ខ្មែរថាមស៍ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ បានចូលមើលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២

៣៤. ការវិភាគទិន្នន័យ គឺគ្រាន់តែបែងចែកទៅជាតម្លៃលេខលំដាប់តាមជម្រើសនីមួយៗនៃជម្រើសទាំងប្រាំ ១ = មិនយល់ស្របទាំងស្រុង ២ = មិនយល់ស្រប ៣ = ធម្មតា ៤ = យល់ស្រប ៥ = យល់ស្របទាំងស្រុង



IJM

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**
ប្រអប់សំបុត្រលេខ ៥៨១៩៧
រដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី ២០០៣៧ សហរដ្ឋអាមេរិក
ទូរសព្ទ ៧០៣.៨៦៥.៥៨៩៥
ទូរសារ ៧០៣.៨៦៥.៥៨៩៩
IJM.org

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** គឺជាអង្គការសកល ដែលការពារប្រជាជនក្រីក្រពីអំពើហិង្សានៅទូទាំងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ សហការជាដៃគូជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជួយសង្គ្រោះជនរងគ្រោះពីអំពើហិង្សា នាំឧក្រិដ្ឋកម្មមកជំនុំជម្រះរកយុត្តិធម៌ ស្តារសម្បទាជនរងគ្រោះ និងពង្រឹងប្រព័ន្ធយុត្តិធម៌។

អង្គការត្រូវបានទទួលស្គាល់ថាជាអង្គការមួយ ក្នុងចំណោមអង្គការមិនស្វែងរកប្រាក់ចំណេញទាំង ១០ ដែល "ធ្វើឱ្យមានការផ្លាស់ប្តូរ" ដោយសារព័ត៌មានសហរដ្ឋអាមេរិក និងរបាយការណ៍ពិភពលោក គំរូដ៏មានប្រសិទ្ធភាពរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវបានទទួលស្គាល់ដោយក្រសួងការបរទេសសហរដ្ឋអាមេរិក វេទិកាសេដ្ឋកិច្ចពិភពលោក និងអ្នកដឹកនាំនៅជុំវិញពិភពលោក ក៏ដូចជាត្រូវបានចុះផ្សាយដោយក្រសួងការបរទេស ទស្សនាវដ្តី Forbes, The Guardian សារព័ត៌មាន The New York Times, The Times of India សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ វិទ្យុជាតិសាធារណៈ និងសារព័ត៌មាន CNN ក្នុងចំណោមបណ្តាញផ្សព្វផ្សាយជាច្រើនផ្សេងទៀត។

អត្ថបទ និងរូបភាពទាំងអស់ © ២០២៣ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។